ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរកការពិត



◆ តួនាទីរបស់អាស៊ានចំពោះសាលាក្ដីខ្មែរក្រហម

◆ សក្ខីកម្ម ឌុច ប្រឆាំងនឹងអតីតមេដឹកនាំខ្មែរក្រហម

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ១៤៧ ខែមីនា ឆ្នាំ២០១២

# ស្វែងរកការពិត

ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

លេខ១៤៧ ខែមីនា ឆ្នាំ២០១២

## មាតិកា

◆តួនាទីរបស់អាស៊ានចំពោះសាលាក្ដីខ្មែរក្រហម ........................ ១

**ផ្នែកឯកសារ**

◆សុន្ទរកថារបស់សមមិត្តលេខា ប៉ុល ពត ........................ ៣

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

◆សក្ខីកម្ម ឌុច ប្រឆាំងនឹងអតីតមេដឹកនាំខ្មែរក្រហម ........................ ១៤

◆អតីតយោធាខ្មែរក្រហមរៀនពីប្រវត្តិអតីតកាល ........................ ២១

◆ឈឺចាប់ពេលនឹកឃើញរឿងដើម ........................ ២៣

**ផ្នែកច្បាប់**

◆កាតព្វកិច្ចក្នុងការផ្ដល់ព័ត៌មានទៅកាន់សាធារណជន ........................ ២៥

**វេទិកាពិភាក្សាសាធារណៈ**

◆តើគឺជាល្បែងនយោបាយ នៅឯសាលាក្ដីខ្មែរក្រហម? ........................ ៣២

◆ការពិនិត្យមើលសាឡើងវិញលើការបរបោ ........................ ៣៦

◆តើ ឌុច ជាឈើខ្ចឹម ឬឈើពុកសម្រាប់ នួន ជា? ........................ ៤៤

◆គំនិតនិងទស្សនៈរបស់និស្សិតចំពោះសក្ខីកម្មរបស់ ឌុច ........................ ៤៥

◆ប្រតិកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណី........................ ៤៧

**ទំព័រស្រាវជ្រាវរកគ្រួសារ**

◆ ឪពុករបស់ខ្ញុំស្លាប់នៅគុកទួលស្លែង ........................ ៥៤

◆ សូមឲ្យអតីតកាលកន្លងផុតទៅចុះ ........................ ៥៦

◆ ជីវិតគ្រួសារខ្ញុំត្រូវប្រល័យលើទឹកដីកំណើត ........................ ៥៨



ឌុច នៅក្នុងបន្ទប់សវនាការក្នុងនាមជាសាក្សី

**រក្សាសិទ្ធិ**

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ០២៩១ពម/៩៩
ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

រូបថតឯកសារៈ មជ្ឈមណ្ឌលឯកសារកម្ពុជា
និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង

**ស្នេរលេខនេះ** ៖ ថេសា បាឡែក, គ្រីស្ទៀន អូស៊ីហែដ, ស៊ីវ ហេឌើ, ហេង ឌិចហុង, កុំ មេន, ហ៊ួ ឆ្នួន **អ្នកនិពន្ធនិងស្រាវជ្រាវ** ៖ ទាវ សារៈមុនិន្ទ, សោម ប៊ុនថន, ស៊ិន សុធីតា **អ្នកបកប្រែ** ៖ ទែន សុខស្រីនិត **និពន្ធនាយកទូទៅ** ៖ ឆាំង យុ **ជំនួយការនិពន្ធនាយក** ៖ ញាណ សុជាតិ **ក្រាហ្វិកកុំព្យូទ័រ** ៖ ស៊ឹម សុភ័ក្ត្រ **គ្រប់គ្រងការចែកផ្សាយ** ៖ ឆេង វើង Email: dccam@online.com.kh, Homepage: www.dccam.org

# តួនាទីរបស់អាស៊ានចំពោះសាលាក្តីខ្មែរក្រហម

រដ្ឋាភិបាលនៃប្រទេសមួយចំនួននៅតំបន់អាស៊ីនៅតែចាត់ទុកបញ្ហាសិទ្ធិមនុស្សជាទស្សនៈរបស់បស្ចឹមប្រទេស ។ យ៉ាងណាមិញ អស់រយៈពេលជាច្រើនទសវត្សរ៍កន្លងមកនេះ ប្រជាជនក្នុងប្រទេសជាច្រើននៅតំបន់អាស៊ីបានបង្ហាញពីជំនឿដែរថា សិទ្ធិមនុស្សគឺជាបញ្ហាសកលលោក ។ អាស្រ័យហេតុនេះ បញ្ហាសិទ្ធិមនុស្ស និងនីតិរដ្ឋគឺជាសមាសធាតុដ៏សំខាន់នៃគោលការណ៍លទ្ធិប្រជាធិបតេយ្យ ។ ខណៈពេលដែលប្រទេសនៅអាស៊ី និងនៅសមាគមន៍ប្រជាជាតិអាស៊ីអាគ្នេយ៍ (អាស៊ាន) កំពុងដើរតួនាទីដ៏សំខាន់ក្នុងបញ្ហានយោបាយពិភពលោក និងសេដ្ឋកិច្ចអន្តរជាតិ វាពិតជាសំខាន់ណាស់ដែលថាការប្រព្រឹត្តនិងការបំពេញតួនាទីរបស់ប្រទេសជាសមាជិកអាស៊ានឆ្លុះបញ្ចាំងពីការផ្លាស់ប្តូរដែលកំពុងតែកើតមានឡើងក្នុងតំបន់អាស៊ី ។

គោលការណ៍ដ៏ចម្បងមួយរបស់អាស៊ានគឺកិច្ចសហប្រតិបត្តិការសង្គមវប្បធម៌ «ដើម្បីធ្វើឲ្យប្រទេសជាសមាជិកនីមួយៗដឹងពីសក្តានុពលភាពក្នុងវិស័យអភិវឌ្ឍរបស់ខ្លួនឲ្យកាន់តែច្បាស់» ។ ដោយសារតែលក្ខណៈស្រដៀងគ្នាទាំងផ្នែកប្រវត្តិសាស្ត្រ និងវប្បធម៌ សមាជិកប្រទេសអាស៊ានមានការស្វែងយល់គ្នាដ៏ប្រសើរមួយក្នុងការដោះស្រាយបញ្ហារបស់ប្រទេសជាសមាជិក ។


កម្ពុជា


ប្រ៊ុយណេ


ឥណ្ឌូនេស៊ី


ឡាវ


ម៉ាឡេស៊ី


ភូមា


ហ្វីលីពីន


សិង្ហបុរី


ថៃ


វៀតណាម

ដូច្នេះបណ្តាសមាជិកអាស៊ានទាំងអស់គឺឋិតក្នុងគោលជំហរដ៏ប្រសើរបំផុតក្នុងការជួយប្រទេសកម្ពុជាឲ្យទទួលបានលទ្ធផលវិជ្ជមានពីដំណើរការជំនុំជម្រះក្តីខ្មែរក្រហម និងពីបទពិសោធន៍ដែលទទួលបានពីដំណើរការកាត់ក្តីនេះ ។

រហូតមកដល់សព្វថ្ងៃនេះ ប្រទេសថៃគឺជាសមាជិកអាស៊ានតែមួយគត់ដែលបានផ្តល់វិភាគទានជាថវិកាបន្តិចបន្តួចដល់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាឬសាលាក្តីខ្មែរក្រហម ។ ប៉ុន្តែសមាគមន៍អាស៊ានទាំងមូល និងសមាជិកដទៃទៀតនៅតែមានឱកាសផ្តល់វិភាគទានក្នុងការកសាងនីតិរដ្ឋក្នុងប្រទេសកម្ពុជាតាមរយៈផ្តល់មូលនិធិជាថវិកាឬជាជំនួយសប្បុរសធម៌ដល់សាលាក្តីនេះ ។

បន្ថែមលើជំនួយផ្នែកហិរញ្ញវត្ថុ ប្រទេសជាសមាជិកអាស៊ានអាចផ្តល់ជាវិភាគទានបែបសាមញ្ញ និងមិនចំណាយថវិកាច្រើនទេ ។ សកម្មភាពទាំងនោះរួមមានៈ

◆**ជំនួយផ្នែកបច្ចេកវិទ្យាៈ** ប្រទេសជាសមាជិកដូចជាប្រទេសសិង្ហបុរីជាដើមមានធនធានមនុស្សក្នុងវិស័យបច្ចេកវិទ្យាប្រកបដោយវិជ្ជាជីវៈខ្ពស់ដែលអាចជួយស្វែងរកនិងជីកកកាយរណ្តៅសាកសពចំនួនប្រមាណ១៩,០០០កន្លែងទូទាំងប្រទេសកម្ពុជា ។

◆**កិច្ចការចងក្រងឯកសារៈ** រដ្ឋាភិបាល អ្នកការទូត សាកលវិទ្យាល័យនិងប្រជាពលរដ្ឋរបស់ប្រទេសជាសមាជិកអាស៊ានអាចប្រគល់ជូនកម្ពុជានូវឯកសារដែលអាចយកមកប្រើប្រាស់ជាភស្តុតាងដល់សាលាក្តីខ្មែរក្រហមឬជួយប្រជាជនកម្ពុជាស្វែងយល់ពីប្រវត្តិសាស្ត្ររបស់ខ្លួនឲ្យកាន់តែប្រសើរឡើង ។

◆**ការផ្តល់ប្រឹក្សាៈ** តាមការសិក្សាបានឲ្យដឹងថា ចំនួនមួយភាគបីឬប្រមាណពីរលាននាក់នៃប្រជាជនដែលរួចរស់រានមានជីវិតពីរបបកម្ពុជាប្រជាធិបតេយ្យនៅតែទទួលរងជំងឺតានតឹងផ្លូវចិត្ត ។ នៅក្នុងគម្រោងសហការជាមួយអង្គការចិត្តសង្គមអន្តរវប្បធម៌ មជ្ឈមណ្ឌលឯកសារកម្ពុជាបានរកឃើញថា ការព្យាបាលបែបសាមញ្ញដូចជាលំហាត់ដកដង្ហើមឬវិធីសាស្ត្រទទួលទានដំណោកអាចជាវិធីសាស្ត្រដ៏ប្រសើរមួយក្នុងការជួយព្យាបាលអ្នករួចរស់រានមានជីវិតពីរបបកម្ពុជាប្រជាធិបតេយ្យដែលប្រឈមមុខនឹងកំហឹង ជំងឺដេកមិនលក់ និងមុខសញ្ញាផ្សេងៗនៃជំងឺតានតឹងផ្លូវចិត្តនេះ ។ ជាមួយគ្នានេះយើងក៏បានរកឃើញថា វិធីសាស្ត្ររបស់ប្រទេសលោកខាងលិចក្នុងការព្យាបាលរោគសញ្ញាខាងលើនេះដូចជាការព្យាបាលជាក្រុមមិនអាចទទួលយកបានឬមិនមានប្រសិទ្ធភាពទេក្នុងបរិបទប្រទេសកម្ពុជាឡើយ ។ ដោយសារតែមានវប្បធម៌ និងភាពយោគយល់ពីកំណើតផ្នែកចិត្តសាស្ត្ររបស់ប្រទេសជាសមាជិកអាស៊ាន អ្នកផ្តល់ប្រឹក្សាពីបណ្តាប្រទេសអាស៊ានអាចផ្តល់ជំនួយដ៏ប្រសើរដល់ប្រទេសកម្ពុជាតាមរយៈការផ្តល់ប្រឹក្សាយោបល់ដល់ជនរងគ្រោះនិងជនដែលដល់នៃរបបខ្មែរក្រហម ។

◆**បច្ចេកវិទ្យាប្រព័ន្ធកុំព្យូទ័រៈ** ការបរិច្ចាគជាកុំព្យូទ័រថ្មីៗ សម្ភារបញ្ចាំងរូបភាព និងប្រព័ន្ធកុំព្យូទ័រផ្សេងទៀតដល់បុគ្គលិករបស់សាលាក្តីខ្មែរក្រហមគឺជាវិភាគទានដ៏មានតម្លៃបំផុត ។ ដូចគ្នានេះ ការបរិច្ចាគជាប្រព័ន្ធបញ្ជូនសម្លេងឬវិទ្យុដល់ប្រជាជនកម្ពុជាពិតជាមានសារៈសំខាន់ក្នុងការជួយឲ្យប្រជាជនកម្ពុជាតាមដានដំណើរការវិវឌ្ឍន៍របស់សាលាក្តីខ្មែរក្រហមនេះបាន ។

◆**មធ្យោបាយដឹកជញ្ជូនៈ** ការបរិច្ចាគជារថយន្តធំៗ និងរថយន្តក្រុងតូចៗគឺជាមធ្យោបាយមួយដ៏ចាំបាច់បំផុតក្នុងការដឹកជញ្ជូនប្រជាជនដែលមិនមានលទ្ធភាពធ្វើដំណើរពីតំបន់ដាច់ស្រយាលមកទីក្រុងភ្នំពេញ ។

◆**អ្នកស្ម័គ្រចិត្តៈ** ប្រទេសជាសមាជិកអាស៊ានអាចបញ្ជូនអ្នកស្ម័គ្រចិត្តដើម្បីជួយក្នុងកិច្ចខំប្រឹងប្រែងផ្សព្វផ្សាយសាធារណៈដើម្បីធានាថាប្រជាជនកម្ពុជាទាំងអស់បានយល់ដឹងពីដំណើរការរបស់សាលាក្តីនិងឱកាសក្នុងការចូលរួមតាមដានក្នុងដំណើរការនីតិវិធីរបស់សាលាក្តី ។

ប្រជាជនកម្ពុជាបានរង់ចាំយុត្តិធម៌អស់រយៈពេលជាងសាមសិបឆ្នាំមកហើយ ។ ប្រសិនបើដំណើរការប្រកបដោយរលូនសាលាក្តីខ្មែរក្រហមនិងមានសក្តានុពលក្នុងការជួយឲ្យមានការចងចាំចំពោះព្រឹត្តិការណ៍ដែលបានកើតឡើងក្នុងប្រទេសកម្ពុជា និងជំរុញឲ្យប្រជាជនក្នុងតំបន់អាស៊ីទាំងអស់ធានាថាឧក្រិដ្ឋកម្មប្រហាក់ប្រហែលគ្នានេះនឹងមិនកើតឡើងម្តងទៀតទេ ។ ប្រជាជនកម្ពុជាមានក្តីសង្ឃឹមថាប្រទេសជាសមាជិកអាស៊ាននឹងបង្ហាញនូវការគាំទ្រផ្នែកសិទ្ធិមនុស្សក្នុងតំបន់អាស៊ីតាមរយៈការផ្តល់ជំនួយជាតម្រូវការចាំបាច់ដល់សាលាក្តីខ្មែរក្រហមដែលកំពុងតែដំណើរការនេះ ។

**ឆាំង យុ**

# សុន្ទរកថារបស់សមមិត្តលេខា ប៉ុល ពត ក្នុងឱកាសមហាមីទ្ទីងទទួលអំណរខួបទី១០នៃកំណើតកងទ័ពបដិវត្តន៍កម្ពុជា

### ដកស្រង់ចេញពីឯកសារ D៣០៨៨៣

*ថ្ងៃទី១៧ ខែមករា ឆ្នាំ១៩៧៨*

ខ្ញុំសូមគោរពសមមិត្តជាតំណាងកងទ័ពកម្ពុជាទាំងអស់ដែលនៅក្នុងអង្គមីទ្ទីងខួបឆ្នាំទី១០ នៃកំណើតកងទ័ពបដិវត្តន៍កម្ពុជា ។ យើងសូមគោរពសមមិត្តជាតំណាងកម្មករទាំងអស់ ហើយនិងសូមគោរពសមមិត្តទាំងអស់ដែលតំណាងគ្រប់ក្រសួង-មន្ទីរនិងគ្រប់អង្គភាពបដិវត្តន៍របស់យើងដែលបានអញ្ជើញមករួមក្នុងអង្គមីទ្ទីងនេះដែរ ។

ជាដំបូង ខ្ញុំសូមតាងនាមបក្សកុម្មុយនីស្តកម្ពុជា យើងសូមតាងនាមគណៈកម្មាធិការយោធានៃមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា សូមតាងនាមរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ព្រមទាំងសូមតាងប្រជាជនកម្មករ-កសិករសមូហភាពរបស់យើងទាំងទូទាំងប្រទេស សូមសម្តែងនូវការគោរពស្ញប់ស្ញែង និងកោតសរសើរយ៉ាងកក់ក្តៅស្និទ្ធស្នាលនិងជ្រាលជ្រៅបំផុតចំពោះកងទ័ពបដិវត្តន៍កម្ពុជាយើងទាំងមូលដែលនៅក្នុងទីនេះក្តី នៅតាមអង្គភាពនីមួយៗក្តី ហើយជាពិសេសនៅតាមសមរភូមិទូទាំងប្រទេសដែលកំពុងប្រយុទ្ធយ៉ាងអង់អាចក្លាហាន ការពារកម្ពុជាប្រជាធិបតេយ្យ ការពាររដ្ឋអំណាចកម្មករ-កសិកររបស់បក្ស ការពារប្រជាជន សមូហភាពយើង ។

យើងទាំងអស់គ្នា គោរពស្ញប់ស្ញែង និងកោតសរសើរកងទ័ពបដិវត្តន៍កម្ពុជាយើងពីព្រោះកងទ័ពបដិវត្តន៍កម្ពុជាយើងនេះហើយដែលជាសសរគោលយ៉ាងរឹងមាំ ជាឧបករណ៍ផ្តាច់ការប្រដាប់អាវុធរបស់បក្សយ៉ាងស្មោះត្រង់ បានប្រយុទ្ធតស៊ូក្នុងចលនាសង្គ្រាមបដិវត្តន៍ជាបន្តបន្ទាប់ពីឆ្នាំ១៩៦៨ មកដល់សព្វថ្ងៃនេះ ហើយបានទទួលជ័យជម្នះជាបន្តបន្ទាប់ បានលើកស្ទួយនូវឋានៈយ៉ាងខ្ពង់ខ្ពស់កិត្តិយសដ៏ឧត្តុង្គឧត្តមរបស់ប្រទេសកម្ពុជាដែលពីមុនធ្លាប់តែអាប់ឱនរបស់ប្រជាជនកម្ពុជា របស់បដិវត្តន៍កម្ពុជា របស់បក្សកុម្មុយនីស្ត



កងប្រដាប់អាវុធរបស់កម្ពុជាប្រជាធិបតេយ្យនៅព្រលានយន្តហោះពោធិ៍ចិនតុង

កម្ពុជាយើងទាំងមូលឲ្យលេចត្រដែតត្រដឹមឡើងទាំងលើផ្ទៃប្រទេសកម្ពុជាទាំងលើផ្ទៃអន្តរជាតិ ។

ដូច្នេះ ក្នុងឱកាសដែលយើងជួបជុំគ្នាដើម្បីធ្វើពិធីទទួលអំណរខួបឆ្នាំទី១០ នៃកងទ័ពបដិវត្តន៍យើង យើងមានសេចក្តីរីករាយឥតឧបមា មានមោទកភាពប្រៀបបានចំពោះកងទ័ពបដិវត្តន៍កម្ពុជាយើង ពីព្រោះកងទ័ពនេះបានប្រយុទ្ធទ្រាំលំបាកវេទនាគ្រប់បែបយ៉ាង ហើយបានធ្វើពលីកម្មគ្រប់បែបយ៉ាងរាប់សិបឆ្នាំកន្លងមកហើយ ដើម្បីរំដោះប្រទេស រំដោះប្រជាជន ដើម្បីរដ្ឋអំណាចកម្មករ-កសិករបដិវត្តន៍របស់បក្ស ដើម្បីសេចក្តីថ្កុំថ្កើងរបស់ប្រទេសជាតិកម្ពុជា ដើម្បីសេចក្តីថ្កុំថ្កើងរបស់ប្រជាជនកម្ពុជាទាំងមូល និងដើម្បីការពារទឹកដីកម្ពុជាឲ្យគង់វង្សក្នុងពេលបច្ចុប្បន្នក៏ដូចជាគង់វង្សជរាបតរៀងទៅ ។

ឃើញប្រវត្តិនៃកងទ័ពបដិវត្តន៍កម្ពុជារបស់យើងបាន យើងមានជំនឿជឿជាក់លើកងទ័ពបដិវត្តន៍កម្ពុជារបស់យើងបាន យើងពេញចិត្តពេញថ្លើមចំពោះកងទ័ពបដិវត្តន៍របស់យើង ។ ឯប្រវត្តិរបស់កងទ័ពបដិវត្តន៍កម្ពុជាយើង យើងទាំងអស់គ្នាបានមានឱកាសសន្ទនាពិភាក្សាគ្នាជាញឹកញាប់ហើយ ។ ក្នុងឱកាសនេះ ខ្ញុំសូមលើកតែបញ្ហាខ្លះដើម្បីមកជម្រាបអង្គមីទ្ទីងរបស់យើង ។

ដំបូងសុំនិយាយអំពីកំណើតនៃកងទ័ពបដិវត្តន៍កម្ពុជា

ក្នុងបញ្ហាទី១នេះ ខ្ញុំសូមលើកជាសំនួរឡើងថា តើកងទ័ពបដិវត្តន៍កម្ពុជាកកើតឡើងពីណាមក? តើកងទ័ពបដិវត្តន៍កម្ពុជាកកើតឡើងតាមប្រភពណា? ហើយតើកងទ័ពនេះកកើតឡើងពង្រីងពង្រីកខ្លួននិងធំធាត់ឡើងខ្លាំងក្លាឡើងក្នុងកាលៈទេសៈណា?

កងទ័ពបដិវត្តន៍កម្ពុជាយើងមិនមែនកកើតឡើងដោយសារាចរ១ច្បាប់ ៤-១០ច្បាប់អំពីរដ្ឋាភិបាលនេះ អំពីរដ្ឋាភិបាលនោះ អំពីសភាពនោះ ដើម្បីឲ្យចាត់តាំងជាកងទ័ពបដិវត្តន៍កម្ពុជាទេ ។ មិនមែនអង្គការនេះមួយ អង្គការនោះមួយចុះហត្ថលេខាឲ្យជ្រើសរើសយុវជនមកចូលកងទ័ពស្លៀកពាក់ខោអាវជាកងទ័ពកាន់អាវុធជាកងទ័ព ហើយទៅជាកងទ័ពបដិវត្តន៍កម្ពុជានោះទេ ។ កងទ័ពរបស់យើងកកើតឡើងដោយមានការតស៊ូបដិវត្តន៍របស់ប្រជាជនក្រោមការដឹកនាំរបស់បក្សកុម្មុយនីស្តកម្ពុជា គឺបក្សកុម្មុយនីស្តកម្ពុជាបានលើកមាគ៌ាជាយុទ្ធសាស្រ្ត និងជាយុទ្ធវិធីដោយចក្រពត្តិនិយមដែលជ្រៀតជ្រែកឈ្លានពានកាន់កាប់ប្រទេសកម្ពុជាវាយសក្តិភូមិ នាយទុន ប្រតិកិរិយា ដែលជិះជាន់សង្កត់សង្កិនប្រជាជនកម្ពុជា ដើម្បីតស៊ូជាមួយចក្រពត្តិ ដើម្បីតស៊ូជាមួយប្រជាជនកម្ពុជា ដើម្បីតស៊ូជាមួយវណ្ណៈជិះជាន់ បក្សយើងបានកំណត់ថាត្រូវតស៊ូអាវុធ ហើយដើម្បីតស៊ូអាវុធត្រូវមានកងទ័ព ។ កងទ័ពបដិវត្តន៍នេះមានភារកិច្ចវាយចក្រពត្តិនិងពួកវណ្ណៈជិះជាន់ ។ ក្នុងការដឹកនាំរបស់បក្សជាបន្តបន្ទាប់ កងទ័ពនេះបានកកើតឡើងពីបាតដៃទទេ កកើតឡើងពីមួយនាក់កកើតឡើងពីពីរនាក់បី-បួននាក់វាយខ្មាំង ។ វាយខ្មាំងដោយប្រើហិង្សាបដិវត្តន៍ ពិសេសវាយខ្មាំងដោយប្រើហិង្សាអាវុធ ។ វាយខ្មាំងតាំងពីអាវុធបូរាណ វាយខ្មាំងតាំងពីអាវុធពាក់កណ្តាលសម័យរហូតទៅដល់វាយខ្មាំងដោយអាវុធសម័យ ។ វាយខ្មាំងពីមួយនាក់ វាយខ្មាំងពីមួយពួក វាយខ្មាំងពីមួយក្រុម វាយខ្មាំងពីមួយអនុសេនាតូច វាយខ្មាំងពីអនុសេនាធំរហូតដល់វាយខ្មាំងជាកងវរៈសេនាតូច វាយខ្មាំងជាកងវរៈសេនាធំរហូតវាយខ្មាំងជាកងពល ហើយរហូតវាយខ្មាំងដោយច្រើនកងពល ។ នេះជាការកកើតរបស់កងទ័ពបដិវត្តន៍យើងជាបន្តបន្ទាប់ដោយមានបក្សដឹកនាំដោយបក្សកំណត់មាគ៌ាមួយត្រឹមត្រូវថាតស៊ូអាវុធវាយខ្មាំង ហើយដើម្បីតស៊ូអាវុធត្រូវមានកងទ័ពបដិវត្តន៍ ។

ប្រវត្តិដ៏សង្ខេបប៉ុណ្ណោះរបស់កងទ័ពបដិវត្តន៍កម្ពុជាយើងបញ្ជាក់ឲ្យឃើញថា កងទ័ពយើងមិនមែនបង្កើតឡើងដោយសារាចរសំបុត្រស្នាមមួយពីរនោះទេ ។ កងទ័ពនេះប្រសូត្រចេញមកដោយភ្លើងប្រយុទ្ធតាំងពីបាតដៃទទេរហូតដល់ធំធាត់ដល់សព្វថ្ងៃ ។ ធំធាត់សព្វថ្ងៃ មិនមែនធំធាត់តិចតួចទេ គឺធំធាត់ដោយវាយចក្រពត្តិអាមេរិកដែលជាមេក្លោងចក្រពត្តិធំជាងគេ ក្នុងសកលលោកឲ្យបរាជ័យយ៉ាងអាម៉ាស់ ហើយធំធាត់រហូតដល់សព្វថ្ងៃនេះ វាយយួនឈ្លានពានវាតទី លេបទឹកដី ក៏ឲ្យបរាជ័យយ៉ាងអាម៉ាស់ដែរ ។ មកពីកងទ័ពនេះកកើតឡើងដោយមានបក្សដឹកនាំក្នុងការប្រយុទ្ធ ។

ឯសំនួរមួយទៀតថា តើកងទ័ពនេះកកើតឡើងធំធាត់ឡើងពីប្រភពណា?

ខ្ញុំសុំជម្រាបដូចតទៅៈ

កងទ័ពបដិវត្តន៍កម្ពុជាយើងកកើតឡើងពីប្រភពនៃកម្មករ-កសិករ ពីប្រភពនៃប្រជាជនជាវណ្ណៈក្រីក្រ ជាវណ្ណៈ

មូលដ្ឋាន ។ កងទ័ពយើងតាំងពីកកើតឡើងរហូតដល់សព្វថ្ងៃនេះ បើ និយាយពីសមាសភាពវណ្ណៈគឺកសិករភាគច្រើនដាច់ខាត ។ បន្ទាប់មក គឺកសិករកណ្តាលថ្នាក់ក្រោម ។ សមាសភាពកសិករក្រ និងកសិករ កណ្តាលថ្នាក់ក្រោមមានកៅសិបប្រាំភាគរយជាកម្មាភិបាល និងជា យុទ្ធជន ។ ក្រៅពីនេះ មានកសិករកណ្តាល ហើយនិងសមាសភាព បដិវត្តន៍ផ្សេងទៀតដែលចូលរួមដែរ ។ ឃើញសមាសភាពវណ្ណៈនៃ កងទ័ពបដិវត្តន៍យើងយ៉ាងនេះ បានឃើញប្រភពកំណើតរបស់កងទ័ព បដិវត្តន៍យើង ។ ប្រជាជនក្រីក្រជាប្រភពនៃការកកើតនៃកងទ័ពបដិវត្តន៍ យើងគឺប្រជាជនក្រីក្រនេះហើយជាកម្លាំងពង្រឹងពង្រីកកងទ័ព បដិវត្តន៍កម្ពុជា ។

ប្រជាជនកសិករ និងកណ្តាលថ្នាក់ក្រោម ហើយបន្ទាប់មក កសិករកណ្តាលគឺមានចំនួនច្រើនណាស់លើសពីប៉ែតសិបភាគរយ នៃប្រជាជនទូទាំងប្រទេស ។ ប្រជាជនទាំងអស់នេះជាប្រភពដ៏ធំ មហិមា ដ៏ច្រើនសន្ធឹកសន្ធាប់មិនចេះរីងស្ងួតទេ ក្នុងការផ្តល់កម្លាំង ដល់កងទ័ពបដិវត្តន៍យើងឲ្យកងទ័ពបដិវត្តន៍យើងកាន់តែធំធាត់ កាន់តែខ្លាំងក្លា កាន់តែខ្លាំងពូកែថែមទៀត ។ យើងមិនព្រួយពីបញ្ហា កងទ័ពរបស់យើងទៅជារីងស្ងួតវិញទេ ពីព្រោះចំនួនប្រជាជនជា វណ្ណៈភាពមូលដ្ឋានមានចំនួនច្រើនដ៏មហិមា ។ នេះនិយាយពីចំនួន ។ ម្យ៉ាងទៀត ទន្ទឹមនឹងចំនួននេះកងទ័ពយើងក៏មានធាតុពិតតាម ធាតុវណ្ណៈប្រជាជននេះដែរ ។ កសិករក្រ និងកសិករកណ្តាលថ្នាក់ ក្រោម អាចសន្មត់បានថា ជាវណ្ណៈអធន និងពាក់កណ្តាលអធននៅ ជនបទ ។ វណ្ណៈកសិករក្រ និងកណ្តាលថ្នាក់ក្រោមមានចំនួនច្រើន លើសលប់យ៉ាងនេះ ហើយមានធាតុពិតវណ្ណៈជាវណ្ណៈមូលដ្ឋាន យ៉ាងនេះនាំឲ្យកងទ័ពរបស់យើងធំធាត់ឡើងពង្រឹងពង្រីកខ្លួនជាចំនួន ក៏បានច្រើន ហើយព្រមជាមួយនេះរក្សាធាតុជាវណ្ណៈភាពវណ្ណៈ អធន និងពាក់កណ្តាលវណ្ណៈអធនក៏បានជាប់លាប់ ។ ហើយ កសិករក្រ និងកណ្តាលថ្នាក់ក្រោមនេះដែលមានវណ្ណៈភាពដើមល្អ ហើយនេះកសិករក្រនិងកណ្តាលថ្នាក់ក្រោមនេះមិនមែននៅឯកោ អនាថាទេ មិនមែនកសិករក្រ និងកណ្តាលថ្នាល់ក្រោមនៅរាយប៉ាយ ទេ គឺកសិករក្រ និងកណ្តាលថ្នាក់ក្រោមនេះឋិតនៅក្រោមការដឹកនាំ របស់បក្សមានគុណភាពខាងនយោបាយ សតិអារម្មណ៍ និងចាត់តាំង សមូហភាព ។ ប្រជាជនទាំងនេះហើយដែលផ្តល់កម្លាំងកងទ័ព ។ ប្រជាជនក្រីក្រនេះហើយជាមាតារបស់កងទ័ពយើង ។ បើមាតានេះ ល្អ ហើយបុត្រាបុត្រីក៏ល្អ ។ មាតានេះ វណ្ណៈភាពដើមក៏ល្អ ហើយបក្ស បានបំពាក់បំប៉នខាងនយោបាយ បំពាក់បំប៉នខាងសតិអារម្មណ៍ បំពាក់ បំប៉នខាងចាត់តាំងសមូហភាពកាន់តែរឹងប៉ឹងជាបន្តបន្ទាប់ទៀត ។ មាតាល្អយ៉ាងនេះ បុត្រាបុត្រីជាកងទ័ពក៏ល្អយ៉ាងនេះដែរ ។ តទៅ ទៀត យើងត្រូវឈរលើប្រភពប្រជាជនកសិករក្រ កសិករកណ្តាល ថ្នាក់ក្រោម ដើម្បីពង្រឹងពង្រីកកងទ័ពបដិវត្តន៍កម្ពុជាយើង ។ បើខុស ពីប្រភពនេះ កងទ័ពយើងលែងខ្លាំងហើយ ។ ឧបមាថា ថ្ងៃមុខទៀត យើងងាកទៅរកប្រភពផ្សេងដើម្បីជ្រើសរើសកងទ័ព កងទ័ពយើង លែងខ្លាំងហើយ អាវុធសម័យទំនើបយ៉ាងណាក៏ដោយ ។ បើ ប្រភពដើមមិនល្អ ហើយកងទ័ពនេះមិនខ្លាំងទេ ។ កូនថ្លោសទាល់តែ ម្តាយមាំមានសុខភាពល្អ ។សុខភាពល្អរបស់យើងចង់និយាយនៅ ទីនេះគឺវណ្ណៈភាពមាំទាំដំហរបដិវត្តន៍រឹងប៉ឹងទ្រាំទ្រការលំបាកប្រយុទ្ធ អង់អាចក្លាហាន ។ ម្តាយមានធាតុបដិវត្តន៍ខ្លាំងក្លា បានបុត្រមាន ធាតុបដិវត្តន៍ខ្លាំងក្លា ។ បុត្រទាំងនេះ ហើយដែលប្រយុទ្ធជាមួយ ខ្មាំងខ្លាំងក្លា ខ្មាំងប៉ុណ្ណាក៏ប្រយុទ្ធឈ្នះដែរ ។ នេះជាមាគ៌ា និងជា គោលជំហរចាត់តាំងកងទ័ពបដិវត្តន៍របស់យើងជារៀងរហូត ។

តទៅទៀត ក៏យើងត្រូវដំណើរការកសាងពង្រឹងពង្រីក កងទ័ពយើងទៅតាមប្រភពដើមនៃកសិករក្រ និងកណ្តាលថ្នាក់ ក្រោមជាមូលដ្ឋានបានកងទ័ពនេះមានធាតុពិតវណ្ណៈរឹងប៉ឹង ទាំងធាតុពិតវណ្ណៈដើមរបស់គេទាំងធាតុពិតវណ្ណៈអធនដែលបក្ស បានបំពាក់ឲ្យគេ ពីព្រោះកងទ័ពយើងគ្មានសក្តិ គ្មានប្រាក់ខែទេ តែជាកងទ័ពធ្វើបដិវត្តន៍ដ៏បរិសុទ្ធបំពេញភារកិច្ចបដិវត្តន៍ដ៏ខ្ពង់ខ្ពស់ ការពារប្រទេស ការពាររដ្ឋអំណាចកម្មករ កសិកររបស់បក្ស ការពារប្រជាជនសមូហភាព ។ ដូច្នេះទាល់តែតែមានស្មារតីបដិវត្តន៍ ខ្ពង់ខ្ពស់ណាស់បានប្រយុទ្ធអង់អាចក្លាហាន ។ កត្តាមនុស្សបដិវត្តន៍ ជាកត្តាសំខាន់ជាមូលដ្ឋាន ។ ឯកត្តាសម្ភារ និងកត្តាបច្ចេកទេស ជាកត្តាសំខាន់បន្ទាប់ ។ បើមានមនុស្សបដិវត្តន៍ខ្លាំងហើយគឺប្រយុទ្ធ ខ្លាំងណាស់ ។

ចំពោះសំនួរទីបីដែលលើកឡើងថា តើកងទ័ពបដិវត្តន៍យើង កកើតឡើងក្នុងកាលៈទេសៈណា?

កងទ័ពបដិវត្តន៍យើងមិនមែនកកើតឡើងក្នុងសន្តិភាពទេ ។

កងទ័ពយើងមិនមែនកកើតឡើងក្នុងសាលាយោធាទេ ឬក្នុងបណ្ឌិត្យសភាយោធាណាទេ ។ កងទ័ពយើងកកើតឡើងក្នុងភ្លើងប្រយុទ្ធដ៏សន្ធោសន្ធៅក្នុងសភាពការណ៍តស៊ូបដិវត្តន៍លំបាកវេទនាត្រាំត្រែងជាបន្តបន្ទាប់ ហើយកងទ័ពបដិវត្តន៍នេះប្រយុទ្ធជម្នះឧបសគ្គគ្រប់បែបយ៉ាងដើម្បីធំធាត់ឡើងដើម្បីពង្រឹងពង្រីកខ្លួនឡើង ។ ដូច្នេះកងទ័ពបដិវត្តន៍នេះមិនមែនសាកល្បងនៅក្នុងសង្គ្រាមបដិវត្តន៍ ៖ សង្គ្រាមផ្ទៃក្នុង១៩៦៨-១៩៦៩ សង្គ្រាមជាមួយចក្រពត្តិអាមេរិក១៩៧០-១៩៧៥ ។ ហើយពី១៩៧៥មកដល់សព្វថ្ងៃនេះកងទ័ពយើងប្រយុទ្ធជាមួយផ្នែកចក្រពត្តិអាមេរិកនិងបរិវាក៏ប្រយុទ្ធ ប្រយុទ្ធជាមួយផ្នែកយួនឈ្លានពានលេបទឹកដីក៏ប្រយុទ្ធ ។ ដូច្នេះកងទ័ពនេះ ពង្រឹងពង្រីកខ្លួន លត់ដំខ្លួនក្នុងភ្លើងប្រយុទ្ធជាបន្តបន្ទាប់ ។ លត់ដំក្នុងការប្រយុទ្ធនេះបានធ្វើឲ្យកងទ័ពនេះខ្លាំង ។ ការប្រយុទ្ធនាំឲ្យកងទ័ពយើងកកើតឡើង ពង្រឹងពង្រីកខ្លួនឡើង ធំធាត់ឡើងខ្លាំងក្លាឡើងជាលំដាប់ ។ ការប្រយុទ្ធជាការលត់ដំជាការសាកល្បងនាំឲ្យយើងពិនិត្យកងទ័ពបដិវត្តន៍យើង កម្មាភិបាលយើង យុទ្ធជន យុទ្ធនារីយើងតាមការជាក់ស្តែងក្នុងចលនាជាក់ស្តែងហើយតាមពិសោធន៍ក្នុងការប្រយុទ្ធនេះនាំឲ្យយើងពង្រឹងពង្រីកកងទ័ពយើងកាន់តែខ្លាំងក្រោមការដឹកនាំរបស់បក្ស ។

សរុបសេចក្តីទៅ កងទ័ពបដិវត្តន៍កម្ពុជាយើងកកើតឡើង ៖

◆ ដោយបក្សដឹកនាំតាមមាគ៌ាហិង្សាបដិវត្តន៍ជាក់ស្តែងគឺដោយធ្វើសង្គ្រាមបដិវត្តន៍ ។

◆ កងទ័ពនេះកកើតឡើងក្នុងប្រភពប្រជាជនក្រីក្របានជាកងទ័ពនេះខ្លាំងក្លា ។ ប្រជាជននេះ មានវណ្ណៈភាពដើមជាកសិករក្រ និងជាកសិករកណ្តាលថ្នាក់ក្រោមហើយប្រជាជននេះមានបក្សដឹកនាំទៀត មានបក្សដឹកនាំទាំងនយោបាយ ទាំងសតិអារម្មណ៍ទាំងចាត់តាំង ហើយតាំងជាសមូហភាពទៀត ។

◆ កងទ័ពនេះបានប្រយុទ្ធលត់ដំនិងសាកល្បងជាបន្តបន្ទាប់ក្នុងភ្លើងសង្គ្រាមបដិវត្តន៍ដ៏សន្ធោសន្ធៅ ដូច្នេះកងទ័ពនេះមានលក្ខណៈពេញលេញមានតួអង្គពេញលេញរបស់បក្សកុម្មុយនីស្តកម្ពុជាយើង ។

ដូច្នេះ តទៅទៀត បក្សយើងទាំងមូលប្រជាជនយើងទាំងមូលខិតខំកសាងកងទ័ពបដិវត្តន៍កម្ពុជារបស់យើងតាមគោលការណ៍នេះដើម្បីឲ្យកងទ័ពយើងខ្លាំងក្លាជារៀងរហូតកុំឲ្យប្រែធាតុឲ្យសោះ ។

តទៅនេះខ្ញុំសូមជម្រាបអំពីជ័យជម្នះជាបន្តបន្ទាប់ដែលកងទ័ពបដិវត្តន៍កម្ពុជាយើងដណ្តើមបានក្នុងរយៈកាលបដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យ ក៏ដូចជាក្នុងរយៈកាលបដិវត្តន៍សង្គមនិយមរបស់យើង តើកងទ័ពបដិវត្តន៍យើងដែលកើតឡើងនិងធំធាត់ឡើងជាបន្តបន្ទាប់មានថ្វីអាវុធក្នុងសង្គ្រាមបដិវត្តន៍ជាបន្តបន្ទាប់យ៉ាងណាខ្លះ? យើងត្រូវតែរំឭក និងបង្ហាញឲ្យច្បាស់ថែមទៀតនូវថ្វីអាវុធជាជ័យជម្នះក្នុងសង្គ្រាមបដិវត្តន៍ជាបន្តបន្ទាប់របស់យើងកងទ័ពបដិវត្តន៍កម្ពុជាយើងដើម្បី ៖




ម្យ៉ាងយើងទាំងអស់គ្នាកាន់តែមានមោទកភាពស្រឡាញ់ពេញចិត្តពេញថ្លើម គោរពសរសើរ កោតស្ញប់ស្ញែង និងមានជំនឿជឿជាក់មោះមុតលើកងទ័ពបដិវត្តន៍កម្ពុជាយើង ហើយយើងទាំងអស់គ្នាខំថែបំប៉នពង្រឹងពង្រីកកងទ័ពបដិវត្តន៍កម្ពុជាយើងឲ្យកាន់តែកើនចម្រើនឡើងខ្លាំងក្លាគ្មានឈប់ឈរលើគ្រប់ផ្នែកនយោបាយ សតិអារម្មណ៍ចាត់តាំងមាគ៌ាប្រយុទ្ធរបស់បក្ស ។

ម្យ៉ាងទៀតដើម្បីវាយបំបាក់ឲ្យអស់នូវការឃោសនាចក្រពត្តិ ប្រតិកិរិយា ឈ្លានពានវាតទី លេបទឹកដី ដែលវាឈរលើ

គោលជិហរផលប្រយោជន៍វណ្ណៈ និងនយោបាយឈ្លានពាន វាតទី លេបទឹកដីរបស់ពួកវា វាតែងតែប្រើឧបាយកលឃោសនាដ៏អាស្រូវ របស់វាធ្វើជាអ្នកទោះទាយបង្អាប់បន្ទុះដល់កងទ័ពបដិវត្តន៍នៃប្រទេស តូចតាចប្រទេសក្រីក្រដែលខ្វះខាតខាងគ្រឿងសម្ភារយោធាថា កង ទ័ពបដិវត្តន៍ប្រទេសនោះដាច់ខាតមិនឈ្នះលើកងទ័ពឈ្លានពានវាតទី របស់ពួកមហាអំណាចចក្រពត្តិប្រតិកិរិយា និងរបស់ប្រទេសធំដែល មានមនុស្សច្រើនមានកងទ័ពច្រើន និងមានគ្រឿងសាស្ត្រាវុធច្រើនគ្រប់ បែបយ៉ាង ។ នៅក្នុងប្រវត្តិនៃកងទ័ពបដិវត្តន៍យើង ក៏ពួកទាំងនេះ


ប៉ុល ពត

វាទស្សន៍ទាយថា កងទ័ពយើងត្រូវខ្ទេចខ្ទីអស់រលីងមិនដឹងប៉ុន្មាន លើកប៉ុន្មានសាហើយទេ ។ ពួកវាទាំងនេះផ្សព្វផ្សាយធ្វើជាអ្នកទស្សន៍ ទាយដើម្បីធ្វើសង្គ្រាមចិត្តសាស្ត្រ សង្គ្រាមនយោបាយ គំរាមកំហែង បំភិតភ័យ បំភ័ន្តបំភាំង សំឡុតស្មារតីរបស់ប្រជាជន និងកងទ័ព បដិវត្តន៍នៃប្រទេសតូចតាច ប្រទេសក្រីក្រឲ្យតក់ស្លុត ខ្លបខ្លាច និង សារភាពជាមុនដើម្បីឲ្យវាចូលមកឈ្លានពានរុករានទន្ទ្រានដែនដីគេ ឯងតាមចិត្តវាតទី និងលេបទឹកដីគេឯងតាមបំណងដ៏លោភលន់ របស់វាតាមចិត្ត ។

អាស្រ័យនូវហេតុផលខាងលើនេះហើយដែលយើងទាំង អស់គ្នាត្រូវតែរំឭកនូវអាវុធជាជ័យជម្នះជាបន្តបន្ទាប់របស់កងទ័ព បដិវត្តន៍យើងក្នុងឱកាសដ៏មហាឡារិកនៃខួបឆ្នាំទី១០នៃកំណើត កងទ័ពបដិវត្តន៍កម្ពុជាយើងនេះ ។

ខ្ញុំសូមជម្រាបដោយសង្ខេបនូវថ្វីអាវុធជាជ័យជម្នះដ៏មហា អស្ចារ្យជាបន្តបន្ទាប់ដែលកងទ័ពបដិវត្តន៍កម្ពុជាយើងដណ្តើមបាន ក្នុងសង្គ្រាមបដិវត្តន៍ពី១៩៦៨-១៩៧៨នេះ ដោយចែកជា រយៈកាលសង្គ្រាមបដិវត្តន៍នេះជាបីផ្នែកគឺ ៖

- ១៩៦៨ ដល់ខែមីនា ឆ្នាំ១៩៧០ (រយៈពេលរំដោះប្រទេស)
- ខែមីនា ឆ្នាំ១៩៧០ដល់ខែមេសា ឆ្នាំ១៩៧៥ (រយៈកាលរំដោះប្រទេស)
- ខែឧសភា ឆ្នាំ១៩៧៥ ដល់ខែមករា ឆ្នាំ១៩៧៨ (រយៈកាលការពារប្រទេស)

១) ពីឆ្នាំ១៩៦៨ដល់ខែមីនាឆ្នាំ១៩៧០ មានផ្ទុះសង្គ្រាម ផ្ទៃក្នុងនៅក្នុងប្រទេសយើងដែលវណ្ណៈជិះជាន់ប្រតិកិរិយាមានពួក យោធានិយម លន់ នល់, សិរិ មតៈ ជាមេក្លោង ហើយដែលមាន ចក្រពត្តិអាមេរិកជាអ្នកញាក់ខ្សែប្រឆាំងនឹងបដិវត្តន៍យើង ។ ប្រៀបធៀបកម្លាំងខ្លាំង និងយើងពេលនោះមានដូចតទៅ ៖

បក្សពួក លន់ នល់ បរិវារចក្រពត្តិអាមេរិកមានកងទ័ព របស់វាចំនួន៦ម៉ឺននាក់ទាំងជើងគោក ទាំងជើងទឹក ទាំងជើងអាកាស ទាំងទាហានទាំងកងតម្រួត ។ ឯយើងជំនាន់នោះ បើរាប់គ្រប់ភូមិភាគ ទៅពីឆ្នាំ១៩៦៨ កងឈ្លបយើងមានមិនដល់មួយពាន់នាក់ផង ។

ដូច្នេះប្រៀបធៀបនឹងខ្មាំង យើងនៅខ្សោយណាស់យើង នៅ តូចណាស់ ខ្មាំងវាមានកម្លាំងធំធេង ។ បើប្រៀបធៀបជារូបភាពខ្មាំង ហាក់ដូចជាដំរីសា យើងហាក់ដូចជាស្រមោចសង្ហា ។

ក្នុងសភាពហ្នឹង ហោរាក្នុងប្រទេស និងហោរាក្រៅប្រទេស ដែលសុទ្ធតែហោរាចក្រពត្តិ និងហោរាពួកវណ្ណៈជិះជាន់ វាទាយ ថាខ្មែរក្រហមមុខជាត្រូវខ្ទេចខ្ទីអស់រលីងសាបសូន្យហើយ ។ តែលទ្ធ ផលជាក់ស្តែងវាយ៉ាងម៉េច? លទ្ធផលជាក់ស្តែងរបស់យើងគឺយើង ការពារហើយនិងពង្រីងពង្រីកខ្លួនបាន ។ តែសឹងតែបាតដៃទទេនា ឆ្នាំ១៩៦៨ មកដល់ខែមីនា ឆ្នាំ១៩៧០ យើងមានកងទ័ពប្រមូល

ដីរបស់យើងបួនពាន់នាក់មានកងឈ្លបប្រាំម៉ឺននាក់ទូទាំងប្រទេស ធ្វើសង្គ្រាមឈ្លបតាមខេត្ត១៧ក្នុង១៩ខេត្តទូទាំងប្រទេស ។ យើងមានតំបន់រំដោះជាមូលដ្ឋានបង្អែករបស់យើងដែលមានប្រជាជនប្រាំមួយម៉ឺននាក់ ។ យើងមានមូលដ្ឋានឈ្លបរបស់យើងដែលមានប្រជាជនបីសែននាក់ ។ យើងមានតំបន់ឈ្លបរបស់យើងដែលមានប្រជាជនប្រាំពីរសែននាក់ទៀត ។ ដូច្នេះសរុបទៅដល់ឆ្នាំ១៩៧០ យើងមានតំបន់ យើងមានមូលដ្ឋានឈ្លប យើងមានតំបន់ឈ្លប មានប្រជាជនជាងមួយលានលាននាក់ ។ កម្លាំងយើងធំធាត់ជានិច្ចការពារ ហើយពង្រីងពង្រីកខ្លួនបានជានិច្ច ពង្រីងពង្រីកខ្លួន ទាំងកងទ័ព ទាំងប្រជាជន ទាំងតំបន់រំដោះ ទាំងមូលដ្ឋានឈ្លប ទាំងតំបន់ឈ្លប ទាំងកងទ័ពប្រមូលផ្តុំ ទាំងកងឈ្លប ។ កម្លាំងនេះខ្លាំងណាស់ក្នុងសង្គ្រាមផ្ទៃក្នុងធ្វើឲ្យខ្មាំងវាបរាជ័យយ៉ាងធ្ងន់ធ្ងរណាស់ ។ យើងការពារ ហើយនិងពង្រីងពង្រីកកម្លាំងទ័ពបដិវត្តន៍បានដោយសេរី ដោយសារយើងមានមាគ៌ាត្រឹមត្រូវអនុវត្តសង្គ្រាមប្រជាជនរបស់បក្សត្រឹមត្រូវ ។ ដូច្នេះ ទំនាយរបស់ពួកចក្រពត្តិក្នុងសកលលោក ទំនាយរបស់ពួកចក្រពត្តិ និងពួកប្រតិកិរិយានៅក្នុងប្រទេសដែលប្រឆាំងបដិវត្តន៍ត្រូវវាយបំបាក់និងរលាយខ្សុលទាំងអស់ ។ ពួកវាឃោសនានយោបាយ ឃោសនាសង្គ្រាមចិត្តសាស្ត្រដើម្បីបោកប្រាស់យើង ដើម្បីបំភ័ន្តមតិសកលលោក ។ ប៉ុន្តែប្រវត្តិសាស្ត្រនៃចលនាបដិវត្តន៍យើងបញ្ជាក់ច្បាស់ថា ពីឆ្នាំ១៩៦៨ ដល់ខែមីនាឆ្នាំ១៩៧០ យើងដណ្តើមមហាជ័យជម្នះបានយ៉ាងនេះ ។ ជ័យជម្នះជាជំហានដំបូងមែនតែចាត់ទុកបានថា ជាមហាជ័យជម្នះមូលដ្ឋាននាំឲ្យបក្សយើងនាំឲ្យកងទ័ពយើងនិងនាំឲ្យប្រជាជនយើងបានកសាងជំហរឯករាជ្យម្ចាស់ការហើយពង្រីង និងពង្រីកវាបានយ៉ាងរឹងមាំក្នុងការប្រយុទ្ធឆ្លងកាត់នូវការលំបាកវេទនាយ៉ាងអនេក ។ គោលជំហរឯករាជ្យម្ចាស់ការខ្លួនទីពឹងខ្លួន ខ្លួនកាន់វាសនាខ្លួនដោយខ្លួនឯងបានចេញមក និងបានពង្រីងពង្រីកជាគ្រឹះរឹងមាំក្នុងរយៈកាលប្រយុទ្ធនៅពេលនោះឯង ។

(២) នៅក្នុងរយៈពេលធ្វើសង្គ្រាមរំដោះជាតិវាយចក្រពត្តិអាមេរិក ឆ្នាំ១៩៧០មក១៩៧៥ ពួកហោរាចក្រពត្តិ និងពួកប្រតិកិរិយាក៏វាទស្សន៍ទាយទៀត ។ វាឃោសនាវាយបដិវត្តន៍តាមវិធីគ្រប់បែបគ្រប់យ៉ាងធ្វើម៉េចឲ្យប្រជាជនភ័ន្តច្រឡំ ធ្វើម៉េចកងទ័ពយើងភ័ន្តច្រឡំ ធ្វើម៉េចឲ្យបក្សយើងភ័ន្តច្រឡំ ធ្វើម៉េចឲ្យសកលលោកភ័ន្តច្រឡំ ធ្វើឲ្យខ្លបខ្លាចមហាអំណាចហើយសារភាពថា សុខចិត្តសុខកាយឱនក្បាលទៅឲ្យពួកវាជាន់ឈ្លីតាមចិត្តឲ្យខ្មាំងជំនាន់នោះមានកម្លាំងដូចតទៅៈ

- ពួក លន់ នល់ មានពីប្រាំមួយម៉ឺនមកពីរសែននាក់ ។
- មានពួកអាធិវតី ជាងមួយសែននាក់ចូលមកក្នុងដីយើងទៀត ។
- មានចក្រពត្តិអាមេរិកចូលមកឈ្លានពានកម្ពុជាផ្ទាល់ក្នុងខែមេសា–ឧសភា ឆ្នាំ១៩៧០ ច្រើនម៉ឺននាក់ ។

ក្រៅពីនេះ វាប្រើកប៉ាល់ហោះពាសពេញលើផ្ទៃអាកាសកម្ពុជា ។ ដូច្នេះ កម្លាំងខ្មាំងមានពួកចក្រពត្តិអាមេរិកមានពួកអាធិវតីព្រៃនគរមានពួក លន់ នល់ ។ ក្រៅពីនេះ ក៏មានពួកប្រតិកិរិយាថៃ មានពួកកូរ៉េខាងត្បូង មានពួកតៃវ៉ាន់ ។ល ។ ចូលរួមមកធ្វើសកម្មភាពវាយយើងទៀត ។ កម្លាំងនេះធំធេងណាស់ ។ ដូច្នេះ សកលលោកខាងផ្នែកចក្រពត្តិ និងប្រតិកិរិយា វាទោះទាយជាស្រេចថាបដិវត្តន៍កម្ពុជាយើងមុខជាត្រូវខ្ទេចខ្ទី ត្រូវបរាជ័យទាំងស្រុង ។ ក៏ប៉ុន្តែលទ្ធផលជាក់ស្តែងគឺយើងដណ្តើមបានមហាជ័យជម្នះ១៧ មេសា ឆ្នាំ១៩៧៥ ។ កងទ័ពបដិវត្តន៍យើងដែលពីឆ្នាំ ១៩៧០ មានកងទ័ពប្រមូលផ្តុំតែបួនពាន់នាក់ មានកងឈ្លបតែប្រាំម៉ឺននាក់ធំធាត់ឡើងយ៉ាងឆាប់រហ័សទៅជាកងវរៈសេនាតូចទៅជាកងវរៈសេនាតូច ធំទៅជាកងពល ។ កងទ័ពក៏ធំធាត់ ប្រជាជនក៏ធំធាត់ សេដ្ឋកិច្ចក៏ឧបត្ថម្ភខ្លួនបានវាយខ្មាំងឈ្នះជាមហាជ័យជម្នះ ១៧ មេសា ឆ្នាំ១៩៧៥ ជាមហាជ័យជម្នះក្នុងប្រវត្តិសាស្ត្រកម្ពុជាហើយជាមហាជ័យជម្នះក្នុងប្រវត្តិសាស្ត្រសកលលោកដែលជាលើកដំបូងហើយដែលចក្រពត្តិអាមេរិកត្រូវវាយឲ្យបរាជ័យយ៉ាងអាម៉ាសយ៉ាងនេះ ។ ក្នុងកងទ័ពបដិវត្តន៍យើងវាយចក្រពត្តិអាមេរិកឈ្នះមកពីកងទ័ពនេះចេញមកពីប្រជាជនកម្មករកសិករមកពីកងទ័ពនេះជាកូនចៅរបស់កសិករក្រ និងកណ្តាលថ្នាក់ក្រោមមកពីកងទ័ពនេះបានលត់ដំក្នុងភ្លើងនៃចលនាតស៊ូសង្គ្រាមបដិវត្តន៍ជាបន្តបន្ទាប់ ។ ដូច្នេះ កងទ័ពនេះចេះតែខ្លាំងក្លាជារៀងរាល់ថ្ងៃតាំងពីតូចដល់ធំ តាំងពីដៃទទេរហូតដល់មានអាវុធកាន់តែច្រើនវាយខ្មាំងឈ្លានពានដណ្តើមបានជ័យជម្នះមួយហើយមួយទៀត ។

ជ័យជម្នះរបស់យើងនេះ វាវាយបំបាក់នូវទ្រឹស្តីអាស្រូវនូវគោលការណ៍អាស្រូវ នូវគោលការណ៍ជិហរអាស្រូវ នូវកម្លាំងឃោសនាអាស្រូវ និងពិសពុលដែលថា “ប្រទេសតូចតាចវាយមិនបាន” “ប្រទេសក្រវាយមិនបានងើបមុខមិនរួច” “ប្រទេសតូចត្រូវតែរណបគេ” “ប្រជាជនក្រីក្រត្រូវតែរណបគេ” ។ យើងវាយបំបាក់កម្លាំងឃោសនាពិសពុលរបស់ចក្រពត្តិ និងពួកប្រតិកិរិយាបានញុំាងឲ្យប្រជាជនសកលលោកបានត្រូវលើកទឹកចិត្តកាន់តែក្លៀវក្លាបន្តការតស៊ូដណ្តើមជ័យជម្នះតទៅទៀត ។

៣) ឥឡូវក្នុងការវាយយួនឈ្លានពាន វាតទី លេបទឹកដីហោរាក៏វាទាយទៀត ។ ហោរានេះគឺហោរាចក្រពត្តិ និងប្រតិកិរិយាវាតទីផ្សេងៗនៅក្នុងសកលលោក វាទាយថា កងទ័ពយួនដែលធ្លាប់បានសាកល្បងក្នុងសង្គ្រាមច្រើនសិបឆ្នាំហើយនេះមុខតែយកកម្ពុជាតែក្នុង២៤ម៉ោង ។ វាឃោសនាយ៉ាងនេះដើម្បីបំភ័ន្តមតិសលកលលោកសំឡុតស្មារតីប្រទេសតូចតាចប្រជាជនក្រីក្រឲ្យបាក់បបខួបខ្វាចវាតទៅទៀតតាមទ្រឹស្តីដ៏ពិសពុលរបស់ពួកវាដែលថា “ប្រទេសតូចត្រូវរណបគេ” “ឯករាជ្យម្ចាស់ការខ្លួនទីពឹងខ្លួនមិនបានទេ” ។ល ។ ប៉ុន្តែវាឃោសនាប៉ុណ្ណឹងហើយក៏ដោយក៏វាមិនអាចបំភ័ន្តមតិសកលលោកបានដែរ ។ មតិសកលលោកពេលនោះ បែងចែកជាពីរតែជាទូទៅខបត្តម្ភគាទ្រនិងមានសមានចិត្តចំពោះកម្ពុជាយើង ។

មតិភាគច្រើនជឿជាក់ថាកងទ័ពបដិវត្តន៍កម្ពុជាច្បាស់ជាវាយបណ្តេញយួនឈ្លានពានបានព្រោះកងទ័ពបដិវត្តន៍កម្ពុជានេះធ្លាប់បានវាយឈ្នះចក្រពត្តិអាមេរិកហើយ ។ ប៉ុន្តែមតិមួយផ្នែកតូចក៏មានការជួយព្រួយបារម្ភចំពោះយើងក្រែងយើងទប់ទល់នឹងការឈ្លានពានរបស់យួនមិនបាន ។

ខ្ញុំសុំជម្រាបលទ្ធផលនិងគុណភាពវាយរបស់កងទ័ពបដិវត្តន៍យើងដូចតទៅ ៖

កងទ័ពយួនដែលមកឈ្លានពានកម្ពុជាតាំងពីខែ៥ ឆ្នាំ១៩៧៥ មានដូចតទៅ ៖

ទី១) មានកងសន្តិសុខការពារព្រំដែន ។ កងទ័ពនេះហើយដែលបាញ់រះលើប្រជាជនយើងដែលរកស៊ីធ្វើស្រែចម្ការបាញ់រះលើកងទ័ពយើងយាមល្បាតបាញ់ផ្លោងចូលមកក្នុងដីយើងរាល់ពេលរាល់វេលា ។ ហើយពួកវាហ្នឹងហើយដែលចេះតែរំកិលទីតាំងរបស់វាចូលមកនៅក្នុងដីយើង ។ ហើយពួកវាហ្នឹងឯងដែលនាំឲ្យប្រជាជនវាមកធ្វើផ្ទះសសរខ្វះនៅដីវាសសរខ្វះនៅដីយើងរហូតចូលមកទាំងភូមិៗក្នុងដីយើងហៅថាដណ្តើមដីតាំងពីមួយតឹកពីរតឹកមួយម៉ែត្រ ពីរម៉ែត្រ មួយគីឡូម៉ែត្រ ពីរគីឡូម៉ែត្រឡើងទៅ ។ ពួកវាហ្នឹងវាបង្ករឿងបង្កហេតុហេតុតាមព្រំដែនយើងជាប់ ។ គ្រាន់តែខាងនិរតីក្នុងឆ្នាំ១៩៧៥-១៩៧៦ មួយខែៗវាគ្រាន់តែបាញ់រះបាញ់ផ្លោងរាល់ថ្ងៃរាល់ពេលគិតជាមធ្យមមួយខែៗយើងត្រូវស្លាប់និងរបួសជាង៣០នាក់ ហើយបើនៅខាងស្វាយរៀង និងនិយាយរួមវាបង្ករឿងយើងជាប់ហើយកន្លែងខ្លះមានសភាពខ្លាំងជាងនៅនិរតីទៅទៀត ។ ដូច្នេះតាំងពីខែឧសភា ឆ្នាំ១៩៧៥មកតាំងពីកំពតរហូតដល់រតនៈគិរី កងសន្តិសុខការពារព្រំដែនរបស់យួននេះបង្ករឿងហេតុតាមព្រំដែនរាប់មិនអស់ ។

ទី២) កងទ័ពតំបន់របស់វា ៖ កងទ័ពតំបន់ជាកងទ័ពរបស់ខេត្តវា ។ ខេត្តយួនដែលនៅជាប់ព្រំប្រទល់យើងទាំងអស់សុទ្ធតែមានកងតំបន់របស់វា ។ កងទ័ពតំបន់របស់វាតែងរួមជាមួយកងសន្តិសុខការពារព្រំដែនវាមកអុកឡុកប្រជាជនយើងតាមព្រំដែនជាប់ វាយបុកព្រហើនកោងកាចក្រអើតក្រទមប្រកាន់ឋានៈខ្លួនវាជា “បិតាឥណ្ឌូចិន” ជា “រាមច្បងឥណ្ឌូចិន” “ពួកអាល្អិតៗនៅឥណ្ឌូចិនត្រូវតែស្តាប់បង្គាប់អញ” “អញធ្វើអី ពួកអាល្អិតឯងទាំងអស់គ្នាស្តាប់អញ” ។

ទី៣) កងយុទ្ធភូមិភាគរបស់វា កងស្រួចយុទ្ធភូមិភាគគឺជាកងទ័ពស្រួចប្រចាំយុទ្ធភូមិភាគនីមួយៗដើម្បីធ្វើជាស្នូលអន្តរាគមន៍តាមតំបន់នានានៅក្នុងក្របខណ្ឌយុទ្ធភូមិភាគ ។

សុំបញ្ជាក់ថា កងសន្តិសុខការពារព្រំដែន កងតំបន់និងកងសន្តិសុខយុទ្ធភូមិភាគយួនទាំងបីប្រភេទនេះធ្លាប់បានចូលវ៉ៃយើងច្រើនដងច្រើនគ្រាណាស់តាំងពីខែឧសភា ឆ្នាំ១៩៧៥មកពិសេសក្នុងឆ្នាំ១៩៧៧ ។ ក៏ប៉ុន្តែកងវាទាំងបីប្រភេទនេះបានស្គាល់គុណភាពនៃកងទ័ពបដិវត្តន៍កម្ពុជាយើង ហើយដោយកងទ័ពបដិវត្តន៍កម្ពុជាយើងកម្ចាត់វាយឲ្យខ្ចាត់ខ្ចាយយ៉ាងដំណំជាប់រាល់ៗតែលើកដែលវាចូលមកឈ្លានពានទឹកដីយើង ។

ហេតុនេះហើយ បានជាដើម្បីចូលឈ្លានពានធំមកលើទឹកដី

កម្ពុជានៅខែវិច្ឆិកា និងខែធ្នូ ឆ្នាំ១៩៧៧ ហើយនិងនៅខែមករា ១៩៧៨នេះពួកយួននេះត្រូវកងទ័ពស្រួចរបស់អគ្គសេនាធិការ វាយនៅហាណូយផ្ទាល់តែម្តងជាច្រើនកងពលមានអាវុធសម្បូរបែប មានរថក្រោះរាប់រយគ្រឿង កាំភ្លើងធំរាប់រយគ្រឿងមកធ្វើជាកម្លាំងស្នូលបុកទម្លុះខ្សែការពារព្រំដែនដ៏ស្តើងរបស់យើងហើយ បុកចូលជ្រៅរាប់គីឡូម៉ែត្រ ហើយកន្លែងខ្លះរាប់សិបគីឡូម៉ែត្រ ក្នុងដីយើងពិសេសនៅផ្លូវលេខ៧ និងស្វាយរៀងខាងភូមិភាគបូព៌ា នៅតាកែវនិងកំពតខាងភូមិភាគនិរតីវាសាបព្រួសវិនាសកម្មលើប្រជាជនយើងភូមិករ សហករណ៍ គោក្របី ជ្រូក មាន់ទា ស្រែចម្ការ ច្បារដំណាំ ទ្រព្យសម្បត្តិសប់សារពើខ្ទេចខ្ទីជាច្រើន ។

តើបដិវត្តន៍អី? តើមិត្តភាពពិសេសអី? តើចរចាដោះស្រាយព្រំដែនអី? បើយួនធ្វើយ៉ាងនេះ?

យើងឃើញតែប្រទេសធំព្រហើនកោងកាចដាក់យើង ឃើញតែវាតទីទឹកដី យើងឃើញតែរំលោភឈ្លានពាន យើងឃើញតែធ្វើវិទ្ធង្សនាចង់ធ្វើរដ្ឋប្រហាររំលំកម្ពុជាយើង ។ល ហើយយើងឃើញលទ្ធិប្រទេសធំនេះវាដុះស្អិបជាប់ក្រាសយ៉ាងឃ្មឹកតាំងពីលើដល់ក្រោមរបស់យួន ។

ក៏ប៉ុន្តែខ្ញុំសុំជម្រាបអំពីលទ្ធផលជាក់ស្តែងនៃការឈ្លានពានវាតទីធំរបស់យួនលើកនេះមកលើកម្ពុជាតើវាឈ្នះឬវាចាញ់ ។ គឺវាចាញ់ធ្ងន់ណាស់ ហើយជ័យជម្នះនេះហើយធំដែរប្រៀបបាននឹងមហាជ័យជម្នះរបស់ប្រជាជននិងកងទ័ពបដិវត្តន៍កម្ពុជាយើងទៅលើយួនឈ្លានពាន វាតទី លេបទឹកដីនាថ្ងៃ៦ មករា ១៩៧៨ ។

ទី១) បរាជ័យរបស់យួនខាងយោធា ៖ ជាក់ស្តែងគឺកងទ័ពឈ្លានពានរបស់យួនគ្រប់សមរភូមិត្រូវកងទ័ពបដិវត្តន៍យើងវាយបំបាក់ឲ្យជាក្រញាំទៅព្រំដែនវិញ ។ ខ្មាំងត្រូវស្លាប់និងរបួស ២៩០០០នាក់ ។ រថក្រោះខ្មាំងធុនធំទំនើបថ្លៃរាប់លានដុល្លារមួយគ្រឿងត្រូវវាយខ្ទេចនិងខូចអស់ជាង១៣០គ្រឿងកាំភ្លើងធំខ្មាំងច្រើនសិបគ្រឿងត្រូវខ្ទេចនិងខូច ។ កងពលស្រួចខ្មាំងចំនួន៩កងត្រូវបាក់ ។

ខ្ញុំសុំបញ្ជាក់ថាហេតុដូចម្តេចបានជាយើងឈ្នះខ្មាំងសម្បើមយ៉ាងនេះ? និយាយរួមគឺយើងអនុវត្តមាគ៌ាសង្គ្រាមប្រជាជនរបស់បក្សបានល្អហើយជាពិសេសកងទ័ពបដិវត្តន៍យើងក្តាប់និងអនុវត្តន៍បានស័ក្តិសិទ្ធិនូវមាគ៌ាប្រយុទ្ធរបស់ខ្មាំងរបស់បក្ស ។ ខ្មាំងវាអាងតែរថក្រោះនិងកាំភ្លើងធំ ។ តែបើកាលណាកងទ័ពយើងវាយរថក្រោះខ្មាំងឲ្យខូចនិងឲ្យគាំងទៅអាថ្មើរជើងវារកតែអាយុហើយ ។ ឯវាយរថក្រោះមិនពិបាកអីទេ ។ អ្នកណាក៏វាយបាន គឺយើងប្រើមីនវាយរថក្រោះឲ្យច្រើនដាក់ស្កាត់តាមផ្លូវជាតិ ផ្លូវខេត្ត ផ្លូវលំធំតូចដែលរថក្រោះវាចលនាព្រោះរថក្រោះខ្មាំងបើកបរកាត់វាលស្រូវកាត់វាលពើក កាត់វាលមានទឹកមានស្មៅកាត់ប្រឡាយមេ ប្រឡាយកូនយើងមិនបានទេ ។ ម្ល៉ោះហើយប្រើមីនវាយស្កាត់ផ្លូវវាតែប៉ុន្មាននោះទៅរថក្រោះខ្មាំងត្រូវខ្ទេចខ្ទីនិងខូចដោយមីនយើងឲ្យរកូតរណែលតាមផ្លូវនោះហើយ ។ ព្រមជាមួយគ្នានោះយើងក៏ប្រើកាំភ្លើងបេ៤០ និងដេកា៧៥ និង៨២ផងដែរសម្រាប់វាយរថក្រោះខ្មាំង ។ វាយយ៉ាងនេះរថក្រោះខ្មាំងទៅជាត្រូវឥតបានការអីធំដុំហើយ ។ ឯកាំភ្លើងធំខ្មាំងក៏ត្រូវការចលនាតាមផ្លូវធំតូចទាំងនេះដែរ ព្រោះសុទ្ធតែត្រូវរទេះឡាន និងអាត្រាក់កង់ច្រវាក់អូសវា ។ ពួកអានេះក៏ស្ទុះមិនរួចនឹងមីនយើងដែរ ។ ឯការដឹកជញ្ជូនរបស់ខ្មាំងវិញសោតក៏អ៊ីចឹង ដឹកជញ្ជូនគ្រាប់រំសេវ ដឹកជញ្ជូនពួកអាស្លាប់និងរបួស ដឹកជញ្ជូនស្បៀង ។ល ។ ក៏ត្រូវគាំងដែរដោយមីនយើង ។

ក្នុងសភាពហ្នឹង តើពួកអាថ្មើរជើងវាធ្វើអីកើត? បានរថក្រោះឯណាជួយអន្តរាគមន៍? បានកាំភ្លើងធំឯណាជួយអន្តរាគមន៍? បានគ្រាប់រំសេវឯណាថែម? បានបាយឯណាស៊ី? ហើយក្នុងសភាពហ្នឹងកងទ័ពបដិវត្តន៍យើងវាយខ្មាំងនិងជាប់ ។ មិនយូរប៉ុន្មាន វាត្រូវតែបាក់ទ័ពត្រូវវាយឲ្យខ្ទេចខ្ទីនិងត្រូវរត់ផាយបាក់ទ័ពទៅព្រំដែនវិញ ។

ខ្ញុំសុំជម្រាបថា ខាងថ្មើរជើង ខាងណាមានជំហរបដិវត្តន៍ជាងមានជំហរអធនជាង ខាងនោះឯងហើយឈ្នះ ។ ចំណុចខ្សោយមួយទៀតរបស់កងទ័ពយួនឈ្លានពានវាតទីលេបទឹកដីគឺវាខ្វះបាយស៊ី ពួកវាស៊ីដុំកន្ទក់ ។ បើស៊ីតែដុំកន្ទក់ ហើយមកឈ្លានពានយើងមិនឈ្នះទេ ។

ទី២) បរាជ័យរបស់យួនខាងនយោបាយ ៖

ខាងនយោបាយយួនឈ្លានពានចាញ់ធ្ងន់ណាស់ហើយត្រូវស្អុយអាសោចក្នុងសកលលោកថាជាអ្នកឈ្លានពានវាតទីលេបទឹក

ដីកម្ពុជា ។ ភាគច្រើនដាច់ខាតនៃប្រទេសនិងប្រជាជនដែលស្នេហាឯករាជ្យ យុត្តិធម៌ក្នុងសកលលោកគេឃើញច្បាស់យ៉ាងនេះ ។ មុខមាត់និងនយោបាយ ៖ លទ្ធិប្រទេសធំសហព័ន្ធឥណ្ឌូចិនរបស់យួនឈ្លានពាន វាតទី លេបទឹកដី អ្នកតូចតាចជិតខាងយួនបានបើកអាក្រាតយ៉ាងច្បាស់ក្រឡែតដូចថ្ងៃហើយ ។ តាមរយៈនេះយួនត្រូវឯកកោខ្លាំង ត្រូវគេថ្កោលទោសខ្លាំង (ជាចំហឬមិនចំហ) និងត្រូវទាល់ច្រកខ្លាំង ។

បរាជ័យរបស់យួនខាងនយោបាយម្យ៉ាងទៀតគឺប្រជាជនវៀតណាមឃើញច្បាស់ថានយោបាយឈ្លានពានគេនាំឲ្យប្រទេសនិងប្រជាជនយួនហិនហោចខ្លោចផ្សា ។ ឯគោលបំណងនយោបាយរបស់យួនមួយទៀតដែលត្រៀមអង្គការមួយឬបក្សមួយឬចលនាមួយរបស់យួនយកមកពីស្រុកយួនមកតាំងឬប្រកាសនៅពេលដែលវាដណ្តើមកម្ពុជាយើងបានកន្លែងខ្លះនោះក៏ត្រូវបរាជ័យទាំងស្រុង ។

ទី៣) បរាជ័យរបស់យួនខាងសេដ្ឋកិច្ច-ហិរញ្ញវត្ថុ ៖

ក្នុងការឈ្លានពានរបស់វាដែលជាទំហំធំនិងជាខ្សែសង្វាក់មកលើកម្ពុជាយើងប្រជាធិបតេយ្យ យួនត្រូវចំណាយកម្លាំងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុច្រើនណាស់ក្នុងពេលដែលប្រទេសវានិងប្រជាជនវាកំពុងខ្វះស្បៀង (ខ្វះអង្ករច្រើនលានតោន) ហើយនិងខ្វះលុយកាក់សម្រាប់ដោះស្រាយបញ្ហាក្រោយសង្គ្រាម ។

ចំណាយច្រើនមកឈ្លានពានគេស្មានថាឈ្នះទៅវាចំណេញវិញ តែដល់វាត្រូវចាញ់វាទៅជាខាតទាំងដើមទាំងចុងវាទៅជាហិនហោចដល់សេដ្ឋកិច្ច-ហិរញ្ញវត្ថុរបស់ជាតិ និងប្រជាជនយួនថែមទៀត ដល់អឺចឹងហាមាត់ទៅសុំគេទៀត ដោយយកលេសថា «លំបាកក្រោយសង្គ្រាម» «លំបាកដោយរាំងស្ងួត» បែបពិបាករកអ្នកណាដាក់ទានឲ្យទៀតហើយ ។ ពិសេស អ្នកត្រឹមត្រូវគេលែងឲ្យទៀតហើយ ។

យើងទាំងអស់ឃើញសភាពបរាជ័យរបស់យួនខាងយោធា នយោបាយ និងសេដ្ឋកិច្ចហិរញ្ញវត្ថុទើបវាយតម្លៃនៃមហាជ័យជម្នះរបស់កងទ័ពបដិវត្តន៍កម្ពុជាយើងក្នុងកិច្ចការពារកម្ពុជាប្រជាធិបតេយ្យយើង ។

មិត្តភក្តិជិតឆ្ងាយនៃយើង ហើយប្រទេសនិងប្រជាជនស្នេហាឯករាជ្យនិងយុត្តិធម៌ក្នុងលោកអបអរសាទរយ៉ាងខ្លាំងចំពោះជ័យជម្នះរបស់យើង ។

យើងរក្សាការពារបានយ៉ាងរឹងមាំហើយជ្រៅយ៉ាងខ្ពស់ត្រដែតត្រដឹមនូវទង់ «ឯករាជ្យម្ចាស់ការ ខ្លួនទីពឹងខ្លួន ខ្លួនកាន់កាប់វាសនាខ្លួន ហើយខ្លួនឯង» នូវទង់ «ឯករាជ្យ អធិបតេយ្យភាពបូរណភាពដែនដី» នូវទង់ «កិត្តិយសជាតិ និងប្រជាជនកម្ពុជាយើង» ហើយវាយបំបាក់យ៉ាងខ្លាំង ទង់ឈ្លានពាន វាតទី លេបទឹកដី» វាយបំបាក់យ៉ាងខ្លាំងទង់ «ខ្លបខ្លាចប្រទេសធំតាមសារភាពនិយម» វាយបំបាក់យ៉ាងខ្លាំង ទង់ «លទ្ធិប្រទេសធំ» របស់យួន ។ ទង់ «បក្សតែមួយ ប្រទេសតែមួយ ប្រជាជនតែមួយ» របស់យួនក៏ត្រូវវាយបំបាក់យ៉ាងអាម៉ាស់បំផុត ។

សមមិត្តទាំងឡាយជាទីស្នេហា យើងឃើញមហាជ័យជម្នះរបស់យើងលើយួនឈ្លានពានហើយ ដោយបក្សយើងទាំងមូលឯកភាពជាធ្លុងមួយដឹកនាំវាយកម្ចាត់ខ្មាំង ដោយប្រជាជនយើងទាំងមូលឯកភាពគ្នាជាធ្លុងមួយមានជំហរនយោបាយសតិអារម្មណ៍បដិវត្តន៍ខ្ពស់មានជំហរចាត់តាំងសមូហភាពរឹងប៉ឹងរួមកម្លាំងវាយខ្មាំងក្លាតាមសមរភូមិរៀងៗខ្លួនទាំងមុខទាំងក្រោយ ។

ដោយកងទ័ពបដិវត្តន៍កម្ពុជាដ៏អង់អាចនៃយើងអនុវត្តមាគ៌ាយោធា មាគ៌ាសង្គ្រាមប្រជាជននិងមាគ៌ាប្រយុទ្ធរបស់បក្សបានត្រឹមត្រូវនិងស័ក្តិសិទ្ធិជាអតិបរមា ។

ដោយក្រសួង-មន្ទីរបដិវត្តន៍យើងទាំងអស់គ្នាបំពេញភារកិច្ចរបស់ខ្លួនបានល្អ និងសកម្មប្រយុទ្ធ ។

ដោយមិត្តភិក្កុជិតឆ្ងាយក្នុងសកលលោកយើងនិងប្រទេសប្រជាជនស្នេហាឯករាជ្យនិងយុត្តិធម៌ក្នុងលោកឧបត្ថម្ភ និងមានសមានចិត្តចំពោះបុព្វហេតុការពារប្រទេសរបស់យើងប្រឆាំងយួនឈ្លានពាន ។

យើងឃើញច្បាស់ថា ឈ្លានពាន គឺបរាជ័យ ឯករាជ្យពិតជាឈ្នះ ។

យើងឃើញមហាជ័យជម្នះច្បាស់លាស់ហើយតែមហាជ័យជម្នះនេះគ្រាន់តែជំហានដំបូងទេ ។ យើងត្រូវឃើញថែមទៀតថាខ្មាំងសត្រូវគ្រប់ប្រភេទនៅបន្តធ្វើសកម្មភាពចង់យាយីយើងដើម្បីយកប្រទេសយើងធ្វើជារណបវាទៀតតាមរូបភាព

ផ្សេងៗ ៖ ជាឈ្លានពាន ចារកម្ម សង្កត់គំរាមកំហែង វិទ្ធង្សនា ខែសុីរូងផ្ទៃក្នុងប៉ងប្រាថ្នារំលំរដ្ឋអំណាចបដិវត្តន៍យើងតាមរដ្ឋប្រហារ វិច្ឆេទកម្ម បាញ់រះ បាញ់ផ្លោងតាមព្រំដែន ។ ល ។

ដូច្នេះយើងទាំងអស់គ្នាត្រូវក្តាប់ភារកិច្ចធំរបស់បក្សយើងឲ្យជាប់និងឲ្យណែនក្នុងដៃគឺ ៖

- ◆ ការពារកម្ពុជាប្រជាធិបតេយ្យ
- ◆ បន្តបដិវត្តន៍សង្គមនិយម
- ◆ កសាងសង្គមនិយមឲ្យបានល្អ ។

ជាក់ស្តែងយើងត្រូវ៖

១) លើកកម្ពស់ស្មារតីប្រុងប្រយ័ត្នបដិវត្តន៍ខ្ពស់ទៅឡើងថែមទៀត បំពាក់បំប៉នឲ្យល្អជាប់ជានិច្ចនូវនយោបាយសតិអារម្មណ៍ និងចាត់តាំងរបស់បក្សរក្សាការសម្ងាត់ការពារបក្សបដិវត្តន៍ ប្រជាជនសមូហភាព រដ្ឋអំណាចបដិវត្តន៍និងកងទ័ពបដិវត្តន៍យើង បង្កើនគុណភាពនិងពង្រឹងពង្រីកកម្លាំងការពារប្រទេសយើងឲ្យណែនគ្រប់ពេលវេលាទាំងកងស្រួច តំបន់និងឈ្លបទប់ទល់និងកម្ចាត់ខ្សែនិងសកម្មភាពសន្តិសម្ព័ន្ធចារកម្មរបស់ខ្មាំង ។

២) លើកកម្ពស់ស្មារតីប្រយុទ្ធនិងសកម្មភាពវាយសម្រុកបំពេញភារកិច្ចបញ្ចប់ផែនការបីគោលនិងប្រាំមួយគោលមួយហិកតាឆ្នាំ១៩៧៧ ហើយបីគោលកន្លះ និងប្រាំពីរគោលហិកតាឆ្នាំ១៩៧៨នេះ ឲ្យសម្រេចទាំងស្រុង ។ ហើយគ្រប់រោងចក្រការដ្ឋាន អង្គភាព ក្រសួងមន្ទីរទាំងអស់អនុវត្តឲ្យស័ក្តិសិទ្ធិនូវការងាររបស់អង្គភាពខ្លួនទីមួយៗឲ្យសម្រេចតាមផែនការកំណត់និងឲ្យលើសផែនការថែមទៀត ។

យើងទាំងអស់គ្នា ខិតខំទៅឡើងកុំឲ្យកម្លាំងណាមួយ ឬកម្លាំងណាម្នាក់កប់ឲ្យសោះដើម្បីរួមចំណែកការពារប្រទេសក៏ឲ្យបានល្អកសាងប្រទេសក៏ឲ្យបានល្អ ហើយនិងលើកស្ទួយជីវភាពប្រជាជនយើងឲ្យបានឆាប់រហ័ស ។ កម្លាំងទាំងអស់ត្រូវកម្រើករំពុកឡើងស្ទុះស្ទាញទៅមុខវាយសម្រុកយកមហាជ័យជម្នះថ្មីៗទៀតក្នុងភារកិច្ចរបស់ខ្លួន ។

៣) យើងក៏ត្រូវសាមគ្គីឲ្យអស់លទ្ធភាពនិងសមត្ថភាពរបស់យើងតាមមាគ៌ានយោបាយបរទេសយើងដែលបានចែងច្បាស់ក្នុងរដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យយើងស្ថិតនៅជាប់ខាងក្នុងមហាគ្រួសារប្រទេសមិនចូលបក្សសម្ព័ន្ធ ។

ក្នុងប្រទេសតតិយលោក ហើយពិសេសមហាគ្រួសារប្រទេសមិនចូលបក្សសម្ព័ន្ធមានសភាពស្មុគស្មាញខ្លះដែរនៅផ្ទៃក្នុងខ្លួនក៏ពិតមែនតែប្រទេសនេះ ពិសេសប្រទេសមិនចូលបក្សសម្ព័ន្ធមានលក្ខណៈសម្បត្តិល្អជាច្រើនគឺ៖មានចំនួនច្រើននៅសកលលោកគិតជាប្រទេស និងគិតជាប្រជាជន មានទំនាស់ខ្លាំងច្រើនមុខ និងជ្រាលជ្រៅជាមួយចក្រពត្តិនិយមអាណានិគមនិយមចាស់ថ្មី ពូជសាសន៍និយម ត្រួតត្រានិយម វាតទីនិយម ហើយមានការតស៊ូប្រឆាំងយ៉ាងខ្លាំង ច្រើនមុខជាមួយចក្រពត្តិនិយមអាណានិគមចាស់-ថ្មី ពូជសាសន៍ ត្រួតត្រានិយម វាតទីនិយម ។ល ។ ប្រឆាំងអំពើឈ្លានពានវាតទីលេបទឹកដីវិទ្ធង្សនាអំពើហួងហែងគ្រប់បែបយ៉ាង ។ តស៊ូយ៉ាងស្វិតស្វាញនិងខ្ជាប់ខ្ជួនដើម្បីឯករាជ្យភាព អធិបតេយ្យភាព បូរណភាពដែនដី សមភាពយុត្តិធម៌ ឯករាជ្យម្ចាស់ការខ្លួន កាន់កាប់វាសនាដោយឯងរបស់ប្រទេសនីមួយៗ ហើយជាពិសេស ចំពោះប្រទេសកម្ពុជាយើងប្រទេសមិនចូលបក្សសម្ព័ន្ធជាច្រើនជាប់ខាតបានជួយឧបត្ថម្ភគាំទ្រនិងមានសមានចិត្តជាបន្តបន្ទាប់ទាំងក្នុងសង្គ្រាមប្រាំឆ្នាំប្រឆាំងចក្រពត្តិអាមេរិករំដោះជាតិទាំងចាប់ពីក្រោយរំដោះប្រទេសថ្ងៃទី១៧ មេសា ១៩៧៥មក ។ ប្រទេសមិនចូលបក្សសម្ព័ន្ធជាច្រើនជាប់ខាតគោរពឯករាជ្យអធិបតេយ្យភាព បូរណភាពដែនដីកម្ពុជា ហើយទាក់ទងជាមួយយើងដោយស្មើភាពត្រឹមត្រូវល្អណាស់ ។ កម្ពុជាប្រជាធិបតេយ្យយើងត្រូវការប្រទេសជាមិត្តយ៉ាងនេះណាស់ ។

៤) ឯការដោះស្រាយជម្លោះជាមួយវៀតណាម តើកម្ពុជាប្រជាធិបតេយ្យត្រូវដោះស្រាយយ៉ាងណា?

ចំពោះបញ្ហានេះ រដ្ឋាភិបាលយើងបានប្រកាសជាក់លាក់ច្រើនលើកគ្រាហើយ ។ នៅក្នុងឱកាសនេះ ខ្ញុំសុំប្រកាសជាថ្មីម្តងទៀតក្នុងនាមនៃរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យយើងតាមមាត្រា ២១នៃរដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ ។ មាត្រា២១ចែងថា ៖

◆ កម្ពុជាប្រជាធិបតេយ្យមានសុឆន្ទៈដ៏មោះមុតចង់មានបំណងមិត្តភាពយ៉ាងជិតស្និទ្ធជាមួយប្រទេសទាំងអស់ដែលមានព្រំដែនជាប់ជាមួយខ្លួនហើយនិងជាមួយប្រទេសជិតខាងឆ្ងាយទាំងអស់លើសកលលោកតាមគោលការណ៍គោរពអធិបតេយ្យភាព

និងបូរណភាពដែនដីគ្នាទៅវិញទៅមកដាច់ខាត ។

◆ កម្ពុជាប្រជាធិបតេយ្យប្រកាន់ខ្ជាប់នូវនយោបាយឯករាជ្យ សន្តិភាព អព្យាក្រឹត មិនចូលបក្សសម្ព័ន្ធណាមិនអនុញ្ញាតឲ្យបរទេសណាតាំងមូលដ្ឋានសឹកនៅក្នុងប្រទេសកម្ពុជាដាច់ខាត តស៊ូដាច់ខាតនឹងការជ្រៀតជ្រែកគ្រប់បែបយ៉ាងពីខាងក្រៅមកកិច្ចការផ្ទៃក្នុងប្រទេសកម្ពុជាតស៊ូដាច់ខាតនឹងអំពើវិទ្ធង្សនាឈ្លានពានខាងយោធាក្ដី ខាងនយោបាយក្ដី ខាងវប្បធម៌ ខាងសេដ្ឋកិច្ចក្ដី ខាងសង្គមកិច្ចក្ដី ខាងទូត ឬតាមរូបភាពយកនាមថាមនុស្សធម៌ក្ដី ។

◆កម្ពុជាប្រជាធិបតេយ្យមិនជ្រៀតជ្រែកដាច់ខាតកិច្ចការផ្ទៃក្នុងប្រទេសណាទាំងអស់ ។ កម្ពុជាប្រជាធិបតេយ្យគោរពដាច់ខាតលក្ខខណ្ឌដែលប្រទេសនីមួយៗមានអធិបតេយ្យភាពនិងមានសិទ្ធិអំណាចចាត់ចែងនិងសម្រេចកិច្ចការប្រទេសខ្លួនដោយខ្លួនឯងពេញទីគ្មានការជ្រៀតជ្រែកក្នុងរដ្ឋធម្មនុញ្ញយើងនេះម្ដង ។ បើភាគីវៀតណាមឈប់ជ្រៀតជ្រែក ឈប់ធ្វើវិទ្ធង្សនា ឈប់បាញ់រះបាញ់ផ្លោង ឈប់ឈ្លានពានវាតទីមកលើកម្ពុជាប្រជាធិបតេយ្យដោយកម្ចាត់អស់នូវលទ្ធិប្រទេសធំមកលើកម្ពុជានូវគោលការណ៍សហព័ន្ធឥណ្ឌូចិនរបស់វៀតណាមនូវគោលការណ៍បក្សតែមួយប្រទេសតែមួយ ប្រជាជនតែមួយនៅក្នុង “ឥណ្ឌូចិន” នេះជាឫសគល់នៃនយោបាយសង្កត់សំឡុត-គំរាម វិទ្ធង្សនា ឈ្លានពានវាតទីលេបទឹកដីរបស់វៀតណាមមកលើកម្ពុជានោះគ្មានអីយើងទំនាស់គ្នាទេ មិត្តភាពពិតប្រាកដនឹងកើតឡើង ហើយចេះពង្រឹងពង្រីកជាលំដាប់ទៅជាដាច់ខាត ។

នេះជាគោលបំណងនៃរដ្ឋាភិបាលនិងប្រជាជនកម្ពុជាយើងដែលតូចយ៉ាងនេះគ្មានត្រូវការរឿងទៅបង្ករឿងនិងនរណាទេ ចង់បានតែសុខក្នុងឯករាជ្យភាពនិងបូរណភាពដែនដីខ្លួនតែប៉ុណ្ណោះ ។

សមមិត្តទាំងឡាយជាទីស្នេហា

កងទ័ពបដិវត្តន៍កម្ពុជាដ៏ឧត្ដមនៃយើងបានរីកធំធាត់ឡើង ១០ឆ្នាំហើយ ។ កងទ័ពបដិវត្តន៍នេះបានធ្វើដំណើរផ្លូវឆ្ងាយហើយដោយប្រយុទ្ធឆ្លងកាត់ឧបសគ្គគ្រប់បែបយ៉ាងនិងហ៊ានធ្វើពលិកម្មគ្រប់បែបយ៉ាងដើម្បីបក្សវណ្ណៈបដិវត្តន៍ប្រជាជន និងប្រទេសកម្ពុជាយើង ។ ផ្លូវដែលសមមិត្តទាំងឡាយនៃកងទ័ពបដិវត្តន៍យើងបានឆ្លងកាត់កន្លងផុតមកគឺឧត្តុង្គឧត្ដមណាស់ ត្រចេះត្រចង់ណាស់មហាអស្ចារ្យណាស់ក្នុងប្រវត្តិសាស្ត្រកម្ពុជាយើង ។ វីរភាពបដិវត្តន៍របស់បណ្ដាមិត្តនៃកងទ័ពបដិវត្តន៍យើងខ្ពង់ខ្ពស់ណាស់ដែលជាទីគោរពកោតសរសើរ និងស្ញប់ស្ញែង ។ យើងទាំងអស់គ្នាមានមោទកភាពណាស់ដោយមានកងទ័ពបដិវត្តន៍កម្ពុជាមួយយ៉ាងនេះ ។

ក៏ប៉ុន្តែ យើងទាំងអស់គ្នា ក៏ឃើញច្បាស់ថា ភារកិច្ចបដិវត្តន៍របស់កងទ័ពកម្ពុជាយើងនៅធ្ងន់ទៀតក្នុងកិច្ចការពារកម្ពុជាប្រជាធិបតេយ្យ ការពាររដ្ឋអំណាចកម្មករ-កសិកររបស់បក្ស ការពារបក្ស បដិវត្តន៍វណ្ណៈ និងប្រជាជនយើង ហើយនិងកិច្ចការរួមចំណែកកសាងប្រទេសនិងលើកស្ទួយជីវភាពប្រជាជនយើងឲ្យបានធូរធារនិងសម្បូរសប្បាយឆាប់រហ័ស ។

ភារកិច្ចរបស់បណ្ដាលសមមិត្តកងទ័ពបដិវត្តន៍យើងធ្ងន់ធ្ងរមែនតែឧត្តុង្គឧត្ដមណាស់ ។

សូមសមមិត្តទាំងឡាយជ្រោងទង់ជ័យជម្នះនៃកងទ័ពជ្រោងទង់ជ័យជម្នះនៃកងទ័ពបដិវត្តន៍កម្ពុជាយើងតទៅទៀតឲ្យខ្ពស់ត្រដែតត្រដឹមឡើងដោយ ៈ

១) ខិតខំកសាងខ្លួនសមមិត្តនិងអង្គភាពសមមិត្តឲ្យបានល្អស្អាតនឹងរឹងប៉ឹងជានិច្ចតាមជំហរនយោបាយ-សតិអារម្មណ៍និងចាត់តាំងរបស់បក្សព្រមទាំងតាមមាគ៌ាសង្គ្រាមប្រជាជននិងមាគ៌ាប្រយុទ្ធរបស់បក្ស ។

២) អង្គភាពនីមួយៗត្រូវវាយសម្រុកបំពេញភារកិច្ចបដិវត្តន៍ក្នុងឋានៈជាកងឈានមុខពុះពារឧបសគ្គជម្នះការលំបាកទាំងឡាយដើម្បីដណ្ដើមមហាជោគជ័យថ្មីៗថែមទៀត ។

ជយោ បក្សកុម្មុយនីស្តកម្ពុជា ដ៏ត្រឹមត្រូវនិងភ្លឺស្វាងមហាអស្ចារ្យ!

ជយោ បដិវត្តន៍ ដ៏ខ្លាំងក្លា មហាអស្ចារ្យ!

ជយោ ប្រជាជនកម្ពុជា ដ៏មហិមា មហាអស្ចារ្យ!

ជយោ កងទ័ពបដិវត្តន៍កម្ពុជា ដ៏អង់អាចក្លាហាននិងខ្លាំងពូកែមហាអស្ចារ្យ!

ជយោ កងទ័ពបដិវត្តន៍កម្ពុជា ដ៏អង់អាចក្លាហាននិងខ្លាំងពូកែមហាអស្ចារ្យ!

ជយោ កងទ័ពបដិវត្តន៍កម្ពុជា ដ៏អង់អាចក្លាហាននិងខ្លាំងពូកែមហាអស្ចារ្យ!

# សក្ខីកម្ម ឌុច ប្រឆាំងនឹងអតីតមេដឹកនាំខ្មែរក្រហម

ក្រោយពេលដែលអង្គជំនុំជម្រះតុលាការកំពូលសម្រេចផ្តន្ទាទោសឲ្យជាប់ពន្ធនាគារអស់មួយជីវិត សម្រាប់ឧក្រិដ្ឋកម្មនៅមន្ទីរស-២១ ក្នុងសំណុំរឿង០០១ កាំង ហ្កេកអ៊ាវ ហៅ ឌុច ត្រូវបានបង្គាប់ឲ្យធ្វើជាសាក្សីនៅក្នុងសំណុំរឿង០០២ ប្រឆាំងនឹងអតីតមេដឹកនាំខ្មែរក្រហមទាំងបីគឺ នួន ជា, ខៀវ សំផន និង អៀង សារី ។ ឌុច បានក្លាយទៅជាសាក្សីកម្រ និងសំខាន់ដែលអាចឆ្លើយបំភ្លឺ និងលាតត្រដាងនូវការពិតមួយផ្នែកធំពីគោលនយោបាយផ្តាច់ការរបស់ខ្មែរក្រហម ។ ការចូលរួមរបស់ ឌុច ក្នុងសំណុំរឿង ០០២ នេះ អាចចាត់ទុកជាចំណុចរបត់មួយទៀតនៅក្នុងដំណើរការអង្គជំនុំជម្រះក្តីរបស់មេដឹកនាំខ្មែរក្រហម ។ ដូច្នេះ តើយើងទាំងអស់គ្នានឹងស្តាប់ឮការពិតអ្វីខ្លះដែល ឌុច នឹងបកស្រាយនៅចំពោះមុខអង្គជំនុំជម្រះ និងមេដឹកនាំខ្មែរក្រហមទាំងបីរូបនេះ?

**សក្ខីកម្មថ្ងៃទីមួយ (ថ្ងៃ១៩ មីនា ឆ្នាំ២០១២)**

នៅរសៀលថ្ងៃច័ន្ទ ទី១៩ ខែមីនា ឆ្នាំ២០១២ ចៅក្រមអង្គជំនុំជម្រះសាលាដំបូងរបស់សាលាក្តីខ្មែរក្រហមបានបង្គាប់ឲ្យ កាំង ហ្កេកអ៊ាវ ហៅ ឌុច មកបង្ហាញខ្លួននៅក្នុងបន្ទប់សវនាការដើម្បីធ្វើសក្ខីកម្មទាក់ទងនឹងបញ្ហារដ្ឋបាល និងរចនាសម្ព័ន្ធគ្រប់គ្រង តួនាទី និងការទទួលខុសត្រូវរបស់ជនជាប់ចោទ នួន ជា, ខៀវ សំផន, និង អៀង សារី ក្នុងអំឡុងរបបគ្រប់គ្រងពីឆ្នាំ១៩៧៥ដល់ ១៩៧៩ ។ ទំនងជាមិនបានត្រៀមទុក ឌុច បានមកបង្ហាញខ្លួនក្នុងសម្លៀកបំពាក់ជាអ្នកទោស ។ តំណាងសហព្រះរាជអាជ្ញាជាតិ សេង ប៊ុនឃៀង បានចោទសួរសំណួរទៅកាន់ ឌុច ។ ដំបូង ឌុច បានរៀបរាប់ពីប្រវត្តិរូបផ្ទាល់ខ្លួននិងប្រវត្តិនៃការសិក្សា ។ ក្រោយពីបានក្លាយជាគ្រូបង្រៀនម្នាក់នៅក្នុងសាលារៀនមួយនៅទីក្រុងភ្នំពេញ ឌុច បានរៀនសូត្រពីមនោគមន៍វិជ្ជាកុម្មុយនីស្តតាមរយៈការផ្សព្វផ្សាយទ្រឹស្តីកុម្មុយនីស្តរបស់ ម៉ៅ សេទុង តាមវិទ្យុ ។ ឌុច បានក្លាយជាបេក្ខជនរបស់បក្សកុម្មុយនីស្តកម្ពុជាក្រោមការឧទ្ទេសនាមរបស់ សុន សេន ។ តួនាទីដំបូងរបស់ ឌុច គឺជាប្រធានមន្ទីរម-១៣នៅក្នុងតំបន់រំដោះពិសេសរបស់ខ្មែរក្រហម ស្ថិតនៅក្រោមបញ្ជារបស់ សុន សេន និង វន វេត ដែលជាសមាជិកគណៈមជ្ឈិមរបស់បក្ស ។ មន្ទីរនេះមានមុខងារសួរចម្លើយធ្វើទារុណកម្ម និងសម្លាប់អ្នកទោសដែលចាត់ទុកជាខ្មាំងរបស់បក្សកុម្មុយនីស្តកម្ពុជា ។ ឌុច បានរៀបរាប់ថា ជារៀងរាល់ឆ្នាំ សមាជិកគណៈមជ្ឈិមបក្សទាំងអស់ត្រូវចូលរួមអង្គមីទ្ទីងមួយដើម្បីទទួលបញ្ជានិងការអប់រំពីគោលការណ៍បក្សពី ប៉ុល ពត ។ បន្ទាប់មកសមាជិកទាំងនោះនឹងផ្តល់វគ្គបណ្តុះបណ្តាលរយៈពេលពីរសប្តាហ៍ទៅកាន់សមាជិកបក្សតាមតំបន់ពីគោលការណ៍បក្ស ស្ថានភាពខ្មាំង និងស្ថានការណ៍សមរភូមិ ។ ជាក់ស្តែង ឌុច ក៏បានបង្រៀនជនក្រោមបង្គាប់របស់ខ្លួនពីគោលការណ៍របស់បក្សដែរ ។ ឌុច បានបញ្ជាក់ថា គ្រប់សមាជិកបក្សកុម្មុយនីស្តកម្ពុជាទាំងអស់ទទួលបានទស្សនាវដ្តីទង់បដិវត្តដែលរៀបរៀងឡើងដោយ ប៉ុល ពត និង នួន ជា ម្នាក់



ឌុច នៅក្នុងសវនាការថ្ងៃទីមួយក្នុងឯកសណ្ឋានទណ្ឌិត

មួយក្បាលដើម្បីរៀនសូត្រពង្រឹងនិងកសាងខ្លួនតាមគោលការណ៍កំណត់របស់បក្សដែលមានចែងក្នុងទស្សនាវដ្ដីទង់បដិវត្តនេះ ។

## សក្ខីកម្មថ្ងៃទីពីរ (ថ្ងៃ២០ មីនា ឆ្នាំ២០១២)

### សវនាការពេលព្រឹក

នៅព្រឹកថ្ងៃអង្គារ៍ ទី២០ ខែមីនា ឆ្នាំ២០១២ អង្គជំនុំជម្រះសាលាដំបូងបានបន្តស្ដាប់សក្ខីកម្មរបស់ កាំង ហ្គេកអ៊ាវ ហៅ ឌុច តាមរយៈការចោទសួររបស់ព្រះរាជអាជ្ញា ។ តំណាងព្រះរាជអាជ្ញាជាតិ សេង ប៊ុនយៀង បានសួរទៅកាន់ ឌុច ពីសមាសភាពខ្មាំងរបស់បក្សកុម្មុយនីស្តកម្ពុជា ។ ឌុច បានឆ្លើយតបថា “ខ្មាំងរបស់អង្គការមានច្រើនដែលសរុបជារួមមុនឆ្នាំ១៩៧៥គឺ ប្រជាជនសាមញ្ញលួចចូលតំបន់រំដោះ ទាហាន លន់ នល់ ទាហានហាណូយ ពួកចក្រពត្តិអាមេរិក


ឌុច នៅក្នុងសវនាការថ្ងៃទីពីរ (រូបថត ៖ អ.វ.ត.ក)

ហើយក្រោយឆ្នាំ១៩៧៥គឺ រួមបញ្ចូលទាំងប្រជាជនមូលដ្ឋានរំដោះ និងកម្មាភិបាលបក្ស ។ បន្ទាប់មកទៀត ឌុច បានរៀបរាប់ថា ក្រោយថ្ងៃជ័យជម្នះរបស់ខ្មែរក្រហមលើទីក្រុងភ្នំពេញនៅថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៩ ឌុច បានចូលរួមអង្គប្រជុំមួយនៅទីក្រុងភ្នំពេញដឹកនាំដោយ សុន សេន ។ នាពេលនោះ ឌុច ត្រូវបានចាត់តាំងជាអនុប្រធានមន្ទីរស-២១ ។ ក្រោយពេលដែល ណាត ប្រធានមន្ទីរស-២១ ត្រូវបានបញ្ឈប់ពីតំណែងជាប្រធានមន្ទីរ ស-២១ ឌុច បានឡើងជំនួសវិញ ។ ក្នុងអំឡុងពេលនេះ ឌុច មានតួនាទីអាន និងសង្ខេបចម្លើយសារភាព ហើយរាយការណ៍ឲ្យ នួន ជា ដើម្បីចេញសេចក្ដីសម្រេច ។ អ្នកទោសរបស់មន្ទីរស-២១ មិនមែនមានត្រឹមតែទាហាន លន់ នល់ និងបញ្ញាជនប៉ុណ្ណោះទេគឺរួមបញ្ចូលទាំងកម្មាភិបាលខ្មែរក្រហមទៀតផង ។ ឌុច បានបញ្ជាក់នៅចំពោះមុខអង្គជំនុំជម្រះថា នៅចុងឆ្នាំ១៩៧៥ កម្មាភិបាលខ្មែរក្រហមជាន់ខ្ពស់ត្រូវបានចាប់ខ្លួន និងបញ្ជូនមកមន្ទីរស-២១ ។ ចាប់តាំងពីពេលនោះមក នៅចុង ១៩៧៦ កម្មាភិបាលខ្មែរក្រហមជាច្រើនត្រូវបានចាប់ខ្លួន និងបញ្ជូនមកមន្ទីរស-២១ដើម្បីសួរចម្លើយ ធ្វើទារុណកម្ម និងសម្លាប់ ។

ក្រោយពេលសម្រាកពេលព្រឹក តំណាងព្រះរាជអាជ្ញាជាតិ បានបន្តសួរសំណួរទៅកាន់ ឌុច ទាក់ទងនឹងមនោគមន៍វិជ្ជារបស់បក្សកុម្មុយនីស្តកម្ពុជា ។ ឌុច បានពន្យល់ថា មនោគមន៍វិជ្ជារបស់បក្សគឺផ្អែកសំខាន់លើគោលការណ៍ “បដិចក្រសមុបាត” ដែលបង្រៀនសមាជិកបក្សឲ្យផ្លាស់ប្ដូរផ្នត់គំនិតពីរបបមួយទៅរបបមួយទៀត ។ មនោគមន៍វិជ្ជារបស់បក្សគឺបញ្ចុះបញ្ចូលប្រជាជនឲ្យចូលបដិវត្តន៍កម្ចាត់ខ្មាំងបំផ្លាញ និងចងកំហឹងនឹងខ្មាំងក្បត់បក្ស ។ ទាក់ទងនឹងបញ្ហាជីវភាពរស់នៅ និងការរៀបអាពាហ៍ពិពាហ៍ ឌុច បានស្រាយបំភ្លឺថាអង្គការបានកំណត់របបអង្ករតែពីរកំប៉ុងប៉ុណ្ណោះ សម្រាប់ប្រជាជនដោយលើកហេតុផលថាស្រុកទេសនៅក្រ ។ ចំណែកឯការរៀបការ និងការបង្កើតប្រជាជនជំនាន់ក្រោយ ក៏ជាគោលការណ៍សំខាន់របស់អង្គការ ប៉ុន្តែរាល់កុមារទាំងអស់ត្រូវបានចាត់ទុកថាជាកម្មសិទ្ធិផ្ដាច់មុខរបស់អង្គការ ។ ឌុច បានបន្តទៀតថា នៅថ្ងៃទី២០ ខែឧសភា ឆ្នាំ ១៩៧៥ លេខាបក្សកុម្មុយនីស្តកម្ពុជា បានចេញឯកសារមួយបង្គាប់ឲ្យរៀបចំជាសហករណ៍តាមភូមិទូទាំងប្រទេសកម្ពុជា ។ ក្នុងអំឡុង ពេលនោះ វត្តអារាម និងអត្តសញ្ញាណសាសនាត្រូវបានបំផ្លិចបំផ្លាញ ព្រះសង្ឃត្រូវបានផ្សឹកហើយ ចំណែកប្រជាជនខ្មែរ-ឥស្លាមត្រូវបានពង្រាយតាមសហករណ៍នីមួយៗដោយរស់នៅជាមួយប្រជាជនមូលដ្ឋានខ្មែរក្នុងគោលបំណងបំបាត់អត្តសញ្ញាណរបស់ជនជាតិខ្មែរ-ឥស្លាម ។ លើសពីនេះទៀត រាល់ផលិតកម្មទាំងអស់រួមទាំងផលិតកម្មស្រូវគឺជាកម្មសិទ្ធិតែមួយគត់របស់បក្ស ។

### នួន ជា វាយប្រហារដោយពាក្យសម្ដីទៅលើ ឌុច

ខណៈពេលដែលលោក ម៉ៃឃើល ខណារ៉ាស់ មេធាវីការពារ

ក្តីរបស់ អៀង សារី កំពុងតែតទល់មតិជាមួយនឹងព្រះរាជអាជ្ញាពីបញ្ហាដាក់ឯកសារចំពោះមុខសាក្សីដើម្បីចោទសួរ ជនជាប់ចោទ នួន ជា បានលើកដៃ ហើយនិយាយតែមួយឃ្លាថា «គេមិនយកឈើពុករលួយ ស្អុយ មកឆ្លាក់ជាព្រះពុទ្ធរូបដើម្បីទេសនាឲ្យពុទ្ធបរិស័ទស្តាប់ទេ» ។ ឌុច នៅស្ងៀមមិនមានប្រតិកម្មអ្វីចំពោះការវាយប្រហាររបស់ នួន ជា នេះឡើយ ក្រៅពីអង្គុយញញឹមមួយកន្លែង ។ ប៉ុន្តែ មេធាវីដើមបណ្តឹងរដ្ឋប្បវេណីបានចាត់ទុកសេចក្តីថ្លែងរបស់ នួន ជា ថាជាការគម្រាមគំហែងមកលើ ឌុច ហើយសំណូមពរឲ្យចៅក្រមជួយអន្តរាគមន៍ដើម្បីចៀសវាងការវាយប្រហារបែបនេះកើតឡើងម្តងទៀតនាពេលអនាគត ។ ចៅក្រមអង្គជំនុំជម្រះសាលាដំបូងបាននិយាយយ៉ាងច្បាស់ទៅកាន់ នួន ជា និងមេធាវីការពារក្តី នួន ជា ថា ឌុច ដែលជាសាក្សីដ៏សំខាន់ក្នុងសំណុំរឿង០០២ មិនបានស្ម័គ្រចិត្តមកធ្វើសក្ខីកម្មចំពោះអង្គសវនាការនេះទេ ។ ប៉ុន្តែ ចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូងទៅវិញទេគឺជាអ្នកចេញសេចក្តីបង្គាប់ឲ្យ ឌុច មកធ្វើសក្ខីកម្ម ។ ចៅក្រមបានបន្តទៀតថា នួន ជា និងមេធាវីរបស់ខ្លួននឹងបានតទល់ជាមួយនឹង ឌុច នៅពេលមេធាវីការពារក្តី នួន ជា ទទួលបានវេនវេលាសម្រាប់ចោទសួរសាក្សី ។

ទាក់ទងនឹងបញ្ហាខាងលើ ប៊ូ ម៉េង ជាអតីតអ្នកទោសនៅមន្ទីរស-២១ និងជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមបានចាត់ទុកពាក្យសម្តីរបស់ នួន ជា ថាជា«ការគម្រាមកំហែង និងជាការបិទសិទ្ធិក្នុងការនិយាយស្តី» ដល់សាក្សី ហើយបានតិះទៀនថា «នួន ជា និយាយបែបនេះគឺជារឿងខុស» ពីព្រោះ តុលាការមានសិទ្ធិក្នុងការស្តាប់រឿងរ៉ាវទាំងឡាយណាដែលសាក្សីអាចស្រាយបំភ្លឺបាន មិនថារឿងរ៉ាវដាក់បន្ទុក ឬដោះបន្ទុកលើជនជាប់ចោទឡើយ ។

### សវនាការពេលរសៀល

ក្រោយពេលសម្រាកអាហារថ្ងៃត្រង់ ឌុច ត្រូវបានតំណាងសហព្រះរាជអាជ្ញាជាតិចោទសួរបន្តទៀត ។ ឌុច បានបញ្ជាក់ចំពោះមុខអង្គជំនុំជម្រះថា ឌុច បានធ្វើការងារពាក់ព័ន្ធនឹងគោលការណ៍របស់បក្សភាគច្រើន ។ មានឯកសារជាច្រើនដែលចាត់ទុកជាគោលការណ៍សម្ងាត់របស់បក្សរួមទាំង ទស្សនាវដ្តីទង់បដិវត្ត ពីព្រោះមានតែសមាជិកបក្សមួយចំនួនតែប៉ុណ្ណោះដែលទទួលបានទស្សនាវដ្តីនេះ ។ នៅពេលសួរថាតើគោលបំណងនៃមនោគមន៍វិជ្ជារបស់បក្សកុម្មុយនីស្តកម្ពុជាជាអ្វី? ឌុច បានឆ្លើយតបថា មុនឆ្នាំ១៩៧០ បក្សកុម្មុយនីស្តកម្ពុជាមានទស្សនវិស័យរំដោះប្រជាជនកម្ពុជាឲ្យរួចផុតពីការគាបសង្កត់ និងកេងប្រវ័ញ្ចរបស់ពួកប្រតិកិរិយា និងពួកមូលធននិយម ។ ឌុច បានបន្តបកស្រាយពីគោលការណ៍ជម្លៀសប្រជាជនពីទីក្រុងទៅជនបទថាជាគម្រោងមួយរបស់បក្សកុម្មុយនីស្តកម្ពុជាដើម្បីទទួលបានជ័យជម្នះ និងបំបាត់ពួកមូលធននិយម ។ ក្នុងអំឡុងពេលជម្លៀសជនដែលជាមុខសញ្ញានៃគោលការណ៍កម្ទេចរបស់បក្សត្រូវបានសម្លាប់ភ្លាមៗ ហើយចំណែកប្រជាជនសាមញ្ញត្រូវបានជម្លៀសឲ្យទៅរស់នៅជាមួយប្រជាជនមូលដ្ឋានតាមតំបន់ជនបទ ។ ទាក់ទងនឹងស្ថានភាពការងារតាមសហករណ៍ ឌុច បានអះអាងថា នៅតាមសហករណ៍នីមួយៗមាន «លេខាបក្ស» ម្នាក់ជាអ្នកគ្រប់គ្រងហើយលេខាបក្សនោះនឹងអនុវត្តគោលការណ៍របស់បក្សដោយឲ្យប្រជាជនក្នុងសហករណ៍ធ្វើស្រែចម្ការដោយទទួលបានរបបអង្ករពីរកំប៉ុងក្នុងរយៈពេលមួយថ្ងៃ ។ ជាពិសេសជាងនេះ គោលការណ៍របស់បក្សកុម្មុយនីស្តកម្ពុជាគឺថាប្រទេសជាតិត្រូវដឹកនាំ និងគ្រប់គ្រងដោយវណ្ណៈកសិករ និងកម្មករ អាស្រ័យហេតុនេះ ឌុច បាននិយាយថាមានតែកសិករ និងកម្មករតស៊ូរបស់ខ្មែរក្រហមប៉ុណ្ណោះដែលត្រូវបានចាត់តាំងជាលេខាបក្ស និងគណៈគ្រប់គ្រងតាមតំបន់ ។

## សក្ខីកម្មថ្ងៃទីបី (ថ្ងៃ២១ មីនា ឆ្នាំ ២០១២)

### សវនាការពេលព្រឹក

នៅព្រឹកថ្ងៃពុធ ទី២១ ខែមីនា ឆ្នាំ២០១២ អង្គជំនុំជម្រះសាលាដំបូងបានបន្តអង្គនីតិវិធី ដោយដោះស្រាយបញ្ហាមួយចំនួនកាលពីរសៀលម្សិលមិញនេះ រួចបន្តស្តាប់សក្ខីកម្មរបស់ ឌុច ។ ជាកិច្ចបន្ត តំណាងសហព្រះរាជអាជ្ញាជាតិបានសួរ ឌុច ពីគោលការណ៍បង្កើតសហករណ៍តាមតំបន់ ។ ឌុច បានបញ្ជាក់ថា សហករណ៍ត្រូវបានបង្កើតឡើងដើម្បីបម្រើដល់គោលការណ៍បង្កបង្កើនផលស្រូវ និងគ្រប់គ្រងទិន្នផលស្រូវសម្រាប់កងទ័ពផ្គត់ផ្គង់ដល់បក្ស និងប្រជាជនក្នុងតំបន់ ។ ឌុច បានអះអាងថា បក្សកុម្មុយនីស្តកម្ពុជាបានគ្រប់គ្រងគ្រប់វិស័យក្នុងស្រុកទាំងអស់ដូចជាមធ្យោបាយផលិតកម្ម ម៉ោងធ្វើការមធ្យោបាយដឹកជញ្ជូនទំនិញ ។ល។ ទាក់ទងនឹងបញ្ហាអនាម័យ និងសេវាកម្មសុខាភិបាល ឌុច បានអះអាងថា លេខាបក្ស

កុម្មុយនីស្តកម្ពុជាមិនបានដោះស្រាយបញ្ហាអនាម័យ និងបញ្ហាសុខាភិបាលនេះទេ ។ ប៉ុន្តែ ក្រោយមកមានបទបញ្ជាពីថ្នាក់លើថាឲ្យដាំទឹកពុះសម្រាប់បរិភោគ ។ យ៉ាងណាមិញ ក្នុងអំឡុងពេលនោះ ឌុច បាននិយាយថាមានការខ្វះខាតថ្នាំសង្កូវយ៉ាងច្រើនសន្ធឹកសន្ធាប់ ប៉ុន្តែលេខាបក្សនៅតែមិនអនុញ្ញាតឲ្យប្រើប្រាស់ថ្នាំបារាំង ហើយជំនួសមកវិញនូវថ្នាំបុរាណខ្មែរមានឈ្មោះថា“ថ្នាំអាចម៍ទន្សាយ” និងប្រើប្រាស់ទឹកដូងជំនួសឲ្យស៊ីរ៉ូម ។ សហព្រះរាជអាជ្ញាជាតិក៏បានចោទសួរម្តងទៀតទាក់ទងនឹងសមាសភាពខ្មាំងរបស់បក្សកុម្មុយនីស្តកម្ពុជា ហើយ ឌុច បានឆ្លើយថាលេខាបក្សកុម្មុយនីស្តកម្ពុជាបានបង្កើតមន្ទីរសន្តិសុខជាច្រើនទូទាំងប្រទេសគឺដើម្បីកម្ចាត់ខ្មាំងខាងក្រៅ និងខ្មាំងខាងក្នុងជួរបក្ស ។ ឌុច បាននិយាយថា “ប៉ុល ពត និង នួន ជា ជាអ្នកក្តាប់កិច្ចការក្នុងប្រទេសទាំងមូល” ។ ឌុច បានបន្ថែមទៀតថាខ្មាំងរបស់បក្សកុម្មុយនីស្តកម្ពុជាគឺជនដែលជាប់និន្នាការជាមួយនឹងសហរដ្ឋអាមេរិក ដូចជាពួកសេអ៊ីអា និងទាហានវៀតណាម ។

### សវនាការពេលរសៀល

តំណាងសហព្រះរាជអាជ្ញាជាតិបានចោទសួរ ឌុច បន្ថែមទាក់ទងនឹងគោលការណ៍បក្សកុម្មុយនីស្តកម្ពុជា ហើយ ឌុច បានបញ្ជាក់ថាគោលការណ៍របស់បក្សគឺបង្កើត “សង្គមនិយម” មួយ ហើយសមាជិកបក្សគ្រប់រូបមានកាតព្វកិច្ចចូលរួមកសាងសង្គមនិយមនេះ ។ ត្រង់ចំណុចនេះ តំណាងសហព្រះរាជអាជ្ញាជាតិបានផ្ទេរការកិច្ចចោទសួរសាក្សីទៅឲ្យតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ លោក វីលៀម ស្មីត ។ លោក វីលៀម ស្មីត បានប្តូរប្រធានបទមកសួរ ឌុច ពីរចនាសម្ព័ន្ធរបស់បក្សកុម្មុយនីស្តកម្ពុជាចាប់ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ។ ឌុច បានលើកឡើងពីលក្ខន្តិកៈនៃបក្សកុម្មុយនីស្តកម្ពុជាធ្វើឡើងនៅឆ្នាំ១៩៧១ និងឆ្នាំ១៩៧៦ ដោយអះអាងថាគោលដៅនៃលក្ខន្តិកៈនេះគឺដើម្បីបង្កើត “គោលការណ៍មូលដ្ឋានបក្ស” ។ លក្ខន្តិកៈទាំងនេះផ្តោតសំខាន់លើ “មាគ៌ាគ្រប់គ្រងរបស់បក្ស” និង“ការអប់រំផ្នែកសីលធម៌” ។ លក្ខន្តិកៈកាលពីឆ្នាំ១៩៦០ បានកំណត់ថាសមាជិកបក្សដែលបានបម្រើបក្ស១០ឆ្នាំ ទើបអាចទទួលតំណែងក្នុងជួរថ្នាក់ដឹកនាំបាន ។ ប៉ុន្តែ ក្រោយមក ប៉ុល ពត បានកែប្រែលក្ខន្តិកៈនេះ ហើយជំនួសមកវិញលក្ខន្តិកៈ១០ថ្មី ។ ឌុច បានបញ្ជាក់ថា ប៉ុល ពត និង នួន ជា គឺ ជាអ្នកចេញសេចក្តីសម្រេចក្នុងការជ្រើសរើសសមាជិកបក្សជាន់ខ្ពស់ ។ បន្ទាប់មកទៀត សហព្រះរាជអាជ្ញារងអន្តរជាតិបានចោទសួរសំណួរពីពាក្យមួយចំនួនរបស់ខ្មែរក្រហមទៅកាន់ ឌុច ។ ឌុច បានបកស្រាយថាពាក្យ “ការបង្កើតសង្គមនិយម” គឺសំដៅទៅលើការបង្កើតបក្សនយោបាយគ្រប់គ្រងតែមួយគត់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ទាក់ទងនឹងភាពខុសគ្នារវាង “បដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យ” និង “បដិវត្តន៍សង្គមនិយម” ឌុច បានពន្យល់ថា ផ្នែកមួយនៃការធ្វើបដិវត្តន៍ជាតិគឺសំដៅលើការបំបាត់ពួកចក្រពត្តិនិយមក្នុងប្រទេស ចំណែកឯទស្សនៈ “ប្រជាធិបតេយ្យ” គឺសំដៅលើការចែកចាយដីធ្លីទៅឲ្យប្រជាកសិករ ។ សម្រាប់ខ្មែរក្រហម ការធ្វើ “បដិវត្តន៍សង្គមនិយម” គឺផ្តោតសំខាន់ទៅលើដំណើរការផលិត និងការចែកចាយផលិតកម្មទាំងនោះ ។ ជាឧទាហរណ៍ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដីស្រែ និងចម្ការកៅស៊ូទាំងអស់គឺជា “កម្មសិទ្ធិរបស់បក្ស” ។ ខណៈដែលសហព្រះរាជអាជ្ញាបានចោទសួរ ឌុច ថាតើប្រជាជនមានជម្រើសក្នុងការចូលរួមដំណើរការផលិតកម្មរបស់បក្សដែរឬទេ ឌុច បានបញ្ជាក់ថាប្រជាជនគ្មានជម្រើសអ្វីឡើយក្រៅពីធ្វើការតាមបញ្ជារបស់អង្គការ ។ ឌុច បានបន្តថាចំនួនប្រជាជនដែលជាសមាជិកបក្សសរុបគឺប្រមាណប្រាំភាគរយនៃចំនួនប្រជាជនសរុបក្នុងអំឡុងពេលនោះ ។ ឌុច បានអះអាងថា ប៉ុល ពតគឺជាអ្នកដែលកែប្រែទ្រឹស្តីម៉ៅ ហើយយកមកអនុវត្តក្នុងបរិបទប្រទេសកម្ពុជាដើម្បីវាយប្រហារលើវណ្ណៈចំនួនប្រាំដែលមាននៅក្នុងប្រទេសកម្ពុជា ។



ភាគីព្រះរាជអាជ្ញាជាតិ និងអន្តរជាតិ (រូបថត ៖ អ.វ.ត.ក)

ក្រោយពេលឈប់សម្រាកពេលរសៀល សហព្រះរាជអាជ្ញារងអន្តរជាតិបានបន្តសួរសំណួរ ឌុច ពីពាក្យគន្លឹះមួយចំនួនដើម្បី

ស្វែងយល់ពីគោលនយោបាយ និងរចនាសម្ព័ន្ធរបស់បក្សកុម្មុយនីស្តកម្ពុជាបន្ថែមទៀត ។ ឌុច បានបកស្រាយថា "អនុធន" គឺសំដៅលើអ្នកដែលមានជីវភាពសមរម្យដូចជាគ្រូបង្រៀន និងគ្រូពេទ្យជាដើម ។ ចំណែកឯ "នាយទុន" គឺសំដៅលើអ្នកដែលសល់ប្រាក់ច្រើន ហើយប្រើប្រាស់ប្រាក់នោះដើម្បីទាញយកផលចំណេញបន្ថែមទៀត ។ ឌុច ពន្យល់ថា "សក្តិភូមិ" គឺសំដៅលើអ្នកដែលប្រើបុណ្យស័ក្តិទៅរកលុយដោយកេងប្រវ័ញ្ចលើអ្នកដទៃ ។ ខណៈពេលសហព្រះរាជអាជ្ញារងអន្តរជាតិបានចោទសួរ ឌុច ថាតើវណ្ណៈសក្តិភូមិនេះរាប់បញ្ចូលទាំងខ្សែរាជវង្សានុវង្សដែរឬទេ ឌុច បានបញ្ជាក់ថានៅក្នុងឯកសារវិភាគរបស់ ប៉ុល ពត មានការបកស្រាយវណ្ណៈសក្តិភូមិនេះថាជាប់ពាក់ព័ន្ធនឹងរាជវង្សានុវង្សដែរ ។ ដោយឡែកសម្រាប់ពាក្យ "បក្រពត្តិ" ឌុច បានបកស្រាយថាក្រុមនេះគឺសំដៅលើពួកអាមេរិកកាំងហើយ ចំណែកឯពាក្យ "ប្រតិកិរិយា" វិញគឺសំដៅលើជនទាំងឡាយណាដែលប្រឆាំងនឹងបដិវត្តន៍ខ្មែរក្រហម ។ "ចលនាមហាជន" គឺសំដៅលើ "គោលការណ៍មហាអស្ចារ្យ មហាលោតផ្លោះ" របស់បក្សកុម្មុយនីស្តកម្ពុជាឆ្ពោះទៅរកសង្គមនិយមមួយដែលប្រជាជនទាំងអស់ត្រូវតែធ្វើតាមអង្គការបដិវត្តន៍ ។ ទាក់ទងនឹងការចេញសេចក្តីសម្រេច ឌុច បានរៀបរាប់ថានៅក្នុងលក្ខន្តិកៈនៃគោលការណ៍បក្សកុម្មុយនីស្តកម្ពុជា "រាល់សេចក្តីសម្រេចទាំងអស់ត្រូវធ្វើឡើងជាសមូហភាព" ។ មានន័យថាសមាជិករបស់បក្សទាំងអស់ចូលរួមប្រជុំពិភាក្សា និងបញ្ចេញមតិយោបល់ក្នុងសេចក្តីសម្រេចនោះ ។ ប៉ុន្តែ ឌុច បានអះអាងថាជាក់ស្តែងមានតែសមាជិកលេខាបក្សមួយចំនួនតូចតែប៉ុណ្ណោះដែលបានក្តោបក្តាប់អំណាចក្នុងការចេញសេចក្តីសម្រេចចុងក្រោយបង្អស់ ។ បន្ថែមលើនេះ ឌុច បានបន្តបកស្រាយពី "ការប្រជុំជីវភាព" នៃរបបកម្ពុជាប្រជាធិបតេយ្យថាការប្រជុំនេះគឺជាការប្រជុំតិះទៀនគ្នាដែលសមាជិកបក្សធ្វើការតិះទៀនលើសកម្មភាពគ្នាទៅវិញទៅមក ។ ឌុច បានបញ្ជាក់ថា "ការប្រជុំតិះទៀន" នេះគឺជាគោលការណ៍តម្រូវរបស់បក្ស ហើយប្រសិនបើបេក្ខជនណាម្នាក់មិនបានចូលរួមប្រជុំនោះបេក្ខជននោះត្រូវបានដកហូតបេក្ខភាពជាសមាជិកបក្ស ។ បន្ថែមលើនេះ នៅតាមមូលដ្ឋានសមាជិកម្នាក់ៗ តែងតែតាមដានសកម្មភាពរបស់សមាជិកម្នាក់ទៀតដើម្បីតិះទៀនកំហុសគ្នាទៅវិញទៅមក ។ កំហុសធ្ងន់ធ្ងរត្រូវតែរាយការណ៍ជូនថ្នាក់លើដាច់ខាត ។

**សក្ខីកម្មថ្ងៃទីបួន (ថ្ងៃ២៦ មីនា ឆ្នាំ២០១២)**

**សវនាការពេលព្រឹក**

នៅព្រឹកថ្ងៃច័ន្ទ ទី២៦ ខែមីនា ឆ្នាំ២០១២ អង្គជំនុំជម្រះសាលាដំបូងបានបន្តស្តាប់សក្ខីកម្មរបស់ ឌុច ។ លោក វីលៀម ស្មីត បានជម្រាបជូនអង្គសវនាការពីប្រធានបទដែលត្រូវបានយកមកពិភាក្សាកាលពីសប្តាហ៍មុនដូចជាគោលការណ៍មូលដ្ឋានរបស់បក្សកុម្មុយនីស្តកម្ពុជា លក្ខន្តិកៈនៃការចូលជាសមាជិកបក្ស តួនាទីរបស់បក្សជន និងទំនាក់ទំនងរវាងអង្គការចាត់តាំងរបស់ បក្សកុម្មុយនីស្តកម្ពុជា ។ល ។ ឌុច បានបកស្រាយចំពោះមុខអង្គជំនុំជម្រះថា រាល់ការប្រជុំតិះទៀន និងស្វ័យតិទៀនរបស់បក្សតែងតែមានការកត់ត្រាជានិច្ច ។ កំណត់ត្រានេះត្រូវបានចាត់ទុកថាជារបាយការណ៍ដែលនឹងត្រូវយកទៅរាយការណ៍ជូនលេខាបក្ស ។ បន្ទាប់មកទៀត លោក វីលៀម ស្មីត បានចោទសួរពីខ្លឹមសារនៃគោលការណ៍បក្សមួយចំនួនដូចជា "គោលការណ៍ម្ចាស់ការឯករាជ្យ ខ្លួនទីពឹងខ្លួន" ។ ឌុច បានពន្យល់ថាគោលការណ៍នេះមានន័យថាបក្សកុម្មុយនីស្តកម្ពុជាត្រូវតែឯករាជ្យដោយមិនជាប់បក្សសម្ព័ន្ធជាមួយនឹងបក្សកុម្មុយនីស្តចិន វៀតណាម ហើយមនោគមន៍វិជ្ជារបស់បក្សកុម្មុយនីស្តកម្ពុជាមានលក្ខណៈខុសដោយឡែកពីលទ្ធិម៉ាក្ស–លេនីន ។ ចំណែកឯគោលការណ៍ដែលចែងថា "ត្រូវធ្វើបដិវត្តន៍កសាងខ្លួនឯងដាច់ខាតនិងកាន់កាប់វាសនាខ្លួនឯងគឺសំដៅលើការតស៊ូដើម្បីបដិវត្តន៍លុបបំបាត់ពួកវណ្ណៈអធនទាំងឡាយណាដែលទាញយកផលចំណេញពីប្រជាជនរបស់ខ្មែរក្រហម ។ ទាក់ទងនឹងគោលការណ៍ទី៩របស់បក្សកុម្មុយនីស្តកម្ពុជា វីលៀម ស្មីត បានសួរ ឌុច ថាតើគោលការណ៍មួយនេះបានដាក់ទម្ងន់ដ៏ធ្ងន់ធ្ងរដល់បក្សជនដើម្បីសម្រេចគោលដៅរបស់បក្សកុម្មុយនីស្តដែរឬទេ ។ ជាការឆ្លើយតប ឌុច បានអះអាងថាទាំងសមាជិកបក្ស និងប្រជាជនកម្ពុជាទូទៅគឺមានភារកិច្ច ហើយសំខាន់បំផុតគឺកាតព្វកិច្ចបម្រើបដិវត្តន៍ដាច់ខាត ។ បន្ថែមលើនេះ វីលៀម ស្មីត បានផ្តោតសួរទាក់ទងនឹងលក្ខណៈសម្បត្តិបេក្ខជនរបស់បក្សកុម្មុយនីស្តកម្ពុជាដោយបញ្ជាក់ថាមានតែសមាជិកស្នូលបម្រើបដិវត្តន៍តែប៉ុណ្ណោះដែលត្រូវបានចាត់ចូលជាសមាជិកបក្សពេញសិទ្ធិ ។ ឌុច បានគូសបញ្ជាក់ថាលេខា

បក្សសំខាន់ៗ បានបង្កើតគោលការណ៍ឲ្យមានជា "សម្ព័ន្ធយុវកក" ដើម្បីកត់ត្រាអត្តសញ្ញាណរបស់បក្សជនដែលនឹងត្រូវជ្រើសតាំងជាសមាជិកបក្សពេញសិទ្ធិ ។ ក្រោយពីទទួលវគ្គបណ្ដុះបណ្ដាលពីមនោគមន៍វិជ្ជា និងគោលការណ៍បក្សកុម្មុយនីស្តកម្ពុជា បក្សជនទាំងនេះត្រូវបានចាត់តាំងជាយុវជនបក្សដែលមានអាយុមិនលើសពី១៨ឆ្នាំ ។ សម្រាប់សមាជិកដែលមានអាយុលើសពី១៨ឆ្នាំ មានអាជីពនិងប្រាក់បៀវត្សរ៍ត្រូវបានចាត់តាំងជាសមាជិកអង្គការស្នូលរបស់បក្ស ។ "សម្ព័ន្ធយុវកក" និង "អង្គការស្នូល" គឺជាអង្គការដ៏សំខាន់ក្នុងការពង្រីកកម្លាំងនិងគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ។ លក្ខណៈសម្បត្តិនៃបេក្ខជនបក្សដ៏ "ស្អាតស្អំ" បំផុតគឺសំដៅលើបេក្ខជនដែលមានប្រវត្តិរូបបដិវត្តន៍ល្អ ជាកសិករ និងកម្មករ ។ ទាក់ទងនឹងការជ្រើសតាំងបេក្ខជនបក្សនេះ ឌុច បានអះអាងថាបក្សជនបក្សត្រូវមានលក្ខណៈសម្បត្តិសំខាន់ប្រាំយ៉ាងៈ ១) ប្រយុទ្ធល្អអាស្រ័យតាមបរិបទសង្គម ២) ពង្រីកជាប់នូវគោលការណ៍របស់បក្សជាមួយនឹងមហាជន ៣) មានជំហរជាវណ្ណៈកសិករ កម្មករ ៤) មានសីលធម៌ ស្អាតស្អំ មិនផឹកស្រា មិនមានស្រីមិនល្បែងពាលា ពួកមានមិត្តភក្តិខិលខូច ៥) ស្អាតស្អំខាងនយោបាយៈ មិនធ្វើសកម្មភាពក្បត់ជាមួយខ្មាំងមិនជាប់សមាសធាតុជាបងប្អូនខ្មាំង ។ វីលៀម ស្មិត ក៏បានលើកយា "ពិនិត្យសាកសួរស្ទង់មតិមហាជន" ដើម្បីឲ្យ ឌុច បកស្រាយ ។ ឌុច បានបញ្ជាក់ថាសមាជិកនៃអង្គការស្នូលរបស់បក្សត្រូវតាមដានប្រវត្តិរូបបេក្ខជនបក្សតាមភូមិភាគជាប្រចាំ ។ បន្ទាប់មកទៀត ឌុច បានពន្យល់ពី "ចលនាក្ដៅ និងចលនាមិនសូវក្ដៅ" ថាចលនាក្ដៅគឺជាចលនាខាងយោធាប្រយុទ្ធតាមសមរភូមិ ចំណែកឯចលនាមិនក្ដៅសំដៅលើសកម្មភាពបំពេញកិច្ចការតាមមន្ទីរ និងអង្គភាពទូទៅ ។ ចលនាវាយសម្រុកដកស្ទូង និងធ្វើចម្ការនៅតាមសហករណ៍តាមផែនការកំណត់ក៏ត្រូវបានចាត់ទុកថា ជាចលនាក្ដៅដែរ ។ ដើម្បីត្រូវបានចាត់តាំងជាសមាជិកក្នុងជួរដឹកនាំបក្ស បក្សជនត្រូវមានគោលជំហរ "មិនភ្លេងពេក និងមិនស្ដាំពេក" ។ ឌុច ពន្យល់ថា "មិនភ្លេង" គឺមិនមែនឃើញអ្វីក៏ថា ជាខ្មាំង ។ បេក្ខជនបក្សទាំងអស់ត្រូវតែមានគោលជំហរ "តស៊ូវណ្ណៈ និងអត់ធ្មត់" ក្នុងការសម្រេចផែនការរបស់បក្ស ។ បក្សកុម្មុយនីស្តមិនត្រូវការ "ជនអត្មានិយម និងសួនគ្នួ" ទេ ហើយក្រុមនេះគឺជាមុខសញ្ញាសម្រាប់ការកម្ទេច ។

ក្រោយពេលសម្រាកពេលព្រឹក សហព្រះរាជអាជ្ញារងអន្តរជាតិក៏បានបន្តចោទសួរ ឌុច បន្ថែមទៀតពាក់ព័ន្ធនឹងខ្លឹមសារមួយចំនួនដែលមានចែងនៅក្នុងគោលការណ៍បក្សកុម្មុយនីស្តកម្ពុជា ។ ឌុច បានបកស្រាយដោយសង្ខេបលើខ្លឹមសារមួយចំនួននៃគោលជំហរដែលបេក្ខជនបក្សត្រូវតែបំបាត់ចោលដូចតទៅ ៖ ការិយាល័យនិយម ៖ មិនមានមេ មិនមានកើយ ។ នាយម៉ឺននិយម ៖ មិនមានសេនាការពារឆ្វេងស្ដាំ ។ យោធានិយម ៖ មិនគិតតែពីកម្ទេចខ្មាំងដោយគ្មានមូលដ្ឋានច្បាស់លាស់ ។ សេរីនិយម និងអន្ដោម័ត ៖ មិនធ្វើអ្វីតាមតែចិត្តចង់ ។ ឌុច បាននិយាយបន្ថែមទៀតថា សម្រាប់ "គោលការណ៍វាយសម្រុកក្ដៅជាប់" នេះគឺមានន័យថា "ការងារត្រូវតែធ្វើទាំងយប់ទាំងថ្ងៃដើម្បីសម្រេចតាមផែនការរបស់ថ្នាក់លើ" ។ អ្វីដែលសំខាន់បំផុតនោះគឺថា បេក្ខជនបក្សត្រូវប្រកាន់ខ្ជាប់តាមគោលការណ៍ "រក្សាការសម្ងាត់" របស់បក្ស ។ គោលការណ៍រក្សាការសម្ងាត់នេះគឺជាមូលដ្ឋានគ្រឹះការងារដោយមិនត្រូវចង់ដឹង ចង់ឮការងាររបស់អ្នកដទៃ ។ ទាក់ទងទៅនឹងឯកសារសម្ងាត់ ឌុច បានបញ្ជាក់ថាក្នុងឯកសារនោះមានចារយ៉ាងច្បាស់នូវឈ្មោះអ្នកទទួល ។ ជាក់ស្ដែង ឯកសារសម្ងាត់មន្ទីរស-២១មានចារឈ្មោះអ្នកទទួលដូចជា នួន ជា ជាដើម ។ ខណៈដែលសហព្រះរាជអាជ្ញារងអន្តរជាតិបានចោទសួរពីខ្លឹមសារ "ចុះប្រឡូកជាមួយមហាជន" ឌុច បានពន្យល់ថា បេក្ខជន និងសមាជិករបស់បក្សកុម្មុយនីស្តកម្ពុជាត្រូវបញ្ជ្រាបមនោគមន៍វិជ្ជានិងមាគ៌ានយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាក្នុងចំណោមប្រជាជនតាមមូលដ្ឋាន ។ បើនិយាយពីវិន័យបក្សកុម្មុយនីស្តកម្ពុជាវិញ ឌុច បានអះអាងថា "វិន័យបក្សកុម្មុយនីស្តកម្ពុជា" គឺជា "កាតព្វកិច្ច" ដែលបេក្ខជន និងសមាជិកបក្សទាំងអស់ត្រូវតែអនុវត្ត ។ ប្រសិនបើសមាជិកបក្សណាមួយបានប្រព្រឹត្តកំហុសតូចតាច សមាជិកនោះត្រូវបានកោះហៅមកតិះទៀន និងធ្វើស្វ័យតិះទៀន ។ នៅពេលដែលមានការប្រព្រឹត្តកំហុសធ្ងន់ធ្ងរ នឹងមានការរាយការណ៍ទៅថ្នាក់លើដើម្បីសម្រេច ។ មុននឹងទទួលទណ្ឌកម្ម សមាជិកដែលប្រព្រឹត្តខុសនោះត្រូវបានដកហូតអភ័យឯកសិទ្ធិជាសមាជិកបក្ស បន្ទាប់មកត្រូវបានចាប់ខ្លួនសួរចម្លើយ និងកម្ទេច ។ ឌុច បានអះអាងបន្ថែមទៀតថា គ្មានប្រព្រឹត្តច្បាប់ដើម្បីធ្វើការកាត់សេចក្ដីចំពោះកំហុសដែល

ប្រព្រឹត្តឡើងក្នុងរបបខ្មែរក្រហមឡើយ ។ ដូច្នេះ មានតែការចាប់ខ្លួនសួរចម្លើយ និងកម្ទេចតែប៉ុណ្ណោះគឺជាគោលការណ៍កាត់សេចក្តីដ៏ចម្បងរបស់បក្សកុម្មុយនីស្តកម្ពុជា ។

### អង្គសវនាការពេលរសៀល

ក្រោយពេលសម្រាកអាហារថ្ងៃត្រង់មក អង្គជំនុំជម្រះសាលាដំបូងបានបន្តដំណើរការនីតិវិធីរបស់ខ្លួនស្តីពីសក្ខីកម្មរបស់ ឌុច ដោយផ្តើការឆ្លើយតបមួយចំនួនទាក់ទងនឹងការស្នើសុំផ្សេងៗរបស់ភាគីក្នុងដំណើរការនីតិវិធីនេះ ។ ជាកិច្ចបន្ត លោក វីលៀម ស្មីត បានដាក់ឯកសារប្រវត្តិរូបមួយដើម្បីចោទសួរសំណួរមួយចំនួនទៅកាន់ ឌុច ។ ឌុច បានបកស្រាយចំពោះមុខអង្គជំនុំជម្រះថា ក្នុងប្រវត្តិរូបរបស់សមាជិកបក្សទាំងអស់រួមទាំងបុគ្គលិកមន្ទីរស-២១ ជាជនទាំងឡាយដែលស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់ ឌុច តែទទួលបានឈ្មោះបដិវត្តន៍ ។ ឌុច បានអះអាងថាគម្រោងធ្វើប្រវត្តិរូបនេះត្រូវបានយកទៅអនុវត្តទូទាំងប្រទេសគ្រប់អង្គភាពទាំងអស់ ។ គម្រោងនេះត្រូវបានចាត់ទុកថាជាការរាយការណ៍ដ៏ស្មោះត្រង់បំផុតពីសមាសភាពបេក្ខជន និងសមាជិកបក្សកុម្មុយនីស្តកម្ពុជា ។ ក្រៅពីនេះសម្រាប់គោលការណ៍រាយការណ៍វិញថ្នាក់ក្រោមត្រូវតែរាយការណ៍ជូនថ្នាក់លើជាប្រចាំពីសភាពការណ៍តាមមូលដ្ឋាន ។ បន្ទាប់មកទៀត សហព្រះរាជអាជ្ញារងអន្តរជាតិបានចោទសួរ ឌុច ពីការរាយការណ៍ពី "សភាពការណ៍ និងលទ្ធផលសម្រេចបាន" ជូនថ្នាក់លើ ។ ឌុច បានគូសបញ្ជាក់ថា "សភាពការណ៍" នេះគឺសំដៅលើ "ស្ថានភាព" ការងារ ។ ឧទាហរណ៍ជាក់ស្តែងនៅមន្ទីរស-២១ ឌុច ត្រូវរាយការណ៍ជូនថាលើពីចំនួនអ្នកទោសជាដើម ។ ចំណែកឯ "លទ្ធផលសម្រេចបាន" វិញគឺសំដៅលើការបំពេញកិច្ចការចប់ជាស្ថាពរដូចជាចំនួនចម្លើយសារភាពដែលបានទាញយកពីអ្នកទោសមន្ទីរស-២១ ។ ឌុច បានអះអាងថា ឌុច តែងតែរាយការណ៍ជូន សុន សេន ក្នុងចន្លោះរវាងបីថ្ងៃនិងប្រាំថ្ងៃម្តងពីស្ថានភាពការងារ ។ ឌុច ក៏បានរាយការណ៍ពីការងារសំខាន់ដើម្បីឲ្យថ្នាក់លើសម្រេច ។ ខណៈពេលនោះ សហព្រះរាជអាជ្ញាអន្តរជាតិបានសួរថា តើនរណាជាថ្នាក់លើរបស់ ឌុច? ឌុច បានអះអាងដោយចង្អុលទៅខាងស្តាំដៃរបស់ខ្លួនថាថ្នាក់លើនោះគឺបងនួន ឬ នួន ជា តែម្តង ។ *(សក្ខីកម្មរបស់ ឌុច មានបន្តទៀតនៅថ្ងៃបន្ទាប់)* ។

**ផែន សុខស្រីនិត**


ឌុច នៅក្នុងសវនាការ (រូបថត : អ.វ.ត.ក)

# អតីតយោធាខ្មែរក្រហមរៀនពីប្រវត្តិអតីតកាល

ប្រាក់ ពៅ មានស្រុកកំណើតនៅស្រុកឈូក ខេត្តកំពត ។ សព្វថ្ងៃ ពៅ ស្នាក់នៅវិទ្យាស្ថានទ័ពជើងគោក ភូមិ៤ ឃុំត្រែងត្រយឹង ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ។

ស្ថិតក្នុងឯកសណ្ឋានទាហានដ៏ក្លាហានវ័យ៤៦ឆ្នាំ ពៅ បានរៀបរាប់ពីរឿងរ៉ាវខ្លះៗរបស់ខ្លួនដែលបានជួបប្រទះក្នុងរបបខ្មែរក្រហមថាគាត់បានចូលបដិវត្តន៍នៅឆ្នាំ១៩៧៤ នៅភូមិតាកែន ឃុំតាកែន ស្រុកឈូក ខេត្តកំពត ដែលស្ថិតក្នុងភូមិភាគនិរតីក្រោមការគ្រប់គ្រងរបស់ តាម៉ុក និង សំ ប៊ិត ។ ពេលចូលដំបូង ពៅ មាននាទីជាអ្នករត់សំបុត្រ ។ ពេលខ្លះ ពៅ ក៏ធ្លាប់បានរត់សំបុត្រពីខេត្តកំពតទៅខេត្តបាត់ដំបងដែរ ដោយចំណាយពេលទាំងទៅ និងត្រលប់មកវិញអស់មួយសប្តាហ៍ ។

ពៅ បានបន្តថា ពេលធ្វើការងារជាអ្នករត់សំបុត្រនេះ គាត់បានដឹងពីសភាពការណ៍ខ្លះដែរពីការរង្គោះរង្គើរនៅតាមតំបន់ដែលបានឆ្លងកាត់ដូចជាមានតំបន់ខ្លះប្រជាជនហូបបបរ តំបន់ខ្លះប្រជាជនហូបបាយនៅក្នុងឆ្នាំ១៩៧៥ ប៉ុន្តែវាអាស្រ័យទៅតាមតំបន់នោះៗ ជាក់ស្តែង ដូចជានៅខាងកំពង់ឆ្នាំង សាលាលេខប្រាំ អង្គការឲ្យហូបបាយ ហើយពេលដែលគាត់ទៅដល់បាត់ដំបង តំបន់ប្រឡាយនាងហត អង្គការឲ្យហូបបបរ ។ ពៅ បន្តទៀតថា នៅតំបន់ផ្សេង ការរស់នៅកាលចន្លោះឆ្នាំ១៩៧៥-១៩៧៦ គឺមានការលំបាកណាស់ ទាំងអ្នកឈឺ ទាំងអ្នកមិនឈឺ ត្រូវបានបង្ខំឲ្យធ្វើការពេញម៉ោងតែម្តង ។ ការងារទៀតសោធគឺធ្វើចាប់ពីម៉ោងប្រាំកន្លះទៀបភ្លឺរហូតដល់ម៉ោងដប់មួយកន្លះថ្ងៃហើយពេលរសៀលចាប់ពីម៉ោងមួយរហូតដល់ម៉ោងប្រាំល្ងាច ។ ចំពោះរបបអាហារដែលទទួលបានគឺបីពេលក្នុងមួយថ្ងៃដោយពេលព្រឹកអង្គការឲ្យបបរ ហើយពេលថ្ងៃអង្គការឲ្យបាយតែអង្គការវាល់ឲ្យមួយត្រឡោកដូងតូចៗ ។ តំបន់ដែល ពៅ រស់នៅខាងស្រុកឈូកនៅចន្លោះឆ្នាំ១៩៧៦-១៩៧៧ ការរស់នៅមិនលំបាកអីទេគឺមធ្យមទេ ។ អង្គការឲ្យហូបបបរ និងបាយក្នុងមួយអាទិត្យ ។ និយាយបណ្តើរញញឹមបណ្តើរ ពៅ ប្រាប់ថា អង្គការចែកបាយឲ្យហូបមួយឆ្អែតតែម្តងជាមួយនឹងម្ហូបអាហារដូចជា សាច់ជ្រូក មាន់ ត្រី ជាដើមសម្រាប់ប្រជាជនទូទាំងស្រុកឈូកនេះ ។ ប៉ុន្តែចំពោះការងារវិញមិនខុសពីតំបន់ដទៃនោះទេគឺធ្វើការធ្ងន់ដូចគ្នា ។ កាលនោះ អង្គការចាត់តាំងឲ្យលើកទំនប់ដែលគេហៅថា ទំនប់កោះស្លាមានប្រវែងប្រាំទៅប្រាំមួយគីឡូម៉ែត្រ ហើយខ្នងលើមានកម្ពស់ដល់ទៅសាមសិបម៉ែត្រ ។ ការជីក និងលើកទំនប់នេះមិនប្រើគ្រឿងយន្តទេ គឺប្រើកម្លាំងមនុស្សរាប់ពាន់នាក់សុទ្ធសាធ ។ ក្រោយពីធ្វើការងារជានិរសារអស់រយៈពេលជិតពីរឆ្នាំ នៅថ្ងៃ០៤ ខែមិថុនា ឆ្នាំ១៩៧៦ ពៅ ត្រូវបានអង្គការចាត់តាំងឲ្យទៅនៅក្នុងកងពល ៩០៣ ដែលមាន នួន ប៉ែត ជាប្រធាន ។ ទៅដល់ទីនោះ ពៅ ស្ថិតក្នុងកងអនុសេនាតូចលេខ៥៣ចំណុះកងពល៩០៣ ដោយមិនមានតួនាទីអ្វីឡើយ ។ ពៅ បញ្ជាក់ថា ក្រោយពេលដែលចេញពីការងារជានិរសារ ហើយចូលទៅជាកងទ័ពនោះ ខ្លួនមិនបានដឹងរឿងអ្វីផ្សេងទៀតទេ ហើយមួយថ្ងៃៗ ដឹងតែពីហ្វឹកហាត់រហូតដល់ម៉ោងឮស្នូរជួងទៅហូបបាយ ។ ចំពោះកងទ័ពនៅពេលនោះមិនការលំបាករឿងហូបចុក ឬធ្វើការងារធ្ងន់នោះទេ ។ បើនិយាយពីការសម្លាប់ប្រជាជន ពៅ នៅចាំបានថានៅអង្គភាពរបស់ខ្លួនមិនមានការយកមនុស្សទៅសម្លាប់នោះទេ គ្រាន់តែឮល្បីពីការកាប់សម្លាប់ ។ ពៅ មានអារម្មណ៍ភិតភ័យ ដូច្នេះរាល់ថ្ងៃ ពៅ ខិតខំកសាងខ្លួនឲ្យបានល្អ ជាពិសេសមិនដើរហើររហេតរហូត នៅពេលអង្គការដាក់ទិសឲ្យទៅណាគឺទៅហ្នឹង ។ ដោយសម្លឹងមើលមុកដែលទុកនៅពីមុខ ពៅ បានរៀបរាប់បន្តថា ទោះបីជាមិនមានការសម្លាប់មនុស្សនៅក្នុងអង្គភាពរបស់ខ្លួនមែន ប៉ុន្តែ ពៅ នៅតែមានការសង្ស័យពីបញ្ហានោះខ្លះដែរព្រោះពេលណាដែលកូនទាហានធ្វើខុសអង្គការតែងតែហៅទៅកសាង ។ ទន្ទឹមនឹងនោះ អ្នកដែលឲ្យអង្គការហៅយកទៅគឺមិនដែលបានឃើញត្រលប់មកវិញទេ ។ កងទ័ពវៀតណាមបានវាយចូលខេត្តកំពតក្នុងឆ្នាំ១៩៧៩ កង

ទ័ពក្នុងកងពលរបស់ ពៅ មួយចំនួនបាននាំគ្នាខ្លួនទៅតាមព្រំដែនថៃជាប់ខេត្តកោះកុង ។

នៅអំឡុងឆ្នាំ១៩៨៤-១៩៨៥ នៅកោះកុង ពៅ ធ្លាប់បានឃើញ ខៀវ សំផន ចុះទៅមើលតាមកងពលរបស់គាត់ ។ ពៅ នៅចាំបានថាមានពេលមួយនោះ ខៀវ សំផន បាននិយាយពីឯកសារខ្មែរក្រហមដែលទាក់ទងទៅនឹងការក្បត់របស់ តាម៉ុក ដោយ ខៀវ សំផន បាននិយាយថាកាលពីជំនាន់ស្តេចសោយរាជ្យ តាម៉ុក ក្បត់ស្តេចម្តងហើយដល់ជំនាន់ប៉ុល ពត នេះ តាម៉ុកក្បត់ប៉ុល ពត ទៀត ។ និយាយដោយអស់សំណើច ពៅ លើកឡើងថា «ខ្ញុំជឿផងមិនជឿផងដោយគិតក្នុងចិត្តថាបើនៅជាមួយគ្នាហេតុអ្វីបានជាគាត់បែកកេរ្តិ៍ពី តាម៉ុក ដូច្នេះ?» ពៅ បញ្ជាក់ថា ខៀវ សំផន ឧស្សាហ៍ចុះមកកងពលរបស់គាត់ណាស់រហូតដល់ឆ្នាំ១៩៩០-១៩៩១ ។ ក្រោយមកនៅឆ្នាំ១៩៩១ មេបញ្ជាការវរៈសេនាធំរបស់ ពៅ បាននាំទ័ពមកវាយនៅកំពង់ឆ្នាំង ហើយបន្តដំណើរឆ្ពោះទៅសំឡូតតែត្រូវកងទ័ពរដ្ឋាភិបាលវាយផ្តាច់ផ្លូវជាតិ៥៦ទៅកោះកុង និងថ្មស ។ មួយរយៈក្រោយមក មេបញ្ជាការនៅខាងសំឡូតបានបញ្ជូនព័ត៌មានឲ្យរកកន្លែងចូលសិន ព្រោះនៅតាមផ្លូវទៅសំឡូតនិងតំបន់មួយចំនួនត្រូវទ័ពរដ្ឋាភិបាលក្តាប់បានអស់ហើយ ។ ពេលនោះក្រុមរបស់ ពៅ ក៏សម្រេចចិត្តស្នាក់នៅស្រុកក្រវាញ ខេត្តពោធិ៍សាត់ជាបណ្តោះអាសន្ន ។ ក្រោយមកទៀតនៅខែកញ្ញា ឆ្នាំ១៩៩៦ កងពលរបស់ ពៅ បានចុះចូលជាមួយរដ្ឋាភិបាលនៅស្រុកក្រវាញ ខេត្តពោធិ៍សាត់តែម្តង ។

ទោះជាយ៉ាងណាក៏ដោយ ពៅ បានបញ្ជាក់ថាក្នុងរយៈកាល បីឆ្នាំ ប្រាំបីខែ ម្ភៃថ្ងៃ សមាជិកគ្រួសាររបស់គាត់ទាំងអស់មិនមាននរណាម្នាក់ស្លាប់ ឬបាត់ខ្លួនឡើយ ។ សព្វថ្ងៃ ប្រាក់ ពៅ មានប្រពន្ធ និងមានកូនប្រុសស្រីប្រាំមួយនាក់ ។ ក្រោយពីបានចុះចូលជាមួយរដ្ឋាភិបាលមក ពៅ នៅតែប្រកបការងារជាទាហានដដែលដោយធ្វើជាគ្រូបង្រៀននាយទាហានផ្នែកវិន័យសណ្តាប់ធ្នាប់នៃវិទ្យាស្ថានកងទ័ពជើងគោក ។

**ឆាយ សារៈមុនិន្ទ**



នាយទាហានចូលរួមវគ្គបណ្តុះបណ្តាលស្តីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យនៅវិទ្យាស្ថានទ័ពជើងគោក

# ឈើចាប់ពេលនឹកឃើញរឿងដើម

ទោះបីជាប្រទេសកម្ពុជាមានសន្តិភាពហើយក៏ដោយ ប្រជាជនកម្ពុជាមួយចំនួនធំនៅតែទទួលរងផលប៉ះពាល់ផ្លូវចិត្តពីរបបខ្មែរក្រហមនៅឡើយ ។ ជាក់ស្តែងនៅក្នុងវគ្គបណ្តុះបណ្តាលស្តីពី «ការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ពីឆ្នាំ ១៩៧៥-៧៩» ដែលរៀបចំដោយមជ្ឈមណ្ឌលឯកសារកម្ពុជា នៅខេត្តកំពង់ឆ្នាំង មានសិក្ខាកាមប្អូននាក់ក្នុងចំណោមប្រាំពីរនាក់នៃក្រុមពិភាក្សាបានបង្ហូរទឹកភ្នែកនៅពេលរៀបរាប់ពីប្រវត្តិអតីតកាលរបស់ខ្លួនឡើងវិញ ។

អែម ចំរើន ដែលបានចូលរួមវគ្គបណ្តុះបណ្តាលនោះបានមានប្រសាសន៍ថា គាត់ស្រក់ទឹកភ្នែក ព្រោះគាត់នឹកឃើញយប់មួយនៅពេលដែលគាត់កំពុងដេកជាមួយម្តាយនៅលើផ្ទះ ស្រាប់តែឈ្លបមកលបចាប់ម្តាយគាត់យកទៅបាត់ ។ ព្រឹកឡើង គាត់ភ្ញាក់ពីដំណេកមិនឃើញម្តាយ គាត់ក៏រត់ទៅសួរអ្នកភូមិ ។ ទើបដឹងថាម្តាយគាត់ត្រូវឈ្លបចាប់យកទៅបាត់ហើយ ។ គាត់ដើររកម្តាយតាមផ្ទះអ្នករស់នៅក្បែរខាងគ្នាទៀត ប៉ុន្តែរកមិនឃើញ ។ ចំរើនបានបន្តដើររកម្តាយរហូតឃើញម្តាយគាត់កំពុងជាប់ច្រវ៉ាក់នៅរោងមួយកន្លែង ។ ភ្លាមនោះ គាត់ក៏ស្ទុះទៅរកម្តាយ ប៉ុន្តែឈ្លបបានច្រានគាត់ចេញ ។ ចំរើន បន្តថា គាត់នៅតែរន្ធត់នៅពេលរៀបរាប់ពីរឿងរ៉ាវនេះ ។

ចំរើន មានអាយុ៤៤ឆ្នាំ កើតនៅខេត្តក្រចេះ ។ ចំរើន មានឪពុកជាទាហាន លន់ នល់ និងម្តាយជាមេផ្ទះ មានស្រុកកំណើតនៅឃុំពន្លៃ ស្រុកបរិបូណ៌ ខេត្តកំពង់ឆ្នាំង ។ ឪពុក ចំរើន មកធ្វើការងារនៅភ្នំពេញបានមួយរយៈ មេបញ្ជាការក៏បញ្ជូនគាត់ឲ្យទៅប្រចាំការនៅខេត្តក្រចេះ ដែលពេលនោះម្តាយគាត់ក៏ទៅជាមួយដែរ ។ នៅទីនោះ មានការវាយប្រយុទ្ធគ្នាយ៉ាងខ្លាំងក្លារវាងកងទ័ពរដ្ឋាភិបាល លន់ នល់ និងចលនាតស៊ូខ្មែរក្រហម ដែលក្រោយមកយោធាខ្មែរក្រហមវាយរំដោះបាន ។ ឪពុក ចំរើន បានបន្លំខ្លួនជាជនស៊ីវិលដើម្បីគេចខ្លួនដោយប្រើកង់ឌុប ចំរើន និងប្រពន្ធ ។ ឪពុក ចំរើន បានធាក់កង់ទាំងយប់ទាំងថ្ងៃដើម្បីឲ្យឆាប់ដល់ទីក្រុងភ្នំពេញ ប៉ុន្តែការធ្វើដំណើរនោះមិនបានលឿនទេ ព្រោះជារឿយៗមានយន្តហោះអាមេរិកទម្លាក់គ្រាប់បែក និងស្កាត់បាញ់ទៅលើអ្នកដំណើរ ។ ពេលមួយនោះ ឪពុក ចំរើន បានបោះកង់ចោលរួចនាំប្រពន្ធកូនទៅពួនក្រោមដើមឈើពេលឮសូរសំឡេងយន្តហោះមក ។

ឪពុក ចំរើន ជិះកង់រយៈពេលមួយអាទិត្យទើបមកដល់ជ្រោយចង្វារ ។ ជាអកុសល កងយោធាហាមឃាត់មិនឲ្យចូលក្រុងឡើយ ។ ឃើញសភាពការណ៍ដូច្នេះ ឪពុក ចំរើន ក៏ជិះកង់ត្រឡប់ទៅខេត្តកំពង់ធំ ដែលជាតំបន់គ្រប់គ្រងដោយលន់ នល់វិញ រួចសុំទូកអ្នកនេសាទត្រីជិះឆ្លងទន្លេពីផាត់សណ្តាយ (ខេត្តកំពង់ធំ) ត្រឡប់មកស្រុកកំណើត នៅស្រុកបរិបូណ៌ ខេត្តកំពង់ឆ្នាំង ។

មិនយូរប៉ុន្មាន មេបញ្ជាការបានកោះហៅឪពុក ចំរើន ឲ្យត្រឡប់មកភ្នំពេញវិញបន្ទាប់ពីដឹងថាគាត់រស់នៅស្រុកកំណើត ។ ប៉ុន្តែពេលនោះ ឪពុកគាត់មិនហ៊ានធ្វើដំណើរតាមកង់ ឬរថយន្តដូចពេលមុនទៀតទេ គឺគាត់ជិះយន្តហោះឈ្នួលវិញ ។ ឪពុក ចំរើន ស្នាក់នៅភ្នំពេញបានពីរថ្ងៃ មេបញ្ជាការក៏បញ្ជូនគាត់ឲ្យទៅឈរជើងនៅទីរួមខេត្តបាត់ដំបង ។ ក្រុមគ្រួសារ ចំរើន ក៏ប្តូរទៅរស់នៅជាមួយឪពុកទៀត ។ ក្រោយមក ម្តាយ ចំរើន ប្រសូត្របានកូនប្រុសមួយទៀត ។

ចំរើន រស់នៅបាត់ដំបងបានរយៈពេលបីឆ្នាំ យោធាខ្មែរក្រហមក៏វាយរំដោះបាន ។ ពេលនោះ កងទ័ព លន់ នល់ ជាច្រើនប្រចាំការនៅបន្ទាយ រួមទាំងឪពុក ចំរើន បានបាញ់អបអរ រួចហើយក៏បោះអាវុធចោល ព្រោះគាត់ដឹងថាខ្មែរក្រហមនឹងសួររកអ្នកធ្លាប់ធ្វើទាហានមិនខាន ។ ដូច្នេះ ឪពុករបស់ ចំរើន បានប្តូរសម្លៀកបំពាក់ទាហានមកជាស៊ីវិលវិញ ចំណែកម្តាយគាត់រៀបចំខោអាវ និងសម្ភារប្រើប្រាស់ដាក់លើកង់ដើម្បីចាកចេញ ។

ឪពុកម្តាយ ចំរើន បានធ្វើដំណើរសំដៅត្រឡប់មកខេត្តកំពង់ឆ្នាំងវិញ ប៉ុន្តែយោធាខ្មែរក្រហមដែលយាមនៅតាមផ្លូវបានស្ទាក់សួរគ្រួសារគាត់ ព្រោះខ្លាចគាត់វិលត្រឡប់ចូលទៅទីក្រុងភ្នំពេញវិញ ។ គ្រួសារណាដែលមិនស្តាប់ការហាមឃាត់នេះ ហើយនៅតែបន្តដំណើរទៅមុខទៀត យោធាបាញ់សម្លាប់ចោលតែម្តង ។ មកដល់ស្រុកមោងឫស្សី យោធាខ្មែរក្រហមបានបញ្ជាឲ្យអ្នកជម្លៀសធ្វើដំណើរចុះទៅតាមផ្លូវលំឆ្ពោះទៅទន្លេសាប ។ នៅពេលដែលគ្រួសារ ចំរើន បន្តដំណើរដល់ភូមិវត្តគ យោធាខ្មែរក្រហមមួយក្រុមស្នើយកកង់ពីឪពុករបស់គាត់ រួចបញ្ជាឲ្យគ្រួសារគាត់រស់នៅទីនោះមួយរយៈ ។

ចំរើន រស់នៅវត្តគរយៈពេលមួយសប្តាហ៍ ប្រធានភូមិក៏ផ្លាស់ក្រុមគ្រួសារគាត់ឲ្យទៅរស់នៅភូមិចក ។ ទៅដល់ដំបូងឪពុកម្តាយ ចំរើន ត្រូវដើររកឈើ និងស្លឹកត្នោតមកសង់រោងដើម្បីស្នាក់នៅ ។ បន្ទាប់មកប្រធានភូមិបានបែងចែកឪពុកគាត់ឲ្យនៅកងភ្ជួរ ម្តាយនៅកងដកស្ទូង ចំណែកគាត់នៅកងកុមារ ។ រាល់ថ្ងៃចំរើនមិនសូវបានជួបមុខឪពុកទេ ព្រោះគាត់ត្រូវចេញទៅភ្ជួរនៅភូមិឆ្ងាយៗ ។ នៅរដូវវស្សាការងាររមមាញឹកខ្លាំងណាស់ ។ ប្រធានភូមិបានចាត់តាំងម្តាយគាត់ឲ្យទៅដកស្ទូងនៅជាប់ជើងភ្នំធិបតី ។ នៅទីនោះម្តាយ ចំរើន ត្រូវធ្វើការងាររហូតដល់យប់ជ្រៅទើបឈប់ ចំណែករបបអាហារមានតែបបរ និងសម្លបន្តិចបន្តួចប៉ុណ្ណោះ ។ ប្អូនប្រុស ចំរើន បានធ្លាក់ឈឺរាគមួល និងហើមដោយសារខ្វះជីវជាតិ ។ ម្តាយ ចំរើន ទៅសុំអនុញ្ញាតពីប្រធានកងដើម្បីយកកូនទៅព្យាបាលនៅមន្ទីរពេទ្យមោងឫស្សី ប៉ុន្តែដោយសារជំងឺធ្ងន់ធ្ងរពេកប្អូន ចំរើន បានស្លាប់រយៈពេលមួយថ្ងៃបន្ទាប់ពីទៅដល់មន្ទីរពេទ្យនោះ ។ ទោះបីជាម្តាយ ចំរើន សុំអង្វរយកកូនចេញពីមន្ទីរពេទ្យយ៉ាងណាក្តី ក៏គ្រូពេទ្យមិនអនុញ្ញាតទេ គឺឲ្យគាត់ត្រឡប់មកធ្វើការដូចធម្មតាវិញ ។ ចំណែក ឪពុក ចំរើន មិនបានដឹងរឿងនេះទេ ព្រោះគាត់ត្រូវចេញទៅភ្ជួរនៅភូមិផ្សេង ។


អែម ចំរើន

ជាញឹកញាប់ នៅពេលដែលឪពុក ចំរើន ត្រឡប់មកពីភ្ជួរ គាត់បានណែនាំ ចំរើន ថា “ទៅថ្ងៃមុខកូនកុំហៅ ប៉ា ថា ប៉ា ទៀត” ។ ចំរើន បានចងចាំ ហើយឈប់ប្រើពាក្យ “ប៉ា” ចាប់តាំងពីថ្ងៃនោះមក ។

ថ្ងៃមួយ ចំរើន និងកូនអ្នកមូលដ្ឋានម្នាក់បានទៅលួចបូតស្រូវនៅក្នុងភូមិ ស្រាប់តែឈ្លបឃើញ ។ ឈ្លបនោះមិនបានវាយធ្វើបាប ចំរើន ទេ គឺគ្រាន់តែហៅគាត់សួរឈ្មោះ និងតួនាទីឪពុកម្តាយប៉ុណ្ណោះ ។ បន្ទាប់មក ចំរើន យកស្រូវដែលគាត់បូតបានទៅឲ្យម្តាយគាត់បុកដាំបាយហូប ។ យប់នោះ នៅពេលដែល ចំរើន កំពុងដេកជាមួយម្តាយនៅលើផ្ទះស្រាប់តែឈ្លបមកលបចាប់ម្តាយគាត់យកទៅបាត់ ។ ពេលព្រឹក ចំរើន ភ្ញាក់ពីដេក មិនឃើញម្តាយក៏ទៅសួរអ្នកភូមិ ទើបដឹងថា ម្តាយគាត់ឈ្លបចាប់យកទៅបាត់ហើយ ។ ចំរើន ដើររកម្តាយតាមផ្ទះអ្នករស់នៅក្បែរខាងគ្នាទៀត តែរកមិនឃើញ ។ ចំរើន បានដើររកបន្ត រហូតឃើញម្តាយកំពុងជាប់ច្រវ៉ាក់នៅរោងមួយកន្លែង ។ ពេលនោះ ចំរើន ក៏ស្ទុះទៅរកម្តាយ ប៉ុន្តែឈ្លបខ្មែរក្រហមច្រានគាត់ចេញ ។ រហូតដល់ពេលរសៀល ទើប ចំរើន ឃើញម្តាយគាត់ត្រឡប់មកផ្ទះវិញទាំងទឹកមុខតក់ស្លុត ប៉ុន្តែគាត់មិនបានដឹងថាមានរឿងកើតឡើងចំពោះម្តាយគាត់ទេ ។

ចំរើន រស់នៅភូមិវត្តគ រហូតដល់ឆ្នាំ១៩៧៩ ទើបក្រុមគ្រួសារគាត់ត្រឡប់មករស់នៅស្រុកកំណើតវិញ ។ ចំរើន បញ្ជាក់ថា ចាប់តាំងរបបខ្មែរក្រហមដួលរលំ ឪពុកម្តាយគាត់មិនដែលនិយាយពីប្រវត្តិរបស់គាត់ឡើងវិញទេ ទោះបីមានការសួរនាំពីបងប្អូន ឬអ្នករស់នៅជិតខាងក៏ដោយ ។ ចំណែកគាត់ នៅតែរន្ធត់ និងតានតឹងក្នុងចិត្តពេលរំឭកពីអតីតកាលរបស់ក្រុមគ្រួសារ ពិសេសពេលឃើញម្តាយគាត់ជាប់ច្រវ៉ាក់ ។

ផលប៉ះពាល់ផ្លូវចិត្តដែលបន្សល់ទុកពីរបបខ្មែរក្រហមនោះ មិនមែនកើតមានតែចំពោះ ចំរើន ម្នាក់នោះទេ ប៉ុន្តែវាបានកើតចំពោះមនុស្សទូទៅដែលយើងមិនបានដឹង និងដែលមានរយៈពេលជាងសាមសិបឆ្នាំមកហើយ ។

**សោម ប៊ុនថន**

# កាតព្វកិច្ចក្នុងការផ្តល់ព័ត៌មានទៅកាន់សាធារណជនក្នុង អំឡុងពេលដំណើរការស៊ើបអង្កេតរបស់តុលាការខ្មែរក្រហម

## ១. សេចក្តីផ្តើម

កាលពីឆ្នាំមុន សហចៅក្រមស៊ើបអង្កេតរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការបានប្រកាសពីការបញ្ចប់ដំណើរការស៊ើបអង្កេតលើសំណុំរឿង០០៣ជាសាធារណៈ ។ ការស៊ើបអង្កេតលើសំណុំរឿង០០៣ ត្រូវបានរាយការណ៍ថាខ្វះខាតនូវ "មូលដ្ឋានស៊ើបអង្កេត" ដូចជាការសម្ភាសន៍ជាមួយនឹងជនសង្ស័យ និងសាក្សីរួមទាំងការស៊ើបអង្កេតដល់ទីកន្លែងកើតហេតុជាដើម ។ ស្របពេលជាមួយគ្នានេះ សហចៅក្រមស៊ើបអង្កេតមិនបានបញ្ចេញមតិអ្វីបន្តិចសោះទាក់ទងនឹងវិសាលភាពនៃការស៊ើបអង្កេតលើសំណុំរឿងនេះ ហើយក៏មិនបានបង្ហាញឈ្មោះជនសង្ស័យ ឬព័ត៌មានស្តីពីទីកន្លែង ឬបទឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់សម្រាប់ការស៊ើបអង្កេតនោះដែរ ។ នេះគឺជាទង្វើមួយដែលរំលោភសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការទទួលបានព័ត៌មានសំខាន់ដើម្បីអនុវត្តសិទ្ធិរបស់ខ្លួនក្នុងការចូលរួមក្នុងដំណើរការស៊ើបអង្កេត និងនីតិវិធីផ្សេងៗរបស់តុលាការ ។

ការមិនផ្តល់ព័ត៌មានដល់សាធារណជនស្តីពីដំណើរការស៊ើបអង្កេតរបស់តុលាការបានរារាំងមិនឲ្យជនរងគ្រោះចូលរួមធ្វើជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង០០៣ ។ ជាក់ស្តែងតុលាការខ្មែរក្រហមបានអនុញ្ញាតឲ្យជនរងគ្រោះចូលរួមជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងដំណើរការនីតិវិធីរបស់ខ្លួន ហើយតួនាទីរបស់ជនរងគ្រោះក្នុងការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានផ្តល់ឲ្យដោយវិធានផ្ទៃក្នុងរបស់តុលាការ ហើយក៏ត្រូវបានសង្កត់



អ្នកសារព័ត៌មានជាតិ និងអន្តរជាតិនៅខាងក្រៅបន្ទប់សវនាការ

ធ្ងន់ដោយសកម្មភាពនិងកំណត់ត្រាផ្សេងៗរបស់តុលាការដែលជាដៃគូសហការជាច្រើនរបស់តុលាការខ្មែរក្រហម ។ ដើមបណ្តឹងរដ្ឋប្បវេណីគឺជាធាតុផ្សំមួយដ៏សំខាន់នៅក្នុងប្រព័ន្ធច្បាប់ព្រហ្មទណ្ឌរបស់បារាំងដែលប្រព័ន្ធតុលាការកម្ពុជា និងតុលាការខ្មែរក្រហមបានយកគំរូតាម ។ លើសពីនេះ បទដ្ឋាន និងយុត្តិសាស្រ្តអន្តរជាតិក៏គាំទ្រតម្លៃនៃការចូលរួមរបស់ជនរងគ្រោះដែរ ។ កាតព្វកិច្ចរបស់តុលាការក្នុងការផ្តល់ព័ត៌មានដល់សាធារណជនគឺមានភាពជាប់ពាក់ព័ន្ធនឹងការស៊ើបអង្កេតលើសំណុំរឿង០០៤ ។ ក្នុងគោលបំណងធានាថាជនរងគ្រោះទទួលបាននូវ «ឱកាសសមរម្យមួយ» ដើម្បីដាក់ពាក្យស្នើសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង០០៤សហព្រះរាជអាជ្ញាអន្តរជាតិបានធ្វើការស្នើសុំមួយដែលធ្វើឡើងនៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១១ សុំឲ្យសហចៅក្រមស៊ើបអង្កេត«ចេញសេចក្តីប្រកាសជាសាធារណៈមួយនៅថ្ងៃទី៥ ខែសីហា ឆ្នាំ២០១១ ដោយបរិយាយពីបទឧក្រិដ្ឋកម្មនិងបទល្មើសដែលត្រូវបានស៊ើបអង្កេតនៅក្នុងសំណុំរឿង០០៤» ។ ប៉ុន្តែ សហចៅក្រមស៊ើបអង្កេតមិនអើពើអ្វីទាំងអស់ ។ ការខកខានមិនផ្តល់ព័ត៌មានសំខាន់ៗពីដំណើរការស៊ើបអង្កេតដែលធ្វើឡើងជាបន្តបន្ទាប់នេះបានរារាំងមិនឲ្យមានការចូលរួមពីសំណាក់ដើមបណ្តឹងរដ្ឋប្បវេណីរំលោភសិទ្ធិចូលរួមរបស់ជនរងគ្រោះធ្វើឲ្យដំណើរការស៊ើបអង្កេតរបស់តុលាការមានភាពទន់ខ្សោយ ហើយកាត់បន្ថយកិច្ចខំប្រឹងប្រែងរបស់តុលាការក្នុងជួយជនរងគ្រោះ ។


ប្រជាពលរដ្ឋដើរចូលក្នុងបន្ទប់សវនាការ

## ២. តួនាទីរបស់ជនរងគ្រោះក្នុងនាមជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងអំឡុងដំណើរការស៊ើប អង្កេតរបស់តុលាការ

ជនគ្រោះមានសិទ្ធិក្នុងការចូលរួមធ្វើជាដើមបណ្តឹងរដ្ឋប្បវេណីនៅតុលាការខ្មែរក្រហម ។ ការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីគឺជាមធ្យោបាយដ៏សំខាន់ និងចម្បងដែលជនរងគ្រោះអាចចូលរួមនៅក្នុងអង្គនីតិវិធីរបស់តុលាការបានយ៉ាងមានប្រសិទ្ធភាព ។ សកម្មភាពរបស់ដើមបណ្តឹងរដ្ឋប្បវេណី នៅចំពោះមុខតុលាការខ្មែរក្រហមមានគោលបំណងសំខាន់ពីរ ៖ ទីមួយ ការចូលរួមក្នុងនាមជាដើមបណ្តឹងរដ្ឋប្បវេណីធ្វើឲ្យជនរងគ្រោះទទួលបាននូវសំណងជាសមូហភាព និងសំណងសីលធម៌ ។ បន្ថែមលើនេះ ដើមបណ្តឹងរដ្ឋប្បវេណីអាចចូលរួមនៅក្នុងអង្គនីតិវិធីព្រហ្មទណ្ឌបានដោយសារការគាំទ្ររបស់ព្រះរាជអាជ្ញា ។ ជនរងគ្រោះអាចអនុវត្តសិទ្ធិរបស់ខ្លួនក្នុងការចូលរួមធ្វើជាដើមបណ្តឹងរដ្ឋប្បវេណីចាប់តាំងពីដំណាក់កាលដំបូងនៃអង្គនីតិវិធីរបស់តុលាការបានដូចដែលបានអះអាងដោយអង្គបុរេជំនុំជម្រះនៅក្នុងឆ្នាំ២០០៨ដែលចែងក្នុងវិធានផ្ទៃក្នុង «បញ្ជាក់យ៉ាងច្បាស់ថា ដើមបណ្តឹងរដ្ឋប្បវេណីមានសិទ្ធិដ៏សកម្មក្នុងការចូលរួមក្នុងដំណើរការចាប់ផ្តើមដំបូងនៃការស៊ើបអង្កេត» ។

នៅក្នុងតុលាការដែលដើរតាមច្បាប់ស៊ីវិលឡូវិញ ការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅតុលាការខ្មែរក្រហមនេះគឺផ្អែកលើសមត្ថភាពរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការចូលរួមក្នុងដំណើរការស៊ើបអង្កេតរបស់តុលាការ ។ ដោយសារតែការស្នើសុំធ្វើជាដើមបណ្តឹងរដ្ឋប្បវេណីត្រូវតែ «គួសបញ្ជាក់ឲ្យច្បាស់ពីឧក្រិដ្ឋកម្មដែលបានចោទប្រកាន់» ឬ «បង្ហាញពីពិរុទ្ធភាពរបស់ជនដៃដល់» នោះ ដើមបណ្តឹងរដ្ឋប្បវេណីបានធ្វើការគាំទ្រការចោទប្រកាន់របស់

ព្រះរាជអាជ្ញា ដូចដែលមានចែងនៅក្នុងវិធាន២៣.១.ក ។ បន្ថែមលើការផ្តល់ព័ត៌មានសំខាន់ដល់ការដាក់ពាក្យស្នើសុំធ្វើជាដើមបណ្តឹងរដ្ឋប្បវេណី ដើមបណ្តឹងរដ្ឋប្បវេណីអាចគាំទ្រការស៊ើបអង្កេតជាបន្តបន្ទាប់របស់តុលាការបានតាមរយៈការផ្តល់បទសម្ភាសន៍ ឬតាមរយៈការស៊ើបអង្កេតដែលបង្ហាញពីព័ត៌មានទាក់ទងនឹងបទឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់នោះ ។ ដើមបណ្តឹងរដ្ឋប្បវេណីអាចតម្រូវឲ្យផ្តល់ព័ត៌មានជាក់លាក់ដែលជាប់ពាក់ព័ន្ធនឹងដំណើរការស៊ើបអង្កេតជាបន្តបន្ទាប់ ដូច្នេះការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីអាចផ្តល់ឲ្យតុលាការនូវ "ព័ត៌មានដើម" ពីព្រឹត្តិការណ៍ហើយ អាចជម្រាបតុលាការពីបញ្ហាដែល "មានជាប់ពាក់ព័ន្ធផ្ទាល់នឹងអង្គនីតិវិធីនៃអង្គបុរេជំនុំជម្រះបាន" ។

## ៣. ព័ត៌មានគឺមានសារសំខាន់សម្រាប់ការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងដំណើរការស៊ើបអង្កេតរបស់តុលាការ



ដើមបណ្តឹងរដ្ឋប្បវេណីកំពុងដើរចូលក្នុងបន្ទប់សវនាការ

ជនរងគ្រោះត្រូវតែទទួលបាននូវព័ត៌មានចាំបាច់នៅក្នុងអំឡុងដំណើរការស៊ើបអង្កេតជាបន្តបន្ទាប់របស់តុលាការដើម្បីទាមទារសំណង និងការគាំទ្រពីព្រះរាជអាជ្ញានៅពេលដែលដើមបណ្តឹងរដ្ឋប្បវេណីចូលរួមនៅក្នុងដំណើរការនីតិវិធី ។ ប្រសិនបើជនរងគ្រោះ និងដើមបណ្តឹងរដ្ឋប្បវេណីសំខាន់ៗមិនទទួលបានព័ត៌មានសំខាន់ៗ និងមានន័យនៅក្នុងអំឡុងដំណើរការស៊ើបអង្កេតទេនោះមានន័យថា ជនរងគ្រោះ និងដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានរារាំងមិនឲ្យអនុវត្តសិទ្ធិក្នុងការចូលរួមដូចដែលមានចែងនៅក្នុងវិធានផ្ទៃក្នុងរបស់តុលាការខ្មែរក្រហម ។ ការខកខានមិនបានផ្តល់ព័ត៌មានដល់ជនរងគ្រោះដែលរារាំងមិនឲ្យមានការចូលរួមពីដើមបណ្តឹងរដ្ឋប្បវេណីបានប៉ះពាល់ដល់ដំណើរការស៊ើបអង្កេតរបស់តុលាការដោយរំលោភបំពានលើដំណើរការនេះដែលមានចែងនៅក្នុងវិធានផ្ទៃក្នុងរបស់តុលាការ និងដោយរារាំងមិនឲ្យដើមបណ្តឹងរដ្ឋប្បវេណីចូលរួមឲ្យបានពេញលេញ ។ ទាំងអស់នេះបានឆ្លុះបញ្ចាំងឲ្យឃើញថាកិច្ចខិតខំប្រឹងប្រែងដែលតុលាការបានអះអាងថានឹងជួយជនរងគ្រោះ និងទទួលស្គាល់តម្លៃនៃការចូលរួមរបស់ជនរងគ្រោះគឺជាការប្តេជ្ញាចិត្តក្លែងក្លាយតែប៉ុណ្ណោះ ។

បើទោះបីជាវិធានផ្ទៃក្នុង៥៦.១ចែងថា ដំណើរការស៊ើបអង្កេតរបស់តុលាការគួរតែប្រព្រឹត្តឡើងជាសាធារណៈ ហើយថាដំណើរការនេះគួរតែរក្សាជាការសម្ងាត់ក៏ដោយ ក៏សហចៅក្រមស៊ើបអង្កេតមិនត្រូវបានរារាំងមិនឲ្យផ្តល់ព័ត៌មានជាក់លាក់ណាមួយដល់សាធារណជនដែរ ។ វិធាន៥៦.២ អនុញ្ញាតឲ្យសហចៅក្រមស៊ើបអង្កេតផ្សព្វផ្សាយព័ត៌មានទាក់ទងនឹងការស៊ើបអង្កេតជាបន្តបន្ទាប់ដែលសហចៅក្រមស៊ើបអង្កេត "ចាត់ទុកថាមានសារសំខាន់ក្នុងការជម្រាបដល់សាធារណជនឲ្យបានដឹងពីដំណើរការនេះ កែប្រែព័ត៌មានដែលមិនពិត" និង "ផ្តល់ព័ត៌មានដែលមានកម្រិតពីដំណើរការស៊ើបអង្កេតរបស់តុលាការទៅកាន់អ្នកសារព័ត៌មាន ឬភាគីដែលមិនជាប់ពាក់ព័ន្ធនៅក្នុងកាលៈទេសៈលើកលែងណាមួយ" ។ ថ្មីៗនេះអង្គបុរេជំនុំជម្រះបានគូសបញ្ជាក់ពីសារៈសំខាន់នៃការអានពីវិធានផ្ទៃក្នុងទាំងអស់របស់តុលាការក្នុងនោះរួមទាំងវិធាន៥៦ដែលផ្តោតលើ "គោលការណ៍ និងនីតិវិធីសំខាន់" ជាពិសេសគឺ វិធាន២១.១.ក ដែលចែងថាតុលាការ "ត្រូវតែធានាថាជនរងគ្រោះបានដឹងពីសិទ្ធិរបស់ខ្លួននៅក្នុងការចូលរួមអង្គនីតិវិធីរបស់តុលាការ" ។ នៅក្នុងអំឡុងដំណើរការស៊ើបអង្កេតរបស់តុលាការលើសំណុំរឿង ០០៣ សកម្មជនរបស់តុលាការជាច្រើនបានទទួលស្គាល់សិទ្ធិចូលរួម

របស់ដើមបណ្តឹងរដ្ឋប្បវេណី ហើយបានលើកឡើងពីសារសំខាន់នៃព័ត៌មានដែលជួយសម្របសម្រួលដល់ការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី ។ យ៉ាងណាមិញ សហចៅក្រមស៊ើបអង្កេតបានរារាំងជនរងគ្រោះមិនឲ្យដឹងពីសិទ្ធិរបស់ខ្លួនក្នុងការចូលរួមនៅក្នុងដំណើរការនីតិវិធីរបស់តុលាការដោយអាក់ខានមិនបានផ្តល់ព័ត៌មានសំខាន់ពីការដាក់ពាក្យស្នើសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី និងការចូលរួមរបស់ជនរងគ្រោះ ។

### ៤. ជនរងគ្រោះគួរតែទទួលបានព័ត៌មានជាបន្តបន្ទាប់ដើម្បីទទួលបានការចូលរួមដែលមានន័យ និងការស៊ើបអង្កេតរបស់តុលាការ

តាមធម្មតា ព័ត៌មានផ្តល់ឲ្យសាធារណៈនៅក្នុងដំណើរការស៊ើបអង្កេតរបស់តុលាការត្រូវបានតម្រូវឲ្យផ្សព្វផ្សាយឲ្យបានលឿនបំផុតដើម្បីអនុញ្ញាតឲ្យជនរងគ្រោះអាចដាក់ពាក្យស្នើសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីមុនកាលបរិច្ឆេទកំណត់ ។ បន្ថែមលើនេះ ដើមបណ្តឹងរដ្ឋប្បវេណីមានសិទ្ធិចូលរួមនៅក្នុងអង្គនីតិវិធីរបស់អង្គបុរេជំនុំជម្រះដែលដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានរារាំងមិនឲ្យអនុវត្តនៅពេលដែលអ្នកទាំងអស់នេះមិនអាចបំពេញពាក្យស្នើសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីឲ្យបានមុនដំណើរការស៊ើបអង្កេតចាប់ផ្តើម ។ ជនរងគ្រោះអាចនឹងចូលរួមយ៉ាងមានន័យនៅក្នុងដំណើរការស៊ើបអង្កេតរបស់តុលាការបាន ។ ក្នុងនាមជាដើមបណ្តឹងរដ្ឋប្បវេណីនិងជាអ្នកដាក់ពាក្យស្នើសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីអ្នកទាំងអស់នេះអាចស្នើសុំឲ្យមានការស៊ើបអង្កេតនៅក្នុងដំណាក់កាលសកម្មនៃដំណើរការស៊ើបអង្កេតក្រោយ និងមុនការទទួលបានសេចក្តីប្រកាសពីការបញ្ចប់ដំណើរការស៊ើបអង្កេតរបស់តុលាការបាន ។ យុត្តិសាស្ត្ររបស់តុលាការខ្មែរក្រហមបានសង្កត់ធ្ងន់ថាព័ត៌មានគួរតែត្រូវផ្តល់ជូនសាធារណជនជាបន្តបន្ទាប់ដើម្បីឲ្យដើមបណ្តឹងរដ្ឋប្បវេណីចូលរួមនៅក្នុងអង្គនីតិវិធីរបស់តុលាការមុនពេលដែលបទចោទប្រកាន់ជាផ្លូវការត្រូវបានធ្វើឡើង ។

#### ១) ការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីអាចធ្វើទៅរួចបានមុនពេលដែលបទចោទប្រកាន់ ជាផ្លូវការត្រូវបានធ្វើឡើង

វិធាន២៣.១.ខ ចែងថា ដើម្បីទទួលស្គាល់ជាដើមបណ្តឹងរដ្ឋប្បវេណី អ្នកដាក់ពាក្យស្នើសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីត្រូវតែ "បង្ហាញឲ្យឃើញពីផលប៉ះពាល់ដោយផ្ទាល់នៃបទឧក្រិដ្ឋកម្មយ៉ាងហោចណាស់មួយដែលត្រូវបានចោទប្រកាន់ជនជាប់ចោទ ហើយដែលខ្លួនបានទទួលរងគ្រោះ" ។ យុត្តិសាស្ត្រ និងការអនុវត្តថ្មីៗរបស់តុលាការខ្មែរក្រហមបានបញ្ជាក់យ៉ាងច្បាស់ថា ជនទាំងឡាយណាដែលមានឈ្មោះនៅក្នុងសេចក្តីសន្និដ្ឋានបឋមរបស់ព្រះរាជអាជ្ញានឹងក្លាយជាជនត្រូវចោទដោយស្វ័យប្រវត្តិ យោងតាមវិធាន២៣ស្ទួន១.ខ ។ យោងតាមសទ្ទានុក្រមនៃវិធានផ្ទៃក្នុងរបស់តុលាការខ្មែរក្រហម "ជនត្រូវចោទ" "សំដៅទៅលើជនទាំងឡាយណាដែលត្រូវនាំមកកាត់ទោសនៅក្នុងរឿងក្តីមួយនៅក្នុងរវាងអំឡុងពេលដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ និងដីកាបញ្ជូនរឿងទៅជំនុំជម្រះឬដីការលុបចោលរឿងមិនឲ្យជំនុំជម្រះ" ។

ជាក់ស្តែង ដីការបស់ការិយាល័យសហចៅក្រមស៊ើបអង្កេតបានគូសបញ្ជាក់ថា ជនទាំងឡាយណាដែលមានឈ្មោះនៅក្នុងសេចក្តីសន្និដ្ឋានបឋមគឺជាជនត្រូវចោទ ។ ដីកានេះចែងថា ៖ "ប្រសិនបើជនម្នាក់មិនមានឈ្មោះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ជននោះនឹងទទួលបានឋានៈជា "ជនត្រូវចោទ" ដែលនេះគឺជារឿងក្តីរបស់ជនទាំងអស់ដែលមានឈ្មោះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ" ។ ស្រដៀងគ្នានេះ សហចៅក្រមស៊ើបអង្កេតបានកត់សម្គាល់ថា ៖ "ជនដែលមានឈ្មោះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរគឺសំដៅទៅលើ "ជនត្រូវចោទ" ដែលស្របទៅតាមនីតិវិធីព្រហ្មទណ្ឌបារាំង ។ ដូច្នេះ ការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីអាចចាប់ផ្តើមមុនពេលការចោទប្រកាន់ត្រូវបានចោទមកលើជនដែលត្រូវបានស៊ើបអង្កេត ។

#### ២) ព័ត៌មានត្រូវតែផ្តល់ឲ្យទាន់ពេលវេលាដើម្បីបំពេញទៅតាមកាលបរិច្ឆេទកំណត់ក្នុងការដាក់ពាក្យស្នើសុំធ្វើជាដើមបណ្តឹងរដ្ឋប្បវេណី

ព័ត៌មានផ្តល់ឲ្យសាធារណៈនៅក្នុងដំណើរការស៊ើបអង្កេតរបស់តុលាការគឺមានសារសំខាន់ដើម្បីឲ្យដំណើរការដាក់ពាក្យស្នើសុំធ្វើជាដើមបណ្តឹងរដ្ឋប្បវេណីដើរទៅមុខដូចបាន ដូចដែលមានចែងនៅក្នុងវិធានផ្ទៃក្នុងរបស់តុលាការ ។ យោងតាមការកែទម្រង់ថ្មីនៃវិធានផ្ទៃក្នុងរបស់តុលាការ ការដាក់ពាក្យស្នើសុំធ្វើជាដើម

បណ្តឹងរដ្ឋប្បវេណីត្រូវតែដាក់ជូនតុលាការ នៅក្នុងអំឡុងដំណាក់កាលស៊ើបអង្កេត ។ ជាពិសេស វិធាន២៣ស្ទួន២ចែងថា ជនរងគ្រោះត្រូវដាក់ពាក្យស្នើសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី«ជាលាយលក្ខណ៍អក្សរមិនលើសពីរយៈពេលដប់ប្រាំថ្ងៃ ក្រោយពេលដែលសហចៅក្រមធ្វើការគូសបញ្ជាក់ពីភាគីដែលចូលរួមនៅក្នុងដំណើរការបញ្ចប់នៃដំណើរការស៊ើបអង្កេតរបស់តុលាការ» ។ នេះឆ្លុះបញ្ចាំងឲ្យឃើញថាព័ត៌មានចាំបាច់ត្រូវតែផ្តល់ឲ្យដើមបណ្តឹងរដ្ឋប្បវេណីឲ្យបានគ្រប់គ្រាន់មុនពេលកាលបរិច្ឆេទកំណត់របស់តុលាការដើម្បីឲ្យដើមបណ្តឹងរដ្ឋប្បវេណីអាចដាក់ពាក្យស្នើសុំដែលបង្ហាញពី «ផលប៉ះពាល់ផ្ទាល់នៃបទឧក្រិដ្ឋកម្មយ៉ាងហោចណាស់មួយដែលត្រូវបានចោទប្រកាន់ទៅលើជនជាប់ចោទ ដែលដើមបណ្តឹងរដ្ឋប្បវេណីបានទទួលរងគ្រោះថ្នាក់លើផ្នែករាយកាយ ផ្នែកសម្ភារ និងផ្នែកសតិអារម្មណ៍ដែលជាអំណះអំណាងដែលអាចឲ្យដើមបណ្តឹងរដ្ឋប្បវេណីទទួលបានសំណងសីលធម៌ និងសំណងជាសមូហភាព» ។

**៣) ព័ត៌មានត្រូវតែផ្តល់ឲ្យបានលឿន ដើម្បីឲ្យដើមបណ្តឹងរដ្ឋប្បវេណីបានដឹងពីសិទ្ធិក្នុងការចូលរួមនៅអង្គបុរេជំនុំជម្រះ**

បន្ថែមលើដំណើរការដាក់ពាក្យស្នើសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលចាប់ផ្តើមឡើងនៅក្នុងអំឡុងពេលស៊ើបអង្កេតរបស់តុលាការដើមបណ្តឹងរដ្ឋប្បវេណីមានសិទ្ធិក្នុងការចូលរួមអង្គបុរេជំនុំជម្រះដែលជនរងគ្រោះអាចនឹងត្រូវបានរារាំងមិនឲ្យអនុវត្តសិទ្ធិនេះនៅពេលដែលជនរងគ្រោះមិនទទួលបានព័ត៌មានគ្រប់គ្រាន់ដើម្បីចូលរួមអង្គនីតិវិធីនៅក្នុងដំណាក់កាលស៊ើបអង្កេតរបស់តុលាការ ។ ក្នុងអំឡុងពេលដំណាក់កាលស៊ើបអង្កេត ដើមបណ្តឹងរដ្ឋប្បវេណីអាចសំណូមពរឲ្យសហចៅក្រមស៊ើបអង្កេត «ចេញដីកា ឬអនុវត្តវិធានការស៊ើបអង្កេតណាមួយដែលខ្លួនគិតថា មានប្រយោជន៍ដល់ការស៊ើបអង្កេត» ឬ «សំណូមពរឲ្យសហចៅក្រមស៊ើបអង្កេតសម្ភាសន៍ខ្លួនឯង ឬ សាក្សីណាមួយធ្វើដំណើរទៅកាន់ទីកន្លែងប្រព្រឹត្តឧក្រិដ្ឋកម្ម ស្វែងរកអ្នកជំនាញ ឬស្វែងរកភស្តុតាងផ្សេងៗជំនួសឲ្យដើមបណ្តឹងរដ្ឋប្បវេណីខ្លួនឯងផ្ទាល់» ។ លើសពីនេះដើមបណ្តឹងរដ្ឋប្បវេណីមានសិទ្ធិប្តឹងឧទ្ធរណ៍នៅក្នុងអង្គបុរេជំនុំជម្រះរបស់តុលាការដែលដើមបណ្តឹងរដ្ឋប្បវេណីខ្លួនឯងមិនអាចអនុវត្តប្រសិនបើអ្នកទាំងអស់នោះបានចូលរួមធ្វើជាដើមបណ្តឹងរដ្ឋប្បវេណីមុនពេលកាលបរិច្ឆេទកំណត់សម្រាប់ការប្តឹងឧទ្ធរណ៍ ។ ការដកហូតសិទ្ធិរបស់ជនរងគ្រោះក្នុងការចូលរួមអង្គនីតិវិធីនៃអង្គបុរេជំនុំជម្រះគឺជាការរំលោភបំពានលើវិធានផ្ទៃក្នុងរបស់តុលាការ ។

**៤) ដើមបណ្តឹងរដ្ឋប្បវេណីត្រូវតែទទួលបានព័ត៌មានឲ្យបានទាន់ពេលវេលាដើម្បីចូលរួមឲ្យបានសកម្មនៅក្នុងដំណើរការស៊ើបអង្កេតរបស់តុលាការ**

វិធានផ្ទៃក្នុងផ្អែកលើការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី «ដើម្បីគាំទ្រការកាត់ទោស» ហើយចូលរួមនៅក្នុងដំណើរការស៊ើបអង្កេតជាបន្តបន្ទាប់ ។ ដូច្នេះ ដើមបណ្តឹងរដ្ឋប្បវេណីត្រូវតែបានដឹងពីដំណើរការស៊ើបអង្កេតជាបន្តបន្ទាប់របស់តុលាការ ដើម្បីចូលរួមឲ្យបានសកម្ម និងទាន់ពេលវេលា ។ ព័ត៌មានផ្តល់ឲ្យសាធារណៈដែលទទួលបានក្រោយពេលដំណើរការបញ្ចប់នៃដំណើរការស៊ើបអង្កេតនឹងរារាំងដើមបណ្តឹងរដ្ឋប្បវេណីមិនឲ្យចូលរួមឲ្យបានពេញលេញ ។

**៥) ព័ត៌មានផ្តល់ឲ្យសាធារណៈនៅក្នុងសំណុំរឿង០០៣ មិនគោរពទៅតាមបទដ្ឋានសម្រាប់ការផ្តល់ពេលវេលាឲ្យទាន់ពេលវេលាដែលបទដ្ឋាននេះត្រូវបង្កើតនៅក្នុងសំណុំរឿង០០២ និងយុត្តិសាស្ត្រពាក់ព័ន្ធផ្សេងៗ**

ខុសពីសំណុំរឿង០០៣ ជនរងគ្រោះទទួលបានព័ត៌មានមូលដ្ឋានស្តីពីដំណើរការស៊ើបអង្កេតជាបន្តបន្ទាប់នៅក្នុងអំឡុងពេលដំណើរការស៊ើបអង្កេតលើសំណុំរឿង០០២ ។ យ៉ាងណាមិញសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះបានសម្រេចថា «សហចៅក្រមមិនបានផ្តល់ព័ត៌មានដល់ជនរងគ្រោះឲ្យបានទាន់ពេលវេលាទេ» ដូច្នេះ «សិទ្ធិរបស់ជនរងគ្រោះមិនត្រូវបានការពារទាល់តែសោះ» ។ ដូច្នេះ ដំណើរការស៊ើបអង្កេតលើសំណុំរឿង០០២ បានក្លាយជាឧទាហរណ៍មួយដែលថាព័ត៌មានផ្តល់ឲ្យសាធារណៈត្រូវបានផ្តល់ឲ្យជនរងគ្រោះយឺតយ៉ាវដែលជនរងគ្រោះមិនអាចតម្រូវទៅតាមលក្ខន្តិកៈរបស់តុលាការបាន ។

**៥ ៊ ព័ត៌មានត្រូវតែផ្តល់បានគ្រប់គ្រាន់ ដើម្បីទទួលបានការចូលរួមដ៏ជោគជ័យរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងការចូលរួមដែលមានជាប់ពាក់ព័ន្ធនឹងដំណើរការស៊ើបអង្កេត ជាបន្តបន្ទាប់**

ជនរងគ្រោះត្រូវតែទទួលបានព័ត៌មានដែលគ្រប់គ្រាន់ទាក់ទងនឹងដំណើរការស៊ើបអង្កេតជាបន្តបន្ទាប់របស់តុលាការ ដើម្បីឲ្យជនរងគ្រោះគោរពទៅតាមលក្ខន្តិកៈរបស់តុលាការក្នុងការដាក់ពាក្យស្នើសុំធ្វើជាដើមបណ្តឹងរដ្ឋប្បវេណី ហើយដើម្បីចូលរួមក្នុងដំណើរការស៊ើបអង្កេតជាបន្តបន្ទាប់របស់តុលាការ ។ ដើម្បីឲ្យប្រាកដសិទ្ធិរបស់ភាគីទាំងអស់គួរតែត្រូវបានគិតគូរនៅក្នុងពេលដំណើរការស៊ើបអង្កេត ។ ប៉ុន្តែ ការផ្តល់ព័ត៌មានចាំបាច់នៅក្នុងដំណើរការស៊ើបអង្កេតមានភាពស៊ីសង្វាក់គ្នានឹងសិទ្ធិរបស់ជនរងគ្រោះ និងដើមបណ្តឹងរដ្ឋប្បវេណី ហើយការផ្តល់ព័ត៌មានចាំបាច់នេះក៏នឹងមិនបង្កឲ្យមានផលប៉ះពាល់ដល់ភាគីផ្សេងៗដែលមានជាប់ពាក់ព័ន្ធនៅក្នុងការស៊ើបអង្កេតនេះដែរ ។

**១) ជនរងគ្រោះត្រូវតែទទួលបានព័ត៌មានគ្រប់គ្រាន់ដើម្បីអនុវត្តសិទ្ធិរបស់ខ្លួនក្នុងការធ្វើជាដើមបណ្តឹងរដ្ឋប្បវេណី**

ដើមបណ្តឹងរដ្ឋប្បវេណីអាចក្លាយជាដើមបណ្តឹងរដ្ឋប្បវេណីដ៏ជោគជ័យបានគឺពឹងផ្អែកទៅលើព័ត៌មានស្តីពីដំណើរការស៊ើបអង្កេតជាបន្តបន្ទាប់ដើម្បីផ្សារភ្ជាប់កាលៈទេសៈរបស់អ្នកដាក់ពាក្យស្នើសុំធ្វើជាដើមបណ្តឹងរដ្ឋប្បវេណីទៅនឹងជនសង្ស័យ និងឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់នៅក្នុងដំណើរការស៊ើបអង្កេតដូចដែលមានចែងនៅក្នុងវិធានផ្ទៃក្នុង ។ វិធាន២៣ ស្ទួន៤ចែងថា ការដាក់ពាក្យស្នើសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីៈ បានផ្តល់ព័ត៌មានលម្អិតស្តីពីឋានៈរបស់ខ្លួនក្នុងនាមជាជនរងគ្រោះចង្អុលបង្ហាញលើឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ផ្តល់ភស្តុតាងពីគ្រោះថ្នាក់ដែលទទួលរង និង "ទំនងជាបង្ហាញពីពិរុទ្ធភាពរបស់ជនដែលដែលត្រូវបានតុលាការចោទប្រកាន់" ។ កាលបើជនរងគ្រោះដែលត្រូវបានទទួលស្គាល់ថាជាដើមបណ្តឹងរដ្ឋប្បវេណីនោះមានន័យថា ជនរងគ្រោះនោះបានបង្ហាញថា ជនរងគ្រោះបានរងគ្រោះថ្នាក់ដោយសារតែផលប៉ះពាល់នៃបទឧក្រិដ្ឋកម្មយ៉ាងហោចណាស់មួយដែលត្រូវបានចោទប្រកាន់ទៅលើជនជាប់ចោទ ដែលនេះគឺជាអំណះអំណាងមួយសម្រាប់ការទាមទារសំណង ។ ដូច្នេះ ដើមបណ្តឹងរដ្ឋប្បវេណីចាំបាច់ត្រូវការព័ត៌មានសំខាន់ស្តីពីជនជាប់ចោទ និងឧក្រិដ្ឋកម្ម ដែលឋិតនៅក្រោមការស៊ើបអង្កេត ។

**២) ជនរងគ្រោះត្រូវតែទទួលបានព័ត៌មានឲ្យបានគ្រប់គ្រាន់ដើម្បីទទួលបានការចូលរួមដែលមានន័យនិងជាប់ពាក់ព័ន្ធនឹងដំណើរការស៊ើបអង្កេតរបស់តុលាការ**

នៅពេលដែលជនរងគ្រោះខ្វះខាតព័ត៌មានគ្រប់គ្រាន់ស្តីពីដំណើរការស៊ើបអង្កេតជាបន្តបន្ទាប់របស់តុលាការនោះការដាក់ពាក្យស្នើសុំរបស់ជនរងគ្រោះអាចនឹងមិនមានជាប់ពាក់ព័ន្ធអ្វីជាមួយនឹងការស៊ើបអង្កេតរបស់តុលាការទេ ។ ពាក្យស្នើសុំដែលត្រូវបានដាក់ជូនដោយគ្មានការដឹងឮពីការស៊ើបអង្កេតជាបន្តបន្ទាប់របស់តុលាការមិនអាចផ្តល់ព័ត៌មានដែលជាប់ពាក់ព័ន្ធនឹងបទចោទប្រកាន់ដែលត្រូវបានស៊ើបអង្កេតទេ ។ ហើយការបែងចែកសំណុំឯកសារនៃអ្នកដាក់ពាក្យស្នើសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលមិនជាប់ពាក់ព័ន្ធនឹងវិសាលភាពនៃការស៊ើបអង្កេតគឺជាការចំណាយពេលវេលានិងធនធានឥតប្រយោជន៍សម្រាប់ផ្នែកគាំពារជនរងគ្រោះនិងសហចៅក្រមស៊ើបអង្កេត ។ បន្ថែមលើនេះ ជនរងគ្រោះអាចនឹងមានការរំពឹងទុកដែលមិនអាចសម្រេចទៅបានទាក់ទងនឹងសមត្ថភាពរបស់ខ្លួនក្នុងការចូលរួមតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ប្រសិនបើគ្មានព័ត៌មានគ្រប់គ្រាន់ដើម្បីធ្វើឲ្យសំណុំឯកសារស្នើសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ខ្លួនទទួលបានជោគជ័យ ។ ជាលទ្ធផលការស៊ើបអង្កេតនឹងទទួលរងផលប៉ះពាល់នៅពេលដែលជនរងគ្រោះមិនមានឱកាសដើម្បីផ្តល់ព័ត៌មានដែលជាប់ពាក់ព័ន្ធនឹងការស៊ើបអង្កេតជាបន្តបន្ទាប់របស់តុលាការ ។ ការរារាំងមិនឲ្យមានការចូលរួមពីជនរងគ្រោះនៅក្នុងទិដ្ឋភាពបែបនេះគឺជាការប្រឆាំងនឹងវិធានរបស់តុលាការនិងរំលោភបំពានលើគតិម្លៃនៃវិធាននេះដែលបានចែងថាដើមបណ្តឹងរដ្ឋប្បវេណីគួរតែចូលរួមនៅក្នុងការស៊ើបអង្កេតជាបន្តបន្ទាប់របស់តុលាការ ។

**៣) សិទ្ធិរបស់ជនរងគ្រោះ និងដើមបណ្តឹងរដ្ឋប្បវេណីដែលពឹងផ្អែកទៅលើព័ត៌មានដែលផ្តល់ឲ្យសាធារណៈដ៏សំខាន់គឺមិនមានជាប់ពាក់ព័ន្ធនឹងសិទ្ធិរបស់ភាគីដទៃទៀតទេ**

វិធានផ្ទៃក្នុងរបស់តុលាការខ្មែរក្រហមទទួលស្គាល់ពីតម្រូវការចាំបាច់ក្នុងការធានាឲ្យមានតុល្យភាពរវាងសិទ្ធិរបស់ជនទាំងអស់ដែលមានជាប់ពាក់ព័ន្ធនៅក្នុងដំណើរការស៊ើបអង្កេតរបស់តុលាការដោយគ្មានការមើលរំលងលើសិទ្ធិរបស់ជនរងគ្រោះ និងដើមបណ្តឹងរដ្ឋប្បវេណីឡើយ ។ វិធាន២១ ដែលរៀបរាប់ពី

គោលការណ៍សំខាន់ៗរបស់តុលាការបានរំពឹកថា ច្បាប់វិធាន សេចក្ដីបង្គាប់ និងបទបញ្ញត្តិរបស់តុលាការខ្មែរក្រហមទាំងអស់ "គួរតែត្រូវបានបកស្រាយដើម្បីការពារផលប្រយោជន៍របស់ជនសង្ស័យ ជនត្រូវចោទ ជនជាប់ចោទ និងជនរងគ្រោះ ហើយដើម្បីធានាឲ្យបាននូវភាពប្រត្យក្ស និងតម្លាភាពផ្លូវច្បាប់នៃអង្គនីតិវិធីរបស់តុលាការ" ។ លើសពីនេះ តុលាការត្រូវតែ "រក្សាឲ្យបាននូវគុណភាពនៃសិទ្ធិរបស់ភាគីទាំងអស់" ដែលចូលរួមនៅក្នុងអង្គនីតិវិធី ពីព្រោះថាគុណភាពនេះមានសារសំខាន់ក្នុងការកំណត់ថាតើព័ត៌មានណាខ្លះដែលត្រូវឲ្យសាធារណជនដឹងនៅក្នុងអំឡុងដំណើរការស៊ើបអង្កេត ។ ហើយគុណភាពនេះក៏ត្រូវបានសង្កត់ធ្ងន់នៅក្នុងវិធានរបស់តុលាការដែរទាក់ទងនឹងព័ត៌មានដែលសាធារណជនអាចដឹងនៅក្នុងអំឡុងពេលដែលអង្គនីតិវិធីចាប់ផ្ដើមជាបន្ដបន្ទាប់ ។ ដោយសារតែសិទ្ធិរបស់ជនរងគ្រោះ និងដើមបណ្ដឹងរដ្ឋប្បវេណី មិនអាចលុបបំបាត់ដោយសិទ្ធិរបស់ភាគីដទៃទៀត នោះវាពិតជាសំខាន់ក្នុងការផ្ដល់ព័ត៌មានដល់សាធារណជនឲ្យបានគ្រប់គ្រាន់ដើម្បីឲ្យអ្នកទាំងអស់នោះដឹងពីសិទ្ធិរបស់ខ្លួន ។

## ៦. សេចក្ដីសន្និដ្ឋាន

នៅក្នុងអំឡុងដំណើរការស៊ើបអង្កេតលើសំណុំរឿង ០០៣របស់តុលាការ សហចៅក្រមស៊ើបអង្កេតអាក់ខានមិនបានបំពេញកាតព្វកិច្ចរបស់ខ្លួនក្នុងការផ្ដល់ព័ត៌មានសំខាន់ដល់ជនរងគ្រោះឲ្យទាន់ពេលវេលាដែលទង្វើនេះបានរារាំងការចូលរួមរបស់ដើមបណ្ដឹងរដ្ឋប្បវេណី និងបានរំលោភបំពានលើសិទ្ធិរបស់ជនរងគ្រោះក្នុងការចូលរួមធ្វើជាដើមបណ្ដឹងរដ្ឋប្បវេណីដើម្បីទាមទារសំណង និងការគាំទ្រពីព្រះរាជអាជ្ញា ។ បន្ថែមលើនេះ ការខ្វះខាតនូវព័ត៌មានសាធារណៈបានប៉ះពាល់ដល់ការស៊ើបអង្កេតរបស់តុលាការដោយរារាំមិនឲ្យមានការចូលរួមពីសំណាក់ជនរងគ្រោះ និងដើមបណ្ដឹងរដ្ឋប្បវេណីសំខាន់ៗ ។ សហចៅក្រមស៊ើបអង្កេតត្រូវតែផ្ដល់ព័ត៌មានសំខាន់ដល់ជនរងគ្រោះឲ្យទាន់ពេលវេលា ដើម្បីឲ្យជនរងគ្រោះចូលរួមនៅក្នុងធ្វើជាដើមបណ្ដឹងរដ្ឋប្បវេណី និងចូលរួមនៅក្នុងដំណើរការស៊ើបអង្កេតជាបន្ដបន្ទាប់របស់តុលាការ ។ ដោយសារតែដំណើរការស៊ើបអង្កេតលើសំណុំរឿង០០៤ជាបន្ដបន្ទាប់របស់តុលាការជិតត្រូវបានបញ្ចប់ហើយនោះ សហចៅក្រមស៊ើបអង្កេតមានករណីកិច្ចយ៉ាងចាំបាច់ក្នុងការផ្ដល់ព័ត៌មានសំខាន់ៗ ដើម្បីអនុញ្ញាតឲ្យជនរងគ្រោះចូលរួមធ្វើជាដើមបណ្ដឹងរដ្ឋប្បវេណី នៅក្នុងដំណើរនីតិវិធីរបស់តុលាការ ។ បើមិនដូច្នោះទេ ដំណើរការចូលរួមរបស់ដើមបណ្ដឹងរដ្ឋប្បវេណីដែលមានចែងនៅក្នុងវិធានផ្ទៃក្នុងនឹងត្រូវកាត់ផ្ដាច់ ហើយកិច្ចខំប្រឹងប្រែង និងជំនឿរបស់តុលាការដែលជឿលើតម្លៃនៃការចូលរួមរបស់ជនរងគ្រោះនឹងក្លាយជារឿងក្លែងក្លាយ ។

ថេសា បារ៉ែឡែក



ប្រជាពលរដ្ឋកំពុងតម្រង់ជួរចូលបន្ទប់សវនាការ

# តើគឺជាល្ខោននយោបាយនៅឯសាលាក្តីខ្មែរក្រហម?

នៅអង្គជំនុំជម្រះក្តីរបស់សាលាក្តីខ្មែរក្រហមនៅកម្ពុជា សហមេធាវីការពារក្តីអន្តរជាតិរបស់ អៀង សារី បានអះអាងថា វត្តមានទាំងបង្ខំរបស់កូនក្តី អៀង សារី ក្នុងបន្ទប់សវនាការនេះគឺជា “ការសើចចំអក” មួយ ហើយថាដំណើរការនីតិវិធីរបស់តុលាការគឺគ្រាន់តែជាការ “បោកបញ្ឆោតមួយ និងជាតុលាការសម្តែងល្ខោន” តែប៉ុណ្ណោះ ។ អៀង សារី ជាអតីតរដ្ឋមន្ត្រីក្រសួងការបរទេសនៃរបបកម្ពុជាប្រជាធិបតេយ្យបានស្នើសុំចូលរួមតាមដានដំណើរការនីតិវិធីពីបន្ទប់ឃុំឃាំងដោយសារតែបញ្ហាសុខភាព ។ ចៅក្រមបានបដិសេធការស្នើសុំនេះដោយទទួលស្គាល់ហេតុផលរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីដែលថាវត្តមានរបស់ជនជាប់ចោទគឺជាខ្លឹមសារដ៏សំខាន់សម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីទាំង ៣,៨៦៦រូបដែលត្រូវបានទទួលស្គាល់លើកដំបូងបង្អស់ក្នុងប្រវត្តិសាស្ត្រឲ្យចូលរួមក្នុងដំណើរការនីតិវិធីរបស់តុលាការអន្តរជាតិនេះ ។ យ៉ាងណាមិញ លោក ម៉ៃឃើល កាណាវ៉ាស់ មេធាវីការពារក្តី អៀង សារី យល់ឃើញថា សិទ្ធិក្នុងការទទួលបានការកាត់ទោសដោយយុត្តិធម៌របស់ជនជាប់ចោទត្រូវបានរំលោភបំពាន ។ ប៉ុន្តែ មេធាវីដើមបណ្តឹងរដ្ឋប្បវេណីក៏បានអះអាងថា យ៉ាងហោចណាស់វត្តមានរបស់ជនជាប់ចោទអាចនឹងបំពេញបំណងរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការទាមទារឲ្យមានការទទួលស្គាល់ចំពោះទុក្ខវេទនាដែលអ្នកទាំងអស់នេះបានរងគ្រោះនៅក្នុងអំឡុងរបបខ្មែរក្រហម ។ ជាមួយគ្នានេះ សាលក្រមសំណុំរឿង០០១កាត់ទោសប្រធានមន្ទីរ ស-២១(គុកទួលស្លែង) បានគូសបញ្ជាក់រួចទៅហើយថា ក្តីសង្ឃឹមទទួលបានសំណងដ៏មានន័យពីតុលាការគឺជារឿងខកចិត្តមួយ ដូច្នេះ



ទិដ្ឋភាពនៅក្នុងបន្ទប់សវនាការ (រូបថត : អ.វ.ត.ក)

ដំណើរការនីតិវិធីនេះត្រូវបានចាត់ទុកជាប្រយោជន៍មួយដែលសាធារណជនទាំងអស់អាចទទួលបានការយល់ដឹងពីឧក្រិដ្ឋកម្មរបស់ជនជាប់ចោទហើយអាចនឹងជួយដល់ការតស៊ូប្រឈមមុខនឹងអតីតកាលរបស់ប្រជាជនកម្ពុជាដែលរួចរស់រានមានជីវិតពីរបបខ្មែរក្រហមនេះ ។ លើសពីនេះ ដំណើរការនីតិវិធីនេះក៏បានជំរុញឲ្យមានការស្វែងយល់ពីជនជាប់ចោទដែរ ។ សំណុំរឿង០០២នេះធ្វើការចោទប្រកាន់ជនជាប់ចោទ អៀង សារី, នួន ជា និង ខៀវ សំផន ដែលជាប្រមុខរដ្ឋនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ ព្រះរាជអាជ្ញាបាននិយាយនៅក្នុងដីការបឋមកាលពីសប្តាហ៍មុនថាជនជាប់ចោទ

ទាំងនេះគឺជា «ចោរនិងឃាតករសម្លាប់ប្រជាជនកម្ពុជាគ្រប់ជំនាន់» ។ ជនរងគ្រោះសង្ឃឹមថា ជនជាប់ចោទទាំងបីនឹងធ្វើការសុំខមាលទោសជាសាធារណៈ ។ ជាចុងក្រោយ ជនរងគ្រោះចង់បានចម្លើយពីជនជាប់ចោទដែលយើងដឹងថាជនជាប់ចោទទាំងនេះអាចនឹងមិនផ្តល់ចម្លើយដែលអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមចង់បាន ។

ជនជាប់ចោទទាំងបីរូបមានវត្តមាននៅក្នុងអង្គសវនាការ ប៉ុន្តែរាល់ការឆ្លើយតបរបស់ជនជាប់ចោទទាំងនេះមិនបានផ្តល់ព័ត៌មានអ្វីជាជាងការបដិសេធ និងទំនងជាចរចាទៅលើឧក្រិដ្ឋកម្មដ៏ឃោរឃៅទាំងអស់នោះដែលព្រះរាជអាជ្ញាបានរៀបរាប់នៅក្នុងដីកាបឋមឡើយ ។ ដោយសារតែទទួលបានព្រះរាជទានទោស និងការលើកលែងទោសពីបទចោទប្រកាន់របស់តុលាការប្រជាជនកាលពីខែសីហា ឆ្នាំ១៩៧៩ អៀង សារី ទទូចនិយាយថា រាល់ការកាត់ទោសមកលើគាត់នឹងត្រូវធ្លាក់ចូលក្នុងករណីគ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ ។ នៅពេលធ្វើសេចក្តីថ្លែងការណ៍ អៀង សារី បានស្នើសុំមានវត្តមានក្នុងដំណើរការនីតិវិធីរហូតដល់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាចេញសេចក្តីសម្រេចចុងក្រោយលើបណ្តឹងសាទុក្ខរបស់ក្រុមមេធាវីការពារក្តីខ្លួនទាក់ទងនឹងការកាត់ទោសពីរដងចំពោះបទល្មើសតែមួយនេះ ។ អៀង សារី បានប្រកាសថាគាត់នឹងមិនផ្តល់សក្ខីកម្មណាមួយឡើយលុះត្រាតែបញ្ហាខាងលើនេះត្រូវបានដោះស្រាយ ។ ដូចគ្នាដែរ នួន ជា បានធ្វើឲ្យអង្គជំនុំជម្រះក្តីនេះកាន់តែយ៉ាប់យ៉ឺនដោយនិយាយថា គាត់នឹងមិនចូលរួមក្នុងដំណើរសវនាការទេលុះត្រាតែអង្គសវនាការស្តីពីអង្គហេតុចាប់ផ្តើមដំណើរការនៅថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០១១ ។ ចៅក្រមបានសួរថា តើ នួន ជា នឹងធ្វើសក្ខីកម្មដែរឬយ៉ាងណា ។ ជាការឆ្លើយតប ក្រុមមេធាវីការពារក្តីរបស់ នួន ជា បានអះអាងថា «នួន ជា នឹងធ្វើសក្ខីកម្ម បើគាត់សម្រេចចិត្តដូច្នោះ» ។ សូម្បីតែ ខៀវ សំផន ជាអ្នកអះអាងមុនគេថានឹងសហការជាមួយនឹងតុលាការក៏បានដកខ្លួន និងទទូចថានឹងសម្រេចថាតើត្រូវធ្វើសក្ខីកម្មឆ្លើយតបនឹងការចោទប្រកាន់របស់ព្រះរាជអាជ្ញាដោយផ្អែកទៅតាមករណីអង្គហេតុនីមួយៗ ។ ជាការពិត ខៀវ សំផន បានឆ្លើយតបនឹងកំណត់ហេតុរបស់ព្រះរាជអាជ្ញាយ៉ាងល្អដោយធ្វើការទទួលស្គាល់ការចោទប្រកាន់របស់ព្រះរាជអាជ្ញាផងនិងចង្អុលបង្ហាញចំណុចខ្សោយនៃកំណត់ហេតុនោះផង ។ ខៀវ សំផន អះអាងថា តំណែងជាប្រមុខរដ្ឋនៃរបបកម្ពុជាប្រជាធិបតេយ្យមិនមានអំណាចក្នុងការចេញសេចក្តីសម្រេចណាមួយឡើយ ។ ប្រសិនបើ ខៀវ សំផន មានអំណាចនយោបាយណាមួយក្នុងរបបខ្មែរក្រហមមែននោះ ខៀវ សំផន បានសួរព្រះរាជអាជ្ញា «ចុះហេតុអ្វីមិននាំសម្តេច សីហនុ មកកាត់ទោសដែរទៅ?» តាមពិត ខៀវ សំផន បានក្លាយជាប្រមុខរដ្ឋក្រោយពេលដែល សម្តេច សីហនុ បានលាលែងពីតំណែងនេះកាលពីខែមេសា ឆ្នាំ១៩៧៦ ។ ដោយបានចង្អុលបង្ហាញពីភាពមិនស៊ីសង្វាក់គ្នាក្នុងកំណត់ហេតុបឋមរបស់ព្រះរាជអាជ្ញា និងដោយមានការសង្ស័យលើភាពដែលអាចជឿទុកចិត្តបាននៃកំណត់ហេតុរបស់អ្នកសារព័ត៌មានដែលត្រូវបានយកមកធ្វើជាភ័ស្តុតាង ខៀវ សំផន បានសួរទៅកាន់ព្រះរាជអាជ្ញាថា ៖ «តើលោកព្រះរាជអាជ្ញាពិតជាជឿជាក់លើអ្វីដែលខ្ញុំបាននិយាយដែរឬទេ?» សម្រាប់ ខៀវ សំផន កំណត់ហេតុទាំងនោះគឺ ប្រៀបបីដូចជា «រឿងប្រលោមលោក» ទៅវិញទេ ។ អង្គនីតិវិធីតាមផ្លូវច្បាប់របស់តុលាការអន្តរជាតិដ៏សំខាន់នេះប្រាកដជាមានលក្ខណៈពិសេសមួយចំនួនដូចជា ៖ ទាំងរឿងរ៉ាវរបស់ជនរងគ្រោះ និងជនដៃដល់ត្រូវបានលាតត្រដាង ។ រឿងរ៉ាវទាំងនោះ ត្រូវបានពិនិត្យផ្ទៀងផ្ទាត់និងកែសម្រួលហើយគុណភាព និងភាពស៊ីសង្វាក់គ្នានៃការចងចាំទាំងអស់ត្រូវបានចរចាសារជាថ្មីនៅក្នុងដំណើរការនីតិវិធីមួយនេះ ។ ជារឿយៗ ការពិភាក្សាក្នុងបន្ទប់សវនាការនេះទំនងជាធ្វើឲ្យល្អមើលតែប៉ុណ្ណោះ ។ ក្នុងបទសម្ភាសន៍ជាមួយនឹងការសែតភ្នំពេញប៉ុស្តិ៍ លោក គ្រីស្តូហ្វី ដី.ម័រ ជាមេធាវីផង និងជាអ្នកនិពន្ធរឿងប្រលោមលោកផង បាននិយាយថា សាលាក្តីខ្មែរក្រហមអាចផ្តល់មូលដ្ឋានដ៏ប្រសើរមួយសម្រាប់រឿងរ៉ាវឧក្រិដ្ឋកម្មមួយនេះ ។ បន្ថែមលើនោះ យើងអាចនិយាយបានថាតុលាការនេះអាចនឹងបំពេញកិច្ចការរបស់ខ្លួនដូចក្នុងសាច់រឿងល្ខោនក៏ថាបាន ។ អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនិងជាសកម្មជននយោបាយម្នាក់នៅទីក្រុងភ្នំពេញបានប្រកាសក្នុងសេចក្តីថ្លែងការណ៍របស់គាត់ថា គាត់ «ឆ្អែតឆ្អន់នឹងការសម្តែងរបស់តុលាការដែលមើលទៅដូចជាល្ខោននយោបាយនេះណាស់» និងបានដកសិទ្ធិមិនចូលរួមធ្វើជាដើមបណ្តឹងរដ្ឋប្បវេណី

ម្នាក់ក្នុងអង្គជំនុំជម្រះក្តីនេះដែរ ។ ដើម្បីបញ្ជាក់ឲ្យច្បាស់ សកម្មជននយោបាយរូបនេះបាននិយាយសំដៅទៅលើបញ្ហាដែលកើតឡើងដដែលៗ ដូចជាការជ្រៀតជ្រែកផ្នែកបញ្ហានយោបាយ និងការបោះបង់ចោលសំណុំរឿង០០៣ និង០០៤ របស់សាលាក្តីខ្មែរក្រហម ។ លើសពីនេះ ការអះអាងរបស់គាត់អាចឆ្លុះបញ្ចាំងឲ្យឃើញពីទស្សនៈដ៏សំខាន់មួយទាក់ទងនឹងសាលាក្តីខ្មែរក្រហម និងដំណើរការនីតិវិធីផ្លូវច្បាប់ "ក្នុងបទដ្ឋានអន្តរជាតិ" ក្នុងន័យទូទៅមួយគឺ ៖ ការបំពេញកិច្ចការក្នុងលក្ខណៈបែបល្ខោននេះដែលអាចនឹងជះឥទ្ធិពលមកលើជោគជ័យ ឬការបរាជ័យរបស់តុលាការ ។ ដោយសារតែមានការរំពឹងទុកដ៏ធំធេងនៃតួនាទីរបស់តុលាការនេះ បានពង្រីកបទបញ្ញត្តិរបស់ខ្លួនឲ្យហួសពីយុត្តិធម៌តាមផ្លូវច្បាប់ទៅទៀត ។ អ្នកខ្លះអាចសង្ឃឹមថា សាលាក្តីខ្មែរក្រហមនឹងជំរុញឲ្យមានការផ្សះផ្សាជាតិហើយចំណែកអ្នកខ្លះទៀតអាចចាត់ទុកសាលាក្តីខ្មែរក្រហម ជាតុលាការគំរូមួយដើម្បីពង្រឹងច្បាប់ក្នុងសង្គមកម្ពុជា ។ អស់រយៈពេលជាច្រើនឆ្នាំកន្លងមកនេះក្រុមសង្គមស៊ីវិលបានសន្យាជាមួយនឹងអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមថា ដំណើរការកាត់ទោសរបស់តុលាការនាពេលបច្ចុប្បន្ននេះអាចនឹងជួយឲ្យអ្នកទាំងអស់នេះប្រឈមមុខនឹងអតីតកាលរបស់ខ្លួនបាន និងជួយដល់ការផ្សះផ្សាផ្នែកសតិអារម្មណ៍ដែរ ។ មុននឹងសាលាក្តីខ្មែរក្រហមត្រូវបានបង្កើតឡើងដោយកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរដ្ឋាភិបាលកម្ពុជា គោលគំនិតបង្កើតគណៈកម្មាការស្វែងរកការពិតក៏ត្រូវបានលើកយកមកពិភាក្សាដែរ ។ ការគ្មានឧបសគ្គផ្នែកច្បាប់អាចនឹងជួយសម្រួលដល់ការពិភាក្សាសាឡើងវិញពីអតីតកាលកម្ពុជា ។ ផ្ទុយទៅវិញ ដោយសារតែត្រូវបានកំណត់ដោយគោលការណ៍ច្បាប់ជាក់លាក់មួយ សាលាក្តីខ្មែរក្រហមនេះពឹងផ្អែកទៅលើការបែងចែកជនជាប់ចោទជាពីរប្រភេទគឺ "មេដឹកនាំជាន់ខ្ពស់" និង "ជនទាំងឡាយដែលមានការទទួលខុសត្រូវខ្ពស់បំផុត" សម្រាប់ឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងក្នុងអំឡុងរបបខ្មែរក្រហម ដោយមិនបានអើពើចំពោះបរិបទប្រវត្តិសាស្ត្រនៃសង្គ្រាមស៊ីវិលកាលពីបីទសវត្សរ៍មុននិងចំពោះបញ្ហាដែលថា ការបែងចែកឲ្យដាច់ពីគ្នារវាងជនរងគ្រោះ និងជនដៃដល់នៅតែមិនទាន់ច្បាស់លាស់នៅឡើយក្នុងសង្គមកម្ពុជា ។ បន្ថែមលើនេះ ដែនយុត្តាធិការរបស់តុលាការបានរារាំងដល់ការពិភាក្សាដ៏មានន័យពីអតីតកាលរបស់កម្ពុជាហើយវាទំនងជាថាបន្ទប់សវនាការនេះត្រូវបានគិតទៀនថាជាឆាកល្ខោនដែលការងាររដដែលបានកើតឡើងម្តងហើយម្តងទៀត ។ តុលាការនេះគឺជាល្ខោនមួយដែលគ្មានប្រយោជន៍ដល់ដំណោះស្រាយបញ្ហាអតីតកាលឡើយ ។

ការចាត់ទុកសាលាក្តីខ្មែរក្រហមថាជាល្ខោនមិនមែនជាអ្វីដែលប្រឌិតឡើងនោះទេ ។ ដូចយើងឃើញច្បាស់ បន្ទប់សវនាការត្រូវបានសាងសង់ឡើងដូចជារោងល្ខោនដែលមានកៅអីសម្រាប់អ្នកទស្សនាចំនួន៥០០កៅអី ហើយរៀងរាល់ព្រឹកអ្នកតាមដានទស្សនាបានមករង់ចាំមុខសាលសវនាការដើម្បីចាំមើលវាំងននល្ខោនបើក ។ នៅពេលដែលវាំងននល្ខោនត្រូវបានបើកហើយល្ខោនក៏ចាប់ផ្តើម ហើយតួសម្តែងនីមួយៗនៅក្នុងបន្ទប់សវនាការទាំងអស់គ្នាក៏បានដឹងថាការសម្តែងរបស់គេត្រូវបានពិនិត្យយ៉ាងយកចិត្តទុកដាក់បំផុតដោយអ្នកតាមដានទស្សនានៅសាលខាងក្រៅបន្ទប់សវនាការ និងដោយដៃគូរបស់ខ្លួន ។ អ្នកតាមដានទស្សនារួមមានអ្នកតំណាងសារព័ត៌មាន អ្នកសង្កេតការណ៍របស់តុលាការដើមបណ្តឹងរដ្ឋប្បវេណីដែលទទួលបានកៅអីសម្រាប់តាមដានដំណើរការរបស់តុលាការក្នុងបន្ទប់សវនាការមានកំណត់ដោយសារតែចំនួនដើមបណ្តឹងរដ្ឋប្បវេណីច្រើនពេក និងសាធារណជនទូទៅ ។ ជារៀងរាល់ថ្ងៃ យើងឃើញមានឡានដឹកជញ្ជូនសិស្ស ព្រះសង្ឃនិងអ្នកភូមិមកពីគ្រប់ខេត្តក្រុងឲ្យអញ្ជើញមកតាមដានដំណើរការរបស់តុលាការក្រោមការរៀបចំឡើងដោយអង្គការក្រៅរដ្ឋាភិបាល និងសាលាក្តីខ្មែរក្រហម ។ ទាំងព្រះរាជអាជ្ញា និងមេធាវីការពារក្តីបានដឹងយ៉ាងច្បាស់ថា ខ្លួនត្រូវតែទាមទារការចាប់អារម្មណ៍ពីអ្នកតាមដានឲ្យបានច្រើន ប៉ុន្តែព្រះរាជអាជ្ញា និងមេធាវីការពារក្តីក៏បានដឹងថាអ្នកតាមដានទាំងអស់នេះមិនសូវយល់ពីអំណះអំណាងតាមផ្លូវច្បាប់ប៉ុន្មានទេ ។ ជាក់ស្តែងសេចក្តីសន្និដ្ឋានបឋមរបស់ព្រះរាជអាជ្ញាក៏បានឆ្លុះបញ្ចាំងឲ្យឃើញយ៉ាងច្បាស់ពីការទាមទារការចាប់អារម្មណ៍ពីសំណាក់អ្នកតាមដានដំណើរការរបស់តុលាការ ។ ឧទាហរណ៍អស់រយៈពេលមួយថ្ងៃព្រះរាជអាជ្ញាបានរៀបរាប់យ៉ាងរស់រវើកពីអំពើសាហាវឃោរឃៅនៃឧក្រិដ្ឋកម្មក្នុងរបបខ្មែរក្រហមដោយបានបង្ហាញជារូបថត និងខ្សែវីឌីអូ ជាជាងលើកឡើងអំណះអំណាង

តាមផ្លូវច្បាប់ដើម្បីទាមទារការចាប់អារម្មណ៍ពីអ្នកតាមដាន ។ ជាពិសេស ការឆ្លើយតបរបស់ នួន ជា និង ខៀវ សំផន ក៏ត្រូវបានធ្វើឡើងក្នុងន័យទាមទារភាពអាណិតអាសូរពី “ប្រជាជនរបស់ខ្លួន” ដោយរៀបរាប់ពីជីវិតតស៊ូក្នុងនាមជាអ្នកស្នេហាជាតិដែលហ៊ានលះបង់ដើម្បីរំដោះប្រទេសជាតិរបស់ខ្លួនពីការឈ្លានពានពីពួកចក្រពត្តិអាមេរិក និងពួកវៀតណាមប្រតិកិរិយា ។ គួរឲ្យចាប់អារម្មណ៍ការសម្តែងការគោរពដល់អ្នកតាមដានដំណើរការរបស់តុលាការបានក្លាយជារឿងធម្មតារបស់ភាគីទាំងអស់ដែលមានវត្តមានក្នុងបន្ទប់សវនាការ ។ ឧទាហរណ៍ ជារឿយៗ ខៀវ សំផន តែងតែគោរពដល់ព្រះសង្ឃជាច្រើនអង្គដែលតែងតែមានវត្តមានអង្គុយលើកៅអីពីរបីជួរខាងមុខនៅក្នុងសាលសវនាការ ។ ជាញឹកញាប់ ទាំងព្រះរាជអាជ្ញា និងមេធាវីការពារក្តីបានងាកមុខចេញពីចៅក្រម ហើយបែរមកនិយាយទៅកាន់អ្នកតាមដានទស្សនាផ្ទាល់ក្នុងអំឡុងពេលតស៊ូមតិ ។ មានម្តងនោះអ្នកតាមដានដំណើរការរបស់តុលាការនៅក្នុងសាលសវនាការបានទះដៃនៅពេលដែលចៅក្រមបានបដិសេធការស្នើសុំរបស់ អៀង សារី ដោយសុំតាមដានដំណើរការនីតិវិធីរបស់តុលាការពីមន្ទីរឃុំឃាំង ។ តើតុលាការនេះពិតជាតុលាការ “ប្រឌិត” និង “តុលាការល្ខោន” ដូចមតិខ្លះរិះគន់មែនដែរឬទេ? ជាក់ស្តែងតុលាការនេះគឺខុសគ្នាពីតុលាការរបស់របបសាធារណរដ្ឋប្រជាមានិតដែលត្រូវបានបង្កើតឡើងនៅខែសីហា ឆ្នាំ១៩៧៩ ដោយបានកាត់ទោសប្រហារជីវិត ប៉ុល ពត និង អៀង សារី ទាំងគ្មានវត្តមានរបស់ជនជាប់ចោទទាំងពីរនេះក្រោយពេលដែលអង្គជំនុំជម្រះក្តីនេះដំណើរការបានត្រឹមតែពីរបីថ្ងៃ ។ យ៉ាងណាមិញ អង្គជំនុំជម្រះក្តីមេដឹកនាំខ្មែរក្រហមរួមទាំងដំណើរការនីតិវិធីរបស់តុលាការអន្តរជាតិផ្សេងទៀតគឺពិតជាខុសគ្នាពីដំណើរការនីតិវិធីច្បាប់ទូទៅ ។ ប៉ុន្មានឆ្នាំកន្លងមកនេះអ្នកជំនាញខាងច្បាប់បានវិភាគលើបញ្ហាដែនយុត្តាធិការតូចៗរបស់តុលាការអន្តរជាតិដូចជាសាលាក្តីខ្មែរក្រហមជាដើម ហើយចំណែកឯអ្នកវិទ្យាសាស្ត្រនយោបាយក៏បានចោទសួរពីភាពមិនលម្អៀង និងការជ្រៀតជ្រែកផ្នែកនយោបាយរបស់តុលាការ ។ ដើម្បីស្វែងយល់ពីឥទ្ធិពលដែលតុលាការអន្តរជាតិទាំងអស់នេះមានមកលើសង្គម និងប្រទេសជាតិនីមួយៗវាដល់ពេលដែលយើងត្រូវតែពង្រីកវិសាលភាពនៃការវិភាគលើនិមិត្តរូប និងការអនុវត្តរបស់ច្បាប់អន្តរជាតិ ។ សរុបមក បើទោះបីយើងមិនពេញចិត្តក៏ដោយ ក៏យើងត្រូវដឹងថាដំណើរការនីតិវិធីរបស់តុលាការទាំងអស់នេះដែលរួមទាំងសាលាក្តីខ្មែរក្រហមមិនបានដោះបញ្ហាយុត្តិធម៌ និងការទទួលខុសត្រូវតាមផ្លូវច្បាប់ឲ្យបានពេញលេញនោះទេ ។ ជាញឹកញាប់ តុលាការទាំងអស់នេះបែរជាធ្វើការចរចា និងបង្កើតសារជាថ្មីនិងកែប្រែប្រវត្តិសាស្ត្រទៅវិញទេ ។ លើសពីនេះ តុលាការទាំងនេះត្រូវបានរំពឹងថានឹងបំពេញតម្រូវការផ្នែកចិត្តសាស្ត្រ និងសតិអារម្មណ៍ដល់ជនអ្នករស់រានមានជីវិតតែប៉ុណ្ណោះ ។

ដោយឡែក ថេត សម្បត្តិ អ្នកសារព័ត៌មាន និងជាជនរងគ្រោះពីរបបខ្មែរក្រហមបានសម្ភាសន៍ នួន ជា អស់រយៈពេលជាច្រើនឆ្នាំមុនពេលដែល នួន ជា ត្រូវបានឃុំខ្លួននៅសាលាក្តីខ្មែរក្រហម ។ នៅក្នុងភាពយន្តឯកសាររបស់លោក ថេត សម្បត្តិ ដែលមានចំណងជើងថា “សត្រូវរបស់ប្រជាជន” បងធំទី២ របស់ខ្មែរក្រហមដែលត្រូវបានស្គាល់ថាជា នួន ជា បានរំឭកពីមូលហេតុអាថ៌កំបាំងមួយចំនួននៅពីក្រោយរបបដ៏សម្ងាត់របស់ខ្លួនច្រើនជាងអ្វីដែល នួន ជា អាចធ្វើសក្ខីកម្មនៅឯសាលាក្តីខ្មែរក្រហម ។ ថេត សម្បត្តិ ក៏បានរក្សាទុកបទសម្ភាសន៍ដែលមានរយៈពេលរាប់រយម៉ោងជាមួយនឹង នួន ជា ដែលមិនត្រូវបានបញ្ចូលក្នុងភាពយន្តឯកសាររបស់គាត់ហើយតុលាការមិនអាចយកបទសម្ភាសន៍នេះមកប្រើប្រាស់បានទេ ពីព្រោះ ថេត សម្បត្តិ បានសន្យាជាមួយនឹង នួន ជា ថានឹងរក្សាបទសម្ភាសន៍ដើម្បីទុកជាឯកសារស្រាវជ្រាវដល់ក្មេងជំនាន់ក្រោយដោយមិនត្រូវផ្សព្វផ្សាយបទសម្ភាសន៍នេះនៅក្នុងអំឡុងពេលដែល នួន ជា នៅរស់រានមានជីវិតឡើយ ។ ក្នុងស្មារតីនេះ យើងអាចចាត់ទុកបទសម្ភាសន៍ដ៏វែងរបស់ ថេត សម្បត្តិ ជាមួយ នួន ជា ថាជាគណៈកម្មការស្វែងរកពិតតូចមួយបាន ។ យើងអាចមានក្តីសង្ឃឹមតូចមួយថា អតីតកម្មាភិបាលថ្នាក់ក្រោមខ្មែរក្រហម ជនរងគ្រោះ និងជនដែលជាអតីតកម្មាភិបាលខ្មែរក្រហមផង និងជនរងគ្រោះផងអាចនឹងចាប់ផ្តើមនិយាយពីការពិតរបស់ខ្លួន ។ វាអាចទៅរួចដែលថា គណៈកម្មការស្វែងរកការពិតអាចនឹងបំពេញតម្រូវការដល់សង្គមកម្ពុជាច្រើនជាងសាលាក្តីខ្មែរក្រហម ។

**គ្រីស្សៀន អូស្ទីហែដ**

# ការពិនិត្យមើលសារឡើងវិញលើការចរចារឆ្ពោះទៅរកការបង្កើតយុត្តាធិការបុគ្គលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

***(តពីលេខមុន)***

នៅថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ១៩៩៩ នាយករដ្ឋមន្ត្រី ហ៊ុន សែន បានធ្វើដំណើរទៅកាន់ទីក្រុងញូយ៉កដើម្បីចូលរួមអង្គសន្និបាតរបស់អង្គការសហប្រជាជាតិ ហើយក៏បានជួបជាមួយនឹងលោក កូហ្វី អាណាន់ ។ នាយករដ្ឋមន្ត្រីបានអានសារលិខិតមួយដែលយកធ្វើជាមូលដ្ឋាននៃការចរចានេះដោយអះអាងថា ការជួបពិភាក្សាគ្នារវាងអង្គការសហប្រជាជាតិជាមួយនឹងរាជរដ្ឋាភិបាលកម្ពុជាមុននេះបានឈានទៅរក "ការព្រមព្រៀងគ្នាជាទូទៅមួយក្នុងការនាំយកមេដឹកនាំខ្មែរក្រហមជាជនដែលបង្កការបំផ្លិចបំផ្លាញធ្ងន់ធ្ងរ និងការសម្លាប់រង្គាលមកកាត់ទោស" ។ ប៉ុន្តែនាយករដ្ឋមន្ត្រីមិនបានរៀបរាប់ឲ្យបានលម្អិតជាងនេះទេ ។ នាយករដ្ឋមន្ត្រី ហ៊ុន សែន បាននិយាយទៅកាន់លោកអគ្គលេខាធិការអង្គការសហប្រជាជាតិថា ៖ រដ្ឋាភិបាលកម្ពុជាបានប្រឹងប្រែងបានសម្រេចក្នុងការកាត់ផ្តាច់មេដឹកនាំខ្មែរក្រហមដែលនៅរស់ ហើយក៏បានជំរុញឲ្យទាហានខ្មែរក្រហមចុះចាញ់រួចចុះចូលជាមួយរដ្ឋាភិបាល ។ យ៉ាងណាមិញ ខ្មែរក្រហមដែលចុះចាញ់ទាំងអស់នេះមិនមែនសបញ្ជាក់ឲ្យឃើញថា ជនទាំងអស់នេះមិនអាចត្រូវបានចោទប្រកាន់នោះទេ ។

ប៉ុន្តែនាយករដ្ឋមន្ត្រី ហ៊ុន សែន មិនបានចាត់តាំងឲ្យរដ្ឋាភិបាលខ្លួនចាប់ខ្លួនមេដឹកនាំខ្មែរក្រហមក្រៅពីមេដឹកនាំខ្មែរក្រហមដែលនៅជាប់ឃុំប៉ុន្មាននាក់ប៉ុណ្ណោះ ហើយបើទោះបីជាឧបនាយករដ្ឋមន្ត្រី សុខ អាន បានជម្រាបអង្គការសហប្រជាជាតិនៅក្នុងអង្គសន្និបាតកាលពីថ្ងៃទី២០ ខែកញ្ញា ថា រាជរដ្ឋាភិបាលកម្ពុជា "មិនមានបំណងកាត់ទោសតែមេដឹកនាំប៉ុណ្ណោះទេ" ក៏ដោយ ក៏អង្គការសហប្រជាជាតិនៅតែខ្លាចថា រាជរដ្ឋាភិបាលកម្ពុជាអាចនឹងប្រែក្រឡាស់គោលជំហររបស់ខ្លួនលើ "ដំណើរការកាត់ទោសនេះ នៅពេលដែលជនត្រូវចោទប្រាំនាក់នោះត្រូវបានចៅក្រមសម្រេចចោទប្រកាន់" ។ អង្គការសហប្រជាជាតិជឿថាស្ថានភាពអាចនឹងប្រែប្រួលខុសពីការស្មាន លុះត្រាតែកិច្ចព្រមព្រៀង និងការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាលកម្ពុជាត្រូវបានទទួលស្គាល់ដោយសាលាក្តីខ្មែរក្រហមជាមួយអង្គការសហប្រជាជាតិ និងការគាំទ្រពីសហគមន៍អន្តរជាតិថា សម្តេច ហ៊ុន សែន មិនអាចដើរចេញពីដំណើរការកាត់ទោសនេះពាក់កណ្តាលទីបានទេ ។ ឃ្លាចុងក្រោយរបស់អង្គការសហប្រជាជាតិគឺថា "ការចរចាដែលមានរយៈពេលពីរថ្ងៃជាមួយនឹងរដ្ឋាភិបាលកម្ពុជា នៅក្នុងដំណាក់កាលកម្រិត និងទម្រង់បែបបទខុសៗគ្នា បានបរាជ័យក្នុងការទាញយកការយល់ឃើញជាទូទៅដូចគ្នាមួយទាក់ទងនឹងបញ្ហាតុលាការ និងទំហំនៃយុត្តាធិការផ្នែកបុគ្គល" ដោយយល់ឃើញថារាជរដ្ឋាភិបាលកម្ពុជាមិនបានបង្ហាញការខំប្រឹងប្រែងពិតប្រាកដដើម្បីបង្កើតតុលាការឯករាជ្យមួយដែលនឹងអាចចាប់ខ្លួនមេដឹកនាំខ្មែរក្រហមដែលត្រូវចោទប្រកាន់ទាំងអស់ឡើយ ។

ស្របពេលជាមួយគ្នានោះ សហរដ្ឋអាមេរិកនៅតែចូលរួមយ៉ាងសកម្មដដែល នៅក្នុងដំណើរការចរចាររវាងរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ ។ នៅចុងខែកញ្ញា ឆ្នាំ១៩៩៩ លោកឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិក ខេន វ៉ាយដឺម៉ាន់ បានជួបជាមួយនឹងក្រុមការងារដែលដឹកនាំដោយឧបនាយករដ្ឋមន្ត្រី សុខ អាន ហើយបាននិយាយថា លោកបានដឹងថា រដ្ឋាភិបាលកម្ពុជាបានព្រួយបារម្ភថា "នៅក្នុងការស្នើរបស់អង្គការសហប្រជាជាតិ យុត្តាធិការផ្នែកបុគ្គលរបស់តុលាការអាចនឹងមានលក្ខណៈស្រដៀងគ្នានឹងយុត្តាធិការរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី និងរ៉ូវ៉ាន់ដា ដែលថា អាចមានជនជាប់ចោទច្រើនត្រូវបានចោទប្រកាន់" ។ ដើម្បីបន្ធូរបន្ថយភាពភ័យខ្លាចរបស់រាជរដ្ឋាភិបាលកម្ពុជានៅក្នុងដំណាក់កាលនៃការចរចានេះ លោកឯកអគ្គរដ្ឋទូតបានណែនាំថា តុលាការ "អាចដាក់កម្រិតលើយុត្តាធិការ

របស់ខ្លួនបានដោយធ្វើការកាត់ទោសតែមេដឹកនាំជាន់ខ្ពស់ចំនួនប្រាំមួយទៅប្រាំពីរនាក់ ដែលមានការទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ឧក្រិដ្ឋកម្មសង្គ្រាម អំពើប្រល័យពូជសាសន៍ ដែលភាគច្រើនសមាជិករបស់គណៈកម្មាធិការអចិន្ត្រៃយ៍នៃបក្សកុម្មុយនីស្តកម្ពុជា ។ នៅដើមខែតុលា លោក ថូម៉ាស់ ហាំម៉ាប៊ឺក បានអនុវត្តវិធីសាស្ត្រស្រដៀងគ្នានឹងយុត្តិសាស្ត្ររបស់នាយករដ្ឋមន្ត្រី ហ៊ុន សែន។ បើទោះបីជាបានជ្រោមជ្រែងដើម្បីធានាថាគ្មានការជ្រៀតជ្រែកផ្នែកនយោបាយនៅក្នុងតុលាការដើម្បីឲ្យតុលាការនេះដំណើរការទៅមុខដោយឯករាជ្យក៏ដោយក៏លោក ថូម៉ាស់ ហាំម៉ាប៊ឺក បានលើកឡើងមតិយោបល់មួយថាច្បាប់បង្កើតតុលាការអាចបញ្ជាក់យ៉ាងច្បាស់ថាចំនួនជនត្រូវចោទមួយចំនួនតូចប៉ុណ្ណោះនឹងត្រូវបានកាត់ទោស ដែលជនទាំងនោះគឺជា «សមាជិកគណៈកម្មាធិការមជ្ឈិមនិងជនដែលមានការទទួលខុសត្រូវសម្រាប់ឧក្រិដ្ឋកម្មធ្ងន់ធ្ងរ» ដើម្បីរឹតត្បិតការកាត់ទោសតែមេដឹកនាំជាន់ខ្ពស់បំផុតដែលក្នុងនោះរួមមាន ឌុច ។


ឆាំង យុ (ឆ្វេង) លោកស្រីម៉ារី រ៉ូប៊ីនសាន់ (អតីតអ្នកតំណាងឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស) និងលោក ថូម៉ាស់ ហាំម៉ាប៊ឺក (ស្តាំ) ពេលទស្សនាសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង

យ៉ាងណាមិញ ការិយាល័យកិច្ចការច្បាប់មិនបានគាំទ្រគំនិតរបស់លោក ថូម៉ាស់ ហាំម៉ាប៊ឺក ដោយសន្មតថា នៅតែគ្មាន «ការយល់ឃើញស្របគ្នាមួយ» ស្តីពី «ទំហំនៃយុត្តាធិការផ្នែកបុគ្គល»របស់តុលាការ ដូច្នេះការស្នើសុំរបស់លោក វ៉ាយដឺម៉ាន់មិនបានឆ្លុះបញ្ចាំងឲ្យបានពេញលេញពីគោលជំហររបស់រដ្ឋាភិបាលសហរដ្ឋអាមេរិកទេ ។ ឯកសារ «មិនមានគោលជំហរ» របស់សហរដ្ឋអាមេរិកនៅខែតុលា ឆ្នាំ១៩៩៩ បានអះអាងថាច្បាប់គ្រប់គ្រងតុលាការ «អាចអនុញ្ញាតឲ្យមានការស៊ើបអង្កេតលើក្រុមជនសង្ស័យតូចមួយសំដៅទៅលើមេដឹកនាំខ្មែរក្រហមជាន់ខ្ពស់និងជនដែលមានការទទួលខុសត្រូវខ្ពស់សម្រាប់ឧក្រិដ្ឋកម្មសាហាវកម្រិតធ្ងន់ ប៉ុន្តែច្បាប់នេះក៏បានចែងថា រាជរដ្ឋាភិបាលកម្ពុជា «គួរតែត្រូវបានជំរុញឲ្យកែប្រែចំនួនជនសង្ស័យដែលមានក្នុងបញ្ជីដើម្បីបង្កើតឲ្យមានការកាត់ទោសកាន់តែច្រើនដែលអាចថា កាត់ទោសជនសង្ស័យចំនួនម្ភៃនាក់ ។ ជាក់ស្តែង តុលាការមិនអាចបន្តធ្វើការស៊ើបអង្កេតច្រើនសម្រាប់ការកាត់ទោសទេ ប៉ុន្តែតុលាការគួរតែមានសិទ្ធិអំណាចក្នុងការស៊ើបអង្កេតច្រើនបែបនេះប្រសិនបើតុលាការមានភស្តុតាងគ្រប់គ្រាន់ដើម្បីចោទប្រកាន់» ។

នៅខែវិច្ឆិកា ឆ្នាំ១៩៩៩ មហាសន្និបាតរបស់អង្គការសហប្រជាជាតិបានចាប់ផ្តើមពិចារណាលើកិច្ចព្រមព្រៀងថ្មីមួយ ជាមួយប្រទេសកម្ពុជាដោយផ្អែកលើសេចក្តីព្រាងមួយដែលធ្លាប់បានគាំទ្រគោលជំហរនិងភាសាប្រើប្រាស់របស់អ្នកស្រាវជ្រាវជំនាញដោយសំណូមពរឲ្យរាជរដ្ឋាភិបាលកម្ពុជា«ធានាថាជនដែលមានការទទួលខុសត្រូវខ្ពស់បំផុតចំពោះការរំលោភបំពានធ្ងន់ធ្ងរលើសិទ្ធិមនុស្សត្រូវបាននាំមកកាត់ទោស» ។ បើទោះបីជានៅខែធ្នូ គណៈកម្មាធិការលើកទីបីរបស់មហាសន្និបាតអង្គការសហប្រជាជាតិបានពិនិត្យឡើងវិញលើសេចក្តីព្រាងច្បាប់នេះដើម្បីនាំយក «មេដឹកនាំខ្មែរក្រហមដែលមានការទទួលខុសត្រូវខ្ពស់ចំពោះការរំលោភបំពានធ្ងន់ធ្ងរបំផុតលើសិទ្ធិមនុស្ស» មកកាត់ទោសហើយភាសាប្រើប្រាស់ត្រូវបានកែប្រែឡើងវិញនៅក្នុងកិច្ចព្រមព្រៀងចុងក្រោយដោយអនុម័តតាមមហាសន្និបាតពេញអង្គ ។

ជាមួយគ្នានោះ នៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៩ លោកអគ្គរាជទូតកម្ពុជាប្រចាំនៅអង្គការសហប្រជាជាតិត្រូវបានបង្ហាញ

អត្ថបទបកប្រែព្រាងមួយនៃសេចក្តីព្រាងច្បាប់របស់រាជរដ្ឋាភិបាលកម្ពុជា ។ នៅក្នុងអត្ថបទបកប្រែនោះ មាត្រា១នៃច្បាប់ចែងថា រាជរដ្ឋាភិបាលកម្ពុជាមានគោលបំណង «នាំយកមេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយណាដែលមានការទទួលខុសត្រូវចំពោះការរំលោភបំពានធ្ងន់ធ្ងរលើច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ច្បាប់ និងទំនៀមទម្លាប់អន្តរជាតិ អនុសញ្ញាអន្តរជាតិ ដែលត្រូវបានប្រព្រឹត្តឡើងនៅចន្លោះថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ រហូតដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ ។ នេះគឺជាអនុស្សរណៈដែលឲ្យជានិយមន័យនៃសមាសធាតុរបស់តុលាការជាន់គ្នានឹងមាត្រា២ ។ អត្ថបទបកប្រែរបស់ស្ថានទូតអាមេរិកបានបកប្រែយុត្តាធិការផ្នែកបុគ្គលជាពីរគឺៈ «មេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ និងជនដែលមានការទទួលខុសត្រូវខ្ពស់ចំពោះការរំលោភបំពានធ្ងន់ធ្ងរ» ។ ប៉ុន្មានសប្តាហ៍ក្រោយមក រាជរដ្ឋាភិបាលកម្ពុជាបានកែប្រែផ្នែកជាច្រើននៃសេចក្តីព្រាងច្បាប់បង្កើតតុលាការខ្មែរក្រហមដោយបង្ហាញខ្លឹមសារចេញពីការបកប្រែជាភាសាអង់គ្លេសនៃ «សេចក្តីព្រាងចុងក្រោយ» នៃច្បាប់បង្កើតតុលាការខ្មែរក្រហមដោយដាក់ជូនអង្គការសហប្រជាជាតិនៅថ្ងៃទី១៨ ខែមករា ឆ្នាំ២០០០ ។ ភាសាដែលប្រើប្រាស់នៅក្នុងអត្ថបទបកប្រែនេះដែលស្តីពីយុត្តាធិការផ្នែកបុគ្គលត្រូវបានកែសម្រួលបន្តិចបន្តួចដែលមានខ្លឹមសារថា «មេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ និងជនដែលមានការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មនិងការរំលោភបំពានធ្ងន់ធ្ងរលើច្បាប់ព្រហ្មទណ្ឌកម្ពុជា ច្បាប់ទំនៀមទម្លាប់អន្តរជាតិ និងអនុសញ្ញាអន្តរជាតិដែលត្រូវបានទទួលស្គាល់ដោយកម្ពុជា ប៉ុន្តែអង្គការសហប្រជាជាតិបានចាត់ទុកការកែប្រែនេះថាគ្មានសារៈសំខាន់ ។ អង្គការសហប្រជាជាតិទំនងជាពេញចិត្តនឹងអនុស្សរណៈនេះដែលបានចែងយុត្តាធិការផ្នែកបុគ្គលដែលខ្លួនចង់បានដូចដែលបានឃើញនៅក្នុង «ឯកសារ» របស់អង្គការសហប្រជាជាតិដែលគ្មានការរិះគន់លើការប្រើប្រាស់ភាសានៃសេចក្តីព្រាងរបស់រាជរដ្ឋាភិបាលកម្ពុជាចុះថ្ងៃទី៥ ខែមករា ឆ្នាំ២០០០ ។ យ៉ាងណាមិញ អង្គការសហប្រជាជាតិនៅតែព្រួយបារម្ភយ៉ាងខ្លាំងថា យុត្តាធិការអាចនឹងមិនត្រូវបានយកទៅអនុវត្ត ។ អង្គការសហប្រជាជាតិកាន់តែមានការព្រួយបារម្ភយ៉ាងខ្លាំងដោយសារតែសម្តេច ហ៊ុន សែន បានថ្លែងកាលពីថ្ងៃទី២២ ខែធ្នូ ឆ្នាំ១៩៩៩ ថា មានតែ «មេដឹកនាំខ្មែរក្រហមបួនទៅប្រាំនាក់ប៉ុណ្ណោះនឹងត្រូវនាំមកកាត់ទោស» ។ បើទោះបីជា នាយករដ្ឋមន្ត្រី ហ៊ុន សែន បាន បដិសេធមិនបង្ហាញអត្តសញ្ញាណរបស់មេដឹកនាំទាំងអស់នោះក៏ដោយ ក៏គាត់បាននិយាយថា នាពេលនេះមេដឹកនាំចំនួនពីរនាក់កំពុងតែជាប់ឃុំឃាំងសំដៅទៅលើ តាម៉ុក និង ឌុច ហើយគាត់ក៏បានរៀបរាប់ពីស្ថានភាពរបស់មេដឹកនាំមួយចំនួនទៀតសំដៅទៅលើ នួន ជា, ខៀវ សំផន, និង អៀង សារី បើទោះបីជា អៀង សារី ទទួលបានព្រះរាជទានទោសពីការចោទប្រកាន់មកលើខ្លួនក៏ដោយ ។ លោក ថូម៉ាស់ ហាំម៉ាប៊ឹក បាននិយាយថា សេចក្តីថ្លែងសុន្ទរកថារបស់នាយករដ្ឋមន្ត្រី ហ៊ុន សែន មានលក្ខណៈដូចគ្នានឹងការប្រកាសឈ្មោះជនត្រូវចោទទុកជាមុនដែរ ។ លោកក៏បានចាត់ទុកសេចក្តីថ្លែងការណ៍ចុងក្រោយមិនហុចប្រយោជន៍អ្វីទេចំពោះការនិយាយដែលថា នាយករដ្ឋមន្ត្រីហ៊ុន សែន គួរតែត្រូវបានដកចេញពីការកាត់ទោសនោះ ។

ឯកសាររបស់អង្គការសហប្រជាជាតិចុះថ្ងៃទី៥ ខែមករា ឆ្នាំ២០០០ បានឆ្លើយតប ដោយទទូចថា «បទដ្ឋានសមធម៌និងយុត្តិធម៌អន្តរជាតិធានាថាដំណើរការកាត់ទោសរបស់តុលាការនឹងមិនមានកម្រិតទេ ដូច្នេះគោលការណ៍ស្តីពីការទទួលខុសត្រូវនឹងទាមទារឲ្យមានការបកស្រាយឲ្យបានច្បាស់» ។ ដោយធ្វើការបកស្រាយលើគោលការណ៍ខាងលើអង្គការសហប្រជាជាតិបានដកស្រង់សេចក្តីថ្លែងរបស់លោកអគ្គលេខាធិការអង្គការសហប្រជាជាតិ កូហ្វី អាណាន់ ដែលនិយាយថា យុត្តិធម៌ និងការទទួលខុសត្រូវទាមទារឲ្យមានការដាក់ទណ្ឌកម្មទៅលើ «មេដឹកនាំនយោបាយទាំងអស់» នៃរបបខ្មែរក្រហម ។ នៅក្នុងកិច្ចពិភាក្សាជាមួយនឹងសហរដ្ឋអាមេរិក ជប៉ុន និងបារាំងកាលពីខែមករា ឆ្នាំ២០០០ អង្គការសហប្រជាជាតិ បានសង្កត់ធ្ងន់ថា «តម្រូវការដ៏សំខាន់ដែលអង្គការសហប្រជាជាតិបានជំរុញឲ្យដើរតាមនោះគឺផ្តោតទៅលើការទាមទារឲ្យមានការធានាពីរដ្ឋាភិបាលកម្ពុជាថាជនត្រូវចោទទាំងអស់ដែលរស់នៅក្នុងទឹកដីកម្ពុជាត្រូវតែបានចាប់ខ្លួនហើយចូលខ្លួនឲ្យតុលាការកាត់ទោស» ។ បើទោះបីជាបញ្ញត្តិបែបនេះមានចែងនៅក្នុងសេចក្តីព្រាងច្បាប់បង្កើតតុលាការខ្មែរ

ក្រហមក៏ដោយ ក៏អង្គការសហប្រជាជាតិចង់បាន "ការធានានេះត្រូវបានយកទៅអនុវត្ត" ។ ដូច្នេះការទាមទារសំខាន់ជាងគេគឺការធានាឲ្យមានការចាប់ខ្លួន "មេដឹកនាំខ្មែរក្រហមទាំងឡាយណាដែលត្រូវបានរដ្ឋាភិបាលកម្ពុជាការពារ" ។

នៅក្នុងអង្គប្រជុំគណៈរដ្ឋមន្ត្រីកាលពីថ្ងៃទី៦ ខែមករា ឆ្នាំ២០០០ នាយករដ្ឋមន្ត្រី ហ៊ុន សែន បានទទួលស្គាល់ថាសម្តេចបានប្រព្រឹត្តកំហុសមួយដោយប្រកាសថាមានតែមេដឹកនាំតែបួនទៅប្រាំនាក់តែប៉ុណ្ណោះដែលត្រូវបានកាត់ទោសដោយជម្រាបដល់រដ្ឋមន្ត្រីទាំងអស់ថា "ខ្ញុំមិនគួរនិយាយអ្វីដែលទាក់ទងជាមួយនឹងប្រព័ន្ធច្បាប់ទេ" ។ ការផ្តល់បទសម្ភាសន៍ក្នុងសន្និសីទកាសែតកាលពីថ្ងៃ០៧ ខែមករា នាយករដ្ឋមន្ត្រី ហ៊ុន សែន បាននិយាយថាជនទាំងឡាយណាដែលបានអះអាងពីចំនួនមេដឹកនាំខ្មែរក្រហមដែលត្រូវកាត់ទោស "គឺសុទ្ធតែខុសរួមទាំងអ្នកស្រាវជ្រាវជំនាញច្បាប់របស់អង្គការសហប្រជាជាតិដែលនិយាយថា មេដឹកនាំប្រមាណម្ភៃទៅសាមសិបនាក់នឹងត្រូវបានកាត់ទោស" ដោយបន្ថែមទៀតថា "យើងរំលោភលើច្បាប់របស់តុលាការ" ប្រសិនបើយើងប្រកាសពីចំនួនមេដឹកនាំដែលត្រូវនាំមកកាត់ទោស" ។ សហរដ្ឋអាមេរិកបានអះអាងនៅក្នុងអង្គប្រជុំជាមួយនឹងអង្គការសហប្រជាជាតិកាលពីខែមករា ឆ្នាំ២០០០ថា សហរដ្ឋអាមេរិកគាំទ្រគំនិតយោបល់របស់អ្នកស្រាវជ្រាវជំនាញរបស់អង្គការសហប្រជាជាតិ ដែលថា តុលាការគួរតែកាត់ទោសមេដឹកនាំខ្មែរក្រហមប្រមាណម្ភៃទៅសាមសិបនាក់ ហើយក៏បានសង្ឃឹមថា ការកាត់ទោសមេដឹកនាំខ្មែរក្រហមចំនួនច្រើនបែបនេះនឹងកើតមានឡើងដោយសង្កត់ធ្ងន់ថា "សហរដ្ឋអាមេរិកនឹងផ្តល់ជាជំនួយ ហើយនឹងដាក់សម្ពាធផ្នែកនយោបាយលើគ្រប់ដំណាក់កាលទាំងអស់របស់តុលាការកាត់ទោសខ្មែរក្រហមដើម្បីធានាឲ្យមានការចាប់ខ្លួននិងនាំយក" ជនសង្ស័យទាំងអស់មកកាត់ទោស ។ ប៉ុន្តែអង្គការសហប្រជាជាតិនៅតែមានការព្រួយបារម្ភថាតុលាការនេះអាចនឹងបញ្ចប់ត្រឹមតែ "ដំណើរការឲ្យមានការកាត់ទោសលើជនត្រូវចោទផ្នែកនយោបាយមួយចំនួនតូចប៉ុណ្ណោះ" នោះមានន័យថា តុលាការអាចនឹងដើរតាមគោលការណ៍របស់គណបក្សនយោបាយប្រជាជនកម្ពុជាដែលទាមទារឲ្យមានការកាត់ទោសតែ "អតីតមេដឹកនាំគោលនយោបាយរបស់របបប្រល័យពូជសាសន៍ខ្មែរក្រហម" ដោយគ្មានការកាត់ទោសជនសង្ស័យផ្សេងទៀតឡើយ ។

ជាមួយគ្នានោះ អង្គការសហប្រជាជាតិនៅតែមានការព្រួយបារម្ភដដែល ។ ដូច្នេះ នៅក្នុងអង្គប្រជុំថ្មីរវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ កាលពីខែមីនា ឆ្នាំ២០០០ អង្គការសហប្រជាជាតិបានណែនាំរាជរដ្ឋាភិបាលកម្ពុជាថា បើនិយាយថា ផ្លូវច្បាប់ឃ្លាដែលថា "ជនទាំងឡាយណាដែលមានការទទួលខុសត្រូវខ្ពស់ចំពោះឧក្រិដ្ឋកម្ម និងការរំលោភបំពានធ្ងន់ធ្ងរនេះមានន័យមិនច្បាស់លាស់ ហើយមានខ្លឹមសារហួសពីអ្វីដែលអង្គការសហប្រជាជាតិបានស្នើឡើងដោយមានការគូសបញ្ជាក់ពីការពង្រីកយុត្តាធិការផ្នែកបុគ្គលដោយដាក់បញ្ចូលទាំងខ្មែរក្រហមថ្នាក់ទាប ។ នៅក្នុងអង្គប្រជុំនេះ អគ្គលេខាធិការអង្គការសហប្រជាជាតិ និងលោក ហាន់ កូរ៉ែល ប្រធានការិយាល័យកិច្ចការច្បាប់របស់អង្គការសហប្រជាជាតិបានបង្ហាញពីក្តីព្រួយបារម្ភដែលថា យន្តការនេះ "អាចមានលក្ខណៈធំទូលាយពេកក្នុងការផ្ទុះបញ្ចាំងឲ្យឃើញពីគោលគំនិតដែលខ្ញុំដឹងថា រដ្ឋាភិបាលកម្ពុជាមានគោលគំនិតធ្វើអ្វី" ។ ក្រោយពីការជួបប្រជុំជាផ្លូវការត្រូវបានបញ្ចប់ ហើយមន្ត្រីក្រុមការងាររបស់លោក ឱម យិនទៀង បានមកជួបសំណេះសំណាលជាមួយនឹងលោកប្រធាន កូរ៉ែល នៅព្រលានយន្តហោះ ហើយអ្នកទាំងពីរ បានយល់ឃើញថា "ឲ្យតែមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមត្រូវបានកាត់ទោស នោះអ្វីៗនឹងគ្មានបញ្ហាឡើយ" ដែលលោក ឱម យិនទៀង "បានចាត់ទុកមេដឹកនាំថាជាជនដែលមានការទទួលខុសត្រូវខ្ពស់ចំពោះឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងអំឡុងរបបខ្មែរក្រហម" ។ លោកប្រធាន កូរ៉ែល បានគូសបញ្ជាក់ថា "នេះគឺជាលក្ខណៈវិនិច្ឆ័យបែបនេះដែលមិនមានចែងនៅក្នុងសេចក្តីព្រាងច្បាប់ដូចដែលបានរៀបរៀងឡើងពេលបច្ចុប្បន្ននេះទេ" ដោយបកស្រាយថាអត្ថបទនៃសេចក្តីព្រាងច្បាប់នាពេលបច្ចុប្បន្នរាប់បញ្ចូលទាំងជនទាំងឡាយណាដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មនៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ។ បន្ទាប់ពីទទួលបានសារលិខិតពីឧបនាយករដ្ឋមន្ត្រី សុខ អាន លោកប្រធានការិយាល័យកិច្ចការច្បាប់របស់អង្គការសហប្រជាជាតិ ហាន់ កូរ៉ែល បានសរសេរថា តើនេះពិតជាគោលបំណង

របស់រាជរដ្ឋាភិបាលកម្ពុជាមែនឬ?

សហចៅក្រមស៊ើបអង្កេត និងសហព្រះរាជអាជ្ញាត្រូវតែមានអាណត្តិច្បាស់លាស់ ។ ក្នុងការប្រព្រឹត្តទៅតាមអាណត្តិដែលមានវិសាលភាពធំដូចដែលមានចែងនៅក្នុងមាត្រា១ នោះអាចនឹងធ្វើឲ្យសហចៅក្រមស៊ើបអង្កេត និងសហព្រះរាជអាជ្ញាទទួលរងនូវការរិះគន់ លុះត្រាតែភាគីទាំងពីរនេះបញ្ឈប់ដំណើរការសំណុំរឿងធំៗដែលអាចស្ថិតនៅក្រោមបទបញ្ញត្តិរបស់តុលាការ ។ សម្តីរបស់លោក ឌិម យិនទៀង នៅព្រលានយន្តហោះជំរុញឲ្យខ្ញុំជឿថា គំនិតរបស់រាជរដ្ឋាភិបាលគឺធ្វើយ៉ាងណាកុំឲ្យវិសាលភាពនៃច្បាប់មានជាប់ពាក់ព័ន្ធនឹងសេចក្តីព្រាងច្បាប់ ។ ខ្ញុំយល់ឃើញថា នេះគឺជាបញ្ហាផ្ទៃក្នុងរបស់កម្ពុជា ។ គាត់បានសុំឲ្យលោកឧបនាយករដ្ឋមន្ត្រី សុខ អាន "ពិនិត្យមើលមាត្រា១នៃសេចក្តីព្រាងច្បាប់ម្តងទៀត ហើយត្រឡប់មកពិភាក្សាជាមួយនឹងអង្គការសហប្រជាជាតិវិញពីការរៀបចំកំណែទម្រង់ ។ បញ្ហានេះត្រូវបានដោះស្រាយសារជាថ្មីម្តងទៀតនៅក្នុងការវិភាគរបស់អង្គការសហប្រជាជាតិលើ សេចក្តីព្រាងច្បាប់កម្ពុជាដែលធ្វើឡើងកាលពីថ្ងៃទី២៨ ខែមីនា ឆ្នាំ២០០០ ។ អង្គការសហប្រជាជាតិ បាននិយាយថាយោងតាមមាត្រា១ យុត្តាធិការផ្នែកបុគ្គលមិនបានឆ្លុះបញ្ចាំងពីគោលគំនិតដែលថា កម្ពុជាមានផ្នែកចូលរួមនៅក្នុងការកំណត់វិសាលភាពនៃយុត្តាធិការ ។ ការបកស្រាយលើឃ្លាដែលថា តុលាការត្រូវកាត់ទោសមេដឹកនាំខ្មែរក្រហមជនខ្ពស់ពិតជាត្រឹមត្រូវ ប៉ុន្តែខ្លឹមសារដែលសំដៅទៅលើជនទាំងឡាយណាដែលមានការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្ម និងការរំលោភបំពានសិទ្ធិមនុស្សធ្ងន់ធ្ងរ មានន័យទូលំទូលាយ ពេកដែលយុត្តាធិការនេះរាប់បញ្ចូលទាំងជនទាំងឡាយណាដែលមានជាប់ពាក់ព័ន្ធ ។ យើងឆ្ងល់ថា នេះគឺកើតឡើងដោយមានចេតនា ។ លក្ខណៈវិនិច្ឆ័យខ្លះមានសារៈសំខាន់ ។ នៅក្នុងដំណាក់កាលនេះ អង្គការសហប្រជាជាតិបានពិចារណាថានឹងបង្រួមយុត្តាធិការផ្នែកបុគ្គលឲ្យមានខ្លឹមសារដូចគ្នានឹងការណែនាំរបស់លោក វ៉ាយដឺម៉ាន់ ឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិក និងលោកថូម៉ាស់ ហាំម៉ាប៊ឺក អ្នកតំណាងពិសេសរបស់លោក កូហ្វី អាណាន់ ។ លទ្ធភាពក្នុងការបង្រួមយុត្តាធិការនេះត្រូវបានលាតត្រដាងនៅក្នុងការវិភាគដែលថា ដោយសារតែការប្រើប្រាស់ភាសា និងដោយសារតួនាទី និងមុខតំណែងពិសេសរបស់គេ នោះជនដែលទទួលខុសត្រូវខ្ពស់ចំពោះឧក្រិដ្ឋកម្ម និងការរំលោភបំពានធ្ងន់ធ្ងរគួរតែត្រូវបាននាំមកកាត់ទោស ។ ករណីនេះពិតជាកើតឡើងសម្រាប់ ឌុច ប៉ុន្តែ វាមិនទាន់ច្បាស់ថា តើមានជនណាខ្លះក្រៅពី ឌុច ដែលតុលាការអាចធ្វើការកាត់ទោសបាន បើទោះបីជាឃ្លានេះបានបញ្ជាក់ពីចំនួនមនុស្សច្រើនដែលតុលាការអាចធ្វើការកាត់ទោសបាន ។

បន្ទាប់មកទៀត នៅក្នុងអង្គប្រជុំជាបន្តបន្ទាប់ជាមួយនឹង



ហាន កូរីល ប្រធានការិយាល័យកិច្ចការច្បាប់របស់អង្គការសហប្រជាជាតិ និងឧបនា

ឧបនាយករដ្ឋមន្ត្រី សុខ អាន និង លោក ឌិម យិនទៀង នៅចុងខែមីនា និងដើមខែមេសា លោកអគ្គរដ្ឋទូតសហរដ្ឋអាមេរិកទទួលបន្ទុកកិច្ចឧក្រិដ្ឋកម្មសង្គ្រាម ដេវីដ ស្ហេហ្វ័រ បានគូសបញ្ជាក់ម្តងទៀតនៃខ្លឹមសាររបស់មាត្រា១ដែលត្រូវបានស្នើឡើងដោយអង្គការសហប្រជាជាតិ ហើយលោកឧបនាយករដ្ឋមន្ត្រីសុខ អានទំនងជាយល់ស្របនឹងការកែប្រែឃ្លាឃ្លោងនៃមាត្រានេះ ។ សហរដ្ឋអាមេរិកបានដាក់សេចក្តីព្រាងច្បាប់បង្កើតតុលាការកាត់ទោសខ្មែរក្រហម

ដែលត្រូវបានកែលម្អនោះក្នុងអង្គប្រជុំជាមួយនឹងអង្គការសហប្រជាជាតិដោយកំណត់វិសាលភាពនៃយុត្តាធិការផ្នែកបុគ្គលឲ្យនៅតូចដដែល ។ គោលបំណងនៃច្បាប់នេះគឺដើម្បីនាំយកមេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយណាដែលទទួលខុសត្រូវខ្ពស់បំផុតសម្រាប់ឧក្រិដ្ឋកម្ម និងការរំលោភបំពានធ្ងន់ធ្ងរដោយសារតែតួនាទីនិងមុខតំណែងពិសេសរបស់ជនទាំងនោះនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។


យករដ្ឋមន្ត្រី សុខ អាន

យ៉ាងណាមិញ ជាការឆ្លើយតបនឹងការថ្លែងរបស់នាយករដ្ឋមន្ត្រី ហ៊ុន សែន ដែលធ្វើឡើងកាលពីថ្ងៃទី១៩ ខែមេសា លោក កូហ្វី អាណាន់ បានងាកមកពិភាក្សាឲ្យបានទូលំទូលាយលើឃ្លាដែលចែងនៅក្នុងយុត្តាធិការផ្នែកបុគ្គលថា កាត់ទោសជនដែលមានការទទួលខុសត្រូវខ្ពស់ចំពោះឧក្រិដ្ឋកម្មធ្ងន់ធ្ងរដែលត្រូវបានប្រព្រឹត្តឡើងដោយគូសបញ្ជាក់ថា វាគឺជាការចាំបាច់ក្នុងការកំណត់និយមន័យនៃឃ្លា នេះដែលមានចែងនៅក្នុងវិសាលភាពរបស់យុត្តាធិការផ្នែកបុគ្គលនេះឲ្យបានច្បាស់លាស់ ជាជាងឃ្លាដែលចែងនៅក្នុងសេចក្តីព្រាងច្បាប់របស់រាជរដ្ឋាភិបាលកម្ពុជា ។ នាយករដ្ឋមន្ត្រី ហ៊ុន សែន បានឆ្លើយតបទៅវិញនៅថ្ងៃទី២២ ខែមេសា ដោយកែប្រែឃ្លានោះទៅជានាំយកមេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យមកកាត់ទោស ។ យ៉ាងណាមិញ នៅក្នុងអនុស្សរណៈថ្មីរបស់គណៈកម្មាធិការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិបានប្រកាន់គោលជំហររបស់ខ្លួនក្នុងការធានាថា ជនដែលមានការទទួលខុសត្រូវខ្ពស់សម្រាប់ការរំលោភបំពានធ្ងន់ធ្ងរបំផុតលើសិទ្ធិមនុស្សត្រូវបាននាំមកកាត់ទោស ។ ស្របពេលជាមួយគ្នានោះនៅក្នុង ការជួបប្រជុំជាមួយនឹងនាយករដ្ឋមន្ត្រី ហ៊ុន សែន នៅចុងខែមេសា ព្រឹទ្ធសមាជិករបស់សហរដ្ឋអាមេរិក ចន ឃែរី បានចោទសួរទៅនាយករដ្ឋមន្ត្រី ហ៊ុន សែន ម្តងហើយម្តងទៀតថា តើនាយករដ្ឋមន្ត្រីយល់ព្រមនឹងការកែប្រែមាត្រា១ នេះដែរឬទេ ប៉ុន្តែនាយករដ្ឋមន្ត្រី ហ៊ុន សែន បានឆ្លើយតបថា គាត់មិនយល់ស្របនឹងការកែប្រែនេះទេក្នុងអំឡុងពេលនេះ ។ ដូច្នេះ លោក ចន ឃែរី បានងាកទៅរកការកែប្រែក្នុងន័យទូលំទូលាយមួយដែលចែងថា សហរដ្ឋអាមេរិកបានគាំទ្រចំពោះការកាត់ទោសមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមនិងជនដែលមានការទទួលខុសត្រូវខ្ពស់សម្រាប់អំពើសាហាវយោរយៅនៃរបបខ្មែរក្រហមនេះ ។ ការិយាល័យកិច្ចការឧក្រិដ្ឋកម្មសង្គ្រាមរបស់ស្ថាប័នរដ្ឋសហរដ្ឋអាមេរិកបានគូសបញ្ជាក់លើការអះអាងរបស់លោក ចន ឃែរី ដោយបញ្ជាក់ថា គោលជំហររបស់សហរដ្ឋអាមេរិកគឺធ្វើការស៊ើបអង្កេត និងកាត់ទោសមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមក្នុងអំឡុងឆ្នាំ១៩៧៥-១៩៧៩ នឹងនាំយកជនដែលមានការទទួលខុសត្រូវខ្ពស់ចំពោះអំពើសាហាវយោរយៅនៃរបបខ្មែរក្រហមមកកាត់ទោស ។ នៅថ្ងៃទី២៩ ខែមេសា អ្នកសារព័ត៌មានបានចោទសួរលោក ចន ឃែរី ថា តើខ្លឹមសារលម្អិតស្តីពីយុត្តាធិការផ្នែកបុគ្គលត្រូវបានយកមកពិភាក្សានិងព្រមព្រៀងហើយឬនៅ ។ អ្នកសារព័ត៌មានក៏បានធ្វើការគូសសម្គាល់ពីភាពចម្រូងចម្រាសដែលថា ភាគីមួយបានគាំទ្រ «ជំរុញឲ្យស្វែងរកដំណោះស្រាយដើម្បីពង្រីកយុត្តាធិការផ្នែកបុគ្គលនេះឲ្យធំ» ប៉ុន្តែភាគីម្ខាងទៀតគឺ «មេដឹកនាំនយោបាយរបស់គណបក្សប្រជាជនកម្ពុជា»

មានបំណងបង្រួមវិសាលភាពនៃយុត្តាធិការនេះដើម្បីចៀសវាង កុំឲ្យមាន "ការកាត់ទោសអ្នកនយោបាយ" ។ ព្រឹទ្ធសមាជិក ចន ឃែរី បានឆ្លើយតបថា "តាមពិតទៅវិសាលភាពរបស់តុលាការត្រូវបានកំណត់ច្បាស់លាស់ហើយ ។ តុលាការនឹងកាត់ទោសជនដែលមានការទទួលខុសត្រូវខ្ពស់សម្រាប់ឧក្រិដ្ឋកម្មធ្ងន់ធ្ងរ ដែលត្រូវបានប្រព្រឹត្តិទៅក្នុងអំឡុងឆ្នាំ១៩៧៥-១៩៧៩ ។ នេះហើយគឺជាវិសាលភាពរបស់តុលាការ ។ យើងក៏បានព្យាយាមពិភាក្សាដើម្បីកំណត់វិសាលភាពនេះឲ្យបានច្បាស់លាស់ដែរ ។ លោកឧបនាយករដ្ឋមន្ត្រី សុខ អាន និងលោកប្រធាន ហាន់ កូរ៉ែល នឹងពិភាក្សាពីបញ្ហានេះ និងបញ្ហាដែលនៅសេសសល់ផ្សេងទៀត" ។

នៅថ្ងៃបន្ទាប់ លោក ឃែរី បាននិយាយម្តងទៀតពីការកាត់ទោសជនដែលមានការទទួលខុសត្រូវខ្ពស់បំផុតសម្រាប់ឧក្រិដ្ឋកម្មធ្ងន់ធ្ងរ ។ ការចរចានៅខែកក្កដា ឆ្នាំ២០០០នៅទីក្រុងភ្នំពេញ និងសេចក្តីសម្រេចចុងក្រោយទោះបីជាប្រឈមនឹងភាពច្របូកច្របល់មិនចេះចប់មិនចេះហើយក៏ដោយ ក៏លោក ហាន់ កូរ៉ែល នៅតែប្តេជ្ញាទាមទារឲ្យមានការព្រមព្រៀងគ្នាលើនិយមន័យរបស់យុត្តាធិការផ្នែកបុគ្គលដែលមានចែងនៅក្នុងមាត្រា១ ដោយសារតែលោកបានដឹងពីគោលបំណងរបស់នាយករដ្ឋមន្ត្រី ហ៊ុន សែន ក្នុងការផ្លាស់ប្តូរគោលជំហររបស់សម្តេចទាក់ទងនឹងបញ្ហាយុត្តាធិការនេះ រួមទាំងបញ្ហាផ្សេងៗទៀត ។ ចាប់ពីខែឧសភា ឆ្នាំ ២០០០ ការកែប្រែលើឃ្លាដែលថាជនដែលមានការទទួលខុសត្រូវខ្ពស់ នៅក្នុងផ្នែកទីពីរនៃយុត្តាធិការផ្នែកបុគ្គលនេះចាប់ផ្តើមទទួលបានការយល់ស្របខ្លាំងពីអង្គការសហប្រជាជាតិ ។ សេចក្តីព្រាងដែលទទួលបានពីលទ្ធផលនៃការចរចារបស់អង្គការសហប្រជាជាតិជាមួយនឹងរាជរដ្ឋាភិបាលបានចែងថាយុត្តាធិការផ្នែកបុគ្គលពង្រីកការកាត់ទោសរបស់តុលាការលើមេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យនិងជនដែលមានការទទួលខុសត្រូវខ្ពស់ចំពោះឧក្រិដ្ឋកម្មដែលស្ថិតនៅក្រោមយុត្តាធិការរបស់តុលាការ ។ យ៉ាងណាមិញ នៅក្នុងសារលិខិតផ្ញើជូនលោក កូហ្វី អាណាន់ នៅថ្ងៃទី១៩ ខែឧសភា នាយករដ្ឋមន្ត្រី ហ៊ុន សែន បាននិយាយយ៉ាងម៉ឺងម៉ាត់ពីការកាត់ទោសមេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យនិងជនដែលមានការទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មធ្ងន់ធ្ងរ ។ នៅក្នុងសារលិខិតជូនលោកឧបនាយករដ្ឋមន្ត្រីសុខ អានកាលពីថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០០ លោក ហាន់ កូរ៉ែល បានសន្និដ្ឋានបញ្ចប់ការពិភាក្សារបស់លោកជាមួយនឹងលោកឧបនាយករដ្ឋមន្ត្រី សុខ អាន ដោយកំណត់យកវិសាលភាពនៃយុត្តាធិការផ្នែកបុគ្គលធ្វើជាប្រធានបទចម្បងសម្រាប់ការពិភាក្សារវាងអង្គការសហប្រជាជាតិជាមួយនឹងរាជរដ្ឋាភិបាលកម្ពុជាដែលរំពឹងថានឹងចាប់ផ្តើមនៅថ្ងៃទី៤ ខែកក្កដា ក្រោយពេលដែលទីប្រឹក្សាអ្នកនាំពាក្យរបស់រដ្ឋាភិបាលកម្ពុជាបានប្រកាសពីគោលបំណងនៃដំណើរទស្សនកិច្ចរបស់លោក ហាន់ កូរ៉ែល ដើម្បីពិភាក្សាពីបញ្ហាសំខាន់ៗទាក់ទងនឹងការបង្កើតតុលាការដើម្បីកាត់ទោសមេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ ។

បញ្ហាមុនគេដែលមានចុះនៅក្នុងរបៀបវារៈសម្រាប់ការពិភាក្សាចាប់ពីថ្ងៃទី៤-៧ ខែកក្កដាគឺ ៖ វិសាលភាពនៃយុត្តាធិការផ្នែកបុគ្គលដែលមានចែងនៅក្នុងមាត្រា១នៃសេចក្តីព្រាងច្បាប់និងក្នុងបទបញ្ញត្តិនៃសេចក្តីព្រាងរបស់អនុស្សរណៈនៃការយោគយល់រវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ។ ខណៈពេលដែលការពិភាក្សានេះដំណើរការទៅមុខរាជរដ្ឋាភិបាលកម្ពុជាទំនងជាព្រមព្រៀងថា សេចក្តីព្រាងច្បាប់មុននឹងរដ្ឋសភាជាតិសម្រេចពង្រីកយុត្តាធិការរបស់តុលាការធំពេក ។ នៅក្នុងការពិចារណាលើជម្រើសផ្សេងៗទាក់ទងនឹងការកែសម្រួលលើមាត្រា១ គណៈប្រតិភូអង្គការសហប្រជាជាតិបានគូសបញ្ជាក់ថា បញ្ហានេះគឺជាបញ្ហានយោបាយដែលអាជ្ញាធរកម្ពុជាត្រូវតែសម្រេច ។

នៅថ្ងៃទី៥ ខែកក្កដា អង្គការសហប្រជាជាតិបានដាក់សេចក្តីព្រាងស្តីពីឯកសារទាក់ទងនឹងមាត្រានៃកិច្ចសហប្រតិបត្តិការ និងអនុស្សរណៈយោគយល់រវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់ទោសតាមច្បាប់កម្ពុជាស្តីពីឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តឡើងនៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យលើតុពិភាក្សាហើយ នៅថ្ងៃដដែលនេះ អង្គការសហប្រជាជាតិបានកែប្រែឯកសារមុនៗនេះដែលចុះកាលពីថ្ងៃទី១៨ ខែមេសា ឆ្នាំ២០០០ ហើយក៏បានសម្រេចថា ការកែប្រែទាំងអស់ដែលធ្វើឡើងនៅក្នុងសេចក្តីព្រាងនេះ ត្រូវគូសសម្គាល់ដោយវង់ក្រចកហើយដាក់ជាអក្សរដិត" ។ មាត្រា៣ និងមាត្រា៥ នៃសេចក្តីព្រាងច្បាប់ថ្មី

របស់អង្គការសហប្រជាជាតិមានបញ្ចូលនូវឃ្លាមួយដែលមានន័យថា វិសាលភាពនៃការកាត់ទោសត្រូវបានកម្រិតមកត្រឹមតែការកាត់ទោសលើមេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យដែលមានឃ្លាបន្ទាប់ទៀតនិយាយថា ខ្លឹមសារបន្ថែមនៅក្នុងមាត្រា១នៃសេចក្តីព្រាងច្បាប់នឹងត្រូវដាក់បញ្ចូល ។ នៅថ្ងៃទី៥ ខែកក្កដា ដដែលនេះ អង្គការសហប្រជាជាតិបានផ្តល់សេចក្តីណែនាំចំនួនពីរទៅលើសេចក្តីព្រាងច្បាប់របស់រាជរដ្ឋាភិបាលកម្ពុជា ។ ក្នុងផ្នែកទីមួយនៃសេចក្តីព្រាងច្បាប់នោះ អង្គការសហប្រជាជាតិបានបង្ហាញគោលជំហរធម្មតាដោយណែនាំថា យុត្តាធិការផ្នែកបុគ្គលរបស់តុលាការគួរតែជាមេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ និងជនជាតិខ្មែរទាំងឡាយណាដែលមានការទទួលខុសត្រូវខ្ពស់ចំពោះឧក្រិដ្ឋកម្ម និងការរំលោភបំពានធ្ងន់ធ្ងរដោយសារតែតួនាទីនិងមុខតំណែងពិសេសរបស់ជនទាំងនោះ ។ ក្នុងផ្នែកទីពីរអង្គការសហប្រជាជាតិបានបង្ហាញគោលជំហរដាច់ខាតដោយប្រើឃ្លាថាយុត្តាធិការផ្នែកបុគ្គលរបស់តុលាការគួរតែជាមេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ និងជនដែលមានការទទួលខុសត្រូវខ្ពស់សម្រាប់ឧក្រិដ្ឋកម្ម និងការរំលោភបំពានធ្ងន់ធ្ងរ ។ ទាំងអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជាបានព្រមព្រៀងគ្នាសម្រេចយកផ្នែកទីពីរនៃសេចក្តីព្រាងច្បាប់ស្តីពីយុត្តាធិការផ្នែកបុគ្គលនៅថ្ងៃទី៦ ខែកក្កដា ។ យ៉ាងណាមិញ នៅថ្ងៃបន្ទាប់ ជម្រើសទាំងពីរដែលនិយាយពីវិសាលភាពនៃយុត្តាធិការនេះស្ថិតនៅក្នុងការពិចារណានៅឡើយទេ ។ នៅក្នុងសេចក្តីណែនាំថ្មីលើសេចក្តីព្រាងច្បាប់នេះ អង្គការសហប្រជាជាតិបានប្រើប្រាស់ឃ្លា មេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យនិងជនដែលមានការទទួលខុសត្រូវខ្ពស់សម្រាប់ឧក្រិដ្ឋកម្ម និងការរំលោភបំពានធ្ងន់ធ្ងរ ។ ខ្លឹមសារនៃសេចក្តីណែនាំនេះមានន័យដូចខាងក្រោម ៖

កំណត់ចំណាំ ៖ គណៈប្រតិភូរបស់អង្គការសហប្រជាជាតិបានបង្ហាញពីការព្រួយបារម្ភដែលថាសេចក្តីព្រាងនៃមាត្រា១ដែលដាក់នៅចំពោះមុខរដ្ឋសភាជាតិមានន័យទូលំទូលាយពេក ។ មាត្រានេះរាប់បញ្ចូលជនទាំងឡាយណាដែលធ្លាប់មានជាប់ពាក់ព័ន្ធនៅក្នុងសកម្មភាពឧក្រិដ្ឋរបស់ខ្មែរក្រហម ។ រដ្ឋាភិបាលកម្ពុជាមិនមានបំណងចង់បានការកាត់ទោសដែលមានលក្ខណៈធំទូលាយបែបនេះទេ ហើយអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាក៏មិនអាចកាត់ទោសសំណុំរឿងដែលមានកម្រិតធ្ងន់ធ្ងរ និងធំទូលាយបែបនេះដែរ ។ ដូច្នេះអង្គការសហប្រជាជាតិសូមបន្ថែមពាក្យ "បំផុត" ដើម្បីជាទិសដៅដើម្បីកំណត់វិសាលភាពនៃយុត្តាធិការផ្នែកបុគ្គលឲ្យបានសមហេតុផល ។ ប្រសិនបើមានដំណោះស្រាយផ្សេងទៀតដើម្បីជួយឲ្យយើងសម្រេចលទ្ធផលដូចគ្នាអង្គការសហប្រជាជាតិនឹងពិភាក្សាលើដំណោះស្រាយនោះ ។ ឆ្លើយតបទៅនឹងសំណូមពររបស់លោកឧបនាយករដ្ឋមន្ត្រី សុខ អាន គណៈប្រតិភូអង្គការសហប្រជាជាតិនឹងពិនិត្យមើលលើសំណើស្តីពីដំណោះស្រាយដែលរាជរដ្ឋាភិបាលកម្ពុជាដោយសង្កត់ធ្ងន់ថាការកែប្រែលើមាត្រានេះគឺជាសេចក្តីសម្រេចនយោបាយដែលត្រូវយកទៅពិភាក្សានៅកម្រិតថ្នាក់ជាតិ ។ យ៉ាងណាមិញ យើងត្រូវតែបញ្ជាក់ថាពាក្យពេចន៍ដែលប្រើប្រាស់នៅក្នុងបទបញ្ញត្តិត្រូវតែស្ថិតនៅក្នុងសមាសធាតុយល់ឃើញរបស់អង្គជំនុំជម្រះ ។ ជាមួយនឹងបទបញ្ញត្តិនេះយើងសូមស្នើឡើងនូវឃ្លាមួយថា ជនដែលយោរឃៅបំផុតនៃបទឧក្រិដ្ឋកម្មនិងការរំលោភបំពានធ្ងន់ធ្ងរ ។ល ។ ***(នៅមានត)***

**ស៊ីន ហេងឌី**

# ដំណឹងស្វែងរកញាតិ

នាងខ្ញុំឈ្មោះ លីម ភានុវណ្ណរង្សីសីហៈ រស់នៅសង្កាត់សន្សំកុសល្យ ខណ្ឌមានជ័យ ក្រុងភ្នំពេញ សូមប្រកាសរកពូឈ្មោះ ហាក់ អុល មកដល់បច្ចុប្បន្នមានអាយុ៧២ឆ្នាំ ។ កាលពីសម័យ លន់ នល់ ពូរបស់នាងខ្ញុំមានផ្ទះនៅទួលគោក ហើយគាត់ធ្វើជាប៉េអឹម ។ គាត់បានបែកពីគ្រួសារនៅម្តុំវត្តលង្កា ពេលដែលខ្មែរក្រហមជម្លៀសប្រជាជនចេញពីទីក្រុងឆ្នាំ១៩៧៥ ។ ចាប់តាំងពីពេលនោះមក គ្រួសារនាងខ្ញុំបាត់ដំណឹងគាត់រហូត ។

ប្រសិនបើ បងប្អូនណាបានដឹង ឬស្គាល់ឈ្មោះពូរបស់នាងខ្ញុំ សូមមេត្តាទាក់ទងមកនាងខ្ញុំតាមរយៈទូរស័ព្ទលេខ ៖ ០១៥ ៥៥៥ ០០៧ ឬមជ្ឈមណ្ឌលឯកសារកម្ពុជា អាសយដ្ឋានផ្ទះលេខ៦៦ ផ្លូវព្រះសីហនុ ខណ្ឌចំការមន ក្រុងភ្នំពេញ ឬទូរស័ព្ទលេខ៖ ០១២ ៩៩៦ ៧៥០ ។ សូមអរគុណ ។

# តើ ឌុច ជាឈើខ្ទឹម ឬឈើពុកសម្រាប់ នួន ជា?

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានបង្គាប់ឲ្យទណ្ឌិត កាំង ហ្កេចអ៊ាវ ហៅ ឌុច អតីតប្រធានមន្ទីរស-២១ មកធ្វើជាសាក្សីសម្រាប់សំណុំរឿង០០២ប្រឆាំងទៅនឹងអតីតមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម នួន ជា, អៀង សារី និងខៀវ សំផន។ នេះគឺជាករណីកម្រមួយក្នុងប្រព័ន្ធតុលាការកម្ពុជាបង្គាប់ឲ្យទណ្ឌិតដែលតុលាការបានសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិតមកធ្វើជាសាក្សី និងផ្តល់សក្ខីកម្មនៅក្នុងសវនាការ ។

ឌុច បានឡើងមកផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការទាក់ទងទៅនឹងរចនាសម្ព័ន្ធបក្សកុម្មុយនីស្តកម្ពុជា រដ្ឋបាល តួនាទី និងការទទួលខុសត្រូវរបស់មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា ។ នៅក្នុងសវនាការ ឌុច បានឆ្លើយតបនឹងសំណួរជាច្រើនដែលបានចោទសួរដោយសហព្រះរាជអាជ្ញានៅថ្ងៃដំបូង ។ នៅថ្ងៃបន្ទាប់នៃដំណើរការសវនាការ ឌុច បន្តឆ្លើយសំណួរពីសំណាក់ព្រះរាជអាជ្ញាដដែលស្របពេលជាមួយគ្នានោះ នួន ជា បានថ្លែងទៅកាន់អង្គសវនាការដោយប្រមាថ និងប្រៀបធៀប ឌុច ទៅនឹង «ឈើដែលពុកផុយ ឈើរលួយ ឈើស្អុយដែលគេយកមកឆ្លាក់ជាព្រះមកទេសនាឲ្យប្រជាជនស្តាប់» ។ ការលើកឡើងនូវពាក្យប្រមាថរបស់ នួន ជា នេះមិនមែនត្រឹមតែមាក់ងាយដល់សាក្សី ឌុច នោះទេ តែគឺជាការប្រមាថដល់អង្គជំនុំជម្រះទាំងមូល ។ នួន ជា គួរតែគិតទៅដល់កាលជាងសាមសិបឆ្នាំមុន ។ អ្នកដែល នួន ជា ប្រមាថថា ជាឈើពុក ឈើរលួយនៅពេលនេះ គឺជាជនបដិវត្តន៍ដ៏សកម្មម្នាក់សម្រាប់បក្សកុម្មុយនីស្តកម្ពុជា ហើយបក្សក៏បានផ្តល់នូវតួនាទីសំខាន់មួយសម្រាប់ ឌុច ក្នុងឋានៈជាប្រធានមន្ទីរសន្តិសុខដ៏សំខាន់របស់បក្សកុម្មុយនីស្តកម្ពុជា ។ ក្នុងនាទីជាប្រធានមន្ទីរសន្តិសុខ ស-២១ ឌុច បំពេញភារកិច្ចដែលបក្សដាក់ឲ្យយ៉ាងខ្ជាប់ខ្ជួន និងសកម្មបំផុត ។ ឌុច មិនដែលបដិសេធចំពោះភារកិច្ចដែលបក្សដាក់មកឲ្យនោះទេ ទោះជាអ្នកទោសដែលយកមក ស-២១ ជាបងប្អូន មិត្តភក្តិ ឬអតីតគ្រូរបស់ខ្លួនក៏ដោយឲ្យតែមានបញ្ជាពីបក្សត្រូវកម្ទេចគឺ ឌុច ត្រូវតែកម្ទេច ។ ដោយគោរពតួនាទីភារកិច្ច និងគោលការណ៍បក្ស ឌុច បានកាត់ផ្តាច់អស់មនោសញ្ចេតនា ។ តើនៅពេលនោះ ឌុច ជាឈើ ខ្លឹម ឬឈើស្អុយសម្រាប់ នួន ជា ក៏ដូចជាបក្សកុម្មុយនីស្តកម្ពុជា?


នួន ជា នៅក្នុងបន្ទប់សវនាការ (រូបថត ៖ អ.វ.ត.ក)

ប្រសិនបើ ឌុច ពិតជាឈើពុក ឈើរលួយ ឈើស្អុយដូច នួន ជា លើកឡើងនៅសវនាការមែននោះ ម៉្លេះ ឌុច ត្រូវបក្សកម្ទេចតាំងពីពេលនោះមកហើយ មិនមែនប្រគល់តួនាទីយ៉ាងសំខាន់ឲ្យនោះទេ ។ ពិតណាស់ ឌុច មិនមែនជាឈើខ្លឹមសម្រាប់ នួន ជា ទៀតទេ ព្រោះវត្តមាន ឌុច នៅចំពោះមុខអង្គសវនាការក្នុងឋានៈជាសាក្សី មិនមានផលប្រយោជន៍ណាមួយចំពោះ នួន ជា ទេ ។ នួន ជា ពិតជាមានការខ្វាចរអាលចំពោះវត្តមាននេះ ព្រោះសក្ខីកម្មរបស់ ឌុច អាចជាការដាក់បន្ទុកបន្ថែមមកលើខ្លួនក៏ដូចជាក្រុមរបស់ខ្លួន ។

**ធាន សារៈមុនិន្ទ**

# គំនិតនិងទស្សនៈរបស់និស្សិតចំពោះសក្ខីកម្មរបស់ ឌុច

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានសម្រេចបណ្តោយឲ្យ កាំង ហ្កេចអ៊ាវ ហៅ ឌុច អតីតប្រធានមន្ទីរ ស-២១ ចូលមកធ្វើសក្ខីកម្មក្នុងសំណុំរឿង០០២ ប្រឆាំងទៅនឹងអតីតមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម នួន ជា, អៀង សារី និង ខៀវ សំផន។ ក្នុងអំឡុងពេលនៃការធ្វើសក្ខីកម្មរបស់ ឌុច មជ្ឈមណ្ឌលឯកសារកម្ពុជាបានចុះទៅមូលដ្ឋាននានាខាងក្រៅរាជធានីភ្នំពេញដើម្បីចាក់ផ្សាយអំពីការផ្សាយបន្តផ្ទាល់នៃការធ្វើសក្ខីកម្មនេះ ។ ទីតាំងដែលមជ្ឈមណ្ឌលឯកសារកម្ពុជាចុះទៅមានដូចជា វត្តអារ៉ាម វិហារឥស្លាម សាលាឃុំ ភូមិករ សាកលវិទ្យាល័យ និងតូបកាហ្វេនានា ។

ក្នុងពេលនៃការធ្វើសក្ខីកម្មនេះ ឌុច បានរៀបរាប់ហេតុការណ៍ជាច្រើននៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ទាក់ទងទៅនឹងសាសនាឥស្លាម ឌុច បាននិយាយថា បក្សកុម្មុយនីស្តកម្ពុជាមានគោលការណ៍ដាក់ពង្រាយជនជាតិឥស្លាមឲ្យរស់នៅជាមួយប្រជាជនខ្មែរតាមសហករណ៍ដើម្បីបំបាត់អត្តសញ្ញាណជនជាតិនេះ ។

ឌុច ក៏បានលើកឡើងផងដែរពីការចាប់ជនជាតិអារ៉ាប់កាន់សាសនាឥស្លាម ដែលរស់នៅភូមិអារ៉ាប់ ក្រុងភ្នំពេញ យកទៅសម្លាប់ក្នុងអំឡុងពេល ណាត គ្រប់គ្រងមន្ទីរស-២១ ។ បន្ថែមទៅលើការអះអាងនេះ នៅក្នុងឯកសារមួយចំនួនដែលសេសសល់ពីរបបខ្មែរក្រហម ក៏បានបង្ហាញឲ្យឃើញពីការបញ្ជារបស់មេដឹកនាំខ្មែរក្រហមឲ្យមានការជម្លៀសជនជាតិឥស្លាមដែលរស់នៅស្រុកក្រូចឆ្មា ក្នុងខេត្តកំពង់ចាម ឲ្យទៅរស់នៅភូមិភាគពាយ័ព្យ បន្ទាប់ពីមានការបះបោរប្រឆាំងនឹងកម្មាភិបាលខ្មែរក្រហមដែលគ្រប់គ្រងនៅតំបន់នោះ និងការបង្ក្រាបយ៉ាងឃោរឃៅរួចមក ។

ខាងក្រោមនេះគឺជាប្រតិកម្មរបស់និស្សិតកម្ពុជាទៅនិងអ្វីដែល ឌុច បានរៀបរាប់នៅក្នុងសក្ខីកម្មរបស់គាត់ ។

**ស៊ឹម សុភ័ក្ត្រ និស្សិតសកលវិទ្យាល័យភូមិន្ទកសិកម្ម**

ខ្ញុំតែងតែតាមដានសវនាការនេះតាមរយៈការផ្សាយបន្តផ្ទាល់ ទោះបីជាខ្ញុំមិនមែនគ្រប់ពេលក៏ដោយ ។ តាមរយៈសក្ខីកម្មរបស់ ឌុច ខ្ញុំដឹងថានរណាខ្លះដែលជាមេរបស់គាត់ ។ ខ្ញុំយល់ថាការចុះមកផ្សព្វផ្សាយរបស់មជ្ឈមណ្ឌលឯកសារកម្ពុជានាពេលនេះមិនត្រឹមជំរុញឲ្យមានការសិក្សាពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យប៉ុណ្ណោះទេ ថែមទាំងបានឆ្លុះបញ្ចាំងពីប្រវត្តិសាស្ត្រពិតដែលប្រជាជនកម្ពុជាបានជួបប្រទះកាលពីជាងសាមសិបឆ្នាំមុន ។ ខ្ញុំជឿថា របបខ្មែរក្រហមពិតជាកើតមានមែនតាមរយៈការនិយាយប្រាប់ពីចាស់ទុំដែលធ្លាប់ឆ្លងកាត់និងតាមរយៈការសិក្សាស្រាវជ្រាវ ។ ខ្ញុំយល់ឃើញថាប្រសិនបើគ្មានតុលាការនេះទេ ក្មេងជំនាន់ក្រោយប្រាកដជាមិនដឹង ឬមិនអាចបែងចែកថាអ្នកណាខុសអ្នកណាត្រូវនោះទេ ។

**ប៉ាក សំណាង និស្សិតសកលវិទ្យាល័យន័រតុន**

នេះគឺជាឱកាសមួយសម្រាប់ ឌុច ដើម្បីឲ្យគាត់អាចធ្វើអំពើល្អឡើងវិញតាមរយៈការនិយាយការពិតពីហេតុការណ៍ដែលកើតមានឡើងក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ឌុច ត្រូវតែបង្ហាញការពិតទៅកាន់តុលាការពីអ្វីដែលគាត់បានដឹងបានឃើញ ។

**នាង ពិសិដ្ឋ និស្សិតសកលវិទ្យាល័យន័រតុន**

ការកាត់ទោសនេះគឺជាគំរូមួយសម្រាប់ប្រជាជនក៏ដូចជាមេដឹកនាំទាំងអស់ដើម្បីកុំឲ្យប្រព្រឹត្តនូវអំពើដូចមេដឹកនាំខ្មែរក្រហមទាំងនោះទៀត ។

**យើ វ័ស៊ីហ្គ និស្សិតមកពីខេត្តកណ្តាល**

ខ្ញុំបានដឹងរឿងរ៉ាវអំពីការធ្វើបាបទៅលើជនជាតិចាមនិងការស្លាប់ពូមីងរបស់ខ្ញុំនៅក្នុងរបបខ្មែរក្រហម ឪពុកម្តាយរបស់ខ្ញុំមិនចង់ឲ្យមានការចងពៀរជាមួយមេដឹកនាំខ្មែរក្រហមទៀតទេ ។

**ស៊ីរ៉ូស ជានិស្សិតមកពីសកលវិទ្យាល័យន័រតុន**

ខ្ញុំសូមឲ្យមានការលើកលែងទោសចំពោះមេដឹកនាំខ្មែរក្រហមដោយសារតែគាត់មានវ័យចំណាស់ទៅហើយ ។ នៅក្នុងសាសនាឥស្លាមក៏មានការអនុញ្ញាតឲ្យអ្នកប្រព្រឹត្តខុសលាងជម្រះអំពើបាប ឬសូមអភ័យទោសពីកំហុសរបស់ខ្លួនដែរ ។

**ម៉ាន សុភា និស្សិតសកលវិទ្យាល័យភូមិន្ទកសិកម្ម**

ខ្ញុំមិនសូវដឹងរឿងរ៉ាវរបស់តុលាការច្រើនទេ ទើបតែពេលនេះខ្ញុំមានឱកាសតាមដានសាលាក្តីនេះ ។ សក្ខីកម្មរបស់ ឌុច នៅថ្ងៃនេះធ្វើឲ្យខ្ញុំដឹងពីហេតុការណ៍ប្រវត្តិសាស្ត្រជាច្រើនអំពីដើមកំណើតនៃបក្សកុម្មុយនីស្តកម្ពុជា ។

**រឿន វិនិច្ឆ័យ និស្សិតផ្នែកគ្រប់គ្រងដីធ្លី**

ខ្ញុំយល់ថា តុលាការនេះផ្តល់ផលប្រយោជន៍ជាច្រើនដល់ក្មេងជំនាន់ក្រោយដើម្បីឲ្យក្មេងទាំងនោះដឹងពីភាពពិតនៃសង្គមកម្ពុជា ហើយក្មេងជំនាន់ក្រោយទាំងនោះអាចត្រៀមខ្លួនដើម្បីកសាងប្រទេសទៅថ្ងៃមុខ ។

**ចាន់ វិបុល និស្សិតផ្នែកកេរ្យត្រសាស្ត្រ**

តាមរយៈសក្ខីកម្មរបស់ ឌុច ខ្ញុំយល់ដឹងបានច្រើនអំពីសាលាក្តីខ្មែរក្រហម ថ្នាក់ដឹកនាំរបស់ខ្មែរក្រហម និងមេដឹកនាំជាន់ខ្ពស់ដែលកំពុងរងការចោទប្រកាន់ក្នុងសំណុំរឿង០០២នេះ ។ ការមើលសក្ខីកម្មនេះគឺជាវិធីសាស្ត្រដ៏ល្អក្នុងការរៀនសូត្រពីរបបកម្ពុជាប្រជាធិបតេយ្យ ។

**នាង ពិសិដ្ឋ និស្សិតផ្នែកវិទ្យាសាស្ត្រសត្វពាហនៈ**

ខ្ញុំមានអារម្មណ៍រីករាយពេលដែលមើលសក្ខីកម្មរបស់ ឌុច នេះ ហើយខ្ញុំគិតថានេះគឺជាវិធីល្អសម្រាប់និស្សិតដូចជារូបខ្ញុំក្នុងការរៀនសូត្រពីប្រវត្តសាស្ត្រ ។ ទើបតែពេលនេះ ខ្ញុំបានដឹងអំពីភាពផ្តាច់ការរបស់មេដឹកនាំខ្មែរក្រហម ។

**ឡៃ សុធារី និស្សិតផ្នែកកសិឧស្សាហកម្ម**

នេះគឺជាឱកាសល្អដែលនិស្សិតរៀនអំពីរបបខ្មែរក្រហម និងបទពិសោធន៍របស់អ្នកដែលបានជួបប្រទះក្នុងរបបនេះ ។ ប៉ុន្តែខ្ញុំមិនសូវដឹងច្រើនពីដំណើរការកាត់ទោសនៅសាលាក្តីខ្មែរទេ ។ នេះគឺជាលើកទីមួយដែលខ្ញុំបានមើលអំពីដំណើរការកាត់ក្តីដូច្នេះ ។

**ធុច និមល និស្សិតផ្នែកអភិវឌ្ឍជនបទ**

ខ្ញុំចាប់អារម្មណ៍ទៅនឹងដំណើការផ្សាយបន្តផ្ទាល់នៃសវនាការនេះជាខ្លាំង ជាពិសេសនៅពេលដែលទណ្ឌិតត្រូវបានកោះហៅឲ្យមកធ្វើជាសាក្សីបែបនេះតាមរយៈសក្ខីកម្មរបស់ ឌុច ខ្ញុំបានរៀនអំពីរបៀបដែលខ្មែរក្រហមគ្រប់គ្រងប្រទេស ។

**សោម ប៊ុនថន និង ធាវ សារៈមុនិន្ទ**



និស្សិតចូលរួមទស្សនាការផ្សាយបន្តផ្ទាល់សវនាការ នៅសាលាជាតិកសិកម្មព្រែកលៀប

# ប្រតិកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីទៅលើសាលដីកាស្ថាពរ របស់ កាំង ហ្គេកអ៊ាវ ហៅ ឌុច

### ◆ធៀវ ឆាប ភេទស្រី មកពីខេត្តកំពង់ធំ




កាលពីមុន ខ្ញុំមិនសូវបានដឹងអំពីតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមប៉ុន្មានទេ ។ ខ្ញុំបានដឹងពីតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមនេះតាមរយៈបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលបានចុះទៅភូមិរបស់ខ្ញុំ ហើយបានប្រាប់ខ្ញុំអំពីសិទ្ធិក្នុងការចូលរួមជាមួយតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ។ បន្ទាប់ពីបានស្តាប់ការពន្យល់ណែនាំពីសំណាក់បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា ខ្ញុំបានសម្រេចចិត្តដាក់ពាក្យបណ្តឹងទៅតុលាការនេះ ដើម្បីស្វែងរកយុត្តិធម៌ឲ្យក្រុមគ្រួសាររបស់ខ្ញុំដែលបានស្លាប់ក្នុងរបបខ្មែរក្រហម ។ អ្វីដែលខ្ញុំរំពឹងចង់បានជាទីបំផុតពីការចូលរួមរបស់ខ្ញុំគឺ ការទទួលបានយុត្តិធម៌សម្រាប់អ្នកដែលបានស្លាប់និងដើម្បីទាមទារសំណងផ្លូវចិត្តចំពោះទុក្ខវេទនាដែលខ្ញុំបានទទួលរង ។ ខ្ញុំបានចូលរួមនៅក្នុងដំណើរការរបស់តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមនៅក្នុងសំណុំរឿង០០១តាំងពីដំបូង ។ ខ្ញុំមិនដែលខកខានក្នុងការចូលរួមម្តងណាឡើយ ។ ខ្ញុំទទួលបានចំណេះដឹងជាច្រើនអំពីតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមតាមរយៈចៅក្រមនិងមេធាវីតំណាងរបស់ខ្ញុំ ។ ខ្ញុំមិនដែលមានគំនិតសងសឹកនឹងមេដឹកនាំខ្មែរក្រហមទាំងនោះទេដោយសារតែយើងមានតុលាការមួយដំណើរការដើម្បីស្វែងរកយុត្តិធម៌ជូនជនរងគ្រោះ ខ្ញុំមានការសប្បាយរីករាយដែលបានចូលរួមនៅក្នុងដំណើការនេះហើយអារម្មណ៍របស់ខ្ញុំហាក់ដូចជាបានធូរស្បើយ ។ កាលពីមុនពេលចូលរួមនៅក្នុងដំណើរការរបស់តុលាការនេះ ខ្ញុំមិនសូវជាសប្បាយចិត្តប៉ុន្មានទេ ។ អារម្មណ៍របស់ខ្ញុំមិនសូវស្ងប់ទេ ។ ពេលខ្លះខ្ញុំមិនសប្បាយចិត្ត ហើយពេលខ្លះទៀត ខ្ញុំមិនអាចទប់ទឹកភ្នែកខ្លួនឯងបានឡើយ ។ ប៉ុន្តែអ្វីៗហាក់ដូចជាបានប្រែប្រួល ។ ខ្ញុំមិនងាយនឹងសម្រក់ទឹកភ្នែកដូចកាលពីមុនទៀតទេ ។ ទោះបីជាពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ខ្ញុំត្រូវបានតុលាការកំពូលបដិសេធម្តងទៀតក៏ដោយ ក៏ខ្ញុំមិនមានការពិបាកចិត្តអ្វីដែរ ។ ផ្ទុយទៅវិញ ខ្ញុំពេញចិត្តដែល ឌុច ត្រូវជាប់ទោសអស់មួយជីវិត ។ បើទោះបីជាខ្ញុំមិនត្រូវបានតុលាការទទួលស្គាល់ជាដើមបណ្តឹងរដ្ឋប្បវេណីក៏ដោយ ក៏ ឌុច ត្រូវបានតុលាការយកមកកាត់ទោសដែរ ។ ខ្ញុំបានកត់សំគាល់ឃើញថា ឌុច បានប្រែទឹកមុខនៅពេលដែលគាត់បានឮពីការដាក់ទោសមកលើគាត់ ។ ឌុច មិនបានក្រឡេកមើលពួកយើងទាំងអស់គ្នាដែលអង្គុយនៅខាងក្រៅទេ ។ ខ្ញុំនឹងបន្តតាមដានដំណើរការរបស់តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមបន្តទៅទៀត បើទោះបីជាសំណុំរឿង០០១ បានបញ្ចប់ទៅហើយក៏ដោយ ។ ខ្ញុំសូមថ្លែងអំណរគុណដល់តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមដែលបានជួយជនរងគ្រោះក្នុងការស្វែងរកការពិតចំពោះឧក្រិដ្ឋកម្មដែលបានកើតឡើងកាលពីអតីតកាល ។

### ◆លឹម យ៉ុន ភេទស្រី មកពីខេត្តកំពង់ធំ

ការប្រកាសសាលដីកាស្ថាពររបស់ ឌុច គឺជាយុត្តិធម៌មួយសម្រាប់ខ្ញុំ ។ ប៉ុន្តែ ខ្ញុំមានការខកចិត្តជាខ្លាំងនៅពេលដែលពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ខ្ញុំត្រូវបានតុលាការបដិសេធចោលម្តងទៀត ។ ការទទួលស្គាល់ខ្ញុំជាដើមបណ្តឹងរដ្ឋប្បវេណីគឺមានសារៈសំខាន់ណាស់សម្រាប់ខ្ញុំ ។ នេះជាការផ្តល់កិត្តិយសដល់អ្នកដែលបានស្លាប់ និងដើម្បីបង្ហាញឲ្យពួកគាត់ដឹងថា អ្នកដែលនៅរស់រានមានជីវិតបានព្យាយាមស្វែងរកយុត្តិធម៌ជូនដល់ព្រលឹងរបស់គាត់ដើម្បីឲ្យគាត់បានទៅកាន់សុគតិភព ។ ខ្ញុំបានស្វែងរកឈ្មោះបងប្រុសខ្ញុំនៅគុកទួលស្លែងជាច្រើនដង ប៉ុន្តែ ខ្ញុំមិនដែល

ទទួលបានលទ្ធផលអ្វីទេ ។ ខ្ញុំមិនដឹងថា ខ្ញុំត្រូវធ្វើអ្វីនោះទេ ។ ក្ដីរំពឹងក្នុងធ្វើដំណើរមកកាន់តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមក្នុងថ្ងៃនេះគឺដើម្បីស្ដាប់លឺផ្ទាល់ត្រចៀកថា តើពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ខ្ញុំត្រូវបានតុលាការទទួលស្គាល់ឬក៏អត់ហើយនឹងស្ដាប់ការដាក់ទោស ឌុច ។ អ្វីដែលគួរឲ្យភ្ញាក់ផ្អើលគឺ ឌុច ត្រូវបានតុលាការដាក់ទោសឲ្យជាប់ពន្ធនាគារអស់មួយជីវិត ដែលព័ត៌មាននេះបានធ្វើឲ្យខ្ញុំមានអារម្មណ៍ស្ងប់ចិត្ត ។ ខ្ញុំនៅតែសោកស្ដាយដោយសារតែពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ខ្ញុំត្រូវបានបដិសេធចោលដដែល បើទោះបីជាខ្ញុំបានរិតខំប្រឹងប្រែងអស់រយៈពេលជាច្រើនឆ្នាំមកហើយក៏ដោយ ។

### ◆លី ហ៊ា ភេទប្រុស មកពីខេត្តបន្ទាយមានជ័យ


លី ហ៊ា

ខ្ញុំបានសម្រេចចិត្តដាក់ពាក្យបណ្ដឹងទៅកាន់តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ដោយសារតែខ្ញុំទទួលរងទុក្ខវេទនាជាខ្លាំងនៅក្នុងរបបខ្មែរក្រហម ។ ខ្ញុំចង់ស្វែងរកយុត្តិធម៌ ។ ខ្ញុំមានការសោកស្ដាយនៅពេលដំបូងដែល ឌុច បានបដិសេធទទួលស្គាល់ខ្ញុំជាអតីតអ្នកជាប់ឃុំឃាំងនៅគុកទួលស្លែង ។ ខ្ញុំទទួលបានយុត្តិធម៌នៅពេលដែល ឌុច ត្រូវបានតុលាការដាក់ទោសឲ្យជាប់ពន្ធនាគារអស់មួយជីវិត ។ ជាងនេះទៅទៀត ខ្ញុំត្រូវបានតុលាការទទួលស្គាល់ជាដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង ០០១វិញ ។ នោះមានន័យថាការឈឺចាប់របស់ខ្ញុំត្រូវបានតុលាការទទួលស្គាល់ ហើយនេះគឺជាអ្វីដែលខ្ញុំបានរំពឹងទុកនៅពេលដែលខ្ញុំធ្វើដំណើរចេញពីផ្ទះមកកាន់តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមនេះ ។ ខ្ញុំមានសេចក្ដីសោមនស្សរីករាយណាស់ ។ នៅពេលនេះ ខ្ញុំអាចអត់ឱនឲ្យកម្មាភិបាលខ្មែរក្រហមថ្នាក់ក្រោមដែលធ្វើការក្រោមបង្គាប់របស់ ឌុច បាន ។

### ◆ផង សារ៉ាត់ ភេទប្រុស មកពីខេត្តសៀមរាប

ខ្ញុំមានការសោកស្ដាយជាខ្លាំងនូវពេលដែលពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ខ្ញុំត្រូវបានតុលាការបដិសេធមិនទទួលស្គាល់ទាំងអង្គជំនុំជម្រះសាលាដំបូង និងអង្គជំនុំជម្រះតុលាការកំពូល ។ ខ្ញុំពេញចិត្តនឹងការដាក់ទោស ឌុច ឲ្យជាប់ពន្ធនាគារអស់មួយជីវិត ។ ប៉ុន្តែខ្ញុំយល់ថា តុលាការគួរពិចារណាករណីរបស់ខ្ញុំជាពិសេសគឺពាក់ព័ន្ធទៅនឹងការឈឺចាប់ដែលខ្ញុំបានទទួលរង ។ ពូរបស់ខ្ញុំពីរនាក់ត្រូវបានយកទៅសម្លាប់នៅគុកទួលស្លែង ។ ខ្ញុំសម្រេចចិត្តដាក់ពាក្យបណ្ដឹងទៅតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម គឺដើម្បីស្វែងរកយុត្តិធម៌ជូនសាច់ញាតិខ្ញុំដែលបានស្លាប់បាត់បង់ជីវិត ។ យុត្តិធម៌សម្រាប់ខ្ញុំមានន័យថា ការឈឺចាប់របស់ខ្ញុំត្រូវបានអ្នកដទៃទទួលស្គាល់ ។


ផង សារ៉ាត់

### ◆នេត ផល្លី ភេទប្រុស មកពីខេត្តកំពង់ចាម


នេត ផល្លី

មូលហេតុដែលខ្ញុំសម្រេចចិត្តដាក់ពាក្យបណ្ដឹងទៅតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមគឺដើម្បីស្វែងរកយុត្តិធម៌ជូនបងប្រុសរបស់ខ្ញុំដែលស្លាប់នៅគុកទួលស្លែង និងជនរងគ្រោះដទៃទៀត ។ ឥឡូវនេះ គោលបំណងរបស់ខ្ញុំបានសម្រេចហើយ ពីព្រោះ ឌុច ត្រូវបានតុលាការកំពូលកាត់ទោសឲ្យជាប់ពន្ធនាគារអស់មួយជីវិត ។ ខ្ញុំមានការជឿជាក់ទៅលើតុលាការនេះក្នុងការនាំយកយុត្តិធម៌ជូនជនរងគ្រោះនៃរបបខ្មែរក្រហម ។ ខ្ញុំយល់ឃើញថា ការចូលរួមរបស់ខ្ញុំ ពិតជាមានអត្ថន័យណាស់ ។ មុនពេលដែលខ្ញុំធ្វើដំណើរមកដល់រាជធានីភ្នំពេញដើម្បីចូលរួមស្ដាប់ការប្រកាសសាលដីការបស់ ឌុច ខ្ញុំសង្ឃឹមក្នុងចិត្តថា តុលាការកំពូលនឹងដាក់ទោស ឌុច ច្រើនជាងកាលពីនៅអង្គជំនុំជម្រះសាលាដំបូង ។ លទ្ធផលគឺដូចទៅ

នឹងអ្វីដែលខ្ញុំបានរំពឹងទុកមែន ។ ខ្ញុំគិតថា ការដាក់ទោស ឌុច មួយជីវិត គឺវាសមហេតុផលទៅនឹងអ្វីដែល ឌុច បានប្រព្រឹត្តនៅក្នុងរបបខ្មែរក្រហម ។ ខ្ញុំជឿជាក់ថា ក្មេងជំនាន់ក្រោយនឹងរៀនសូត្រពីសាលដីកានេះ ដែលថាគ្មាននរណាម្នាក់អាចបំពានលើច្បាប់បាននោះទេ ត្រូវតែទទួលផលនូវអ្វីដែល ឌុច បានប្រព្រឹត្ត ។ ពីមុនខ្ញុំស្អប់ ឌុច ណាស់ ព្រោះគាត់គឺជាមនុស្សម្នាក់ដែលត្រូវតែទទួលខុសត្រូវចំពោះការស្លាប់របស់បងប្រុសខ្ញុំ ។ ខ្ញុំបានព្យាយាមរំងាប់អារម្មណ៍ ដោយដើរតាមគន្លងរបស់ព្រះពុទ្ធដែលទ្រង់មានព្រះបន្ទូលថា «ពៀររំងាប់ដោយការមិនចងពៀរ» ។ ដូច្នេះហើយមានតែទុកឲ្យតុលាការជាអ្នកដោះស្រាយទៅចុះ ខ្ញុំពុំមានការជំទាស់អ្វីនោះទេ ។ ចំពោះសំណងវិញ ខ្ញុំចង់បានសំណងជំងឺចិត្តសម្រាប់បុគ្គលម្នាក់ៗ ដើម្បីខ្ញុំអាចមានលទ្ធភាពប្រារព្ធពិធីបុណ្យតាមបែបព្រះពុទ្ធសាសនា ដើម្បីឧទ្ទិសកុសលជូនដល់បងប្រុសរបស់ខ្ញុំ ។

**◆កែ សាម៉ូត ភេទស្រី មកពីខេត្តកំពង់ធំ**


កែ សាម៉ូត

បងប្រុសរបស់ខ្ញុំឈ្មោះ កែ កេងស៊ី ត្រូវបានបញ្ជូនទៅមន្ទីរស-២១ ។ នៅពេលដែលបងប្រុសរបស់ខ្ញុំបានបាត់ខ្លួន ក្រុមគ្រួសាររបស់ខ្ញុំបានធ្លាក់ខ្លួនលំបាកវេទនាផ្នែកហិរញ្ញវត្ថុ ។ បងប្រុស កេងស៊ី គឺជាអតីតវេជ្ជបណ្ឌិតមួយរូបកាលពីមុនរបបខ្មែរក្រហម ។ ដោយសារតែការបាត់បង់បងប្រុសម្នាក់នេះ ខ្ញុំក៏បានសម្រេចចិត្តដាក់ពាក្យបណ្ដឹងទៅកាន់តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ក្នុងន័យទាមទាររកយុត្តិធម៌ជូនគាត់ ។ ខ្ញុំមានការពេញចិត្តក្នុងការចូលរួមជាមួយតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ។ ខ្ញុំយល់ថា ខ្ញុំទទួលបាននូវយុត្តិធម៌នៅពេលដែល ឌុច ត្រូវបានតុលាការដាក់គុកអស់មួយជីវិត ។ ការដាក់ទោសនេះគឺវាហួសពីអ្វីដែលខ្ញុំបានរំពឹងទុក ។ មុនពេលចេញដំណើរពីផ្ទះមកចូលរួមស្ដាប់ការប្រកាសសាលដីកានេះ ខ្ញុំមិនបានរំពឹងគិតថា ឌុច នឹងត្រូវដាក់គុកអស់មួយជីវិតនោះទេ ។ នៅពេលការប្រកាសសាលដីកាកំពុងតែដំណើរការ ខ្ញុំបានសង្កេតឃើញទឹកមុខរបស់ ឌុច ប្រែទៅជាពណ៌ខ្មៅ នៅពេលដែលគាត់ស្ដាប់ឮថាគាត់ត្រូវបានតុលាការដាក់ទោសឲ្យជាប់ពន្ធនាគារអស់មួយជីវិត ។

**◆អ៊ឹម ពិសិដ្ឋ ភេទប្រុស មកពីខេត្តស្វាយរៀង**


អ៊ឹម ពិសិដ្ឋ

ក្នុងនាមយើងជាមនុស្ស បើទោះបីជាបាត់បង់របស់ដ៏តូចមួយក៏យើងមានអារម្មណ៍សោកស្ដាយដែរ ហើយវាកាន់តែឈឺចាប់ថែមទៀតនៅពេលដែលយើងបាត់បង់សាច់ញាតិជាទីស្រឡាញ់របស់យើង ។ ដូច្នេះហើយដើម្បីស្វែងរកយុត្តិធម៌ជូនសាច់ញាតិដែលបានស្លាប់បាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហម ខ្ញុំមិនដែលខកខានឱកាសណាមួយទេ ក្នុងការចូលរួមដំណើរការរបស់តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ។ ខ្ញុំចង់បានយុត្តិធម៌ ។ កាលពីមុន ខ្ញុំមានការខកចិត្តជាខ្លាំងចំពោះសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ។ ប៉ុន្តែ ឥឡូវនេះ ខ្ញុំមានការពេញចិត្តចំពោះសាលដីការបស់តុលាការកំពូល ។ រំឭកឡើងវិញនូវពេលដែលខ្ញុំធ្វើដំណើរចេញពីផ្ទះដើម្បីមកចូលរួមស្ដាប់ការប្រកាសសាលដីកានេះ ខ្ញុំសង្ឃឹមថា ឌុច នឹងត្រូវបានតុលាការដាក់ទោសអស់មួយជីវិត ។ ជាលទ្ធផលគឺវាដូចទៅនឹងអ្វីដែលខ្ញុំបានរំពឹងទុកមែន ។ ការដាក់ទោសនេះគឺជាមេរៀនដ៏ល្អមួយសម្រាប់ក្មេងជំនាន់ក្រោយដើម្បីរៀនសូត្រពីអតីតកាល និងដើម្បីកុំឲ្យប្រព្រឹត្តនូវកំហុសដែលខ្មែរក្រហមធ្លាប់បានប្រព្រឹត្តនោះទៀត ។

**◆កុំ មេន ភេទស្រី មកពីខេត្តកំពង់ចាម**

ខ្ញុំសម្រេចចិត្តដាក់ពាក្យប្ដឹងទៅកាន់តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមដោយសារតែខ្ញុំស្អប់មេដឹកនាំខ្មែរក្រហមដែលបានធ្វើឲ្យមនុស្សជាច្រើនទទួលរងទុក្ខវេទនា និងបាត់បង់ជីវិតនៅក្រោមការដឹកនាំរបស់ខ្លួន ។ ខ្ញុំចង់ឃើញ ឌុច ត្រូវបានតុលាការយកមកកាត់ទោសតាមផ្លូវច្បាប់ ។ ប្ដីរបស់ខ្ញុំត្រូវបានខ្មែរក្រហមចាប់ខ្លួន និងយកមកសម្លាប់នៅមន្ទីរស-២១ ។ ចាប់តាំងពីពេល

នោះមកជីវិតក្រុមគ្រួសាររបស់ខ្ញុំត្រូវបានប្រែប្រួលជារៀងរហូត ។ ខ្ញុំពេញចិត្តចំពោះការកាត់ទោស ឌុច ឲ្យជាប់គុកអស់មួយជីវិត ។ ការសម្រេចដាក់ទោសបែបនេះគឺជាអ្វីដែលខ្ញុំបានរំពឹងទុកមុនពេលខ្ញុំធ្វើដំណើរចេញពីផ្ទះមកចូលរួមស្តាប់ការប្រកាសនេះ ។ ខ្ញុំជឿជាក់ថា ក្មេងជំនាន់ក្រោយនឹងអាចរៀនសូត្រពីការកាត់ទោសនេះ ។ ខ្ញុំអាចអត់ឱនទោសឲ្យ ឌុច បានដោយសារតែគាត់ចាស់ជរាណាស់ទៅហើយ ហើយត្រូវបានដាក់ទោសសមទៅអ្វីដែលគាត់បានប្រព្រឹត្តទៀត ។ ខ្ញុំយល់ថាយុត្តិធម៌នឹងការផ្តល់សំណងមានសារសំខាន់ដូចគ្នា ។


កុំ មេន

◆ផៃ ហ៊ាប ភេទប្រុស មកពីខេត្តកំពង់ធំ

ខ្ញុំសម្រេចចិត្តដាក់ពាក្យបណ្តឹងទៅតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមដោយសារតែខ្ញុំចង់ដឹងថា ហេតុអ្វីបានជាខ្មែរក្រហមយកបងប្រុសរបស់ខ្ញុំទៅសម្លាប់នៅមន្ទីរស-២១ ។ ខ្ញុំពេញចិត្តចំពោះតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមដែលបានសម្រេចដាក់ទោស ឌុច ឲ្យជាប់ពន្ធនាគារអស់មួយជីវិត ។ ខ្ញុំមានការរំភើបជាខ្លាំងមុនពេលដែលខ្ញុំធ្វើដំណើរមកទីក្រុងភ្នំពេញ ។ មួយថ្ងៃមុនពេលចេញដំណើរ ខ្ញុំគេងមិនលក់នោះទេ ។ ខ្ញុំពេញចិត្តចំពោះសំណងជាសមូហភាពដែលតុលាការផ្តល់ឲ្យ ។ ខ្ញុំក៏សង្ឃឹមថានឹងទទួលបានសំណងជាលក្ខណៈបុគ្គលដែរ ។ ខ្ញុំពេញចិត្តនឹងការផ្តល់សំណងជាជាងការកាត់ទោស ។

◆ម៉ាន សូត ភេទប្រុស មកពីខេត្តកំពង់ធំ

ដោយសារតែខ្ញុំចង់ដឹងថាហេតុអ្វីបានជាខ្មែរក្រហមសម្លាប់កូនប្រុសរបស់ខ្ញុំ ទើបខ្ញុំសម្រេចចិត្តប្តឹងទៅតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ។ ខ្ញុំមិនចង់សងសឹកជាមួយនរណាម្នាក់នោះទេ ។ អ្វីដែលខ្ញុំចង់បាននោះគឺយុត្តិធម៌ ។ ខ្ញុំពេញចិត្តទៅនឹងការដាក់ទោស ឌុច ឲ្យជាប់ពន្ធនាគារអស់មួយជីវិត ។ វាគឺជាអ្វីដែល ឌុច សមនឹងទទួល ។ ខ្ញុំមិនបានគិតច្រើនទៅលើបញ្ហាសំណងនោះទេ ។ ចំពោះខ្ញុំ ការកាត់ទោសមានសារសំខាន់ជាងអ្វីៗទាំងអស់ ។ ខ្ញុំនឹងធ្វើបុណ្យឧទ្ទិសកុសលជូនកូនប្រុសរបស់ខ្ញុំ ។ សាលដីកានេះគឺជាមេរៀនដ៏ល្អមួយសម្រាប់ក្មេងជំនាន់ក្រោយ ដើម្បីកុំឲ្យពួកគេធ្វើតម្រាប់តាមខ្មែរក្រហម ។ ខ្ញុំមានការធូរស្រាលក្នុងចិត្ត បន្ទាប់ពីបានចូលរួមជាមួយតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ។


ម៉ាន សូត

◆ស៊ិន ស៊ីណែត ភេទស្រី មកពីខេត្តកំពង់ធំ


ស៊ិន ស៊ីណែត

យុត្តិធម៌មួយសម្រាប់អ្នកដែលត្រូវបានខ្មែរក្រហមសម្លាប់ ។ ខ្ញុំសប្បាយចិត្តខ្លាំងណាស់ដែលមិនអាចរកអ្វីមកថ្លែងបានទេ ចំពោះកាលដែលមានតុលាការជួយរកយុត្តិធម៌ជូនខ្ញុំ ក៏ដូចជាជនរងគ្រោះដទៃទៀតទូទាំងប្រទេស ។ ទោះបីជាយ៉ាងណាក៏ដោយ ខ្ញុំយល់ឃើញថា យុត្តិធម៌បានផ្តល់ជូនអ្នកស្លាប់នៅគុកទួលស្លែងហើយ ។ ប្រសិនបើគ្មានតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម និងមជ្ឈមណ្ឌលឯកសារកម្ពុជាជួយខ្ញុំទេ ខ្ញុំប្រហែលជាមិនអាចដឹងពីកន្លែងដែលសាច់ញាតិរបស់ខ្ញុំបានស្លាប់បាត់បង់ជីវិតទេ ។ ខ្ញុំសូមថ្លែងអំណរគុណដល់មជ្ឈមណ្ឌលឯកសារកម្ពុជាយ៉ាងអនេក ។ ខ្ញុំពិតជាមនុស្សដែលមានសំណាងណាស់ ។ កាលពីមុនខ្ញុំមិនដឹងថា ត្រូវធ្វើយ៉ាងម៉េចនោះទេចំពោះសាច់ញាតិដែលស្លាប់បាត់បង់ជីវិតទៅ ។ ក្រោយមក ខ្ញុំបានសម្រេចចិត្តដាក់ពាក្យបណ្តឹងទៅកាន់តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមដើម្បីស្វែងរកយុត្តិធម៌ជូនសាច់ញាតិដែលបានស្លាប់បាត់បង់ជីវិត ។ មុនពេលដែលខ្ញុំធ្វើដំណើរមកកាន់ទីក្រុងភ្នំពេញ ខ្ញុំបានអុជធូបជម្រាបប្រាប់ជីតារបស់ខ្ញុំថាខ្ញុំនឹងធ្វើដំណើរមកចូលរួមស្តាប់ការប្រកាស

សាលដីការបស់ ឌុច ។ ខ្ញុំសង្ឃឹមថា ដីការបស់ខ្ញុំនឹងបានឮខ្ញុំនិយាយ ហើយគាត់នឹងបានទៅកាន់សុគតិភព ។ ការកាត់ទោសមានសារសំខាន់ណាស់សម្រាប់ខ្ញុំ និងសម្រាប់ដីការបស់ខ្ញុំ ។ ខ្ញុំទទួលបាននូវយុត្តិធម៌ ហើយបើទោះបីជាយុត្តិធម៌នេះទើបតែទទួលបានក្រោយសាមសិបឆ្នាំហើយក៏ដោយ ។ ខ្ញុំជឿលើកម្មផល ។ ឌុចសមនឹងទទួលនូវអ្វីដែលគាត់បានប្រព្រឹត្ត ។ ខ្ញុំទទួលបានអារម្មណ៍សប្បាយរីករាយពេលត្រឡប់ទៅផ្ទះវិញ បន្ទាប់ពីការរង់ចាំយុត្តិធម៌អស់រយៈពេលជាងសាមសិបឆ្នាំកន្លងមកនេះ ។ ពីមុនខ្ញុំគិតថាយុត្តិធម៌នេះត្រូវបានពន្យាហើយមានពេលខ្លះគិតថា យុត្តិធម៌ប្រហែលជាមិនអាចទទួលបាននោះទេដោយសារតែដំណើរស្វែងរកយុត្តិធម៌នេះ ចំណាយពេលយូរណាស់រហូតមកដល់ថ្ងៃនេះ ។

◆**ង៉ែត អ៊ុយ ភេទស្រី មកពីខេត្តកំពង់ធំ**


ង៉ែត អ៊ុយ

ខ្ញុំសប្បាយចិត្តណាស់នៅពេលដែលឃើញ ឌុចត្រូវបានតុលាការដាក់ទោសឲ្យជាប់គុកអស់មួយជីវិត ។ ប៉ុន្តែជាមួយគ្នានេះដែរ ខ្ញុំមានការខកចិត្តនៅពេលដែលតុលាការបដិសេធសំណើសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ខ្ញុំ ។ នៅទីបញ្ចប់នៃការប្រកាសសាលដីកាឈ្មោះរបស់ខ្ញុំមិនត្រូវបានរាប់បញ្ចូលទៅក្នុងបញ្ជីជនរងគ្រោះនោះទេ ដោយសារតែខ្ញុំមិនមានឯកសារគ្រប់គ្រាន់ដើម្បីបង្ហាញនៅក្នុងសំណុំរឿងរបស់ខ្ញុំ ។ ទោះជាយ៉ាងក៏ដោយ ខ្ញុំនឹងមិនបញ្ឈប់ត្រឹមនេះទេ ខ្ញុំនឹងបន្តនៅក្នុងសំណុំរឿង០០២ទៀត ។ នៅពេលដែលខ្ញុំសម្រេចចិត្តដាក់ពាក្យបណ្តឹងទៅតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម សំណងជំងឺចិត្តដែលខ្ញុំចង់បានគឺសំណងជំងឺចិត្តជាថវិកាដើម្បីខ្ញុំអាចមានលទ្ធភាពធ្វើបុណ្យតាមប្រពៃណីឧទ្ទិសកុសលជូនដល់ព្រលឹងប្តីរបស់ខ្ញុំ ។ បន្ទាប់ពីចូលរួមក្នុងដំណើរការស្វែងរកយុត្តិធម៌អស់រយៈពេលជាច្រើនឆ្នាំមកនេះ ទើបខ្ញុំយល់ឃើញថាអ្វីដែលខ្ញុំចង់បានបំផុតនោះគឺយុត្តិធម៌ ។ ឌុច ត្រូវបានតុលាការដាក់ទោសឲ្យជាប់គុកអស់មួយជីវិត ។ នេះមានន័យថា ខ្ញុំបានធ្វើអ្វីមួយជូនដល់ព្រលឹងប្តីរបស់ខ្ញុំ ។ ខ្ញុំមានអារម្មណ៍ធូរស្បើយជាងមុន ។ សរុបមក ខ្ញុំពេញចិត្តចំពោះការចូលរួមអស់រយៈពេលជាច្រើនឆ្នាំរបស់ខ្ញុំនៅក្នុងដំណើរនេះ ។ ខ្ញុំមិនខឹងគុំគួននឹង ឌុច ទៀតទេ ពីព្រោះ ឌុច ត្រូវបានដាក់គុកហើយ ។ ឌុចត្រូវទទួលរងនូវអ្វីដែលប្តីរបស់ខ្ញុំធ្លាប់បានទទួល ។

◆**ហាវ សោភា ភេទស្រី មកពីខេត្តកំពង់ធំ**


ហាវ សោភា

ខ្ញុំមិនដែលគិតថា ឪពុករបស់ខ្ញុំបានបាត់បង់ជីវិតនៅគុកទួលស្លែងនោះទេ ។ ឪពុករបស់ខ្ញុំបានឃ្លាតចេញពីម្តាយរបស់ខ្ញុំចាប់តាំងពីឆ្នាំ១៩៧៦ ។ រហូតដល់ឆ្នាំ២០០៦ ទើបខ្ញុំបានទទួលដំណឹងថា គាត់ស្លាប់នៅគុកទួលស្លែង ។ រំពេចនោះ ខ្ញុំចង់ស្វែងរកយុត្តិធម៌ជូនឪពុករបស់ខ្ញុំ ។ ខ្ញុំបានប្រាប់ខ្លួនឯងថា ប្រសិនបើតុលាការត្រូវបានបង្កើតឡើងនៅក្នុងប្រទេសកម្ពុជា ខ្ញុំនឹងស្វែងរកយុត្តិធម៌ជូនឪពុករបស់ខ្ញុំ ។ ខ្ញុំចង់ឃើញឪពុករបស់ខ្ញុំស្លាប់ដោយមានមោទនភាព និងទទួលបានយុត្តិធម៌ ។ ខ្ញុំតែងតែសង្ឃឹមថា តុលាការនឹងផ្តល់យុត្តិធម៌ដល់រូបខ្ញុំ ។ បេសកម្មដ៏មានតម្លៃនេះនឹងផ្តល់ឲ្យខ្ញុំនូវភាពយុត្តិធម៌ ។ ខ្ញុំសង្ឃឹមថាការ ប្រកាសសាលដីកានឹងផ្តល់យុត្តិធម៌ដល់ខ្ញុំ ។ ខ្ញុំសូមបួងសួងដល់ព្រលឹងឪពុករបស់ខ្ញុំ ហាវ ហាន សូមឲ្យលោកទទួលបានយុត្តិធម៌ ។ សូមឲ្យលោកដឹងថាកូនស្រីដែលនៅរស់រានមានជីវិតម្នាក់នេះមិនព្រងើយកន្តើយ ហើយក្រោកឈរជានិច្ចដើម្បីស្វែងរកយុត្តិធម៌ជូនលោករហូតដល់ដង្ហើមចុងក្រោយ ។ ខ្ញុំសង្ឃឹមថាលោកនឹងបានទៅកាន់សុគតិភព ។ ខ្ញុំគិតថាដំណើរការនេះមានសារប្រយោជន៍ណាស់ ។ ខ្ញុំបានព្យាយាមអស់រយៈពេលជាច្រើនឆ្នាំចាប់តាំងពីពេលចាប់ផ្តើមរហូតមកដល់បច្ចុប្បន្ននេះ ។ បើទោះបីជាការប្រកាសសាលដីកាមានលទ្ធផលយ៉ាងណាក៏ដោយ ក៏ខ្ញុំគិតថាអាចទទួលយកបានដែរ ពីព្រោះខ្ញុំមានអារម្មណ៍ថា ខ្ញុំទទួលបានយុត្តិធម៌រួចមកហើយ ។ ខ្ញុំមិនហ៊ានរំពឹងអ្វីច្រើននោះទេ ចំពោះការប្រកាសសាលដីកានោះ ។

ទោះបីជាយ៉ាងណាក៏ដោយ ខ្ញុំនៅតែមានអារម្មណ៍ថា ខ្ញុំទទួលបានយុត្តិធម៌ហើយ ពីព្រោះខ្ញុំបានខិតខំប្រឹងប្រែងមកដល់តុលាការកំពូលនេះ ។ ខ្ញុំគិតថា យុត្តិធម៌ស្ថិតនៅក្នុងចិត្តគំនិតរបស់យើង ។ ប្រសិនបើយើងមិនព្យាយាមធ្វើអារម្មណ៍របស់យើងថាគ្រប់គ្រាន់នោះទេ ទោះបីជាលទ្ធផលចេញមកឲ្យកាត់ទោស ឌុច រាប់រយឆ្នាំយ៉ាងណាក៏ដោយ ក៏មិនគ្រប់គ្រាន់សម្រាប់យើងដែរ ។

តើយើងគួរសម្រួលអារម្មណ៍របស់យើងបែបណាដែរ? យើងគួរតែគិតថា ឌុច ត្រូវបានតុលាការនាំយកមកកាត់ទោសរួចមកហើយ ថែមទាំងមានចៅក្រមជាតិ និងចៅក្រមអន្តរជាតិចូលរួមផងដែរ ។ ប្រជាជនកម្ពុជារាប់លាននាក់បានតាមដានដំណើរការកាត់ក្តីនេះ ហើយការឈឺចាប់របស់យើងត្រូវបានគេទទួលស្គាល់ ។ នេះគឺជាអត្ថន័យនិងតម្លៃរបស់តុលាការក៏ដូចជាយើងទាំងអស់គ្នាផ្ទាល់ដែលជាជនរងគ្រោះ ។ ថ្ងៃប្រកាសសាលដីកានេះជាថ្ងៃសំខាន់ហើយម្តាយរបស់ខ្ញុំកំពុងនៅមន្ទីរពេទ្យ ប៉ុន្តែខ្ញុំបានសម្រេចចិត្តធ្វើដំណើរមកកាន់ទីក្រុងភ្នំពេញដោយសារតែខ្ញុំយល់ថា ខ្ញុំបានធ្វើដំណើរមកដល់ដំណាក់ចុងក្រោយនៃដំណើរស្វែងរកយុត្តិធម៌ហើយ ដូច្នេះខ្ញុំត្រូវតែធ្វើដំណើរទៅកាន់ចំណុចនេះដែលខ្ញុំបានទន្ទឹងរង់ចាំអស់រយៈពេលជាយូរយារណាស់មកហើយ ។ បន្ទាប់ពីចូលរួមស្តាប់ការប្រកាសសាលដីកាខ្ញុំនឹងត្រឡប់ទៅមើលថែម្តាយរបស់ខ្ញុំវិញ ។ ម្តាយរបស់ខ្ញុំបានណែនាំឲ្យខ្ញុំធ្វើដំណើរមកទីក្រុងភ្នំពេញ គាត់បាននិយាយប្រាប់ខ្ញុំថា ពួកយើងគឺជាភាគីសំខាន់មួយនៅក្នុងដំណើរនេះ «កូនត្រូវទៅដើម្បីចូលរួមស្តាប់សាលដីកានេះ» ម្តាយរបស់ខ្ញុំបានទទួលរងការឈឺចាប់ផ្លូវចិត្តជាដំណំ ។ គាត់បាននិយាយថា គ្មានអ្វីអាចជួយគាត់បានទេ ដោយសារតែគាត់បានបាត់បង់មនុស្សម្នាក់ដែលសំខាន់បំផុតសម្រាប់ជីវិតគាត់ ។ មនុស្សម្នាក់នោះគឺជាអ្វីៗទាំងអស់របស់គាត់ ជាកម្លាំង និងជាក្តីសង្ឃឹម ។ ប៉ុន្តែឥឡូវនេះ គាត់គ្មានអ្វីនៅសេសសល់នោះទេ ។ គាត់រស់នៅលើលោកនេះដូចដើមត្នោតកំបុតក្បាលអ៊ីចឹង ។

## ◆ញ៉ែម សុផាន ភេទស្រី មកពីខេត្តកំពង់ចាម

ខ្ញុំបានបាត់បង់បងស្រី និងបងប្រុសនៅគុកទួលស្លែង ។ ការបាត់បង់នេះបានធ្វើឲ្យប៉ះពាល់ដល់អារម្មណ៍របស់ខ្ញុំជាខ្លាំង ។ នៅពេលតុលាការទើបតែចាប់ដំណើរការដំបូង ខ្ញុំមានអារម្មណ៍ខ្លាចរអាក្នុងការដាក់ពាក្យបណ្តឹងទៅកាន់តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ។ ខ្ញុំខ្លាចមានការសងសឹកកើតឡើងដូចអ្វីដែលធ្លាប់បានកើតឡើងកាលពីរបបខ្មែរក្រហម ។ ប៉ុន្តែ បន្ទាប់ពីទទួលបានការពន្យល់ណែនាំជាច្រើន ខ្ញុំក៏បានសម្រេចចិត្តដាក់ពាក្យប្តឹងទៅតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមដើម្បីឲ្យព្រលឹងបងប្អូនរបស់ខ្ញុំអាចបានទៅកាន់សុគតិភព ។ ទោះបីជាយ៉ាងណាក៏ដោយខ្ញុំមានអារម្មណ៍ថា ខ្ញុំទទួលបានយុត្តិធម៌មួយចំណែករួចទៅហើយដោយសារតែតុលាការបានខិតខំប្រឹងប្រែងក្នុងការនាំយក ឌុច មកកាត់ទោស ។ ដើម្បីឲ្យអារម្មណ៍របស់ខ្ញុំរឹតតែបានស្ងប់ទៀតនោះ ខ្ញុំចង់មើលឃើញ ឌុច ទទួលរងនូវការឈឺចាប់ដូចអ្វីដែលបងប្អូនរបស់ខ្ញុំធ្លាប់ទទួលរង ហើយខ្ញុំមិនចង់ឃើញ ឌុច ស្លៀកសម្លៀកបំពាក់ទាន់សម័យ និងសុំអភ័យទោសនោះទេ ។ ខ្ញុំមានការយល់ដឹងកាន់តែច្បាស់ថែមទៀត និងបានចូលរួមស្វែងរកយុត្តិធម៌ក្រោយពេលដែលខ្ញុំបានចូលរួមក្នុងដំណើរការកាត់ទោសនេះ បើទោះបីជាដំណើរការនេះប្រព្រឹត្តមិនបានលឿនដូចអ្វីដែលខ្ញុំបានរំពឹងទុកក៏ដោយ ។ អ្វីដែលខ្ញុំខំប្រឹងប្រែងនេះបានចេញផ្លែផ្កាហើយ ។ ខ្ញុំពេញចិត្តនឹងការចូលរួមរបស់ខ្ញុំ ។ ការកាត់ទោសគឺជាអ្វីដែលប្រជាជនកម្ពុជាទន្ទឹងរង់ចាំ ។ បើទោះបីជាវាមិនស្មើនឹងការឈឺចាប់ដែលយើងបានជួបប្រទះក៏ដោយ ក៏យ៉ាងហោចណាស់យើងបានធ្វើអ្វីមួយឆ្លើយតបទៅនឹងអ្វីដែលបានកើតឡើង ដែលនេះប្រសើរជាងកាលដែលយើងមិនបានធ្វើអ្វីសោះ ។ នេះជាការចូលរួមដ៏មានអត្ថន័យមួយសម្រាប់ខ្ញុំដោយសារតែខ្ញុំបានទទួលសេចក្តីស្ងប់ក្នុងចិត្ត ហើយបានរសាយកំហឹងនៅក្នុងខ្លួនទៀតផង ។ ខ្ញុំមិនដែលគិតថា តុលាការនឹងដោះលែង ឌុច នោះទេ ហើយក៏មិនដែលធ្លាប់គិតថា ឌុច នឹងត្រូវតុលាការដាក់ទោសអស់មួយជីវិតនោះដែរ ។ ខ្ញុំសប្បាយចិត្តណាស់នៅពេលនេះ ដោយសារតែខ្ញុំយល់ថា ព្រលឹងរបស់បងប្អូនខ្ញុំដែលបានស្លាប់បាត់បង់ជីវិតទៅអាចបានទៅដល់កាន់សុគតិភពហើយ ។ ជាងនេះទៅទៀត ខ្ញុំចង់មើលឃើញដោយផ្ទាល់ភ្នែកពេលដែល ឌុច ត្រូវបានដាក់ខ្នោះ ហើយបញ្ជូនទៅកាន់មន្ទីរឃុំឃាំង ។ នៅក្នុងអំឡុងពេលនៃសវនការបណ្តឹងឧទ្ធរណ៍ ឌុច ព្យាយាមបញ្ជាក់ពីភាពគ្មានទោសរបស់ខ្លួន ។ មិនតែប៉ុណ្ណោះ មេធាវីរបស់ ឌុច បានលើកឡើងនូវចំណុចល្អៗរបស់ ឌុច ដែលថា ឌុច គ្មានបំណងប្រព្រឹត្តបទល្មើសទាំងអស់នោះទេ ។

អ្វី ៗ ដែលបានលើកឡើងទាំងអស់នេះបានធ្វើឲ្យខ្ញុំវិលវល់យ៉ាងខ្លាំង ។ តែឥឡូវនេះ ខ្ញុំបានឮតុលាការប្រកាសថា ឌុច ពិតជាបានប្រព្រឹត្តកំហុសដោយចេតនាមែនហើយថែមទាំងពេញចិត្តនឹងប្រព្រឹត្តអំពើទាំងនោះទៀត ។ ខ្ញុំពិតជាសប្បាយចិត្ត ។ ខ្ញុំមិនមានអ្វីជំទាស់ទៅនឹងសំណងជំងឺចិត្តនោះទេ បើទោះបីជាគ្រាន់តែចុះឈ្មោះរបស់ខ្ញុំនៅក្នុងបញ្ជីក៏ដោយ ។ សាលដីកានេះមានអត្ថន័យធំធេងណាស់សម្រាប់ប្រជាជនកម្ពុជា ។ វានឹងជួយណែនាំមេដឹកនាំក្រោយ ៗ កុំឲ្យយកតម្រាប់តាម និងជួយឲ្យក្មេងជំនាន់ក្រោយឲ្យបានយល់ដឹងពីប្រវត្តិសាស្រ្តដែលបានកើតឡើង ។ ខ្ញុំនៅតែខឹងនឹង ឌុច ដោយសារតែ ឌុច បានប្រព្រឹត្តមិនល្អមកកាន់ក្រុមគ្រួសាររបស់ខ្ញុំ ។ បន្ទាប់ពីសំណុំរឿង០០១បានបញ្ចប់ទៅ ខ្ញុំនៅតែបន្តចូលរួមនៅក្នុងសំណុំរឿង០០២ទៀត ។ ប៉ុន្តែខ្ញុំមិនដឹងថាខ្ញុំអាចនៅចូលរួមបានយូរប៉ុណ្ណានោះទេ ដោយសារតែអាយុរបស់ខ្ញុំកាន់តែច្រើនទៅហើយ ។ ការដាក់ទោស ឌុច មានសារៈសំខាន់ណាស់ ហើយវាកាន់តែប្រសើរជាងនេះទៅទៀត ប្រសិនបើយើងអាចទទួលបានសំណង ឧទាហរណ៍ដូចជាចេតិយ៍ជាដើម ។ ខ្ញុំមានពាក្យផ្តាំផ្ញើចុងក្រោយមួយថា តុលាការគួរតែប្រកាសឲ្យសាធារណជនបានដឹងថា ឌុច នឹងត្រូវបញ្ជូនទៅដាក់ឃុំឃាំងនៅពន្ធនាគារមួយណាដើម្បីធ្វើឲ្យពួកយើងទាំងអស់គ្នាបានជ្រះស្រឡះក្នុងចិត្ត ។

**◆កែ ខុន ភេទប្រុស មកពីខេត្តកំពង់ធំ**

ខ្ញុំមិនសប្បាយចិត្តទេ នៅពេលដែលសំណងមិនត្រូវបានផ្តល់ឲ្យជនរងគ្រោះ ។ ទោះបីជាសំណងនោះជាអ្វីក៏ដោយ ខ្ញុំគ្រាន់តែសង្ឃឹមថានឹងទទួលបានកន្លែងមួយសម្រាប់រំឭក និងខ្ទិសដល់ព្រលឹងអ្នកដែលស្លាប់ ដាក់ស្នែង អ្នកដែលត្រូវបានសម្លាប់នៅគុកទួលស្លែង និងកន្លែងដទៃទៀត ។ ខ្ញុំចង់បានទាំងការដាក់ទោស និងសំណងជំងឺចិត្ត ។ មកដល់សព្វថ្ងៃនេះ បើទោះបីជាសំណងនោះជាអ្វីក៏ដោយក៏វាលែងប៉ះពាល់ដល់ការចូលរួមដ៏មានអត្ថន័យរបស់ខ្ញុំដែរ ។ បន្ទាប់ពីតស៊ូអស់រយៈពេលជាងបួនឆ្នាំមកនេះ ខ្ញុំមានអារម្មណ៍ថា ខ្ញុំទទួលបានយុត្តិធម៌ខ្លះហើយ ។ ថ្ងៃប្រកាសសាលក្រមជាថ្ងៃដែលមានសារសំខាន់បំផុត ។ ខ្ញុំចង់មើលឃើញថា តើថ្ងៃចុងក្រោយវានឹងបញ្ចប់ទៅយ៉ាងដូចម្តេច ។ តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមមានតម្លៃណាស់សម្រាប់ខ្ញុំ ដោយសារតែតុលាការនេះបានផ្តល់យុត្តិធម៌ជូនខ្ញុំ និងនាំយកជនដែលជាប់ពាក់ព័ន្ធ... 

តុលាការនេះបានផ្តល់យុត្តិធម៌ជូនខ្ញុំ និងនាំយកជនដែលជំពាក់បំណុលឈាមប្រជាជនកម្ពុជាមកកាត់ទោស ។ ខ្ញុំចង់ឲ្យប្រទេសកម្ពុជាពង្រឹងនូវនីតិរដ្ឋរបស់ខ្លួនឲ្យកាន់តែរឹងមាំដើម្បីទប់ស្កាត់កុំឲ្យអំពើឃោរឃៅបែបនេះកើតឡើងម្តងទៀត និងកុំឲ្យក្មេងជំនាន់ក្រោយយកតម្រាប់តាម ។ ខ្ញុំពេញចិត្តចំពោះការចូលរួមរបស់ខ្ញុំកន្លងមកនេះ ។ អ្វីដែលខ្ញុំពេញចិត្តបំផុតនោះគឺតុលាការនេះបានជួយរកយុត្តិធម៌ជូនអ្នកដែលបានបាត់បង់ជីវិត និងអ្នកដែលនៅរស់រានមានជីវិត ។ ទោះបីជា ឌុច ត្រូវតុលាការដាក់ទោសរយៈពេល៤០ឆ្នាំឬក៏មួយជីវិត ឬថ្ងៃណាមួយ ឌុច នឹងស្លាប់ក៏ដោយ ប៉ុន្តែឈ្មោះរបស់ ឌុច នៅតែត្រូវបានចារថាជាឧក្រិដ្ឋជនមួយរូបដដែល ។ ខ្ញុំនៅតែខឹងគុំគួននឹង ឌុច ដោយសារតែ ឌុច បានសម្លាប់បងប្រុសរបស់ខ្ញុំ និងប្រជាជនកម្ពុជា ។

បើនិយាយពីការផ្សះផ្សាវិញ វាពឹងផ្អែកទាំងស្រុងទៅលើពេលវេលា និងលក្ខខ័ណ្ឌនៃសង្គមដែលយើងរស់នៅ ។ ខ្ញុំគិតថាខ្ញុំអាចផ្សះផ្សារបួសបាន លុះត្រាតែ ឌុច ត្រូវបានរកឃើញថាមានកំហុស ។ ខ្ញុំនឹងបន្តស្វែងរកការពិត និងយុត្តិធម៌ចំពោះរបបដែលមេដឹកនាំខ្មែរក្រហមគ្រប់គ្រង ។ចំពោះការប្រកាសសាលដីកានៅក្នុងសំណុំរឿង ឌុច នៅថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២ នេះ ខ្ញុំមានអារម្មណ៍សប្បាយរីករាយណាស់ ដោយសារតែ ឌុច ត្រូវបានតុលាការដាក់ទោសឲ្យជាប់ពន្ធនាគារអស់មួយជីវិត ។ ខ្ញុំហាក់ដូចជាបានស្ងប់ចិត្តមួយកម្រិតហើយ ។ ប៉ុន្តែខ្ញុំមិនពេញចិត្តនឹងសំណងដែលតុលាការសម្រេចផ្តល់ឲ្យនោះទេ ។

សាលដីកានោះមានអត្ថន័យណាស់សម្រាប់ខ្ញុំ និងសម្រាប់ប្រជាជនកម្ពុជាភាគច្រើន ។ វាជាមេរៀនប្រវត្តិសាស្រ្តមួយសម្រាប់ក្មេងជំនាន់ក្រោយបានដឹងនិងរៀនសូត្រ ។ ចំពោះរូបខ្ញុំ ខ្ញុំយល់ថា ឌុច គឺ ជាបុគ្គលម្នាក់ដែលមានអំណាចអាចសម្លាប់នរណាម្នាក់បាននៅក្នុងរបបខ្មែរក្រហម ។ នៅពេលនេះ ខ្ញុំលែងខឹងនឹង ឌុច ទៀតហើយ ដោយសារតែ ឌុច ត្រូវបានតុលាការដាក់គុកអស់មួយជីវិត ។ ខ្ញុំពេញចិត្តនឹងការចូលរួមរបស់ខ្ញុំកន្លងមកនេះ ។ ខ្ញុំយល់ថាតុលាការបានជួយរកយុត្តិធម៌ជូនពួកយើងខ្ញុំហើយបានជួយរកឲ្យឃើញនូវខុសត្រូវស និងខ្មៅ ។

**មជ្ឈមណ្ឌលឯកសារកម្ពុជា**

# ឪពុករបស់ខ្ញុំស្លាប់នៅគុកទួលស្លែង

តើអ្នកនឹងមានអារម្មណ៍បែបណានៅពេលដែលឪពុកជាទីស្រឡាញ់របស់អ្នកបានបាត់ខ្លួនអស់រយៈពេលជាច្រើនឆ្នាំ ហើយក្រោយមកទើបដឹងថា គាត់ត្រូវបានខ្មែរក្រហមដាក់ឃុំឃាំង ធ្វើទារុណកម្មយ៉ាងឃោរឃៅនិងសម្លាប់នៅមន្ទីរស-២១នោះ? រឿងរ៉ាវនេះបានកើតឡើងមកលើរូបខ្ញុំ ហើយខ្ញុំមិនអាចយកពាក្យពេចន៍អ្វីមកធ្វើការប្រៀបធៀបឲ្យសមនិងការរំជួលក្នុងអារម្មណ៍របស់ខ្ញុំបានឡើយ ។

លោកឪពុករបស់ខ្ញុំឈ្មោះ សុក ហេង ។ គាត់គឺជាបុរសសុភាពរាបសារមួយរូបដែលខិតខំប្រឹងប្រែងធ្វើការងារ ចេះជួយយកអាសារអ្នកដទៃនិងជាមនុស្សម្នាក់ដែលគួរឲ្យស្រឡាញ់រាប់អាន ។ គាត់ធ្លាប់រស់នៅឃុំព្រែកកុយ ស្រុកស្អាង ខេត្តកណ្តាល ។ ឪពុកខ្ញុំធ្វើស្រែចម្ការ រកស៊ីលក់ដូរបន្តិចបន្តួច និងជាចុងភៅដ៏ចំណានមួយរូប ។ គាត់បានទិញទំនិញមកពីផ្សារដើម្បីឲ្យម្តាយរបស់ខ្ញុំលក់ដូរនៅផ្ទះផង នឹង មានពេលវេលាគ្រប់គ្រាន់មើលថែកូនចៅនៅផ្ទះផង ។ ទោះបីជាឪពុកខ្ញុំមានពេលខ្លះគាត់មានការមមារញឹកនិងនឿយហត់ពីការងារយ៉ាងណាក៏ដោយ ក៏គាត់តែងតែឆ្លៀតពេលមើលថែកូនៗរបស់គាត់ដែរ ។ ជាពិសេស នៅពេលដែលកូនៗរបស់គាត់ឈឺ ។ ខ្ញុំនៅតែចងចាំមិនភ្លេចនូវរឿងរ៉ាវទាំងឡាយពេលដែលឪពុករបស់ខ្ញុំអង្គុយនៅក្បែរកូនៗនៅពាក់កណ្តាលអាធ្រាត្រមើលថែយើងដើម្បីធានាថាកូនរបស់គាត់នឹងឆាប់ជាសះស្បើយពីជំងឺ ។ នៅពេលនោះ យើងពិតជាកូនដែលមានសុភមង្គលពីព្រោះតែយើងមានឪពុកម្នាក់ដែលមានការទទួលខុសត្រូវនិងជាមេគ្រួសារដ៏ល្អម្នាក់ ។


I08812
( 06បបគ ) 76
76
លេខរៀង :
ផ្នែក :
មកពី :
ប្រវត្តិរូបអ្នកទោសជាប់ឃុំឃាំង
១- ឈ្មោះដើម សុក ហេង
- ឈ្មោះក្រៅ
២- អាយុ ៥១ ឆ្នាំ ជនជាតិ ខ្មែរ ភេទ ប្រុស
៣- ទីលំនៅកំណើតកើតនៅភូមិ
ឃុំ ស្រុក ខេត្ត កណ្តាល
៤- ក្រមួងឪពុកទី មុនថ្ងៃរំដោះភ្នំពេញ ( ក្នុងឆ្នាំ ១៩៧៥ )
៥- ក្រមួងនិងទី បច្ចុប្បន្ន
៦- ឪពុកឈ្មោះ ម្តាយឈ្មោះ
៧- ប្រពន្ធ ឬ ប្តី ឈ្មោះដើម ឈ្មោះក្រៅ
៨- ទីលំនៅកំណើតកើតនៅភូមិ ឃុំ
ស្រុក ខេត្ត កណ្តាល
៩- បច្ចុប្បន្ន នៅ
១០- មានកូនប្រុសចំនួន នាក់ កូនស្រី ៤ នាក់
១១- ទីកន្លែងចាប់ខ្លួន
១២- ចាប់ខ្លួន ថ្ងៃទី ២៧ ខែ ៣ ឆ្នាំ ១៩៧៦ ។ ផ្ទះ បន្ទប់ធំ តូច

ប្រវត្តិរូបសង្ខេបរបស់អ្នកទោស សុក ហេង នៅមន្ទីរស-២១

ជីវិតរបស់យើងបានប្រែប្រួលទាំងស្រុងនៅពេលដែលឪពុកជាទីស្រឡាញ់ត្រូវបានបង្ខំឲ្យចូលបម្រើបដិវត្តន៍ខ្មែរក្រហម ។ គាត់ត្រូវបានខ្មែរក្រហមចាត់តាំងឲ្យធ្វើជាចុងភៅនៅទួលក្រសាំង ហើយខ្ញុំត្រូវបានចាត់តាំងឲ្យធ្វើការនៅកោះខែល ។ ខ្ញុំតែងតែចង់មករួមរស់ជុំគ្នាជាមួយឪពុកម្តាយ និងបងប្អូនរបស់ខ្ញុំវិញ ប៉ុន្តែខ្មែរក្រហមមិនអនុញ្ញាតឡើយ ។ នៅឆ្នាំ១៩៧៥ ឪពុករបស់ខ្ញុំបានមកលេងផ្ទះពីរដង ហើយចាប់តាំងពីពេលនោះមកគាត់ក៏បានបាត់ខ្លួនរហូត ។ នៅពេលនោះ ធ្លាប់មានគេមកប្រាប់ម្តាយខ្ញុំថា ឪពុករបស់ខ្ញុំត្រូវបានខ្មែរក្រហមចាប់ទៅដាក់ឃុំឃាំងនៅកោះគរ

ស្ថិតឃុំរការខ្ពស់ ។ មិនយូរប៉ុន្មាន ម្តាយរបស់ខ្ញុំក៏បានស្លាប់បាត់បង់ជីវិតដោយសារតែគាត់មិនអាចទ្រាំទ្រនឹងការងារលំបាកហើយនឹងអារម្មណ៍ដ៏ឈឺចាប់ បន្ទាប់ពីការបាត់ខ្លួនរបស់ឪពុកខ្ញុំ ។

ស្ថិតនៅក្រោមការដឹកនាំរបស់ខ្មែរក្រហម ខ្ញុំត្រូវបានបង្ខំឲ្យធ្វើការលើកទំនប់និងរែកដីរៀងរាល់ថ្ងៃ ។ ការងារទាំងនោះលំបាកនិងធ្វើឲ្យខ្ញុំហេវហត់យ៉ាងខ្លាំង ។ ខ្មែរក្រហមបានបំបែក


ហេង ឌិចហុង

គ្រួសារយើងចេញពីគ្នា ហើយខ្ញុំមានអារម្មណ៍កណ្តោចកណ្តែងជាខ្លាំងដែលធ្វើឲ្យខ្ញុំគ្មានស្មារតីប្រឹងប្រែងតស៊ូរស់តទៅទៀត ។ ខ្មែរក្រហមមិនដែលអនុញ្ញាតឲ្យខ្ញុំទៅលេងឪពុកដែលខ្ញុំតែងតែនឹកនោះឡើយ ។

បន្ទាប់ពីរបបខ្មែរក្រហមបានដួលរំលំ អ្នកជិតខាងរបស់ខ្ញុំបានប្រាប់ខ្ញុំថា ធ្លាប់បានឃើញរូបថតឪពុករបស់ខ្ញុំនៅទួលស្លែង ។ នៅពេលនោះខ្ញុំចង់ធ្វើដំណើរទៅកាន់ទីក្រុងភ្នំពេញខ្លាំងណាស់ ប៉ុន្តែដោយសារតែជីវភាពរបស់ខ្ញុំមានភាពខ្វះខាតខ្សោយខ្ញុំមិនមានលុយគ្រប់គ្រាន់សម្រាប់ធ្វើដំណើរទៅទេ ។ ប៉ុន្តែបងស្រីរបស់ខ្ញុំបានជិះកង់ទៅកាន់គុកទួលស្លែងហើយបានឃើញរូបថតឪពុក ។ អ្នកនៅទីនោះប្រាប់ថារាល់រូបថតទាំងអស់ដែលដាក់តាំងបង្ហាញនៅទីនោះគឺសុទ្ធតែស្លាប់ទាំងអស់ ។ ព័ត៌មានអំពីការបាត់បង់នេះបានធ្វើឲ្យខ្ញុំមានអារម្មណ៍រន្ធត់ជាខ្លាំងហើយខ្ញុំបានចាប់ផ្តើមគិតថាចាប់ពីពេលនេះតទៅខ្ញុំនិងបងស្រីរបស់ខ្ញុំត្រូវតែប្រឹងប្រែងរស់ដោយខ្លួនឯងពីព្រោះឪពុកម្តាយរបស់ពួកយើងបានក្លាយទៅជាជនរងគ្រោះនៃរបបខ្មែរក្រហមបាត់ទៅហើយ ។

នៅឆ្នាំ២០០៣បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាបានមកជួបខ្ញុំ ហើយបានហុចប្រវត្តិរូបរបស់ឪពុករបស់ខ្ញុំឲ្យមកខ្ញុំដែលប្រវត្តិរូបនោះមាននៅក្នុងបណ្ណសាររបស់ទួលស្លែង ។ នេះគឺជាលើកទីមួយដែលមានមនុស្សមកសួរខ្ញុំអំពីការឈឺចាប់ដែលខ្ញុំបានជួបប្រទះកាលពីរបបខ្មែរក្រហម ។ នៅឆ្នាំ២០០៨ បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាបានមកជួបខ្ញុំម្តងទៀត ហើយបានពន្យល់ខ្ញុំអំពីសិទ្ធិដែលខ្ញុំអាចដាក់ពាក្យបណ្តឹងតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង០០១បាន ។ ខ្ញុំក៏បានសម្រេចចិត្តដាក់ពាក្យបណ្តឹងដោយសារតែខ្ញុំចង់ស្វែងរកយុត្តិធម៌ជូនឪពុករបស់ខ្ញុំនិងខ្ញុំចង់ចូលរួមទប់ស្កាត់កុំឲ្យរបបដ៏ឃោរឃៅនេះកើតឡើងមានជាថ្មីម្តងទៀត ។ ខ្ញុំបានយល់ដឹងកាន់តែច្រើនជាងមុនអំពីប្រវត្តិគុកនៅទួលស្លែងពីមេធាវីរបស់ខ្ញុំ ព្រមទាំងសារព័ត៌មាននានា ។

ខ្ញុំប្រាកដថាឪពុករបស់ខ្ញុំមិនមែនជាភ្នាក់ងាររបស់សេ.អ៊ី.អា.ការ.ហ្សេ.បេ គិញវៀតណាម អតីតមន្ត្រីរបស់ លន់ នល់ ទាហានបុសត្រូវរបស់អង្គការនោះទេ ។ គាត់មិនដែលនិយាយរិះគន់និងពាក់ព័ន្ធនៅក្នុងរឿងនយោបាយណាមួយនោះទេ ។ គាត់គ្រាន់តែជាឪពុកដ៏ស្លូតត្រង់មួយរូបជាអ្នកលក់ដូរតូចតាចមួយរូប និងជាចុងភៅម្នាក់ប៉ុណ្ណោះ ។ ប៉ុន្តែខ្មែរក្រហមបែរជាបំបែកគាត់ចេញពីគ្រួសាររបស់យើងទៅវិញ ។

បន្ទាប់ពីរបបខ្មែរក្រហមត្រូវដួលរំលំ ខ្ញុំនិងបងប្អូនរបស់ខ្ញុំខិតខំប្រឹងប្រែងកសាងគ្រួសារឡើងវិញ ។ ខ្ញុំតែងតែច្រណែនអ្នកដទៃដែលមានឪពុកម្តាយនៅរស់មកដល់សព្វថ្ងៃ ។ ការច្រណែននេះវាធ្វើឲ្យខ្ញុំនឹកឃើញពីឪពុកម្តាយដែលខ្ញុំបានបាត់បង់មិនដែលភ្លេចមួយវិនាទីណាឡើយ ខ្ញុំតែងតែគិតថាជីវភាពគ្រួសាររបស់ខ្ញុំនឹងល្អប្រសើរជាងនេះ ប្រសិនបើឪពុករបស់ខ្ញុំនៅរស់ ។ ខ្ញុំចង់ឃើញ ឌុច ទទួលបានការដាក់គុកអស់មួយជីវិតដើម្បីជាយុត្តិធម៌មួយសម្រាប់ ការស្លាប់របស់ឪពុកខ្ញុំហើយនឹងអ្នកទោសដទៃទៀតដែលត្រូវបានសម្លាប់នៅទួលស្លែង ។

**ហេង ឌិចហុង**

# សូមឱ្យអតីតកាលកន្លងផុតទៅចុះ

នាងខ្ញុំឈ្មោះ កុំ មេន រស់នៅស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម ។ ការរៀនសូត្រគឺសំដៅលើការសិក្សាពីប្រធានបទណាមួយនៅក្នុងថ្នាក់រៀន ។ ប៉ុន្តែក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ពាក្យ "ការរៀនសូត្រ" នេះមានន័យថា "សម្លាប់" ។ ខ្ញុំសូមរៀបរាប់ពីករណីប្តីខ្ញុំឈ្មោះ ស្រី យេង ជាអ្នកស្ម័គ្រចិត្តបម្រើបដិវត្តន៍ខ្មែរក្រហម នៅឆ្នាំ១៩៧០ ។ ដំបូង ប្តីខ្ញុំបានចាត់តាំងធ្វើជាអ្នកយាមមន្ទីរឃុំ និងធ្វើការងារដកស្ទូង ។ ពីរឆ្នាំក្រោយមក គាត់ត្រូវបានអង្គការបញ្ជូនទៅចម្ការអណ្តូង ប៉ុន្តែខ្ញុំមិនដឹងថា គាត់ធ្វើការអ្វីទេ ។ ចំណែកខ្ញុំរស់នៅក្នុងភូមិ ដកស្ទូងស្រូវ និងមើលថែទាំកូន ។ មួយឆ្នាំក្រោយមកទៀត ប្តីខ្ញុំត្រូវបានចាត់តាំងឲ្យទៅវាយសម្រុកការងារបង្កបង្កើនផលស្រូវតាមមូលដ្ឋានផ្សេងៗជាច្រើនកន្លែង ។ ក្នុងអំឡុងពេលនោះ គាត់បានមកលេងផ្ទះក្នុងរយៈពេលមួយខែ ឬពីរខែម្តង ។

នៅពេលដែលខ្មែរក្រហមបានកាន់កាប់អំណាចទាំងស្រុងទូទាំងប្រទេសកម្ពុជាក្នុងឆ្នាំ១៩៧៥ ប្តីខ្ញុំត្រូវបានផ្ទេរទៅវត្តជីដូ និងវត្តទទឹងថ្ងៃដើម្បីវាយសម្រុកការងារបង្កបង្កើតផលស្រូវ ។ នៅឆ្នាំ១៩៧៦ នៅពេលដែលខ្ញុំកំពុងតែរស់នៅតំបន់អូរព្រាម ប្តីខ្ញុំក៏ទទួលបានភារកិច្ចថ្មីនៅកងដឹកជញ្ជូនកៅស៊ូ ។ គាត់បានដឹកជញ្ជូនជ័រកៅស៊ូទៅកំពង់ផែ ហើយចំណែកខ្ញុំគឺជាអ្នកប្រមូលជ័រ ។ យ៉ាងណាមិញ យើងទាំងពីរនាក់មានឱកាសតិចតួចណាស់ក្នុងការជួបគ្នា ។ យើងត្រូវធ្វើការងារធ្ងន់ ប៉ុន្តែទទួលបានរបបអាហារតិច ។ កូនៗរបស់ខ្ញុំធ្លាក់ខ្លួនឈឺដោយមិនមានអាហារហូប ។ ដោយសារកូនឃ្លានខ្លាំងពេក ខ្ញុំក៏ដាច់ចិត្តលួចបេះបន្លែខ្លះៗមកធ្វើម្ហូបឲ្យកូនៗខ្ញុំ ។ សំណាងល្អ ខ្ញុំមិនត្រូវបានឈ្លបខ្មែរក្រហមតាមទាន់ បើមិនដូច្នោះទេ ខ្ញុំប្រាកដជាទទួលរងទណ្ឌកម្មធ្ងន់ធ្ងរជាមិនខាន ។ បើទោះបីជាប្តីខ្ញុំជាសមាជិករបស់កងដឹកជញ្ជូនក៏ដោយ ក៏ខ្ញុំនិងកូនខ្ញុំមិនទទួលបានអ្វីលើសពីអ្នកដទៃដែរ ។ ក្នុងរបបនោះ ទោះបីជាប្រជាជនទាំងអស់រស់នៅហូបចុក និងធ្វើការជាសមូហភាពយ៉ាងណាក្តី ក៏ខ្ញុំមានអារម្មណ៍ថាឯកកោ ភ័យខ្លាច និងអស់សង្ឃឹម ។ ជាក់ស្តែង យើងរស់នៅជាលក្ខណៈអាត្មានិយម និងដាច់ដោយឡែកពីគ្នា ។

នៅឆ្នាំ១៩៧៧ តា សាត ដែលជាកម្មាភិបាលជាន់ខ្ពស់ម្នាក់បានហៅប្តីខ្ញុំឲ្យទៅរៀនសូត្រនៅភ្នំពេញ ។ កាលនោះខ្ញុំមិនដឹងថាពាក្យរៀនសូត្រនោះមានន័យយ៉ាងម៉េចទេ ។ ក្រោយមកអ្នកធ្វើការក្នុងកងជាមួយខ្ញុំបានប្រាប់ខ្ញុំថាប្តីខ្ញុំច្បាស់ជាត្រូវអង្គការសម្លាប់ហើយ ពីព្រោះ "ទៅរៀនសូត្រនេះមានន័យថាស្លាប់" ។ នាពេលនោះ កូនទីបួនខ្ញុំមានអាយុទើបតែប្រាំមួយខែតែប៉ុណ្ណោះ ហើយខ្ញុំមានសភាពទន់ខ្សោយ និងក្រៀមក្រំជាទីបំផុត នៅពេលដឹងពីដំណឹងនេះ ។ ខ្ញុំគ្មានជម្រើសអ្វីក្រៅពីនៅស្ងៀម និងបន្តធ្វើការងារដូចធម្មតា ។ ចាប់តាំងពីពេលនោះមក ខ្ញុំមិនដែលបានទទួលដំណឹងអ្វីពីប្តីខ្ញុំទេ ។ ខ្ញុំបានបន្តធ្វើការងារដោយមិននិយាយស្តីពីការបាត់ខ្លួនរបស់ប្តីខ្ញុំឡើយ ។ ចំណែកឯកូនៗខ្ញុំវិញ កូនស្រីពីរនាក់រស់នៅជាមួយខ្ញុំ ប៉ុន្តែពីរនាក់ទៀតរស់នៅក្នុងកងកុមារ ។ ថ្ងៃមួយ



កុំ មេន

កូនស្រីខ្ញុំអាយុ៤ឆ្នាំបានធ្លាក់ខ្លួនឈឺធ្ងន់ ប្រកាច់បាត់មាត់បាត់ក ខ្ញុំភ័យខ្លាំងណាស់មិនដឹងធ្វើអ្វីត្រូវ ។ គ្មាននរណាម្នាក់ទៅហៅពេទ្យមកពិនិត្យកូនខ្ញុំទេ ។ កូនស្រីខ្ញុំក៏ស្លាប់នៅថ្ងៃនោះតែម្តង ។ ទោះបីជាខ្ញុំជួបនឹងរឿងអកុសលជាច្រើនយ៉ាងណាក្តី ខ្ញុំត្រូវបានបង្ខំឲ្យនៅស្ងៀម ហើយបន្តធ្វើការដូចធម្មតា ។ ខ្ញុំបានរស់នៅចម្ការកៅស៊ូនេះរហូតដល់កងទ័ពរំដោះវៀតណាមបានវាយទម្លាក់ខ្មែរក្រហមពីអំណាច ។

នៅចន្លោះឆ្នាំ១៩៧៥ និងឆ្នាំ១៩៧៩ សមាជិកគ្រួសារខ្ញុំចំនួនប្រាំមួយនាក់បានបាត់ខ្លួន ហើយខ្ញុំបានគិតថាអ្នកទាំងអស់បានស្លាប់ហើយ ។ ប៉ុន្តែ ប៉ុន្មានឆ្នាំក្រោយថ្ងៃរំដោះ ខ្ញុំបានទទួលដំណឹងថា ប្តីខ្ញុំត្រូវបានឃុំឃាំង និងសម្លាប់នៅមន្ទីរស-២១ ដែលសព្វថ្ងៃនេះគឺជាសារមន្ទីរទួលស្លែង ។ តាមពិត វីន ជាអ្នកជិតខាងខ្ញុំបានមកលេងទីក្រុងភ្នំពេញ និងបានទៅទស្សនាសារមន្ទីរទួលស្លែង ហើយក៏បានឃើញរូបថតប្តី ខ្ញុំនៅទីនោះ ។ វីន បានបញ្ជាក់ថាប្តីខ្ញុំបានស្លាប់ហើយ ។ ខ្ញុំពិតជាចង់ទៅគុកទួលស្លែង ប៉ុន្តែខ្ញុំមិនមានថវិកាសម្រាប់ការធ្វើដំណើរនិងស្នាក់នៅទេ ។ ខ្ញុំក៏មិនដឹងថាគុកទួលស្លែងនោះនៅឯណាដែរ ។ ចាប់តាំងពីពេលនោះមក ខ្ញុំបានដឹងយ៉ាងច្បាស់ថាអនាគតក្រុមគ្រួសារខ្ញុំនឹងតែលតោលដោយគ្មានពុកនិងប្តីដែលជាមេគ្រួសារ ។

កេរ្តិ៍តំណែលពីរបបខ្មែរក្រហមបានបន្សល់ទុកឲ្យខ្ញុំនូវភាពក្រីក្រដំឹង ការបែកបាក់គ្រួសារ ភាពភ័យខ្លាច ការមិនជឿទុកចិត្ត និងភាពតានតឹងផ្លូវចិត្ត ។ ខ្ញុំនិងកូនស្រីបីនាក់ខ្ញុំបានតស៊ូជម្នះនឹងសោកនាដកម្មរបស់យើងដោយភាពឈឺចាប់ផ្លូវកាយ និងផ្លូវចិត្ត ។ ការរស់នៅឆ្លងកាត់ស្ថានភាពលំបាកវេទនារបស់កូនខ្ញុំបានធ្វើឲ្យខ្ញុំនឹកឃើញដល់អតីតកាលនៃខ្សែជីវិតខ្ញុំ និងប្តីខ្ញុំក្រោមរបបខ្មែរក្រហម ។ ខណៈដែលពេលវេលាចេះតែកន្លងផុតទៅ ហើយកូនៗខ្ញុំក៏បានធំដឹងក្តី ខ្ញុំបានងាកមកគិតពីអតីតកាលដ៏ឈឺចាប់របស់ខ្ញុំ ។ ខ្ញុំក៏បានសម្រេចឲ្យ "អតីតកាលនេះកន្លងផុតទៅ" ។ ប្តីខ្ញុំពិតជាស្លាប់មែន ហើយគ្មានអ្វីអាចកែប្រែឬនាំយកប្តីខ្ញុំមកវិញបានឡើយ ។ ខ្ញុំក៏ទុកឲ្យពេលវេលាដើរទៅមុខ ហើយក៏មានអារម្មណ៍ធូរស្បើយ ។ យ៉ាងណាមិញ ការចងចាំទាំងអស់នោះមិនងាយនឹងសាបរលុបឡើយ ខ្ញុំយល់ថាយុត្តិធម៌នឹងជួយឲ្យខ្ញុំបំភ្លេចនូវទំព័រអតីតកាលដ៏ឃោរឃៅនេះ ។

**កុំ មេន**



កុំ មេន (រូបឈរទីប្រាំពីខាងស្តាំ) ថតរូបជាមួយដើមបណ្តឹងរដ្ឋប្បវេណីនៅសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង

# ជីវិតគ្រួសារខ្ញុំត្រូវប្រល័យលើទឹកដីកំណើត

ខ្ញុំកើតនៅខែកញ្ញា ឆ្នាំ១៩៦២ នៅស្រុកគងពិសី ខេត្តកំពង់ស្ពឺ ។

នៅឆ្នាំ១៩៧២សង្គ្រាមរវាងយោធាខ្មែរក្រហមនិងទាហានកន្សែងខៀវ លន់ នល់ បានកម្ទេចទីនេះក្លាយជាផេះផង់ ។ ពេលនោះគ្រួសារខ្ញុំត្រូវបង្ខំភៀសខ្លួនមកនូវភូមិអារិយក្សត្រ ស្រុកល្វាឯម ខេត្តកណ្តាល ។ រស់នៅទីនោះបានមួយឆ្នាំដោយសភាពការណ៍មិនសូវស្រួលឈ្លបខ្មែរក្រហមតែងតែឆ្មក់ចូលជាញឹកញាប់ ។ ម្តាយខ្ញុំបានផ្លាស់មកនៅសង្កាត់គីឡូម៉ែត្រលេខ៤ ក្រុងភ្នំពេញជាមួយបងខ្ញុំម្នាក់មានមុខងារជាអនុសេនីយឯកនៃកងទ័ពអាកាសរបស់សាធារណរដ្ឋខ្មែរ ។

ឆ្នាំ១៩៧៤ ក្រុងភ្នំពេញមានភាពវឹកវរជ្រួលច្របល់យ៉ាងខ្លាំងដោយយោធាខ្មែរក្រហមឡោមព័ទ្ធស៊ើរជុំវិញទីក្រុង ហើយតំបន់ខ្លះត្រូវទទួលរងនូវគ្រាប់ផ្លោងជារៀងរាល់ថ្ងៃ ។ បងខ្ញុំពិគ្រោះជាមួយឪពុកម្តាយខ្ញុំគួរតែចាកចេញពីទីក្រុងភ្នំពេញទៅរស់នៅសហរដ្ឋអាមេរិក ។ ដោយគាត់ដឹងថា ពេលខាងមុខយោធាខ្មែរក្រហមនឹងវាយចូលដល់កាន់កាប់ទីក្រុងទាំងមូលខ្មែរក្រហមនឹងសម្លាប់ប្រជាជននៅទីនេះមិនខានឡើយ ។ ម្តាយខ្ញុំបដិសេធមិនទៅទេ គាត់ពន្យល់ទៅបងខ្ញុំវិញថាមិនអាចចាកចេញពីស្រុកកំណើតទេ និងប្រាប់ទៀតថាខ្មែរក្រហមធ្វើសង្គ្រាមដើម្បីរំដោះជាតិ អ្នកទាំងនោះមិនសម្លាប់ប្រជាជនទេ ។ ការយល់ដូចនេះដោយសារគាត់ស្តាប់វិទ្យុខ្មែរក្រហម និងវិទ្យុប៉េកាំង ។

### ការដួលរលំនៃរបបសាធារណរដ្ឋខ្មែរ

នៅល្ងាចថ្ងៃទី១៦ ខែមេសា ឆ្នាំ១៩៧៥ ប្រជាជនឃើញរថក្រោះបើកយ៉ាងគគ្រឹកគគ្រេងថយពីខ្សែត្រៀមចូលទៅកណ្តាលទីក្រុងភ្នំពេញ ។ នេះជាការទម្លាក់អាវុធរបស់ទាហាន លន់ នល់ ។ ឈានចូលដល់ថ្ងៃទី១៧ ខែមេសា វេលាម៉ោងបួនទាបភ្លឺ សំឡេងគ្រាប់ផ្លោងលាយឡំជាមួយនឹងគ្រាប់កាំភ្លើងដៃព្រមទាំងសម្រែកនៃកងយោធាខ្មែរក្រហមបានសម្រុកចូលដល់ទីក្រុងភ្នំពេញដែលជាបេះដូងនៃប្រទេសកម្ពុជា ។ ព្រលឹមស្រាងៗ ឡើងកងយោធាឯកសណ្ឋានពណ៌ខ្មៅយ៉ាងច្រើនដើរតាមដងវិថីសហព័ន្ធរុស្ស៊ីមានក្រុមសាស្ត្រាចារ្យ និស្សិត ប្រជាជនជាច្រើនលើកគ្រវីទង់សព្រមទាំងស្រែកជ័យយោសដើម្បីទទួលកងទ័ពរំដោះ ។

### សភាពការណ៍ប្រែប្រួល

បន្ទាប់ពីសភាពអ៊ូអរទទួលអំណរជ័យជម្នះរបស់កងទ័ពរំដោះកន្លងទៅ សភាពស្ងប់ស្ងាត់នៅតាមដងវិថីនិងមហាវិថីនានាក៏ចាប់ផ្តើមឡើង ។ នៅវេលាម៉ោងពីររសៀលថ្ងៃដដែលនោះ គេឃើញកងទ័ពប្រដាប់ដោយឧបករណ៍បំពងសំឡេងព្រមទាំងកាន់អាវុធជាប់ដៃដើរចេញពីក្រុងភ្នំពេញស្រែកប្រកាសឲ្យប្រជាជនចាកចេញពីទីក្រុងភ្នំពេញដោយបញ្ជាក់ថាអាមេរិកនឹងមកទម្លាក់គ្រាប់បែក ។ ពេលនោះប្រជាជនទាំងឡាយបានធ្វើដំណើរយ៉ាងកកកុញនៅតាមវិថីកម្ពុជាក្រោមឆ្ពោះទៅទិសខាងលិច ។ ក្នុងនោះមានទាំងគ្រួសារខ្ញុំក៏បានរុញឡានសន្សឹមៗក្នុងចំណោមហ្វូងប្រជាជនណែនតាន់តាប់នោះផងដោយធ្វើដំណើរមិនឈប់រហូតដល់ព្រលប់ទើបឈប់នៅខាងកើតផ្សារទឹកថ្លា ។ ព្រលឹមស្រាងៗ ក្រុមកងទ័ពស្លៀកបំពាក់ខ្មៅបណ្តេញប្រជាជនពីក្រោយឲ្យធ្វើដំណើរទៅមុខទៀត ។

ពេលធ្វើដំណើរខ្ញុំឮតែសំឡេងយំលាយឡំនឹងសំឡេងថ្ងូរនៃអ្នកជំងឺរុញនៅលើគ្រែពេទ្យស្រែកសួររកឪពុកម្តាយបងប្អូនកូនចៅ ។ រីឯនៅអមសងខាងផ្លូវប្រទះឃើញសាកសពជាច្រើនខ្លះមានស្លៀកបំពាក់ជាយោធា ខ្លះជាប្រជាជនដេកស្លាប់ប្រឡាក់ដោយឈាមក្រោមកំដៅថ្ងៃខែចែត្រគួរឲ្យអាណោចអាធ័ម ។ ពេលធ្វើដំណើរពេលខ្លះ ខ្ញុំឃើញកងទ័ពដែលប្រកបទៅដោយវិន័យសីលធម៌របស់ខ្មែរក្រហមបានស្នើយកម៉ូតូ នាឡិកា ឬសម្ភារណាដែលត្រូវការពីប្រជាជនប្រៀបដូចជាការប្តូរអីចឹងដូនកាលខ្ញុំបាន

ឃើញអង្គការចងមនុស្សស្រាតនូវតែខោខ្លីបណ្តើរទាំងហ្វូងមិនដឹងជាយកទៅណាទេ ។

ឃើញទិដ្ឋភាពទាំងនេះ បងខ្ញុំប្រាប់ថានេះហើយជារបបកុម្មុយនីស្ត ។ ការធ្វើដំណើរពេញមួយថ្ងៃក្រោយពេលព្រះអាទិត្យលិចបាត់ទៅគ្រួសារខ្ញុំបានមកដល់ស្ពឹងកំពង់ទួលក៏ឈប់សម្រាកយប់ទីពីរ ។ នៅទីនេះក្រោយពេលបាយរួច បងៗខ្ញុំបានប្រមូលអ្វីៗដែលពាក់ព័ន្ធជាមួយទាហានយកទៅបោះចោលនៅតាមគុម្ពោតព្រៃអមស្ពឹង ។ ឈានចូលដល់ថ្ងៃទីបី គ្រួសារខ្ញុំបានមកដល់ត្រាំខ្នារហើយត្រូវអង្គការដកយកឡានព្រមទាំងសម្ភារៈមួយចំនួន ។ ដោយគ្មានសង្ឃឹមថាមិនអាចត្រឡប់ក្រោយវិញបាន បងខ្ញុំក៏សម្រេចចិត្តតាមម្តាយខ្ញុំធ្វើដំណើរបន្តមកនៅភ្នំស្រង់ដែលជាស្រុកកំណើតខ្ញុំតែម្តង ។

## ផែនការប្រមូលផ្តុំប្រជាជន១៧មេសា

សង្គ្រាមបានបញ្ចប់ គ្រួសារខ្ញុំក៏ដូចជាគ្រួសារប្រជាជនដែលមកពីភ្នំពេញដទៃទៀតដែរសង្ឃឹមថានឹងមានជីវិតត្រឡប់មកស្រុកវិញរស់នៅដោយសេចក្តីសុខសាន្ត ។ ផ្ទុយទៅវិញអង្គការប្រមូលគ្រួសារណាមកពីភ្នំពេញឲ្យទៅរស់នៅភូមិថ្មីដោយឡែកពីប្រជាជនចាស់ (ប្រជាជនមូលដ្ឋាន) ។ ក្រោមការតាមដាននិងស្រង់ប្រវត្តិរូប អ្នកណាមាននិន្នាការជាអតីតមន្ត្រីរាជការ ទាហានលន់ នល់ ដោយខ្មែរក្រហមកុហកថា នឹងបញ្ជូនឲ្យទៅទទួលសម្តេចផ្ទុយទៅវិញគ្រួសារទាំងនោះត្រូវខ្មែរក្រហមយកទៅសម្លាប់ទាំងអស់ ។

## ឃុំផុងអន្លង់មរណៈ

ជីវិតប្រជាជន១៧មេសាដូចជាជីវិតសត្វរស់នៅក្រោមការតាមដានឬយកទៅសម្លាប់ថ្ងៃណាក៏បានតាមតែអង្គការកំណត់ ។ បន្ទាប់ពីរស់នៅក្នុងភូមិថ្មីនេះពីរខែ អង្គការបានបញ្ជូនឲ្យទៅរស់នៅក្នុងភូមិថ្មីមួយទៀត ។ នៅកណ្តាលព្រៃនៃទឹកដីឃុំផុង ទីនោះជាកន្លែងលត់ដំមួយដ៏ធំរបស់ស្រុក៥៣ ។ ប្រជាជនដែលបញ្ជូនមកដល់ទីនេះមិនដែលបានត្រឡប់ទៅវិញទេ ដោយទីនោះជាតំបន់ចាញ់សម្បូរសត្វសាហាវ គ្មានអ៊ីហ្វូប ខ្មែរក្រហមបង្ខំឲ្យធ្វើការបាក់កម្លាំងក៏ដូចជាធ្វើទារុណកម្មរួចយកទៅសម្លាប់ ។ ដូចជាមន្ទីរតាអែសូម្បីតែដំឡូងក៏ដាំលើរណ្តៅខ្មោចដែរ គឺពេលដកឡើងដោយទាំងឆ្អឹងខ្មោចមកជាមួយក៏មាន ។

ក្រោយពីទៅដល់ទីនោះ គ្រួសារខ្ញុំក៏ដូចជាគ្រួសារឯទៀតត្រូវបាត់បង់សមាជិកគ្រួសារស្លាប់ជារៀងរាល់ថ្ងៃដោយជំងឺគ្មានថ្នាំព្យាបាល មានគ្រួសារខ្លះឈ្លបហៅយកទៅសម្លាប់ទាំងអស់ជាបន្តបន្ទាប់ ។ មនុស្សរាប់រយនាក់ត្រូវធ្វើការបាក់កម្លាំង ខ្លះហើមខ្លះគ្រុនចាញ់ អង្គុយក្បាលជង្គង់ទាំងពីរស្មើក្បាល ទិដ្ឋភាពបែបនេះក្រុមឈ្លបក្មេងៗតែងសើចចំអកឬគេហៅយើងថាពួកអាសម័យពួកអាកម្លាំងទីបី (អាឱលអំប៉ប់) ដែលមានន័យថា (អា ១៧) ។

នៅទីនេះក្មួយជាទីស្រលាញ់ខ្ញុំពីរនាក់បានស្លាប់ដោយជំងឺរាគ រីឯរូបខ្ញុំនិងបង ឈឺគ្រុនចាញ់ញាក់ជារៀងរាល់ថ្ងៃហើយខំធ្វើការមិនហ៊ានឈប់ ព្រោះខ្លាចអង្គការយកទៅសម្លាប់ ។

ព្រឹកថ្ងៃមួយក្រុមឈ្លបប្រាប់ថាអង្គការឲ្យប្រជាជនទាំងអស់ទៅមហាសន្និបាត ដោយមិនឲ្យយកអ្វីទៅជាមួយឡើយ ។ ពេលនោះគ្រប់ៗគ្រួសារដឹងថា អង្គការប្រមូលយកទៅសម្លាប់ហើយ ។ ខ្លះយកកាំបិតពូថៅ សម្ភារៈណាសំខាន់ៗដាក់ជាប់នឹងខ្លួនគ្រានោះ បងស្រីដែលមានផ្ទៃពោះប្រាំពីរខែបានឃ្លបង្អិចពីខ្ទមឈ្លបម្នាក់ស្ទុះទៅឆក់យក រួចទាត់ធាក់និងវាយគាត់នឹងស្នូលកាំភ្លើងរហូតគាត់ដួលហូរឈាមប្រលាក់ដោកសម្លៀកបំពាក់ ។ ឃើញដូច្នេះប្តីគាត់រត់ទៅលើកពររត់គេចចូលទៅក្នុងហ្វូងមនុស្សរាប់ពាន់នាក់ដែនការសម្លាប់ត្រូវប្រជាជនដឹងអស់ ហើយអ្នកខ្លះមានកាំបិតពូថៅនៅជាប់ខ្លួនផងហ្វូងប្រជាជនដឹកកកុញបានចេញពីព្រៃនោះមកផ្លូវលំមួយឆ្ពោះមករកភូមិស្លាបលែង ។

ថ្ងៃរសៀលបន្តិច មានម៉ូតូសេអិលមួយជិះមកស្ទាក់ផ្លូវអ្នកខ្លះស្គាល់អ្នកជិះនោះថា (តាអែ) ប្រធានស្រុក៥៣ (ស្រុកគងពិសី) ។ ក្រោយឈប់នៅខាងមុខ តាអែ ប្រាប់កងឈ្លបដែលដើរភ្ជង់ហ្វូងមនុស្សថាបំបែកប្រជាជនទាំងអស់នេះឲ្យចូលរស់នៅតាមភូមិជាមួយមូលដ្ឋានវិញ ។

## ផែនការពន្យារស្រាយស្រួលសម្លាប់

ក្រោយពីទទួលផែនការរបស់ តាអែ គណៈស្រុក៥៣មកខ្មែរក្រហមបានបញ្ជូនប្រជាជនថ្មីទាំងអស់ឲ្យចូលទៅរស់នៅតាមភូមិជាមួយប្រជាជនចាស់ទូទាំងស្រុក៥៣ ។

គ្រួសារខ្ញុំរួមជាមួយគ្រួសារមួយចំនួនត្រូវបញ្ជូនទៅនៅ

ភូមិមួយឈ្មោះភូមិក្រោលក្របី ឃុំកក ។ គ្រួសារខ្ញុំក៏ដូចជាគ្រួសារអ្នកឯទៀតដែរ អង្គការបានបញ្ជូនទៅធ្វើការតាមកងចល័តផ្សេងៗគ្នាទាំងអស់ ។

ខ្ញុំត្រូវទៅរស់នៅក្នុងកងចល័តកុមារឃុំ ពេលខ្លះខ្ញុំនឹកក្តុយឪពុកម្តាយ បងប្អូនខ្លាំងពេក ខ្ញុំលួចរត់មកផ្ទះ ពេលយប់កាត់ព្រៃជួបរណ្តៅខ្មោចមានដំបងប្រលាក់ឈាមដែលគេទើបនឹងវាយមនុស្សចោលថ្មីៗក៏មាន ។ មានយប់មួយខ្ញុំឮប្រធានកងខ្ញុំឈ្មោះ មិត្ត សំ និយាយប្រាប់គ្នាគេថាទើបតែមកពីវាយខ្មាំងចោលគ្រួសារ (ប្រជាជន១៧មេសា ឈ្មោះ ថា) ដោយឲ្យគាត់ឆ្លើយថា ពាក់សក្តិ៣សេ.អ៊ី.អារបស់អាមេរិកទើបអង្គការសម្លាប់ចោលតែម្តង ។

ថ្ងៃមួយនោះ កងរបស់ខ្ញុំទៅស្ទូងលើដើម្បីដាំដំឡូងនិងធ្វើព្រៃពោត ។ ខ្ញុំប្រទះឃើញទិដ្ឋភាពជាច្រើនគួរឲ្យស្លុតនោះគឺកន្លែងវះពោះមនុស្សយកប្រមាត់ នៅស្នាមឈាមប្រលាក់ជាប់នឹងដើមពង្រ រណ្តៅសាកសព និងលលាដ៏ក្បាលនៅរាយពាសពេញព្រៃ ។ កុមារមូលដ្ឋានប្រាប់ខ្ញុំថា ទីនេះជាមន្ទីររបស់ឈ្មោះ ភាព (គណៈតំបន់៣៣) ។ អង្គការបានចាប់ទាហាននិងប្រជាជនដោយចាត់ទុកជាឈ្លើយសឹកបញ្ជូនមកទីនេះឬក៏បញ្ជូនទៅមន្ទីរតាអែឲ្យធ្វើការជាទម្ងន់បាក់កម្លាំងទើបអង្គការយកទៅសម្លាប់ចោល នៅកម្លាំងមាំសាច់ស្អាតល្អត្រូវគេយកទៅវះពោះទាំងរស់យកប្រមាត់ខ្លះចាប់ចងដើងព្យួរនៅតាមដើមឈើយោលរហូតទាល់តែស្លាប់ជួនកាលកងឈ្លបណើ្តរឲ្យរត់ទាំងហូងទើបបាញ់វះសម្លាប់ ។

## ជំណើងដែលគួរឲ្យរន្ធត់

រដូវច្រូតដើមឆ្នាំ១៩៧៧ ថ្ងៃមួយនោះដោយឮថាកងចល័តរបស់បងខ្ញុំមកច្រូតស្រូវនៅភូមិត្រពាំងពើក នឹកគាត់ពេកពេលសម្រាកថ្ងៃត្រង់ខ្ញុំរត់ទៅជួបគាត់តែអកុសលទៅដល់កន្លែងកងគាត់ បងម្នាក់ឈ្មោះ បង សឹន ប្រាប់ថា បង ហេង ត្រូវមិត្ត ចន ប្រធានសាខាឃុំ ហៅយកទៅសម្លាប់កាលពីល្ងាចមិញនេះ រីឯខោអាវ គេចែកគ្នាអស់ទៅហើយ ។ កូនគាត់នៅភូមិក៏ត្រូវមិត្ត នឹម ប្រមូលយកទៅសម្លាប់នៅឯទួលខ្មោច ចំពោះឪពុកម្តាយឯង មិត្ត នាង ប្រុងយកទៅសម្លាប់ដែរ តែមិត្ត ហៀង ថាគ្មានរទេះដឹកទេ ព្រោះគាត់ឈឺដើរមិនរួចទុកឲ្យស្លាប់ខ្លួនឯងទៅ ។ បង សឹន ប្រាប់បន្ថែមទៀតថាប្អូនឯងប្រយ័ត្នខំប្រឹងធ្វើការលត់ដំខ្លួនតាមអង្គការ ។

## ទុក្ខមួយមិនទាន់ផុត ទុក្ខថ្មីមួយទៀតក៏មកដល់

ព្រឹកថ្ងៃបន្ទាប់ ហ្វូងកុមារនៅកងជាមួយមកពីភូមិសួរខ្ញុំថាមានឮស្នូរកាំភ្លើងទេពេលមុននេះបន្តិចរួច បញ្ជាក់បន្ថែមទៀតថាកងឈ្លបគេដេញបាញ់បង ហាក់ បងរបស់ឯងស្លាប់បាត់ទៅហើយ ។ ខ្មោចគាត់នៅចោលក្រោមដើមឈើខាងត្បូងភូមិថ្នល់ដាច់ មិនមាននរណាទៅមើលឡើយ ព្រោះអង្គការចោទគាត់ថា ជាសេ.អ៊ី.អាខ្មាំងបង្កប់នៅក្នុងមូលដ្ឋាន ។ តើមានអ្វីកើតឡើងទៀតនៅថ្ងៃខាងមុខ បន្ទាប់ពីបងៗនិងក្មួយៗជាទីស្រលាញ់ត្រូវបានអង្គការសម្លាប់ ឪពុកម្តាយឈឺដើរមិនរួចគ្មានអ្វីហូបនិងអ្នកមើលថែ ។ ខ្លួនឯងរស់រងចាំថ្ងៃអង្គការយកទៅសម្លាប់ព្រោះអង្គការអនុវត្ត (ជីកស្មៅត្រូវជីកទាំងឫស) ។ ម្តងនោះ នៅកងគ្មានអង្ករដាំបបរ ប្រធានកងស្នើខ្ញុំឲ្យទៅស្នើដំឡូងតាមសហករណ៍ ហើយខ្ញុំបានលួចចូលទៅមើលឪពុកម្តាយខ្ញុំអ្វីដែលគួរអោយខ្លោចផ្សានោះគឺៈ ម្តាយខ្ញុំភ្នែកឈឺរាវពពើមថែមទាំងអង្គការឲ្យមើលក្មេងតូចៗពីរនាក់ទៀតដែលជាកូនប្រជាជននៅក្នុងភូមិ) ពេលដឹងថាខ្ញុំមក គាត់ប្រាប់ខ្ញុំថាគាត់ឈឺភ្នែកខ្លាំងណាស់ ពេលយប់រុកសឹងតែផ្ទុះទៅហើយពេលដឹងថាកូនត្រូវអង្គការសម្លាប់ ចំណែកចៅរស់ជាមួយក៏មិនទុកទៀត ឪពុកឈឺដេកលើរនាបរហូតមក ។ ពេលទៅសុំបបរយកមកឲ្យគាត់ សេដ្ឋកិច្ចមិត្ត មាំង និងយាយ ម៉ុន គេដេរស្តីឲ្យជួនកាលលើកវែករកវាយម៉ែ ហើយស្រែកខ្លាំងៗថាស៊ីធ្វើអី ។ ខ្ញុំចូលទៅរកឪពុកខ្ញុំនៅក្នុងខ្ទមងងឹត សម្លឹងទៅរកគាត់តាមពន្លឺថ្ងៃដែលចាំងចូលតាមដំបូលនិងជញ្ជាំងដែលធ្លុះធ្លាយឃើញគាត់សំរាន្តនៅលើរនាបឬស្សីរដេករដុបខាងក្រោមមានរណ្តៅលាមកនិងជេះព្រោះគាត់ងើបមិនរួច ។ ខ្ញុំលូកដៃប្របាច់ជើងគាត់ប៉ះឆ្អឹងខ្នងដូចជាមុខកាំបិត ។ គាត់សួរដោយសំឡេងខ្សាវថានរណា? ខ្ញុំឆ្លើយថា គឺខ្ញុំ ផ្លូន ។ គាត់ហាមាត់ហបៗចេញតែខ្យល់និយាយថា "កូនមានអីហូបទេ ឲ្យពុកហូបផងពុកហេវណាស់" ។ គាត់និយាយលែងរួចដោយហេវហត់ ។ ឃើញនិងឮសម្តីគាត់ធ្វើឲ្យខ្ញុំស្រណោះអាណិតខ្លោចចិត្តស្ទើរបាត់វិញ្ញាណហើយសួរខ្លួនឯងថាតើរកថ្នាំពេទ្យឬអ្វីឲ្យគាត់ហូបនៅឯណា? បើខ្លួនឯងនៅឯកងមិនដែលឃើញឬស្គាល់ថ្នាំពេទ្យ រីឯអ្វីហូបក៏គ្មាន ព្រោះជួនកាលត្រូវដាច់ពេលពីរឬទៅបីថ្ងៃក៏មាន ។ ដោយនៅយូរមិនកើតមុននឹងឈាន

ជើងចេញខ្ញុំយកក្បាលខ្ញុំដាក់ក្រោមជើងគាត់យកដៃស្ទាបគាត់ជាលើកចុងក្រោយរួចលាឪពុកម្ដាយខ្ញុំចេញទៅ ។

រយៈពេលមួយខែក្រោយមក កុមារីម្នាក់មកពីភូមិប្រាប់ថាឪពុកខ្ញុំស្លាប់ហើយ ។ ខ្ញុំបានសុំប្រធានកងឈ្មោះមិត្ត សំ ទៅមើលគាត់ ប្រធានកងនោះឆ្លើយថា ទៅមើលធ្វើអ្វីបើគាត់ស្លាប់ទៅហើយនោះ ។ ខ្ញុំដាច់ចិត្តរត់ទៅមើលឪពុកដោយមិនខ្លាចគេសម្លាប់ឡើយ ។ ពេលទៅដល់ សពរបស់ឪពុកខ្ញុំត្រូវគេរុំយកទៅកប់បាត់ទៅហើយ ដួនគ្នានោះដែរបងស្រីខ្ញុំម្នាក់កំពុងពរកូននៅជាប់នឹងដៃមកមើលឪពុកស្លាប់នោះត្រូវយាយ ប៉ុន តាមមកហៅថាដោយនិយាយថា នាង ហៀង អង្គការចាត់តាំងនាងឲ្យទៅកើបអាចម៍គោនៅក្រោយឯជើងភ្នំ ឥឡូវនេះយកខោអាវទៅផងព្រោះទីនោះរងារណាស់ ។ ដោយឃើញយាយ ប៉ុន ហៅដូច្នេះគាត់ភ័យញ័រទទ្រើកស្ទើរធ្លាក់កូនពីដៃព្រលឹងចេញបាត់ពីខ្លួនដោយដឹងថាតែយាយ ប៉ុន ហៅពីណាទៅហើយ អ្នកនោះមិនដែលគេចរួចពីការយកទៅសម្លាប់ចោលទេ ។

គ្រានោះមានរទេះគោដឹកក្មេងៗប្រលែងគ្នាពេញនៅលើរទេះ ឯម្ដាយដឹងខ្លួនថាត្រូវទៅសម្លាប់ទទូរក្រមាយំ ។ នៅខាងក្រោយរទេះមានឈ្លបបីនាក់ស្ពាយកាំភ្លើងដើរតាមដែលខ្ញុំស្គាល់ម្នាក់មានមាឌធំនោះគឺឈ្មោះ ជឹម ឈ្លបឃុំ ។ ពេលដែលរទេះគោមកដល់មុខផ្ទះយាយ ប៉ុន ស្រែកបង្គាប់ឲ្យបងស្រីខ្ញុំថារទេះមកដល់ហើយដោយគាត់មានរោគហើម ពរកូនតូចនៅជាប់ដៃឈានជើងស្ទើរមិនរួច ភ្លាមនោះ យាយ ប៉ុន ស្ទុះទៅអូសដៃគាត់ធ្វើដំណើរតាមរទេះគោសំដៅទៅរកព្រៃឯជើងភ្នំពេលនោះខ្ញុំតាមសម្លឹងមើលគាត់គួរឲ្យខ្លោចផ្សាដោយមិនអាចជួយគាត់បានរហូតដល់ដាច់កន្ទុយភ្នែកបាត់ស្រមោលឈឹងតាំងពីពេលនោះមកមិនដឹងថាយកឈ្លបទៅសម្លាប់កប់នៅទីណាឡើយ ។ពេលរសៀលបន្តិចមានបុរសពីរនាក់ជាប្រធានកងគេបានមកកកាយយករបស់របរនៅក្នុងផ្ទះម្ដាយរបស់ខ្ញុំដោយនិយាយថាបងស្រីខ្ញុំឲ្យមកយក ។

អ្នកស្លាប់ ស្លាប់ទាំងបិទភ្នែកមិនជិត អ្នកនៅសោកសៅរស់នៅទាំងវេទនារង់ចាំគេយកទៅសម្លាប់បន្ត ។ ឪពុក បងៗព្រមទាំងក្មួយៗត្រូវស្លាប់អស់ ឯម្ដាយខ្ញុំត្រូវរស់នៅឯកោភ្នែកឡើងបាយឈឺមើលអ្វីសឹងតែមិនឃើញត្រូវខ្មែរក្រហមបង្ខំឲ្យធ្វើការគ្មានពេលសម្រាក ។

ចំណែករូបខ្ញុំត្រឡប់ទៅកងវិញ មិនដឹងថាត្រូវឈ្លបធ្វើទារុណកម្មឬយកទៅសម្លាប់ឡើយថ្ងៃណា ។

ថ្ងៃមួយស្នូរកាំភ្លើងឮយ៉ាងខ្លាំងនៅទិសខាងកើត ប្រធានកងទាំងអស់មកប្រជុំឯសាលាឃុំ ។ ខ្ញុំឮគេនិយាយថា ពួកបូព៌ាក្បត់អង្គការឲ្យរៀបចំរទេះគោក្របីត្រៀមស្បៀងអាហារសម្រាប់រត់ចូលព្រៃតស៊ូទៀត ។ ជាឱកាសល្អពេលសភាពការណ៍វាកំពុងជ្រួលច្របល់ខ្ញុំបានរត់ទៅរកម្ដាយខ្ញុំនៅឯភូមិ ។

ក្រោយថ្ងៃ៧ មករា គ្រួសារខ្ញុំត្រូវបាត់បង់ឪពុក បងៗដែលជាទីបង្អែកព្រមទាំងក្មួយជាទីស្រលាញ់សរុបដប់នាក់ ។ អំឡុងរបបខ្មែរក្រហមគ្រប់គ្រងអំណាចប្រទេសកម្ពុជា ប្រជាពលរដ្ឋខ្មែរត្រូវសម្លាប់រង្គាលតាមរយៈបង្អត់អាហារ បង្ខំឲ្យធ្វើការធ្ងន់បាក់កម្លាំងនិងការសម្លាប់ ។ ជាងនេះទៅទៀត កម្មាភិបាលកងឈ្លបភូមិឬឃុំមានសិទ្ធិបណ្ដើរមនុស្សយកទៅសម្លាប់ចោលដូចសត្វធាតុដោយឡែកនៅភូមិភាគនិរតីដឹកនាំដោយ តា ម៉ុក ដែលជាលេខាភូមិភាគខ្មែរក្រហមប្រមូលគ្រួសារប្រជាជន១៧មេសាយកទៅធ្វើទារុណកម្មយ៉ាងសាហាវព្រៃផ្សៃជាទីបំផុត ។ ចំណែកក្មេងៗត្រូវគេប្រមូលដុតទាំងរស់និងមានវិធីសម្លាប់ជាច្រើនទៀតដែលខ្ញុំមិនអាចអធិប្បាយអស់ឡើយ ។

តើអំពើប្រល័យពូជសាសន៍និងបទឧក្រិដ្ឋទាំងនេះអ្នកណាជាអ្នកទទួលខុសត្រូវ បើមេដឹកនាំនៃរបបខ្មែរក្រហម (បើលោក ខៀវ សំផន និងមេដឹកនាំមួយចំនួនទៀតឆ្លើយថាមិនដឹងនោះ) ។ នេះមិនខុសពីចោរដែលចាប់បានហើយឆ្លើយថាខ្លួនមិនមែនចោរនោះទេ ។

ចុងបញ្ចប់ដើម្បីអោយព្រលឹងអ្នកស្លាប់នៅក្រោមរបបព្រៃផ្សៃនេះបិទភ្នែកជិតផងនោះ ខ្ញុំសូមអំពាវនាវដល់រដ្ឋាភិបាលអង្គការអន្តរជាតិសហគមន៍អន្តរជាតិ ក៏ដូចជាតុលាការសូមកាត់ទោសមេស្ដាបនិកនៃរបបវាលពិឃាដឲ្យសក្តិសមកំហុសដែលខ្លួនប្រព្រឹត្ត ។ ខ្ញុំសង្ឃឹមថាក្រោមកិច្ចប្រឹងប្រែងពីមជ្ឈមណ្ឌលឯកសារកម្ពុជានឹងមិនធ្វើឲ្យវិញ្ញាណក្ខន្ធអ្នករងគ្រោះព្រមទាំងប្រជាពលរដ្ឋកម្ពុជាខកចិត្តឡើយ ។

**ហ៊ុំ ឌួន**

# សៀវភៅរំឭកវិញ្ញាណក្ខន្ធអ្នកដែលបានស្លាប់ នៅក្នុងរបបខ្មែរក្រហម










មជ្ឈមណ្ឌលឯកសារកម្ពុជា គ្រោងនឹងបោះពុម្ពផ្សាយនូវសៀវភៅមានកត់ត្រាឈ្មោះរបស់អ្នកដែលស្លាប់បាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហម ។ កន្លងមក មជ្ឈមណ្ឌលឯកសារកម្ពុជាបានចងក្រងនូវឈ្មោះអ្នកដែលស្លាប់ជាង១លាននាក់រួចមកហើយ ។ ប្រសិនបើលោកយាយ លោកតា អ៊ុំ ពូ មីង ប្រាថ្នាចង់ឲ្យឈ្មោះសមាជិកក្រុមគ្រួសារដែលបានស្លាប់បាត់បង់ជីវិតមាននៅក្នុងសៀវភៅនេះ សូមទាក់ទងមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជាតាមរយៈ អេង កុកថាយ ទូរស័ព្ទលេខ ០១២ ៩៥៥ ៨៥៨ ឬ អ៊ីម៉ែល : truthkokthay@dccam.org ឲ្យបានឆាប់រហ័សតាមពេលវេលាដែលអាចធ្វើទៅបាន ។

***សូមផ្តល់ព័ត៌មានដូចខាងក្រោមៈ***

១) ឈ្មោះអ្នកប្រកាសប្រាប់, ២) តើមានបងប្អូនបង្កើតរួមទាំងឪពុកម្តាយស្លាប់ប៉ុន្មាននាក់នៅក្នុងសម័យខ្មែរក្រហម? ៣) ឈ្មោះអ្នកស្លាប់, ៤) ភេទអ្នកស្លាប់, ៥) អាយុអ្នកស្លាប់ (បើអាចចាំបាន), ៦) ត្រូវជាអ្វីនឹងអ្នកប្រកាស (ឧទាហរណ៍ៈ ឪពុក ម្តាយ បងប្រុស ប្អូនប្រុស បងស្រី ឬប្អូនស្រី), ៧) សាច់រឿងទាក់ទងនឹងការស្លាប់ (ឧទាហរណ៍ៈ ស្លាប់នៅទីណា? មូលហេតុអ្វី?), ៨) វត្ថុតាងទាក់ទងនឹងអ្នកស្លាប់ (ឧទាហរណ៍ៈ រូបថត ឯកសារ ឬវត្ថុផ្សេងៗ), ៩) ព័ត៌មានសម្រាប់មជ្ឈមណ្ឌលទាក់ទង (ឧទាហរណ៍ៈ លេខទូរស័ព្ទ អាសយដ្ឋាន) ។

***ប្រសិនបើចង់ស្វែងរកអ្នកដែលបាត់ខ្លួនសូមផ្តល់ព័ត៌មានខាងក្រោមៈ***

១) ឈ្មោះអ្នកបាត់ខ្លួន, ២) ភេទ, ៣) អាយុ, ៤) ត្រូវជាអ្វី, ៥) សាច់រឿងទាក់ទងនឹងការបែកគ្នា, ៦) វត្ថុតាងទាក់ទងនឹងអ្នកបាត់ខ្លួន (ឧទាហរណ៍ៈ រូបថត ឯកសារ ឬវត្ថុផ្សេងៗ) ។

ដើម្បីយុត្តិធម៌និងការចងចាំ
ដែលជាមូលដ្ឋានដ៏សំខាន់ក្នុងការផ្សះផ្សាជាតិ

ឧបត្ថម្ភការបោះពុម្ពផ្សាយដោយរដ្ឋាភិបាល ដេនម៉ាក ន័រវេ ស៊ុយអែត និងសហរដ្ឋអាមេរិក
អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មានលេខ ០២៩១ពម/៩៩ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

**មជ្ឈមណ្ឌលឯកសារកម្ពុជា : ការិយាល័យព័ត៌មានសាធារណៈ**
ផ្ទះលេខ ៦៦, មហាវិថីព្រះសីហនុ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ : (៨៥៥) ២៣ ២១១ ៨៧៥ ទូរសារ : (៨៥៥) ២៣ ២១០ ៣៥៨

DC-Cam/PIR : #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ Fax: (855) 23 210 358 ◆ dccam@online.com.kh ◆ www.dccam.org.
A magazine of the Documentation Center of Cambodia: Searching for the truth. ◆ Number 147, March 2012 ◆ Funded by Denmark, Norway, Sweden, and USA.
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No.0291 P.M/99, 2 August 1999.